

# ជំពូក ១

# កាលដើមដំបូង


រឿងដែលនឹងយកមកជំរាបអ្នកទាំងអស់នេះ បានឃើញក្នុងសៀវភៅ បុរាណមួយដែលមានចំណាស់រាប់ពាន់ឆ្នាំ មកហើយ ។ គ្រប់ពាក្យពេចន៍គឺជាពាក្យពិត ។ ពាក្យខ្លះវាពិបាកនឹងជឿ...
...ប៉ុន្តែភាគច្រើន ការពិតគឺខុសប្លែកជាងរឿងប្រឌិត ។


កាលដើមដំបូង
មុនមនុស្សទី១ត្រូវបាន បង្កើត មុនផែនដី
ព្រះអាទិត្យ ផ្កាយ ក៏មុនពន្លឺ និងពេលវេលា
នោះមានព្រះអម្ចាស់ហើយ ។





ទ្រង់បានគង់នៅឯកកោ
គ្មានការចាប់ផ្ដើម ប៉ុន្តែទ្រង់មិនដែលអផ្សុកទេ ។
ព្រះជាម្ចាស់បានគង់នៅ ប្រកបដោយអង្គទាំងបី
រួមមកតែមួយអង្គនៅពេលតែមួយ
មិនដូចមនុស្សដែលមានកំណត់នោះទេ ។
អង្គនិមួយៗស្មើគ្នា ហើយមានភាពអស់កល្បដូចគ្នា
នឹងរួមមកតែមួយក្នុង ចរិតលក្ខណៈ
ទាំងនិស្ស័យ ព្រះចេស្ដា ព្រះរាជកិច្ច និង
បំណងព្រះហឫទ័យ ។ ទ្រង់មានទំនាក់ទំនងនៃ
សេចក្ដីស្រឡាញ់ក្នុងអង្គទាំងបី ។


ប៉ុន្តែព្រះអម្ចាស់ ចង់ចែករំលែកជីវិត
របស់ទ្រង់ ទ្រង់សម្រេចព្រះទ័យបង្កើត
ឱ្យមានមិត្តភក្តិនិងអ្នកជិតខាងជាច្រើន ។


ព្រះគម្ពីរបានប្រាប់យើងថា ព្រះបានបង្កើតទេវតាជាច្រើនប្រភេទ
ដ៏ស្រស់ស្អាតដើម្បីនឹងសរសើរដំកើងដល់ព្រះនាមទ្រង់នៅជុំវិញបល្ល័ង្ករបស់
ទ្រង់។ ប៉ុន្តែមានទេវតាមួយអង្គឈ្មោះលូស៊ីហ្វឺ ដែលបាននាំទេវតា១ភាគ៣
ធ្វើការបះបោរប្រឆាំងនឹងព្រះ។ ទ្រង់បានបោះពួកគេចេញពីនគរឋានសួគ៌
មកផែនដី ហើយឈ្មោះ លូស៊ីហ្វឺ ត្រូវបានហៅជាអារក្សសាតាំងវិញ។




រឿងរបស់ សាតាំង អាចនឹងឃើញក្នុងគម្ពីរ អេសាយ ១៤:១២-១៤, ៤៥:១៨,
អេសេគាល ២៨:១៣-១៩, ម៉ាថាយ ២៥:៤១ លូកា ១០:១៨, វិវរណៈ ១២:៤, ២០:២

កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃនិង
ផែនដី ។ ឯផែនដីបានខូចហើយនៅទទេ
មានសុទ្ធ តែងងឹតនៅគ្របលើជម្រៅទឹក
ហើយព្រះវិញ្ញាណ នៃព្រះក៏រេរានៅពីលើទឹក ។




នោះព្រះទ្រង់មានបន្ទូលទៅភាពងងឹតថា...
ចូរឱ្យមានពន្លឺឡើង



# ប្រហែលជាឆ្នាំ៤០០៤ មុនគ្រិស្តសករាជ - លោកុប្បត្តិ ១:២-៣

វាមិនមែនដូចជាមនុស្សសម័យបច្ចុប្បន្នបានគិតនោះទេ។
របស់គ្រប់សព្វសារពើ មិនមែនបានកើតឡើងតាមការវិវត្តន៍ទេ។
ព្រះជាម្ចាស់បង្កើតរបស់ទាំងអស់គឺ គ្រាន់តែមានព្រះបន្ទូលប៉ុណ្ណោះ។
ក្នុងរយៈពេល៦ថ្ងៃទ្រង់បានបង្កើតរបស់ សព្វសារពើនៅលើផែនដីនេះ។


នៅថ្ងៃទី៦ពេលដែលព្រះអម្ចាស់បានសូនរូបកាយ
មួយចេញពីធូលីដី មានអារក្សកំពុងលបមើល ។


ព្រះអម្ចាស់ បានចែកជីវិតផ្ទាល់របស់ទ្រង់ដល់រូបកាយ
នោះដោយផ្លុំខ្យល់ដង្ហើម រូបកាយនោះក៏បានក្លាយជា
មនុស្សដែលមានព្រលឹងវិញ្ញាណ ។ មនុស្សបានបង្កើត
ដូចជាអង្គទ្រង់ ហើយវិសេសជាងសត្វពាហនៈ ។


ព្រះអម្ចាស់បានហៅរូបកាយដែលមានជីវិត
នោះជាមនុស្ស ហើយដាក់ឈ្មោះថា អ័ដាម ។
ទ្រង់ទតគ្រប់ទាំងរបស់ដែលទ្រង់បានបង្កើត
រួចហើយមានបន្ទូលថា “**វាជាការល្អប្រពៃណាស់**” ។
លោកុប្បត្តិ ១:៣១, ២:៧

ជារៀងរាល់ថ្ងៃព្រះមានបន្ទូលជាមួយ
អ័ដាម ហើយជាជីវិតដ៏ល្អ ឥតខ្ចោះ។
ទ្រង់បាននាំសត្វពាហនៈមកខាងមុខ អ័ដាម ដូច្នេះ
អ័ដាមអាចដាក់ឈ្មោះឱ្យគ្រប់ទាំងសត្វនិមួយៗ។
នៅពេល សត្វពាហនៈដើរកាត់មុខ អ័ដាម
គាត់ក៏បានដឹងថា គាត់ អត់មានគូដូចពួកសត្វទេ។




ហើយព្រះបានមានបន្ទូលថា...
អញនឹងបង្កើតស្ត្រី
ម្នាក់ដើម្បីជួយអ័ដាម ។
ព្រះអម្ចាស់បានធ្វើឱ្យ អ័ដាម ដេកលក់ស្កប់
ទៅ រួចទ្រង់យកឆ្អឹងជំនីរមួយ ។ ដោយនូវ
ឆ្អឹងជំនីរនោះទ្រង់បានជបឱ្យកើតឡើងជា
មនុស្សស្រីដ៏ស្រស់ស្អាតដើម្បីធ្វើជាជំនួយ
ដ៏ជាទីស្រឡាញ់របស់ អ័ដាម ។

ព្រះអម្ចាស់បានដាស់ អ័ដាម ហើយក៏នាំស្ត្រីនោះឱ្យគាត់ ទ្រង់ប្រាប់ពួកគេឱ្យមានកូនជាច្រើនបំពេញផែនដីចុះ ។ ហើយ អ័ដាម បានដាក់ឈ្មោះឱ្យប្រពន្ធដ៏ស្រស់ស្អាតថា អេវ៉ា ។




ពួកគេសប្បាយនៅក្នុងសួនច្បារ គ្មាន
អំពើបាប គ្មានការស្រេកឃ្លាន វាមិន
ដែលក្តៅពេកឬត្រជាក់ពេកនោះទេ។
លោកុប្បត្តិ ១:២៨, ២:២, ១៦-២២, ២៥


ព្រះមានបន្ទូលប្រាប់ពួកគេ អំពីដើមឈើថា...
ឯងអាចស៊ីផ្លែឈើទាំងអស់ក្នុងសួននេះ តាមចិត្ត ប៉ុន្តែកុំស៊ីផ្លែឈើមួយដើមដែលដាំ នៅចំកណ្ដាលសួន ។ ដ្បិតថ្ងៃណាដែលឯង ស៊ីនោះ នឹងត្រូវស្លាប់ជាមិនខាន ។


សាតាំងបានស្អប់ព្រះ ហើយវាចង់បំផ្លាញនូវគំរោងការណ៍របស់ទ្រង់។ ប៉ុន្តែវាគ្មានមធ្យោបាយដើម្បីទាក់ទងជាមួយនឹងអេវ៉ា ដូច្នេះវាក៏ចូលទៅ ក្នុងសត្វពស់ដ៏ស្អាត ហើយនិយាយតាមមាត់សត្វពស់នោះ។
តើព្រះមានបន្ទូលហាមមិនឱ្យអ្នកបរិភោគផ្លែឈើនៅក្នុងសួនមែនឬ?


ទ្រង់បានប្រាប់ថា
យើងអាចបរិភោគ គ្រប់ផ្លែឈើ
លើកលែងតែដើមមួយនោះ ប៉ុន្តែ
បើសិនយើងប៉ះពាល់វាយើងនឹងស្លាប់ ។


ហាស់ !
អ្នកមិនស្លាប់ទេ ។ អ្នកនឹងបានដូច
ជាព្រះនៅពេលណាបរិភោគផ្លែឈើនោះ អ្នកនឹង
មានប្រាជ្ញាហើយភ្នែកនឹងភ្លឺដូចយើងដែរ ។
អ្នក នឹងដឹងពីល្អនិងអាក្រក់ ។


វាស្រស់ស្អាតគួរឱ្យចាប់ចិត្តហើយជាផ្លែល្អមនឹងធ្វើជាអាហារដ៏ល្អ ។ បើខ្ញុំបរិភោគ វានឹងធ្វើឱ្យខ្ញុំមានប្រាជ្ញា ។ប៉ុន្តែព្រះទ្រង់មានបន្ទូលថា **“កុំបរិភោគផ្លែឈើនេះ”** ។
អេវ៉ា មិនទាន់ដឹងអំពីអ្វីដែលល្អនិងអាក្រក់ទេ ។


អេវ៉ា មិនស្តាប់បង្គាប់ព្រះ
ហើយបានហូបផ្លែនោះ ។
វាជាការយឺតពេលដែល អេវ៉ា ដឹងថា
នាងបានចាញ់ ការបោកបញ្ឆោត ។
វាបានធ្វើឱ្យនាងដឹងល្អ និង អាក្រក់
ប៉ុន្តែភាពអាក្រក់បានគ្រួតត្រាលើនាង ។




លោកុប្បត្តិ ៣:១-៦, វិវរណៈ ២០:២


ហាស់ហ៉ា!
ទ្រង់នឹងសម្លាប់ពួកឯងឥឡូវនេះ។
មើលអ្វីដែលទ្រង់បានធ្វើមកលើអញ។
ពួកគេក៏បានដឹងខ្លួនឡើង
ហើយមានការ
ខ្មាសអៀនដោយដឹងថា
ខ្លួននៅអាក្រាត។



តើយើងបាន ធ្វើអ្វីខុស ?
យើងមិនស្តាប់បង្គាប់ព្រះជាម្ចាស់ បន្តិចទៀតទ្រង់នឹងយាងមក ។ យើង ត្រូវតែបិទបាំងរូបអាក្រាតរបស់យើង ។


អ័ដាម ឯង នៅឯណា ?
ទូលបង្គំឮសំលេងព្រះអង្គ ហើយនឹកខ្លាចពីព្រោះខ្លួននៅអាក្រាត ។
អ្នកណាប្រាប់ឯងថា ខ្លួននៅអាក្រាត ? តើឯងមិនបានស្ដាប់បង្គាប់អញ ហើយបរិភោគផ្លែឈើដែលអញបានហាមឬ ?




លោកុប្បត្តិ ៣:៦-១២


ហ្ស៊ី...
ពស់មកបោកបញ្ឆោតខ្ញុំម្ចាស់ ។
វាបានប្រាប់ ខ្ញុំម្ចាស់ថានឹងមិនស្លាប់ទេ
នឹងបានដូចជាទ្រង់ ប៉ុន្តែមិនបាន ដូចព្រះអង្គទេ
ខ្ញុំម្ចាស់មានអារម្មណ៍មិនល្អសោះ ។


ដូច្នេះព្រះអម្ចាស់ដាក់បណ្ដាសាលើសត្វពស់ដោយមានបន្ទូលថា...
ពីព្រោះឯងបានធ្វើការនេះ អញនឹងធ្វើឱ្យឯងលូននឹងពោះ ហើយត្រូវស៊ីធូលីដី ។
អញនឹងឱ្យពូជឯងនិងពូជនាងមានសេចក្ដីខ្មាំងនឹងគ្នា ។ ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងកូនរបស់នាង ។


នេះគឺកិច្ចសន្យាពីការច្បាំងនៅថ្ងៃអនាគត ។ គ្រាមួយនឹងមកដល់ដែលពូជរបស់នាងនឹងឈ្នះលើ សាតាំង ។ ម្នាក់នេះនឹងនាំមនុស្សជាតិឱ្យបែរមករកព្រះអម្ចាស់វិញ ហើយរំដោះពួកគេពីបណ្ដាសានៃអំពើបាបនិងសេចក្ដីស្លាប់ ។

# លោកុប្បត្តិ ៣:១៣-១៥



ព្រះអម្ចាស់អាចបំផ្លាញ លូស៊ីហ្វើ និងទេវតារបស់វាទាំងអស់បានក្នុងមួយ
រំពេច ។ ប៉ុន្តែទ្រង់បានអនុញ្ញាតឱ្យវារស់នៅទុកជាការល្បងលសម្រាប់
មនុស្សថា តើពួកគេនឹងតាមព្រះឬតាមការបះបោររបស់ សាតាំង ?


ព្រះអម្ចាស់បានដាក់បណ្ដាសាលើមនុស្សថា...
អ័ដាម
ដោយសារឯងព្រមទៅតាមការបបួលរបស់ប្រពន្ធ
ឯង ហើយមិនស្ដាប់បង្គាប់
អញនឹងដាក់បណ្ដាសាលើផែនដីនេះ ។
ឱ្យដុះបន្លានិងអញ្ចាញល្អជាងតិណជាតិ
នឹងឱ្យឯងត្រូវតែធ្វើការ
យ៉ាងខ្លាំងលើដីដើម្បីចិញ្ចឹមជីវិត ។
ឯងនឹងមានទុក្ខព្រួយធ្វើការរកស៊ីដោយការ
ឃ័កញើសរហូតដល់ឯងស្លាប់ ហើយត្រឡប់
ទៅជាដីវិញ ពីព្រោះអញបានយកឯងពីដីមក ។


ឥឡូវដល់ពេលអ័ដាម និង អេវ៉ា ត្រូវស្លាប់ដូចព្រះទ្រង់មានបន្ទូល ប៉ុន្តែព្រះទ្រង់សម្លាប់សត្វពាហនៈជំនួសពួកគេវិញ ។ ហើយយកស្បែករបស់វាធ្វើជាសំលៀកបំពាក់ឱ្យអ័ដាម និង អេវ៉ាពាក់សម្រាប់បិទបាំងកាយ ។


ទ្រង់មិនបានសម្លាប់យើងទេ
យើងនៅរស់ ។


ទ្រង់សម្លាប់សត្វជំនួសយើងវិញ ។
អ័ដាម និង អេវ៉ា មិនស្លាប់នៅថ្ងៃនោះទេ
ពីព្រោះសត្វដែលល្អឥតខ្ចោះបានស្លាប់ជំនួស
ប៉ុន្តែការកាត់ទោសនៃសេចក្តីស្លាប់បាន
ធ្លាក់លើពួកគេ ហើយនៅទីបំផុតពួកគេនឹង
ស្លាប់ដដែល ។ សេចក្តីស្លាប់គឺទោសនៃអំពើបាប ។


ឥឡូវនេះដោយសារ អ័ដាម និង អេវ៉ា ជាអ្នកមានបាប
ព្រះអម្ចាស់បាន បណ្តេញពួកគេចេញពីសួនដ៏ស្រស់ស្អាត
ដើម្បីកុំឱ្យពួកគេបរិភោគផ្លែជីវិត ទៀត
ហើយរស់នៅជារៀងរហូតក្នុងសភាពពេញដោយអំពើបាប ។
លោកុប្បត្តិ ៣:១៧-២៤, អេសេគាល ១៨:៤



ព្រះអម្ចាស់ដាក់ទេវតាវិសេសហៅថា
ចេរូប៊ីន នៅត្រង់ផ្លូវ ចូលសួន
ដើម្បីហាមឃាត់មនុស្សគ្រប់គ្នាបេះផ្លែមកពីដើមឈើ
ជីវិតបរិភោគ ។
បន្ទាប់មកសួនអេដែនក៏ត្រូវបានបំផ្លាញ ហើយ
ដើមជីវិតក៏ត្រូវបានបំបាត់ពីផែនដីដែរ ។
នៅថ្ងៃមួយវានឹងបាន នាំមកផែនដីវិញ
ប៉ុន្តែរឿងនេះខ្ញុំដូចជាប្រាប់ជ្រុលបន្តិច ។


អ័ដាម និង អេវ៉ា មានកូនជាច្រើន
ក្រោយមកទៀតកូនប្រុសកូនស្រី
របស់គេបានរៀបការជាមួយគ្នា
ហើយមានកូនចៅជាច្រើនទៀត។



នៅពេលមនុស្សដំបូងបង្កើតមក ។
ដំណើរជីវិតដែលខូចរាងរៅខុស ពីធម្មតានៃតំណពូជ
ដែលបណ្ដាលមកពីការបង្កាត់ពូជដដែល ៗ
នោះមិនទាន់កើតឡើងនៅឡើយ ។ ប៉ុន្តែក្រោយមកនៅពេលវា
ចាប់ផ្ដើមមានបញ្ហាពីតំណពូជនោះ ព្រះអម្ចាស់បានបង្គាប់ថា
សាច់ញាតិបងប្អូនឯងមិនគួររៀបការជាមួយគ្នាទេ ។



កូនប្រុសដំបូងរបស់ពួកគេគឺ កាអ៊ីន
គាត់បានដាំបន្លែនិងផ្លែឈើ កូនប្រុស បន្ទាប់គឺ អេបិល
គាត់បានចិញ្ចឹមសត្វពាហនៈ ។ តើពួកគេទាំងពីរនាក់
មានម្នាក់ដែលនឹងបំផ្លាញសាតាំងដូចព្រះបានសន្យាឬ ?



កាអ៊ីន និង អេបិល បានដឹងពីព្រះជាម្ចាស់នឹង
ហេតុការណ៍ក្នុងសួន ប៉ុន្តែទ្រង់ឈប់យាងនិង
មានបន្ទូលជាមួយមនុស្សលោកដូចមុន ។ អ័ដាម
និងតំណទាំងអស់របស់គាត់បានបែកចេញពីព្រះ
ដោយការមិនស្ដាប់បង្គាប់ ។ ជីវិតមានការ
លំបាកដោយគ្មានព្រះអម្ចាស់ ។




មានថ្ងៃមួយនៅពេលកូនប្រុសទាំងពីរបានសំរេចចិត្តថ្វាយបង្គំព្រះអម្ចាស់ ។ ឪពុករបស់គេបានប្រាប់ពួកគេពីការដែលព្រះបានសម្លាប់សត្វក្នុងសួន ដូច្នេះដោយសេចក្តីជំនឿ អេបិល បានសម្លាប់សត្វហើយថ្វាយដល់ព្រះអម្ចាស់ ។




លោកុប្បត្តិ ៤:១-៤, រ៉ូម ៣:២៣, ហេព្រើ ១១:៤


ទេ កាអ៊ីន
ព្រះអម្ចាស់បានបដិសេធដង្វាយ
របស់កាអ៊ីន ពីព្រោះគ្មានឈាម ។

ព្រះអម្ចាស់បានសព្វព្រះហឫទ័យជាមួយ
អេបិល និង ដង្វាយ របស់គាត់។
នៅពេលទ្រង់ឃើញឈាមសត្វចៀមដ៏ល្អឥតខ្ចោះ
ព្រះអម្ចាស់បានអត់ទោសអំពើបាបរបស់អេបិល។



ព្រះអម្ចាស់មានបន្ទូលទៅកាអ៊ីនថា
**“បើឯងធ្វើអ្វីដែល ឯងគួរធ្វើ
អញនឹងគាប់ចិត្តជាមួយឯង ឯងក៏នឹងត្រួតត្រា
លើប្អូនប្រុសរបស់ឯងអេបិល
ហើយវានឹងរស់នៅក្រោម អំណាចរបស់ឯង”។**


ឯងគិតថា ឯងជាអ្នកណា? ផ្លែឈើនិងបន្លែរបស់អញមានតំលៃជាងឈាមចៀមរបស់ឯង។ តើអ្វីធ្វើឱ្យឯងពិសេសដូច្នេះ?
បងប្រុសអើយ នៅមាន ឱកាសទៀត ដើម្បីថ្វាយដង្វាយឈាមទៅព្រះ។




លោកុប្បត្តិ ៤:៥-៨

ប៉ុន្តែកាអ៊ីនមិនអាចលាក់អំពើបាបជិតពីព្រះអម្ចាស់ទេ ។
ព្រះទតឃើញនឹងជ្រាបគ្រប់ការទាំងអស់ ។




ទូលបង្គំមិនដឹងទេ។ តើទូល
បង្គំជាអ្នកថែរក្សាប្អូនឬអី ?
ឈាមរបស់ប្អូនឯងនៅលើដី
នៅឡើយ។ វាបានផុស្រកប្រាប់
អញ្ចពីអំពើអាក្រក់របស់ឯង។



ព្រះអម្ចាស់ទ្រង់ជ្រាបគ្រប់ទាំងអស់ ។
ទ្រង់ឃើញមនុស្សទាំងអស់គ្រប់ពេលវេលា គ្មានអ្វីលាក់បាំងចំពោះទ្រង់ទេ ។
ទ្រង់បានឃើញអ្វីដែលកាអ៊ីនធ្វើចំពោះអេបិល ព្រះអម្ចាស់បានដាក់
បណ្ដាសាលើកាអ៊ីន ហើយគាត់បាននាំប្រពន្ធរត់ចេញទៅវាលរហោស្ថាន ។
ទោសរបស់គាត់ធ្វើឱ្យគាត់មានការឈឺចាប់និងសោកស្ដាយយ៉ាងខ្លាំង ។


កាអ៊ីនមិនមែនជាអ្នកសង្គ្រោះដែល
ព្រះបានសន្យានោះទេ ។ គឺខ្លួនគាត់
ជាអ្នកត្រូវការសេចក្ដីសង្គ្រោះវិញ ។

ចុះគិតយ៉ាងម៉េចអំពីការសន្យារបស់ព្រះ
ពីកូនប្រុសម្នាក់ដែល នឹងសង្គ្រោះនោះ ? អ័ដាម
និង អេវ៉ា មានកូនម្នាក់ទៀតឈ្មោះ សេត
ហើយពួកគេបានមានកូនប្រុសស្រីជាច្រើនថែមទៀតដែរ ។




លោកុប្បត្តិ ៤:៩-១៦, ៥:៤, កិច្ចការ
១៧:២៤-២៦


សេត មានកូនប្រុសមួយ និងកូនប្រុសរបស់គាត់ក៏មានកូនប្រុសដែរ ហើយ
មានកូនប្រុសជាច្រើនបានកើតមកថែមទៀត ប៉ុន្តែនៅតែគ្មានអ្នកណាម្នាក់អាច
បំបាត់បណ្តាសានៃអំពើបាបនិងបំផ្លាញសេចក្តីស្លាប់បានទេ។ មិនយូរប៉ុន្មានផែនដី
ពេញដោយមនុស្ស ហើយមានទីក្រុង ភូមិ និង កសិដ្ឋានជាច្រើន។

នៅជំនាន់និមួយៗមនុស្សបាន
កើនឡើងហើយអំពើបាបក៏
បានកើនឡើងដែរ ។
មនុស្សបានប្រព្រឹត្តអំពើបាប នៃការរួមរ័ក
និងអំពើហឹង្សា ហើយអស់ទាំងគំនិតក្នុងចិត្ត
របស់គេពេញដោយអំពើបាប ។
គ្មាននរណាម្នាក់រស់ នៅដោយសុចរិតទេ ។
អ័ដាម បានប្រព្រឹត្តអំពើបាបតែម្តង
តែឥឡូវនេះមនុស្សបាន
ប្រព្រឹត្តអំពើបាបជាច្រើន ។





ព្រះអម្ចាស់មានបន្ទូលថា “**អញស្ដាយចិត្ត ដោយអញបានបង្កើតមនុស្សមកនៅលើផែនដី អញនឹងបំផ្លាញគ្រប់ទាំងអស់ដែលរស់នៅ ផែនដី**”។ សាតាំង ដែលស្អប់នគររបស់ព្រះ វានឹងសប្បាយបើសិនឃើញព្រះអម្ចាស់ បំផ្លាញមនុស្សទាំងអស់។


ឥឡូវនេះ៩ជំនាន់ស្មើនឹង១៨០០ឆ្នាំបានកន្លងផុត
ហើយពិភពលោកនេះពេញដោយបាប ។
មនុស្សបានបង្ខំមនុស្សឱ្យធ្វើជាទាសករ ។
តើព្រះអម្ចាស់នឹងមានគ្រួសារដែល
ស្រឡាញ់ទ្រង់ និងស្តាប់បង្គាប់ទ្រង់ឬទេ ?
លោកុប្បត្តិ ៦:៥-៧, រ៉ូម ៥:១២


ប្រហែលជាឆ្នាំ ២៥០០មុន គ.ស.
នោះនៅមានមនុស្សម្នាក់ដែលតែងតែប្រកបដោយ យុត្តិធម៌និងភាពត្រឹមត្រូវ ។ ថ្វីបើព្រះអម្ចាស់នឹង សម្លាប់មនុស្សទាំងអស់ក៏ដោយ ទ្រង់បានសម្រេច ព្រះហឫទ័យសន្តោសដល់គាត់ ហើយមិនសម្លាប់ គាត់ព្រមទាំងគ្រួសារផងដែរ ។


ណូអេ
អញនឹងបញ្ជូនទឹកជំនន់ដ៏ធំមួយ
ដូច្នេះអ្វីៗទាំងអស់
ដែលមានដង្ហើមត្រូវស្លាប់ ។
ឯងនឹងត្រូវសង់ទូកធំមួយ
ដើម្បីសង្គ្រោះខ្លួននិងគ្រួសាររបស់ឯង
ហើយ សត្វពាហនៈដែរ ។


ឯងត្រូវយកគ្រប់សត្វពាហនៈមួយគូៗ
ដែលនៅលើផែនដី ដាក់លើទូកជាមួយផង ។
ឯងនឹងត្រូវយកសត្វដែលអនុញ្ញាត
ឱ្យបរិភោគចំនួនប្រាំពីរ ។ អញនឹងប្រាប់ឯងនូវរបៀបសង់ទូក
នឹងអ្វីដែលឯងត្រូវការធ្វើដើម្បីរៀបចំសម្រាប់ទឹកជំនន់ជាមុន ។

តើណូអេជាកូនម្នាក់ដែលព្រះបានសន្យានឹងបំផ្លាញ
នូវកិច្ចការរបស់សាតាំងឬ ? តើគាត់នឹងស្ដាប់
បង្គាប់ព្រះឬធ្លាក់ក្នុងអំពើបាបដែរឬទេ ?



ព្រះអម្ចាស់ប្រាប់ណូអេនូវទំហំដែលគាត់ត្រូវធ្វើទូកធំ
នោះ ។ ដើម្បីអាចផ្ទុកគ្រប់សត្វដែលមានខ្យល់ដង្ហើម
មួយគូៗនៅលើផែនដីព្រមទាំងចំណីអាហារ ។

លោកុប្បត្តិ ៦:៨-៩, ១៧-២២, ៧:២


ខ្ញុំប្រាប់អ្នកទាំងអស់ជាចុងក្រោយ
ព្រះអម្ចាស់
នឹងបំផ្លាញលោកិយដោយទឹកជំនន់ដ៏ធំ ។
ពួកអ្នកត្រូវតែ ជឿខ្ញុំ
ហើយចូលរួមជាមួយខ្ញុំនៅក្នុងទូក ។
វាធ្វើឱ្យណូអេក្រៀមក្រំចិត្តនៅពេលគាត់គិតអំពី
មនុស្សទាំងអស់នឹងវិនាសក្នុងទឹកជំនន់ដែលនឹង
មកដល់ ដូច្នេះជារៀងរាល់ថ្ងៃគាត់បានឆ្លៀតឱកាស
ប្រាប់ពួកគេឱ្យឈប់ប្រព្រឹត្តអំពើបាប ។


ហេតុអ្វីព្រះនៃសេចក្ដីស្រឡាញ់នឹងបំផ្លាញកូនចៅរបស់ទ្រង់ ?
អាកញ្ចាស់ល្ងង់ !
ដោយសារអំពើបាប ។ អ្នកត្រូវតែបញ្ឈប់នូវអំពើបាប ហើយប្រព្រឹត្តសេចក្ដីស្រឡាញ់និងយុត្តិធមិជាមួយអ្នកជិតខាងរបស់អ្នក ។

១២០ឆ្នាំបន្ទាប់មក
ពេលដែលទូកបានសង់រួចហើយ ព្រះបានធ្វើឱ្យសត្វពាហនៈមកពីគ្រប់ទីកន្លែងទាំងអស់មួយគូៗលើផែនដីនឹងចូលមកឯណូអេ។






លោកុប្បត្តិ ៧:៧-៩, ពេត្រុសទី២, ២:៥


ជិតអស់ កន្លែងហើយ ។
នេះជាសត្វ ចុងក្រោយ ។
ណូអេ
ដល់ពេលហើយ ចូរចូលក្នុង
ទូកជាមួយគ្រួសារនិងសត្វពាហនៈ ។
បន្តិចទៀតនេះវានឹងហួសពេលសម្រាប់
អ្នកដែលមិនប្រែចិត្តឈប់ធ្វើអំពើបាប ។


ព្រះអម្ចាស់បានបិទទ្វារទូក
ហើយអស់រយៈពេលប្រាំពីរ ថ្ងៃគ្មានអ្វីកើតឡើង។
ហាស់ហាំ ! ចូរមើលពួកល្ងង់និងសត្វពាហនៈជាច្រើនជាប់ឃុំនៅក្នុងទូកដ៏ធំ ដែលនៅកណ្ដាលវាលរាំង ស្ងួត ហើយឆ្ងាយរាប់គីឡូពីទឹក។
ពួកវាបាននៅទីនោះមួយសប្ដាហ៍ហើយ !


ប៉ុន្តែនៅថ្ងៃទីប្រាំពីរវាបានចាប់ផ្ដើមភ្លៀង ហើយប្រភពទឹកធំនៅទីជម្រៅក៏ធ្លាយឡើង ។
ខ្ញុំមិនដែលឃើញអ្វីកើតឡើងដូចនេះទេ ! តើអ្នកគិតថាមនុស្សឆ្កួតនៅក្នុងទូកបាននិយាយត្រូវថា ព្រះអម្ចាស់ចង់សម្លាប់មនុស្សគ្រប់គ្នាចំពោះបាបរបស់គេមែនឬ ?




មុនពេលនេះវាមិនដែលភ្លៀងទេ ។ មានធាតុអាកាសល្អ ហើយចំហាយទឹកឡើងពីដីមកស្រោចស្រប់គ្រប់លើផែនដី ។ គ្មាននរណាម្នាក់ដែលធ្លាប់ឃើញ ឬ ឮពីភ្លៀង ដូច្នេះមនុស្សភាគច្រើនបានគិតថា ណូអេឆ្កួត ព្រោះគាត់គិតថា នឹង មានភ្លៀងធ្លាក់ពីលើមេឃ ប៉ុន្តែណូអេបានជឿអ្វីដែលព្រះមានបន្ទូលប្រាប់ ។




លោកបត្រិ ៧:៩-១១, ១៦

ប្រហែលឆ្នាំ ២៣៤៨ មុន គ.ស.




មានភ្លៀងធ្លាក់មកលើផែនដី៤០ថ្ងៃ៤០យប់
រហូតដល់ទឹកលិចភ្នំទាំងអស់លើផែនដីទាំងមូល ។
គ្រប់ទាំងអស់ដែលមានខ្យល់ដង្ហើមជីវិតបានស្លាប់
លើកលែងតែពួកដែលនៅក្នុងទូកជាមួយណូអេ ។
ពួកគេនឹងនៅក្នុងទូកអស់រយៈពេលជាងមួយឆ្នាំ
មុនគេចេញពីទូក ។





ក្រោយមក ណូអេ បានលែងសត្វព្រាបមួយក្បាល
ហើយវាត្រឡប់ មកវិញដោយពាំស្លឹកឈើមួយមក
នេះមានន័យថា កន្លែង មួយមានដើមឈើដុះវិញហើយ ។
ក្រោយមកគាត់បានលែងវាម្តង ទៀត
ហើយនៅពេលនោះវាមិនបានត្រឡប់មកវិញទេ នេះមាន
ន័យថា វាបានឃើញកន្លែងល្អដើម្បីរស់នៅហើយ ។



លោកុប្បត្តិ ៧:១២, ១៩-២៣, ៨:៩-១១




មិនយូរប៉ុន្មានទូកបានជាប់លើកំពូលភ្នំមួយ ហៅថា
អារារ៉ាត់ ។ ពួកគេទាំងអស់គ្នាបានចេញមកពិភពលោក
ថ្មីមួយដែលគ្មានអំពើបាប ។

ណូអេ បានសង់អាសនៈមួយ
ហើយបានយកសត្វដែលល្អ
ឥតខ្ចោះថ្វាយយញ្ញបូជាដល់ព្រះអម្ចាស់ ។
ទោះបើណូអេជា
មនុស្សសុចរិតក៏ដោយក៏នៅតែមានអំពើបាបក្នុងចិត្ត ។
ដង្វាយ ឈាមទាំងនេះបានថ្វាយដល់ព្រះ
ក្នុងការជំនួសជីវិតរបស់ ណូអេហើយគ្រួសាររបស់គាត់ ។





សត្វពាហនៈទាំង៨នោះ តំណាងឱ្យមនុស្ស៨នាក់ ដែលត្រូវស្លាប់ក្នុងទឹកជំនន់នោះ ប៉ុន្តែព្រះបាន សង្គ្រោះពួកគេដោយព្រះគុណរបស់ទ្រង់។ កិច្ចការ នេះដូចការដែលព្រះអម្ចាស់បានធ្វើក្នុងសួននៅ ពេលទ្រង់បានសម្លាប់សត្វ ដើម្បីធ្វើសំលៀក បំពាក់គ្របបាំង អ័ដាម និង អេវ៉ា។


អញនឹងឱ្យមានឥន្ធនូនៅលើពពកទុកជាការនឹកចាំថា អញ   នឹងមិនបំផ្លាញផែនដីដោយទឹកជំនន់ទៀតទេ ។ ចូរឯងមានកូនជាច្រើន ដើម្បីធ្វើឱ្យមានមនុស្សពេញផែនដីទាំងមូល ។ អញនឹងធ្វើឱ្យ...


...សត្វខ្លាចមនុស្ស ហើយបណ្ដា
សត្វទាំងប៉ុន្មានដែលកំរើកនៅរស់
លូនវាលើផែនដីនោះ នឹងបានជា អាហារដល់ឯង
ដូចជាតិណជាតិ ទាំងអស់ដែលអញឱ្យទៅឯង
ប៉ុន្តែកុំបរិភោគឈាមសត្វ...
...គ្រប់ប្រភេទ ។
កុំឱ្យសម្លាប់មនុស្សឱ្យសោះ
បើសិនជាសម្លាប់នោះ អញនឹងទារឈាមដែលជា
ជីវិតរបស់អ្នកនោះជាមិនខាន ។ អ្នកណាដែលកំចាយ
ឈាមរបស់មនុស្សនោះ ឈាមអ្នកនោះឯងនឹងត្រូវ
ខ្ចាយដោយសារមនុស្សដែរ ពីព្រោះជីវិតគឺជាឈាម ។



ណូអេបានក្លាយជាកសិករម្នាក់
ហើយបានដាំដើមទំពាំងបាយជូរ ។
ពិភពថ្មីគឺដូចជាអផ្សុកមានតែ៤គ្រួសារប៉ុណ្ណោះ។
ប៉ុន្តែមិនយូរប៉ុន្មាន
កូនប្រុសរបស់គាត់នឹងមានកូនចៅជាច្រើនទៀត។


ណូអេ បានយល់ថា ដោយគ្រាន់តែដាក់ផ្លែទំពាំងបាយជូរក្នុងធុងធំ ហើយទុក ពីរបីសប្ដាហ៍វានឹងបង្កើតបានស្រាទំពាំងបាយជូរដែលធ្វើឱ្យគាត់មានអារម្មណ៍ សប្បាយ ។ ណូអេ ចូលចិត្តការហូបស្រាច្រើន ជួនកាលគាត់មិនអាចធ្វើការបាន ហើយដួលសន្លប់ ។ វាបានធ្វើឱ្យគាត់ធ្វើខុសពីព្រះហឫទ័យនៃព្រះជាម្ចាស់ ។



ថ្ងៃមួយណូអេបានផឹកស្រាទំពាំងបាយជូរនោះ ហើយក៏ស្រវឹងរួចដេកអាក្រាត ។ កូនរបស់គាត់ ហាំ បានឃើញកេរ្តិ៍ខ្មាសរបស់ឪពុកហើយគួរឱ្យអស់សំណើច ។ ដូច្នេះក៏ទៅបកកេរ្តិ៍ប្រាប់ដល់ប្អូនទាំងពីរនូវអ្វីដែលគាត់បានឃើញ ។


នៅពេល ណូអេ ភ្ញាក់ ឡើងកូនទាំងពីររបស់ គាត់បានប្រាប់នូវអ្វីដែល ហាំបាននិយាយ ។
កូនប្រុសរបស់ឯង កាណាន ហើយវង្សតំណរទាំងអស់របស់វា នឹងធ្វើជាអ្នកបំរើវង្សតំណរ របស់សិម ។



ជាច្រើនឆ្នាំក្រោយមក បទទំនាយនេះក៏បានកើតឡើង សាសន៏កាណាន
បានកាន់កាប់ទឹកដីភីលីស្ទីនហើយបានក្លាយជាអ្នកបំរើរបស់សាសន៏យូដា។

លោកុប្បត្តិ ៩:២១-២៧, របាក្សត្រទី១, ៤:៤០,
ទំនុកដំកើង ៧៨:៥១, ១០៥:២៣, ២៧, ១០៦:២២


សេត
អ័ដាម និង អេវ៉ា
កាអ៊ីន
អេបិល
ព្រះអម្ចាស់បានសម្លាប់ គ្រប់មនុស្សទាំងអស់
លើកលែងតែមនុស្ស៨នាក់។


ណូអេ ហើយគ្រួសាររបស់គាត់បានប្រកប
ដោយព្រះគុណនៅចំពោះព្រះនេត្រទ្រង់ ។
ទ្វីប អឺរ៉ុប
យ៉ាផែត
ប្រទេស ទួគី
សិម
ហាំ
ទ្វីប អាស៊ី
ទ្វីប អាហ្វ្រិក
ជាច្រើនឆ្នាំក្រោយមក យ៉ាផែតបានទៅទិស ខាងលិចនិងខាងជើង
ដើម្បីរកកន្លែងរស់នៅ នឹងបង្កើតកូនចៅជាច្រើន ។
សិម បានទៅទិសខាងកើត ហើយរស់នៅ ទ្វីបអាស៊ី ។
ហាំ បានទៅទិសខាងត្បូងហើយរស់នៅក្នុងទ្វីបអាហ្វ្រិក




និងអាស៊ីខាងត្បូង ។ វង្សត្រកូលកាណានដែលជាកូនរបស់
ហាំ បានរស់នៅកន្លែងដែលសព្វថ្ងៃនេះហៅថា ភីលីស្ទីន ។
ដូច្នេះហើយពិភពលោកត្រូវមាន
ចំនួនមនុស្សកើនឡើងជាច្រើនវិញ ។


ប្រហែលជាឆ្នាំ ២២៤៧ មុន គ.ស.
កូនប្រុសរបស់ណូអេគឺ ហាំ មានកូនប្រុសម្នាក់ឈ្មោះ
គូស បន្ទាប់មកគូស ក៏បង្កើត នីមរ៉ុឌ
នីមរ៉ុឌធំឡើងធ្វើជាព្រានព្រៃដ៏ខ្លាំងពូកែហើយល្បីល្បាញ
គ្រប់ទីកន្លែងលើផែនដី។
គាត់មិនព្រមស្តាប់បង្គាប់ព្រះ ហើយចាប់ផ្តើម
បង្កើតសាសនាផ្ទាល់ខ្លួននៅកន្លែងមួយហៅថា បាប៊ីឡូន។

មនុស្សនៅបាប៊ីឡូនមិនចង់បែកចេញពីគ្នាហើយនឹងបង្កើតពូជឱ្យពេញផែនដីដូចព្រះអម្ចាស់បានបង្គាប់ទេ។ ដូច្នេះគេបានប្រមូលគ្នាហើយសង់ប៉មដ៏ល្អខ្ពស់មួយជាទីកន្លែងសំខាន់បំផុតសម្រាប់ថ្វាយបង្គំ។




ប៉ុន្តែពួកគេមិនថ្វាយបង្គំព្រះដែលបង្កើត
ពួកគេមកទេ។ សាតាំងបាននាំឱ្យពួកគេ
បង្កើតព្រះផ្ទាល់ខ្លួនរបស់គេ ធ្វើពី
ឈើ ថ្ម និង លោហធាតុ។


ព្រះជាម្ចាស់បានក្រោធពីព្រោះពួកគេមិនព្រម
បែកចេញពីគ្នាឱ្យពេញផែនដី ដូច្នេះទ្រង់បំភាន់
ភាសារបស់ពួកគេឱ្យនិយាយភាសាខុសៗគ្នា។
អ្នកធ្វើការសាងសង់ស្តាប់
គ្នាមិនយល់ ដូច្នេះពួកគេមិនអាច
បន្តធ្វើការសាងសង់ទៀតទេ។


ពួកគេបានចេញទៅតាមក្រុមភាសានិមួយៗ
របស់ខ្លួន ។ មនុស្សខ្លះចេញទៅកន្លែងឆ្ងាយនៅ
លើផែនដី ខ្លះធ្វើដំណើរតាមទូកទៅកាន់កោះ
ដ៏ឆ្ងាយ ខ្លះទៅភាគខាងជើងដែលជាកន្លែង
ត្រជាក់ ហើយខ្លះទៅវាលខ្សាច់ដែលជាកន្លែង
ក្តៅ ។ ដូច្នេះការបង្គាប់របស់ទ្រង់បានសម្រេច
ដោយសាមនុស្សទៅរស់នៅពាសពេញផែនដី ។



នៅពេលផែនដីពេញដោយមនុស្ស វិញ
អំពើបាបក៏កើនឡើងថែម ទៀតដែរ ។
មនុស្សបានថ្វាយបង្គំ រូបចំលាក់
ហើយបានបំភ្លេចព្រះ ដែលមានព្រះជន្មរស់ ។

លោកុប្បត្តិ ១០:៦-១០, ១១:១-៩


ជំពូក ២
អ័ប្រាហាំ


មានមនុស្សម្នាក់ឈ្មោះ អ័ប្រាហាំ
ដែលមិនជឿរូបចំលាក់ជាព្រះពិតទេ។
គាត់ បានដឹងថា ព្រះគឺជាអ្នកបង្កើត
ហើយមិនអាចថ្វាយបង្គំតាមរូបចំលាក់ឡើយ។

ព្រះអម្ចាស់មានបន្ទូលទៅគាត់ថា
“អ័ប្រាហាំ   ចូរចាកចេញពី
ទីក្រុងដែលគោរពរូបចំលាក់នេះទៅ។   ចូរឯងចេញពីស្រុក
ពីញាតិសន្តានទៅនៅឯស្រុកដែលអញនឹងបង្ហាញឯងចុះ។
អញនឹងធ្វើឱ្យឯងជាឪពុកនៃប្រជាជាតិដ៏ធំមួយ។
អញនឹង   ប្រទានពរដល់អស់អ្នកណាដែលឱ្យពរដល់ឯង
ហើយនឹងដាក់
បណ្តាសាដល់អស់អ្នកណាដែលដាក់បណ្តាសាឯង។   គ្រប់
ទាំងប្រជាជាតិនៅលើផែនដីនឹងបានពរដោយសារឯង”។



តើ អ័ប្រាហាំ
ជាកូនដែលបានសន្យាបំផ្លាញអំពើបាបនិងសេចក្តីស្លាប់ឬ ?

ប្រហែលឆ្នាំ១៩២១ មុន គ.ស.



អ័ប្រាហាំ បានដឹងថា
សំលេងដែលគាត់បានឮគឺជាសំលេងរបស់ព្រះអម្ចាស់
ដូច្នេះគាត់ស្តាប់បង្គាប់ដោយមិនខ្វល់ខ្វាយ
ពីកន្លែងណាដែលគាត់ត្រូវទៅទេ។ គាត់បានដឹងថា
គាត់នឹង ឃ្លាតឆ្ងាយពីការថ្វាយបង្គំរូបចំលាក់
ហើយដើរតាមព្រះ ដ៏មានព្រះជន្មរស់។
នេះគឺគ្រប់គ្រាន់សម្រាប់ អ័ប្រាហាំ
ប៉ុន្តែគាត់បាននាំក្មួយឈ្មោះ ឡុត ទៅជាមួយ។


ការធ្វើដំណើររបស់ អ័ប្រាហាំ
បានចុះទៅទឹកដីស្រុកកាណាន ដែល
ជាកន្លែងកូនរបស់ហាំបានតាំងនៅ ។
សព្វថ្ងៃទឹកដីនោះហៅថា ភីលីស្ទីន ។
នៅទីនោះព្រះបានមានបន្ទូលទៅគាត់ថា...
អ័ប្រាហាំ
ចូរដើរឲ្យសព្វគ្រប់ទឹកដីនេះពីចុងម្ខាង
ទៅចុងម្ខាងទៀត
អញនឹងឲ្យទឹកដីកាណានទាំងអស់
នេះដល់កូនចៅរបស់ឯង ។
អញនឹងធ្វើឲ្យឯងមានកូន
ចៅជាច្រើនដែលគេមិនអាចរាប់បាន ពួកគេ
នឹងចំរើនឡើងដូចជាធូលីដី ។


សារ៉ា
យើងចង់បានកូនជាយូរឆ្នាំមក
ហើយ ឥឡូវនេះព្រះអម្ចាស់មាន
បន្ទូលប្រាប់បងថា អូននឹងមានកូន ។
បងដឹងថា
អូនមិនដែលមានកូន
ទេ ហើយឥឡូវនេះអូនហួសអាយុ
ត្រូវមានកូនហើយ ។ តើអូនអាច
នឹងមានកូនយ៉ាងម៉េចកើត ?

លោកុប្បត្តិ ១២:១-៣, ១៣:១៤-១៧




នៅពេលអ័ប្រាហាំធ្វើដំណើរតាមទឹកដី
នោះ គាត់បានឈប់ម្ដងម្កាល ហើយ
ថ្វាយដង្វាយឈាមដល់ព្រះអម្ចាស់ ។
គាត់បានធ្វើយញ្ញបូជាដោយសេចក្ដី
ជំនឿដូចអេបិល ព្រោះគាត់ដឹងថា គាត់
ជាអ្នកមានបាបដែលសមនឹងស្លាប់ ។
ដង្វាយសត្វចៀមមិនអាចលោះអំពើបាបរបស់គាត់បានទេ ។
ប៉ុន្តែនៅពេលព្រះអម្ចាស់បានឃើញសេចក្ដីជំនឿរបស់
អ័ប្រាហាំ ព្រះអម្ចាស់បានបិទបាំងអំពើបាបរបស់គាត់ ។


១០ឆ្នាំក្រោយមក
បងអ័ប្រាហាំ កាលពី១០ឆ្នាំមុនបងបានប្រាប់អូនដែល
ព្រះអម្ចាស់បានមានបន្ទូលថា អូននឹងមានកូន ឥឡូវនេះអូនមាន
អាយុ៧៥ឆ្នាំនិងបងមានអាយុ៨៥ឆ្នាំ។ ពួកយើងចាស់ហើយ
ប៉ុន្តែគ្មានកូន។ ពីថ្ងៃនេះទៅមុខបងកាន់តែចាស់ទៅៗក្នុង ការបង្កើតកូន។
តើបងពិតជាបានឮពីព្រះអម្ចាស់មែនឬ ?


បងដឹង គឺជាព្រះដែលមានបន្ទូលមកបង ប៉ុន្តែបងមិនយល់ថា ហេតុអ្វីទ្រង់ឱ្យយើងរងចាំយូរម្ល៉េះ។ ទ្រង់មានបន្ទូលថា បងនឹងធ្វើជាឪពុក នៃប្រជាជាតិដ៏ធំ ប៉ុន្តែអ្វីដែលបងមានគឺរូបកាយចាស់ ប្រពន្ធក៏ចាស់ ដែលមិនអាចមានកូន ហើយនិងហ្វូងចៀមដ៏ធំមួយនេះ។


អ័ប្រាហាំ
កុំខ្លាចអី អញជាអ្នកការពារឯង
ហើយជារង្វាន់ធំរបស់ឯង ។
តើទ្រង់នឹងផ្ដល់រង្វាន់
អ្វីឱ្យទូលបង្គំ ។ ទូលបង្គំ
នៅតែគ្មានកូនដដែល ?
ឯងនិងសារ៉ា
នឹងមានកូនមួយ


មក អ័ប្រាហាំ ចូរក្រឡេកមើល
ផ្កាយជាច្រើន ហើយមើលប្រសិនបើឯងអាចរាប់
វាបាន កូនចៅរបស់ឯងនឹងច្រើនដូចជាផ្កាយ
ដែលគេមិនអាចរាប់អស់។
ទូលបង្គំជឿថា
អ្វីដែលទ្រង់មានបន្ទូល
នឹងកើតឡើង។


លោកុប្បត្តិ ១៥:១-៦, ១៣-១៤
ពីព្រោះឯងជឿអញ អញនឹងរាប់សេចក្តីជំនឿរបស់ឯង ទុកវាជាសេចក្តីសុចរិត ។ ចូរដឹងប្រាកដថា កូនចៅឯងនឹងធ្វើជាអ្នកដទៃនៅស្រុកមួយដែលមិនមែនជាស្រុករបស់ផងខ្លួន ។ ក្រោយពីពួកគេបានបំរើពួកស្រុកនោះដោយសេចក្តីវេទនាអស់៤០០ឆ្នាំ អញនឹងជំនុំជំរះសាសន៍នោះ ហើយកូនចៅឯងនឹងចេញមកទាំងមានទ្រព្យសម្បត្តិជាច្រើនវិញ ។ បន្ទាប់មកពួកគេនឹងត្រឡប់មកវិញ ហើយរស់នៅទឹកដីនេះ ។


បង
ការសន្យាថាឱ្យមានកូននោះនៅឯណា?
ពីមួយថ្ងៃទៅមួយថ្ងៃអូនកាន់តែចាស់ ។
បង អ័ប្រាហាំ
អូនមិនអាចមានកូនជូនបងបានទេ ។ហើយបន្តិចទៀត
បងនឹងមិនអាចបង្កើតកូនដើម្បីបន្តពូជបានដែរ ។


តាមទម្លាប់ទឹកដីនេះ
អ្នកបំរើស្រីរបស់អូនក៏អាចមាន
កូនជំនួសអូនបានដែរ ។


អ័ប្រាហាំ តើបងឃើញថានេះជាឱកាសចុងក្រោយរបស់យើង ដើម្បីមានកូនឬនៅ ? កុំឱ្យឃឺតពេលឡើយ បងត្រូវតែយក នាងដើម្បីបង្កើតកូនទៅ វាជាពូជរបស់បង ។ វាជាហឫទ័យរបស់ ព្រះអម្ចាស់ ។ តើមានវិធីណាទៀតក្រៅពីនេះ ? តើមានផ្លូវណាផ្សេងទៀតដែលអាចឱ្យបងធ្វើជាឪពុកនៃប្រជាជាតិដ៏ធំបាន ?


វាជា
មធ្យោបាយ តែមួយ ។
អ័ប្រាហាំ មិនបានអធិដ្ឋានទៅព្រះ
គាត់បានភ្លេចកិច្ចសន្យា របស់ព្រះ
ហើយបានស្តាប់បង្គាប់ប្រពន្ធរបស់គាត់វិញ ។

លោកុប្បត្តិ ១៦:១-៤


ពីរបីខែក្រោយមក...
អញនឹងមានកូន ជាមួយ អ័ប្រាហាំ ។
នៅពេល ហាកា បានដឹងថា នាងមានកូនជាមួយអ័ប្រាហាំ នាងក៏មានអំនួត ហើយបានប្រមាថមើលងាយ សារ៉ា ។ សារ៉ា មិនសប្បាយដោយមានការច្រណែន ។

សារ៉ា បានឱ្យ ហាកា ធ្វើការយ៉ាងធ្ងន់
ហើយបានប្រព្រឹត្តដោយគ្មានសប្បុរសចំពោះនាង ។
ព្រះអម្ចាស់មិនដែលមានបំណងឱ្យបុរសម្នាក់
មានប្រពន្ធពីរ ឬមានកូនជាមួយស្រីស្នំទេ ។




ហាកា បានរត់ចេញពី សារ៉ា
ហើយគេចទៅវាលហោស្ថាន ។ នៅពេល ហាកា
អស់កំលាំងហើយមិនអាចទៅមុខទៀតនាងបានដួល ។
ព្រះ បានទតឃើញទុក្ខវេទនារបស់នាង
ហើយមានបន្ទូលទៅកាន់នាងថា...
ហាកា ចូរត្រឡប់ទៅឯសារ៉ា
ហើយ ចុះចូលនិងនាងវិញ ។
ឯងនឹងមានកូន ប្រុសម្នាក់
ហើយឯងនឹងដាក់ឈ្មោះវាថា
អ៊ីស្មាអែល មានន័យថា
ព្រះជាម្ចាស់ជ្រាប ។


តាមរយៈវានឹងមានកូនចៅជាច្រើនរហូតដល់
រាប់មិនអស់ ។ អ៊ីស្មាអែល
នឹងជាមនុស្សឃោរឃៅ
វាតែងតែច្បាំងនឹងមនុស្សរាល់គ្នា ហើយគេ
រាល់គ្នាច្បាំងនឹងវាវិញ ។ វាតែងតែរស់នៅ
ផ្តុំគ្នាទាំងអស់ជាមួយបងប្អូនវា ។

# លោកុប្បត្តិ ១៦:៤-១៦



នៅពេលអ៊ីស្មាអែលកើតមក លោក
អ័ប្រាហាំមានអាយុ៨៦ឆ្នាំ ហើយមិន
យូរប៉ុន្មានអ័ប្រាហាំកាន់តែចាស់មិន
អាចបង្កើតកូនដើម្បីបន្តពូជទៀតទេ។
តើអ៊ីស្មាអែលជាកូនដែលព្រះបាន
សន្យាឱ្យអ័ប្រាហាំឬ ? ប៉ុន្តែព្រះមាន
បន្ទូលថា កូននៃការសន្យានឹងមកតាម
រយៈនាង សារ៉ា និង អ័ប្រាហាំ។





តើព្រះអាចបំពេញកិច្ចសន្យារបស់ទ្រង់ដូចម្តេច
ប្រសិនបើ អ័ប្រាហាំ និង សារ៉ា
មានវ័យកាន់តែចាស់ក្នុងការបង្កើតកូន ?


នៅពេលអ៊ីស្មាអែលមានអាយុ១៣ឆ្នាំ ហើយអ័ប្រាហាំ
មានអាយុ៩៩ឆ្នាំ ព្រះបានមានបន្ទូលទៅគាត់ម្តងទៀតថា...
អ័ប្រាហាំ   អញជាព្រះដែលមានគ្រប់ព្រះចេស្តា ។
ចូរធ្វើកិច្ចការទាំងអស់ដែលអញប្រាប់ឯង
ហើយកុំធ្វើបាបឱ្យសោះ ។   ដូចអញបានប្រាប់ពីមុន
អញនឹងចំរើនកូនចៅរបស់ឯង   ហើយឯងនឹងធ្វើជា
ឪពុកនៃប្រជាជាតិដ៏ច្រើន ។   អញនឹងតាំងការ
សន្យារបស់អញជាមួយឯង   ហើយជាមួយ...


...នឹងកូនចៅរបស់ឯងតទៅមុខ
ទៀត។ អញនឹងឱ្យទឹកដីកាណានដល់
កូនចៅរបស់ឯងទុកជាទ្រព្យសម្បត្តិ
រហូតអស់កល្បជានិច្ច។ សារ៉ានឹង
មានកូនម្នាក់ដូចដែលអញបាន សន្យា
ហើយកូននោះនឹងធ្វើជា
ឪពុកនៃប្រជាជាតិដ៏ច្រើន។


[redacted]
ទេ ដូចអញបាននិយាយតាំងពីកាលដំបូង ឯងនិងសារ៉ា
នឹងមានកូនផ្ទាល់ខ្លួនដែលចេញពីរូបកាយរបស់ឯង ។ កិច្ចសន្យា
នៃការប្រទានពរនឹងបានបន្តតាមវា មិនមែនតាមអ៊ីស្មាអែលទេ ។
ក្នុងរយៈពេលមួយឆ្នាំសារ៉ានឹងបានសម្រាលកូនប្រុសមួយ ។


ឃាស់ឃាំ ! តើនេះនឹងកើតឡើង យ៉ាងម៉េច ? ឥឡូវទូលបង្គំមានអាយុ៩៩ឆ្នាំ ហើយសារ៉ា មានអាយុ៨៩ឆ្នាំ។ រូបកាយទូលបង្គំដូចជារូបកាយស្លាប់ ពួកទូលបង្គំមិនអាចមានកូនបានទេ។ សូមព្រះអនុញ្ញាតឱ្យ កូនអ៊ីស្មាអែលធ្វើជាកូននៃការសន្យាចុះ។


តើវាអាចកើតឡើងឬទេ ? អាច ! ព្រះដែលបានបង្កើតរូបកាយមក ទ្រង់អាចយករូបកាយពីរដែលមានវ័យចំណាស់ ដូចជាស្លាប់នឹងធ្វើឱ្យមានកំលាំងក្នុងការបន្តពូជឡើងវិញ។ ពិតណាស់ព្រះជាម្ចាស់អាចធ្វើបាន !


ពីរបីថ្ងៃក្រោយមកមានបុរស៣នាក់ចេញ
មកពីវាលខ្សាច់ ។ ពួកគេមិនទំនងជាអ្នក
ធ្វើដំណើរឆ្ងាយទេ ហើយមិនមែនជា
មនុស្សនៅក្នុងស្រុកដែរ ។ ពួកគេជាអ្នក
មាំមួននឹងគ្មានការញញើត ហើយ
មិនដឹងថា ពួកគេមានអាយុប៉ុន្មានដែរ ។


អ័ប្រាហាំ បានឃ្លាំមើលពួកគេដើរតម្រង់មក ហើយ គាត់ដឹងថា ពួកគេខុសប្លែកពីធម្មតា ប៉ុន្តែអ្វីដែល គាត់មិនដឹងគឺថា ភ្ញៀវរបស់គាត់បានមកពីឋានសួគ៌ ។
ពួកគេពីរនាក់ជាទេវតាសុចរិត ហើយទីបីជា ព្រះអម្ចាស់ ដែលបង្ហាញអង្គទ្រង់ជារូបទេវតា ដើម្បីទ្រង់អាចមានបន្ទូលទៅកាន់អ័ប្រាហាំ ។ អ័ប្រាហាំបានចេញទៅជួបពួកគេ ។
លោកុប្បត្តិ ១៧:១-២១, ១៨:១-២


អ័ប្រាហាំ ប្រពន្ធ របស់ឯង សារ៉ា នឹងមាន កូនប្រុសមួយ ។
ហ៊ឹស ...
ខ្ញុំចាស់ហើយនិងបងអ័ប្រាហាំ ក៏ចាស់ដែរ ។ តើអាចឱ្យខ្ញុំសប្បាយក្នុង តម្រេកទៀតយ៉ាងម៉េច ?


ហេតុអ្វីសារ៉ាសើចនៅពេល ព្រះជាម្ចាស់មានបន្ទូលថា នាងនឹង មានកូនប្រុសមួយ ?
ខ្ញុំមិនបានសើចទេ ។
ឯងបានសើចមែន ។ ឯងមិនជឿ តើ មានការអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើត ? ដល់វេលា កំណត់ដែលឯងត្រូវចាប់ផ្ដើមមានគភ៌ អញនឹងត្រឡប់មក វិញ លុះគ្រប់ខែហើយឯងនឹងបង្កើតបានកូនប្រុសមួយ ។


មែន៎ គាត់ចាំបាច់ត្រូវតែដឹង។
តើអញគួរតែប្រាប់អ័ប្រាហាំនូវអ្វីដែលអញរៀបនឹងធ្វើឬ ? វានឹងធ្វើជាឪពុកនៃកូនចៅជាច្រើន ហើយវានឹងអប់រំកូនចៅរបស់វាឱ្យចេះគោរពអញ។




លោកុប្បត្តិ ១៨:១០-២២


វាជាការមិនធម្មតាចំពោះព្រះជាម្ចាស់បំផ្លាញមនុស្សសុចរិតជាមួយនិងមនុស្សអាក្រក់នោះទេ ។ បើសិនជាមានមនុស្សសុចរិត៥០នាក់នៅក្នុងក្រុងនោះ តើទ្រង់នឹងធ្វើដូចម្ដេច ? តើព្រះជាម្ចាស់ទុកទីក្រុងទាំងមូលដើម្បីសង្គ្រោះពួកសុចរិតឬ ? ទូលបង្គំដឹងថា ចៅក្រមរបស់មនុស្សទាំងអស់នឹងធ្វើអ្វីដែលមានភាពយុត្តិធម៌ ។
បើសិនអញឃើញមាន មនុស្សសុចរិត៥០នាក់ អញនឹង មិនបំផ្លាញទីក្រុងនោះទេ ។


ទូលបង្គំជាធូលីដីមិនគួរនិយាយទៅកាន់ព្រះអង្គ
ប៉ុន្តែ បើមានមនុស្សសុចរិត៤៥នាក់
តើព្រះអង្គនឹងបំផ្លាញ
ទាំងអស់ដោយខ្វះចំនួនតែ៥នាក់ឬ ?
បើអញឃើញមាន៤៥នាក់
នោះអញមិនបំផ្លាញទេ


តែបើឃើញមានតែ ៤០នាក់ ?
អញនឹងមិនបំផ្លាញបើសិន មានអ្នកសុចរិតតែ៤០នាក់


សូមកុំក្រោធនឹងទូលបង្គំ ចុះបើមាន៣០នាក់ ?
អញមិនបំផ្លាញបើមាន ៣០នាក់
ចុះបើមាន ត្រឹម២០នាក់ ?
អញនឹងមិនបំផ្លាញ ប្រសិន បើមនុស្សសុចរិត២០នាក់ នៅក្នុងទីក្រុងនោះ


សូមមេត្តាកុំខ្ញាល់ នេះជាពេលចុងក្រោយដែលទូលបង្គំសួរព្រះជាម្ចាស់ ប្រសិន បើមានមនុស្សសុចរិតតែ១០នាក់នៅក្នុងទីក្រុង តើព្រះអង្គនៅតែបំផ្លាញឬ ?
ទេ ប្រសិនបើអញ ឃើញមនុស្សសុចរិត១០នាក់ អញនឹងមិនបំផ្លាញទីក្រុង នោះទេ។


យើងនឹងទៅផ្ទះ
គាត់នៅយប់នេះ
បើព្រះអង្គរកមិនឃើញ ១០នាក់
សូមព្រះជាម្ចាស់ដាស់តឿន ដល់ក្មួយខ្ញុំ
គឺឡុតផង ។


នៅល្ងាចនេះទេវតាទាំងពីរអង្គទៅទីក្រុង ហើយដើរកាត់មុខផ្ទះរបស់ឡុត។
ទីក្រុងនេះគឺអាក្រក់ជាង ដែលខ្ញុំបានគិតទៅទៀត។
ពេលនេះខ្ញុំដឹងពីមូលហេតុដែលព្រះ អម្ចាស់នឹងបំផ្លាញគ្រប់ទាំងមនុស្ស សូម្បី តែក្មេងនិងសត្វពាហនៈក៏មិនទុកដែរ។




លោកុប្បត្តិ ១៨:២៣-១៩:២


ឡុត ចូរឯងនាំវាមក ឱ្យយើងបានរួមតំណែក ជាមួយពួកវាផង !
(ឡុតស្រែកពីខាងក្នុង) ចេញទៅឱ្យឆ្ងាយ ឯងមិនអាច ធ្វើការអាក្រក់នេះទេ ។
តើវាគិតថាវាជាអ្នកណា បានជាមានចិត្តធំហើយខ្លាំង ពូកែ ? អាពួកលាក់ពុតដែល មានចិត្តចង្អៀតចង្អល់ ។


អាជនបរទេស យើង នឹងទំលុះទ្វារចូលហើយ ប្រព្រឹត្តអាក្រក់លើឯងជាង អាពីរនាក់នោះទៀត ។
អាពួកសំអប់!
មែនហើយ យើងមិនត្រូវការ កូនស្រីរបស់ឯងទេ យើងត្រូវការ បុរសស្អាតពីរនាក់នោះ ។


នៅពេលទ្បុតខ្លាចពួកគេ ទម្លុះទ្វារចូល ពួកទេវតា ក៏បានបើកទ្វារហើយ មានបន្ទូលថា...
ព្រះអម្ចាស់ ធ្វើឱ្យឯងខ្វាក់
ពួកគេនៅឯណា?


អ្នកណាបិទភ្លើង?
តើអំណាចនេះមកពីណា?
ខ្ញុំមើលមិនឃើញទេ
តើមានអ្វីបានកើតឡើង ?


ឯងត្រូវតែចាកចេញពីក្រុងនៅព្រឹកស្អែក ចូរប្រាប់ដល់អ្នកណាក៏បាន ។ ព្រះអម្ចាស់សុចរិត ហើយមិនបណ្ដោយឱ្យអំពើបាបនេះបន្តទៅទៀតទេ ។
ស្អែកព្រះអម្ចាស់នឹងទំលាក់ភ្លើងមកពីលើមេឃមកកន្លែងនេះ មនុស្សគ្រប់គ្នានៅសូដុមនិងកូម៉ូរ៉ានឹងស្លាប់ ។




លោកុប្បត្តិ ១៩:៤-១៧


កុំងាកក្រោយ!
អឺយ៉ា...!


ទេ ! ប៉ា !
ម៉ាក់បានក្លាយជាអំបិលដោយសារមិនស្តាប់បង្គាប់ព្រះ ។
កុំមើល! បន្តរត់ទៅ!



គ្រប់របស់មានជីវិតក្នុងសូដុមនិងកូម៉ូរ៉ាបានស្លាប់នៅថ្ងៃនោះ ។
ព្រះអម្ចាស់សុចរិតទ្រង់ស្អប់អំពើបាប ជាពិសេសបាបបានធ្វើខុសពី
ការរួមភេទធម្មតា ប្រុសនិងប្រុសស្រីនិងស្រីដូចគ្នា ។ អំពើបាបដែល
ទាក់ទងរួមភេទជាមួយកុមារអាក្រក់ជាងគេទាំងអស់ ។
ព្រះអម្ចាស់ បានសន្យាមិនបំផ្លាញលោកិយដោយសារទឹកទៀតទេ
ប៉ុន្តែ ទ្រង់មិនដែលមានបន្ទូលអ្វីអំពីភ្លើងទេ ។
នៅលើកក្រោយព្រះនឹង បំផ្លាញដែនដីដោយសារភ្លើង ។


ទោសនៃអំពើបាបណាមួយតូចឬធំ
ក៏ដោយជាសេចក្ដីស្លាប់
សេចក្ដីស្លាប់នេះគឺស្លាប់ទាំងសាច់ឈាម
និងស្លាប់អស់កល្បជានិច្ចក្នុងបឹងភ្លើង។
ឡុតត្រូវបានសង្គ្រោះពីការ
ជំនុំជំរះរបស់ព្រះដោយព្រះគុណរបស់ព្រះអម្ចាស់
ប្រពន្ធរបស់គាត់ មិនជឿបណ្ដាំព្រះទេ
នៅពេលទ្រង់បានប្រាប់ពួកគេកុំងាកក្រោយ។
ទោសនៃអំពើបាបទាំងអស់គឺតែងតែ
ស្លាប់ គ្មានការលើកលែង។




លោកុប្បត្តិ ១៩:២៤-២៦, លេវីវិន័យ១៨:២២, រ៉ូម ១:២៣-៣២, ៦:២៣, កូរិនថូសទី១, ៦:៩-១១, វិវរណៈ ២១:៨


យើងបានសោកស្តាយយ៉ាងខ្លាំងដែលឮអំពីប្រពន្ធរបស់ឯង តើ ឯងនឹងធ្វើអ្វីឥឡូវនេះ ?
យើងនឹងលៃលកតាមដំណើរ
ឡុត និងកូនស្រីពីរនាក់បានចេញទៅ ហើយ ព្រះអម្ចាស់បានបន្តប្រទានពរដល់ អ័ប្រាហាំ ។


ព្រះអម្ចាស់បានសន្យាថា សារ៉ានឹងមានកូនម្នាក់ ។ អ័ប្រាហាំ និង សារ៉ាចាប់ផ្ដើមមានចំណង់ចិត្តវិញចំពោះតម្រេកដែលបានភ្លេចយូរមកហើយ ។
បងអ័ប្រាហាំតើមានអ្វីមកសណ្ឋិតនឹងបង ? ជាច្រើនឆ្នាំយូរមកហើយដែលបងខានសំឡឹងមើលមុខអូននូវរបៀបនេះ ។


វាជាការអស្ចារ្យមួយ ! ពីរបីខែក្រោយមក
មនុស្សគ្រប់គ្នាបានដឹងថា សារ៉ាមានផ្ទៃពោះ ។


ដូចព្រះជាម្ចាស់មានបន្ទូល យើងនឹងហៅវាថា អ៊ីសាក ដែលមានន័យថាអ្នកសើច វានឹងជាឪពុក នៃប្រជាជាតិដ៏ធំមួយ ។
ចាំ ពេលព្រះអម្ចាស់បានប្រាប់យើង អូននឹងមានកូននេះធ្វើឱ្យអូនចង់សើច ។ នរណានឹងជឿថា វ័យចាស់ដូចអូនហើយ នៅបំបៅកូនង៉ែតផ្ទាល់ខ្លួនដូចនេះ ។
ព្រះអម្ចាស់បានរក្សាការសន្យារបស់ទ្រង់ដូចដែលទ្រង់តែងតែធ្វើ ។


អ៊ីស្មាអែលជាកូនប្រុស អ័ប្រាហាំ ដែលម្ដាយឈ្មោះ ហាការ ឥឡូវ នេះមានអាយុ១៤ឆ្នាំ ហើយវាស្អប់ទារកដែលទើបនឹងកើតថ្មី។
អាល្ងង់តូចនេះចំអកដាក់អញផង អញនឹងមិនឱ្យជនអេស៊ីព្ទរស់នៅផ្ទះ អ៊ីសាក ទេ។




ព្រះអម្ចាស់មានបន្ទូលទៅអ័ប្រាហាំថា
“សារ៉ានិយាយត្រូវ ចូរបញ្ជូន
ហាការនិងអ៊ីស្មាអែលចេញឱ្យឆ្ងាយ។
អ៊ីស្មាអែលមិនអាចទទួល មរតកជាមួយអ៊ីសាកទេ
ប៉ុន្តែកុំព្រួយបារម្ភអញនឹងថែរក្សាពួកគេ។

ហើយពីព្រោះអ៊ីស្មាអែលជាកូនប្រុសរបស់ឯង
អញនឹងធ្វើឱ្យប្រែជាជាតិ ដ៏ធំមកពីវាផងដែរ ។
ប៉ុន្តែអ្នកសង្គ្រោះដែលអញបានសន្យា
គឺម្នាក់ នឹងវាយឈ្នះសាតាំង
នឹងកើតពីពូជអ៊ីសាកមិនមែនអ៊ីស្មាអែលទេ” ។



អ៊ីស្មាអែល
ធំឡើងក្លាយជាឪពុកនៃជនជាតិអារ៉ាប់ ។ នៅពេល
អ៊ីសាកធំឡើងក្លាយជាឪពុករបស់ជនជាតិអ៊ីស្រាអែល
ជនជាតិ អារ៉ាប់និងអ៊ីស្រាអែលជាបងប្អូនឪពុកតែមួយ ។

លោកុប្បត្តិ ២១:១-៣, ៩-១៤


ឯងជាកូននៃការអស្ចារ្យ
តើឯងនឹង នាំពិភពលោករួចពីអំពើបាបឬ ?
អ័ប្រាហាំបានស្រឡាញ់កូន
ប្រុសរបស់គាត់អ៊ីសាកខ្លាំង ណាស់
ហើយពួកគេមិនអាច បែកចេញពីគ្នាបាន ។


ប៉ា
ហេតុអ្វីប៉ាសំលាប់កូន ចៀមដ៏ស្អាតនោះ
ហើយ ដុតវាលើគំនរថ្មនេះ ?


ព្រះជាម្ចាស់នៃឋានសួគ៌និងផែនដីគឺបរិសុទ្ធ។
ទ្រង់បរិសុទ្ធជាងមនុស្សមានបាបដូចប៉ាឆ្ងាយ ណាស់។
មនុស្សដំបូង គឺអ័ដាមមិនស្ដាប់បង្គាប់ ព្រះ។
ពីពេលនោះមកពូជមនុស្សពោរពេញ ដោយអំពើបាប ។
ព្រះជាម្ចាស់បាន ប្រាប់អ័ដាមថា
ប្រសិនបើគាត់ប្រព្រឹត្ត
បាបគាត់នឹងស្លាប់ ប៉ុន្តែបន្ទាប់ពីអ័ដាម
ប្រព្រឹត្តបាប ព្រះជាម្ចាស់បានសំលាប់
សត្វ ហើយយកស្បែករបស់វាដើម្បី
បិទបាំងកេរ្តិ៍ខ្មាសអ័ដាមនិងអេវ៉ា។


នៅពេលប៉ាសំលាប់ចៀមហើយថ្វាយ ទៅព្រះ វាជាការបញ្ជាក់ថា ប៉ាស្គាល់អំពើ បាបរបស់ប៉ា ហើយថ្វាយចៀមដែលគ្មាន ទោសស្លាប់ជំនួសប៉ា។


អ៊ីសាក បានធំរឹងមាំឡើងហើយរៀនទុកចិត្តលើព្រះជាម្ចាស់របស់
ឪពុកគាត់។ អ័ប្រាហាំបានស្រឡាញ់គាត់អស់ពីចិត្ត ហើយជាញឹកញាប់
ពួកគេបានទៅថ្វាយបង្គំនិងថ្វាយដង្វាយជាមួយគ្នា។
គេបានសំលាប់ ចៀមហើយបូជានៅលើអាសនៈ។


អ័ប្រាហាំ អញចង់ឱ្យឯងយកកូនប្រុសតែមួយរបស់ឯង អ៊ីសាក ដែលឯងស្រឡាញ់ ហើយធ្វើជាដង្វាយបូជាដល់អញ ។


ព្រះជាម្ចាស់
ហេតុអ្វីព្រះជាម្ចាស់ឱ្យទូល
បង្គំធ្វើរឿងបែបនេះ ?
នេះមិនដូចជាទ្រង់ទេ ? មានតែមនុស្សមិនជឿ
ព្រះដែលថ្វាយដង្វាយជាមនុស្ស ! ព្រះអង្គមានបន្ទូលថា
ព្រះអង្គនឹងធ្វើឱ្យ ប្រជាជាតិដ៏ធំកើតពីកូនប្រុសទូលបង្គំ
អ៊ីសាក ។ បើសិនទូលបង្គំសំលាប់វា
នោះការសន្យារបស់ទ្រង់នឹងមិនបានកើតឡើងទេ ។




លោកុប្បត្តិ ២២:២, រ៉ូម ៥:១២


វាអស់រយៈពេល៣ថ្ងៃក្នុងការធ្វើដំណើរ ដូច្នេះយើងនឹងធ្វើដំណើរទៅមកប្រហែលមួយសប្ដាហ៍។
សូមថែរក្សាខ្លួនឱ្យបានល្អអូននឹងអធិដ្ឋានសំរាប់បងនិងកូនរបស់យើង។

បីថ្ងៃក្រោយមក




ប៉ា យើងបានយកអុសមក ហើយ ប៉ាសង់អាសនៈមួយ ប៉ុន្តែឯណាដង្វាយ ?
អ៊ីសាក តើកូនចាំអ្វីដែលប៉ាបានប្រាប់កូនពីព្រះ ដែលមានបន្ទូលមកប៉ា ហើយបណ្តាលឱ្យម្តាយរបស់កូន និងប៉ាមានកូនក្នុងពេលវ័យចាស់ទេ ? ទ្រង់មាន បន្ទូលមកប៉ាម្តងទៀត ។


ពេលនេះទ្រង់មានបន្ទូល
ប្រាប់ប៉ាថា ប៉ាត្រូវការថ្វាយ
កូនឯងដូចជាយញ្ញបូជា។
ខ្ញុំមែន ? ប៉ា
តើពិតមែនឬ ?


តើព្រះបានប្រាប់ប៉ាទេថា កូននឹងទទួលមរតក
ហើយធ្វើជាឪពុកនៃប្រជាជាតិដ៏ធំ ហើយកូនចៅរបស់កូននោះ
នឹងរីកចំរើនដូចជាផ្កាយនៅលើមេឃមែនឬប៉ា ?
ប្រសិនបើកូនស្លាប់ពេលនេះ តើអ្វីទៅជាកិច្ចសន្យារបស់ព្រះ?


ប៉ាបានដឹងថា អ្វីដែលព្រះអម្ចាស់បានសន្យា
ទ្រង់អាច ធ្វើបាន ។ ប្រសិនបើទ្រង់មានបន្ទូលមកកូនឱ្យធ្វើជាឪពុក
នៃប្រជាជាតិដ៏ធំក៏ដោយ ទោះកូនស្លាប់ក៏មិនអីដែរ ។


ប៉ុន្តែវាអាចកើតឡើង យ៉ាងម៉េចបើកូនស្លាប់?
ប៉ាមិនដឹងទេ លុះត្រាតែទ្រង់ នឹងធ្វើឱ្យកូនរស់ពីស្លាប់វិញ ។
ប៉ា យើងត្រូវតែស្តាប់បង្គាប់ព្រះ ទោះបីមានអ្វីកើតឡើងក៏ដោយ ។

លោកុប្បត្តិ ២២:៣-៩


ទោះបីអ័ប្រាហាំដឹងថាគាត់បានស្តាប់បង្គាប់ព្រះ តែវាពិតជាបានធ្វើឱ្យចិត្តរបស់គាត់បារម្ភ ហើយ ដៃរបស់គាត់ញ័រ នៅពេលគាត់ធ្វើតាមរបៀបធម្មតានៃការថ្វាយដង្វាយបូជា។
អ័ប្រាហាំបានចងដៃចងជើងកូនរបស់គាត់ ហើយដាក់កូននៅលើអាសនៈ។ បន្ទាប់មកគាត់ក៏យកកាំបិតតម្រង់ចាក់ករបស់វា។

ដោយការអធិដ្ឋាននៃសេចក្ដីជំនឿដល់ព្រះ
អ័ប្រាហាំបានលើកកាំបិត ។ នៅពេល
គាត់ហៀបនឹងចាក់កកូន ភ្លាមនោះ
គាត់បានឮសំលេងពីឋានសួគិថា...




អ័ប្រាហាំ
! អ័ប្រាហាំ !
កុំធ្វើឱ្យមានគ្រោះថ្នាក់ដល់កូន ។


ឥឡូវអញដឹងថាឯងទុកចិត្ត អញ ពីព្រោះឯងស្តាប់បង្គាប់ដោយ អស់ពីចិត្ត ព្រមទាំងថ្វាយកូនប្រុស តែមួយដល់អញ ។


នៅពេលអ័ប្រាហាំងើបឡើង គាត់បានឃើញចៀមឈ្មោលមួយជាប់ក្នុងគុម្ពោតព្រៃ។
ប៉ា មើល ព្រះអម្ចាស់បានផ្ដល់ចៀមឈ្មោលដើម្បីថ្វាយជំនួសខ្ញុំ !


អ័ប្រាហាំ ដោយសារឯងបានធ្វើកិច្ចការនេះ
មិនបានសំចៃទុក កូនប្រុសរបស់ឯង
អញនឹងចំរើនពរដល់ឯង
ហើយឱ្យកូនចៅឯងបាន
ចំរើនឡើងដូចផ្កាយនៅលើមេឃ ។
កូនចៅរបស់ឯងនឹងធ្វើជាម្ចាស់ទឹកដី
នេះ ហើយបំផ្លាញសត្រូវរបស់ឯង ។
តាមរយៈកូនចៅរបស់ឯងម្នាក់
ដែលមិនទាន់កើតនៅឡើយ
គ្រប់ជាតិនៅផែនដីទាំងអស់នឹងបានពរ ។
លោកុប្បត្តិ ២២:៩-១៨,
ហេព្រើ ១១:១៧-១៩
ប៉ា ទ្រង់គឺប្រកប
ដោយមេត្តាករុណា
ដូចប៉ាបាននិយាយមែន!


អ័ប្រាហាំមានកូនប្រុសពីរនាក់ អ៊ីស្មាអែល និង អ៊ីសាក ។
អ៊ីសាកគឺកូនដែលព្រះអម្ចាស់បានជ្រើសរើសបន្តនូវកិច្ច
សន្យាដែលបានធ្វើជាមួយអ័ប្រាហាំ ។ អ៊ីសាកមានកូនម្នាក់
ឈ្មោះ យ៉ាកុប ដែលប្តូរឈ្មោះមកជា អ៊ីស្រាអែល ។
ហើយយ៉ាកុបក៏មានកូនប្រុស១២នាក់ទៀត ក្រោយមក
គ្រួសារទាំងដប់ពីររបស់ពួកគេបានចុះទៅអេស៊ីព្ទ ហើយ
នៅទីនោះជាកន្លែងដែលពួកគេក្លាយជាទាសករ ។
(១៧០៦ឆ្នាំមុន គ.ស.)

# លោកុប្បត្តិ ២១:៥, ១៣, ២៤:៦៧, ២៥:១២-១៨, ២១-២៦,២៩:២៣-៣០

កូន១២នាក់របស់ យ៉ាកុប បានក្លាយជាកុលសម្ព័ន្ធទាំង ១២នៃសាសន៍អ៊ីស្រាអែល ។

អ៊ីស្មាអែលក៏បង្កើតចៅហ្វាយប្រុស១២នាក់ ហើយបានក្លាយជាប្រជាជនអារ៉ាប់ ។





## ជំពូក ៣

# ម៉ូសេ


ឆ្នាំ១៧០៦មុន គ.ស.
ក្នុងអំឡុងពេលគ្រោះទុរភិក្ស យ៉ាកុប
ដែលជាចៅប្រុសរបស់ អ័ប្រាហាំបាននាំកូនប្រុស១២នាក់
ហើយកូនរបស់គេទាំងអស់និង
អ្នកបំរើបានចុះទៅរស់នៅអេស៊ីព្ទ ។ហើយនៅក្នុងប្រទេស
អេស៊ីព្ទពួកគេបានចំរើនដូចជាធូលីដី ។


មិនយូរប៉ុន្មានកូនចៅរបស់យ៉ាកុប ដែលបានប្តូរឈ្មោះ
ជាអ៊ីស្រាអែល មានចំនួនច្រើនជាងជនជាតិអេស៊ីព្ទ។


ផារ៉ោន ជាអ្នកគ្រប់គ្រងប្រទេសអេស៊ីព្ទ
បានធ្វើឱ្យកូនចៅរបស់យ៉ាកុបក្លាយជាពួក ទាសករ ហើយបានបង្ខំធ្វើការងារយ៉ាង
ធ្ងន់ដោយឱ្យធ្វើឥដ្ឋ។ បន្ទាប់ពីគេរស់ នៅទីនោះជាង៣០០ឆ្នាំ ពួកគេបានភ្លេច
កិច្ចសន្យាដែលព្រះអម្ចាស់បានប្រាប់ មកអ័ប្រាហាំនិងព្ធយុកោរបស់គេ។


ព្រះអម្ចាស់បានប្រាប់អ័ប្រាហាំថា វង្សតំណរបស់គាត់នឹងចុះទៅរស់នៅប្រទេសអ្នកដទៃ ហើយធ្វើជាទាសករនៅទីនោះ។ ទ្រង់ក៏សន្យាទៀតថា បន្ទាប់ពី៤00ឆ្នាំទ្រង់នឹងកាត់ទោសប្រជាជាតិនោះ ហើយនាំពូជពង្សរបស់អ័ប្រាហាំត្រឡប់មកទឹកដីសន្យាវិញ។


ខ្ញុំប្រាប់អ្នកជាការពិត !
ផារ៉ោនភ័យខ្លាចពួកយើងកំពុង មានគ្នាច្រើន។
គាត់នឹង សំលាប់ទារកទាំងអស់។ ជន
ជាតិអេស៊ីព្ទសុទ្ធតែទន់ខ្សោយ ហើយខ្ជិល។
ពួកប្រុសៗសាសន៍ របស់យើងមានកំលាំងខ្លាំង
ដោយធ្វើការងារយ៉ាង នឿយហត់។
ដូច្នេះពួកគេ ខ្លាចពួកយើង។
ពួកគេនឹងមិនសំលាប់
កូនខ្ញុំទេ ព្រះជាម្ចាស់នឹង
ការពារវា។
ហ៎ា ! តើព្រះអាច
ធ្វើយ៉ាងម៉េចដើម្បីប្រឆាំងនឹង
អំណាចរបស់ ផារ៉ោន បាន ?




ផារ៉ោន ក្នុងភាសាអេស៊ីព្ទមានន័យថា ស្ដេច

លោកុប្បត្តិ ៤៦:៥-៧, និក្ខមនម ១:១-១២, ២២


ម៉ែ តើខ្ញុំនឹងប្រាប់ពួកទាហាន និង អ្នកជិតខាងដូម្ដេច នៅពេលពួកគេសួរថា កូនរបស់ម៉ែនៅឯណានោះ ?
កូនឯងគ្រាន់តែប្រាប់ ពួកគេត្រង់ថា ម្ដាយរបស់វា បានបោះវាចូលទៅក្នុងទឹកស្ទឹង ដូច្នេះពួកទាហាននឹងមិន ត្រូវការធ្វើទេ ។


ប្រហែលជាឆ្នាំ១៥២៥ មុន គ.ស.
ម៉ែ តើម៉ែដឹងច្បាស់ថា វាមិនលិចឬ ?
កន្ត្រកវានឹងអណ្ដែត ពីព្រោះម៉ែបានលាប ជ័រយ៉ាងក្រាស់ ។


តើយើងនឹងជួបប្អូនប្រុសតូច ម្តងទៀតឬទេ ? អ៊ូ ជនជាតិ អេស៊ីព្ទទាំងនោះអាក្រក់ណាស់ !
ព្រះជាម្ចាស់នឹងថែរក្សាវា កូនតាមឱ្យកៀកនិងចាំឃ្លាំមើល ។


បុត្រីរបស់ផារ៉ោនបានចុះ
មកងូតទឹកស្ទឹង ។
មើលនុះន៎
មានសំលេង
យំចេញពីកន្ត្រកនោះ !


វាប្រហែលជាកូន ជនជាតិហេព្រើរ ។
អ៊ូ វាគួរឱ្យស្រលាញ់ មែនទេ ?
វាពិតជាឃ្លាន


ខ្ញុំនឹងថែរក្សាវា បើសិនខ្ញុំរកបាននរណាម្នាក់ ដែលអាចធ្វើជាមេដោះ ។
នោះជាក្មេងហេព្រើរម្នាក់ ។ ប្រហែលវាស្គាល់នរណាម្នាក់ដែល អាចធ្វើជាមេដោះបាន ។


ខ្ញុំម្ចាស់នឹងទៅរក ។ ប្រហែល
ខ្ញុំម្ចាស់អាចរកមេដោះសំរាប់វាបាន ។
ខ្ញុំម្ចាស់ស្គាល់ស្ត្រីហេព្រើរម្នាក់ គេទើប
តែបោះកូនរបស់គាត់ចូលក្នុងស្ទឹង
គាត់នៅមានទឹកដោះគ្រប់គ្រាន់ ។

និក្ខមនំ ២:៣-៩


នៅផ្ទះស្ត្រីដែលដាក់កូនបណ្ដែតទឹកក្នុងកន្ត្រក ។
តើខ្ញុំបានធ្វើអ្វី ? តើខ្ញុំនឹងឃើញកូនរបស់ខ្ញុំទៀតទេ? តើព្រះជាម្ចាស់ខ្វល់ខ្វាយឬទេ ?
អ្នកគ្មានផ្លូវជ្រើសរើសទេ ។ អ្នកមិនអាចលាក់កូនរបស់អ្នករហូតទេ ។ មិនយូរមិនឆាប់ពួកទាហាននឹងរកឃើញ ហើយសំលាប់វាចោល ។ ឯងត្រូវតែទុកចិត្តលើព្រះជាម្ចាស់ ។
ម៉ែ! ម៉ែ!


ម៉ែ បុត្រីរបស់ផារ៉ោនមកស្ទឹងហើយបានឃើញប្អូន
ប្រុសតូចយើង ។ គាត់ចង់យកវាចិញ្ចឹម ហើយគាត់កំពុង
ស្វែងរកស្ត្រីម្នាក់ដែលអាចធ្វើជាមេដោះបាន !
ឥឡូវគាត់កំពុងមកទីនេះជួបម៉ែ !
មានពរហើយព្រះ
ដ៏អស់កល្ប !


ខ្ញុំបានឮថា កូនរបស់
អ្នកមីងស្លាប់។
ខ្ញុំសោកស្ដាយណាស់ ខ្ញុំបាន
ឃើញទារកមួយនេះនៅក្នុងស្ទឹង។
ខ្ញុំនឹងជួយ
ផ្ដត់ផ្គង់ឱ្យអ្នកមីងថែរក្សាវា។


នៅពេលវាលែងដោះ ខ្ញុំនឹងយកទៅ វាំងដើម្បីអប់រំ ហើយតែងតាំងធ្វើជា ផារ៉ោន នៃ ប្រទេសអេស៊ីព្ទ។ យើងនឹងហៅវាថា ម៉ូសេ។
នៅពេលម៉ូសេធំឡើង នាងបានបង្រៀនវាអំពីព្រះពិតរបស់ព្វយុកោរបស់វា។ ព្រះអម្ចាស់មានបំណងពិសេសមួយសំរាប់ក្មេងតូចនេះ។


នៅពេលម៉ូសេមានអាយុ៥ទៅ៦ឆ្នាំ
បុត្រីផារ៉ោនបានយកវាទៅវាំង ។
លោតឡើងមកបុត្រាតូច
ហើយយើងនឹងជិះរាជរថទៅវាំង ។
តើវាអាច
រត់លឿនឬទេ ?
អគុណចំពោះការថែរក្សាម៉ូសេ
វាទំនង ជាមានសុខភាពល្អណាស់ ។
វានឹងធំឡើងហើយមាន
អំណាចនិងទ្រព្យសម្បត្តិជាច្រើន ។
និក្ខមនំ ២:៨-១០


ដោយសារម៉ូសេជាកូនចិញ្ចឹមរបស់បុត្រីផារ៉ោន
គាត់បានធំឡើងក្លាយជា មហាបុរសម្នាក់ក្នុងប្រទេសអេស៊ីព្ទ ។
គាត់មានវាសនាទទួលទ្រព្យសម្បត្តិ និងមានអំណាច
ប៉ុន្តែគាត់មិនភ្លេចពង្សាវតាររបស់គាត់ទេ ។


ម៉ូសេ ខ្ញុំប្រាប់អ្នក
ព្រះអម្ចាស់នៃព្ធយុកោយើងគឺ អ័ប្រាហាំ អ៊ីសាក និង យ៉ាកុប
ទ្រង់មានបន្ទូលប្រាប់អ័ប្រាហាំថា វង្សតំណរបស់គាត់នឹងកើនច្រើន
ហើយគេនឹងក្លាយជា ពួកដទៃក្នុងទឹកដីដែលមិនមែនជារបស់គេ។
ឥឡូវទាំងអស់នេះកំពុងកើតឡើងហើយ !


បាទ ហើយទ្រង់បាន
ប្រាប់អ័ប្រាហាំថា យើងនឹង
មានទុក្ខលំបាកក្នុងទឹកដីរបស់អ្នក
ដទៃអស់រយៈពេល ៤00ឆ្នាំ។
ឥឡូវនេះយើងបានរស់នៅទីនេះ
អស់៣៥៩ឆ្នាំហើយ នៅសល់
តែ៤១ឆ្នាំទៀតប៉ុណ្ណោះ។


ហើយទ្រង់បានប្រាប់អ័ប្រាហាំទៀតថា ទ្រង់នឹងជំនុំជំរះប្រជាជាតិនោះចំពោះការអាក្រក់ដែលគេនឹងប្រព្រឹត្តមកលើយើង ហើយពេលនោះយើងចាកចេញដោយយកទ្រព្យសម្បត្តិជាច្រើន ហើយត្រឡប់ទៅកាន់ទឹកដីដែលព្រះអម្ចាស់ផ្តល់ឱ្យព្ធយុកោរបស់យើង ។


នោះហាក់ដូចជាមិនគួរឱ្យជឿ ។
ផារ៉ោននឹងមិន ឱ្យទាសកររបស់ទ្រង់ចាកចេញទេ ហើយពិតជានឹងមិន
ឱ្យគេចាកចេញដោយមានទ្រព្យសម្បត្តិដែរ ។ ប៉ុន្តែប្រហែល
ជាមានវិធីមួយ ។ ហេតុអ្វីយើងត្រូវរងចាំ៤១ឆ្នាំទៀត ?


ពួកហេព្រើរត្រូវរងការឈឺចាប់ក្រោមអំណាចចៅហ្វាយរបស់ពួកគេ។ ពួកគេត្រូវតែធ្វើការជាអ្នកធ្វើឥដ្ឋក្នុងរណ្តៅភក់។ ម៉ូសេមិនអាចទ្រាំបានដោយឃើញពួកគេមានការឈឺចាប់ ដូច្នេះគាត់បានសម្រេចចិត្តនឹងធ្វើអ្វីមួយចំពោះការនេះ។
ក្រោកឡើងប្រយ័ត្ន គាត់វាយឯងស្លាប់ !
ក្រោកឡើង អាជ្រូកកខ្វក់ !
អេប៊ីស ក្រោកឡើង។
និក្ខមនំ ២:១០-១១


ថ្ងៃមួយម៉ូសេបានឃើញជនជាតិ
អេស៊ីព្ទម្នាក់កំពុងវាយប្រជាជន របស់គាត់យ៉ាងសាហាវ ។
ដល់ពេលដែលត្រូវ
ដោះលែងហើយ ការនេះ
ត្រូវតែឈប់ ។


ឯងឈប់ធ្វើទៀត!
ម៉ូសេបានសំលាប់ជនជាតិអេស៊ីព្ទម្នាក់ ហើយបានកប់សាកសពនោះ ប៉ុន្តែមានម្នាក់បានឃើញ គាត់ ហើយបានរាយការណ៍ដល់ ផារ៉ោន។


ឈប់ ឯងត្រូវតែ ប្រឈមមុខនឹងការកាត់ទោស ពីបទសំលាប់មនុស្ស!
គឺលោកម៉ូសេ!
ឱ ព្រះជាម្ចាស់! តើខ្ញុំបានធ្វើអ្វីអញ្ចេះ?


ប្រហែលជាឆ្នាំ១៤៩១ មុន គ.ស.
ម៉ូសេ បានចាកចេញពីអេស៊ីព្ទ ហើយ គេចទៅវាលរហោស្ថាន ។ គាត់នៅតែឯង គ្មានគ្រួសារឬមិត្តភក្តិ គាត់មិនបានរំដោះ ប្រជាជនរបស់ខ្លួន ហើយក៏មិនបាន រំដោះខ្លួនគាត់ផងដែរ ។
និក្ខមនំ ២:១១-១៥


ម៉ូសេ បានដើរអស់រយៈពេលជាច្រើនថ្ងៃ ។
នៅពេលគាត់មិនអាច ដើរទៅឆ្ងាយទៀត
គាត់បានមកជិតជំរុំពួកអ្នកគង្វាល ។
មើលន៎ !
មាន បុរសម្នាក់!
គាត់ទំនងជាជិតស្លាប់
សូមយកទឹកមក ។
គាត់ជាជនជាតិ
អេស៊ីព្ទ !

ម៉ូសេ
បានរកឃើញជីវិតថ្មីជាមួយមនុស្សស្រុកម៉ាឌាន ។
គាត់ស្វែងយល់ពីរបៀបរស់នៅវាលរហោស្ថាន
បានរៀបការ និងក្លាយជាអ្នកគង្វាលចៀម ។
៤០ឆ្នាំបានកន្លងផុតទៅ
ម៉ូសេស្ទើតែពុំមានការចងចាំពីប្រទេសអេស៊ីព្ទ ។ ម៉ូសេ
អស់សេចក្តីសង្ឃឹមនឹងជួបប្រជាជនគាត់ម្តងទៀត ។




នោះគឺពិតជាចំឡែក !
គុម្ពាតព្រៃនោះ មានភ្លើងមកពីណា
? ហេតុអ្វីវាឆេះមិនសុស ?
វាមានភ្លើងឆេះរហូត ។


ម៉ូសេ
ចូរដោះស្បែកជើងចេញ
ឯងកំពុងឈរនៅលើដីបរិសុទ្ធ ។
អញជាព្រះរបស់ព្ធយុកោឯងគឺ
អ័ប្រាហាំ អ៊ីសាក និង
យ៉ាកុប ។


អញបានឃើញការឈឺចាប់
និងបានឮការអធិដ្ឋាននៃ
ប្រជារាស្ត្ររបស់អញនៅប្រទេសអេស៊ីព្ទ ។
វាដល់ពេលនាំ ពួកគេចេញពីការកៀបសង្កត់
ហើយនាំពួកគេត្រឡប់ទៅ
ទឹកដីដែលអញបានសន្យាឱ្យព្ធយុកោរបស់គេ ។
និក្ខមនំ ២:១៦-៣:១០


អញនឹងបញ្ជូនឯងទៅផារ៉ោន ហើយឯងនឹងនាំប្រជារាស្ត្ររបស់អញចេញពីទាសភាពរបស់ពួកគេ។ ឯងនឹងប្រាប់វាឱ្យដោះលែងប្រជារាស្ត្ររបស់អញ ប៉ុន្តែវានឹងមិនព្រម។ បន្ទាប់មកអញនឹងបង្ហាញពីអំណាចរបស់អញដល់អេស៊ីព្ទ។ ក្រោយមកនោះផារ៉ោននឹងដោះលែងពួកគេទៅ។


”ប៉ុន្តែពួកគេនឹងមិនជឿថា
ព្រះអង្គបានបញ្ជូនទូលបង្គំ
មកទេ ពួកគេនឹងសើច។


ចូរទម្លាក់ដំបង
របស់ឯងទៅដី ។


ឆ្កែ? ដំបងរបស់ខ្ញុំ!


វាបានក្លាយជាពស់មានពិសយ៉ាងសាហាវ !


ចូរចាប់កន្ទុយពស់ លើកឡើង ។


វាបានក្លាយមក
ជាដំបងរបស់ខ្ញុំវិញ ។


ចូរទៅប្រទេសអេស៊ីព្ទ
អញនឹងបង្ហាត់
ឯងនូវអ្វីដែលត្រូវនិយាយ ហើយប្រាប់
ឯងនូវអ្វីដែលត្រូវធ្វើ។ បងរបស់ឯង
អើរ៉ុន នឹងធ្វើជាជំនួយការរបស់ឯង។
និក្ខមនំ ៤:១-៤, ១២-១៦


ឆ្នាំ១៤៤៥មុន គ.ស.
បងនឹងត្រឡប់ទៅអេស៊ីព្ទ! ចុះគិតយ៉ាងម៉េចអំពី អ្នកទាំងអស់ដែលចង់សំលាប់បងនៅទីនោះ?
វាបានកន្លងផុត៤០ឆ្នាំមកហើយ ។ អ្នកទាំងអស់ដែលស្គាល់ប្រវត្តិបង បានស្លាប់អស់ហើយ គ្មាននរណាម្នាក់ នៅស្គាល់បងទេ ។


រហូតដល់ ផារ៉ោន ដោះលែងប្រជារាស្ត្ររបស់ ព្រះអម្ចាស់ចេញទៅ ។
បងនឹងទៅរយៈ ពេលប៉ុន្មានថ្ងៃ ?


ចូរហៅចាស់ទុំទាំងអស់ មកជុំគ្នា ! ពេលវេលានៃការរំដោះ បានមកដល់ហើយ !
ពួកគេជានរណា?
នោះគឺ អើរ៉ុន ជាពួកលេវី ម្នាក់ផ្សេងទៀតមើលដូចពួកយើង ប៉ុន្តែគាត់មិនមែនជាទាសករទេ ។


ម៉ូសេ
បានកើតមក៨០ឆ្នាំមុន ក្នុង
អំឡុងពេលការសំលាប់ដ៏ធំមួយនៅថ្ងៃ
នោះ ដែលផារ៉ោនបានចាប់ផ្តើមសំលាប់
ទារកទាំងអស់ ។ ម្តាយរបស់គាត់បានលាក់
គាត់ក្នុងកន្ត្រកបណ្តែតក្នុងទឹកស្ទឹង ។ ដោយ
គំរោងការណ៏របស់ព្រះអម្ចាស់ បណ្តាលឱ្យ
បុត្រីរបស់ផារ៉ោនបានឃើញម៉ូសេ ហើយ
ព្រះនាងបានរើសឡើងនិងចិញ្ចឹមគាត់
ដូចជាជនជាតិអេស៊ីព្ទ ។
ចូលជិតខ្ញុំមក
បងប្អូន ចាស់ទុំទាំងអស់នៃ
ជនជាតិអ៊ីស្រាអែល ។


និក្ខមនំ ៤:២៩-៣១
៤០ឆ្នាំមុន ម៉ូសេ បានសម្រេចចិត្តស៊ូទ្រាំទទួលការឈឺចាប់
ជាមួយជនជាតិផ្ទាល់របស់គាត់ ជាជាងសោយរាជ្យជាមួយជនជាតិ
អេស៊ីព្ទ ។ គាត់ព្យាយាមរំដោះពួកយើងដោយអំណាចផ្ទាល់របស់គាត់ ប៉ុន្តែមិនបាន
ជោគជ័យ ។ អស់រយៈពេល៤០ឆ្នាំកន្លងមក គាត់បានរស់នៅវាលខ្សាច់នៃទឹកដីដែល
ព្រះបានសន្យាឱ្យព្ធយុកោរបស់យើង ។ ហើយព្រះអម្ចាស់ទើបតែមានបន្ទូលទៅ
កាន់គាត់ និងបានបង្ហាញនូវរបៀបនាំពួកយើងឱ្យរួចផុតពី ផារ៉ោន ! ឥឡូវនេះ
ម៉ូសេនឹងបង្ហាញទីសំគាល់ដល់អ្នក ដែលគាត់នឹងប្រើដើម្បីធ្វើឱ្យ
ផារ៉ោនមានចិត្តដោះលែងពួកយើងទៅ ។


ព្រះនៃអ័ប្រាហាំមានបន្ទូលមកខ្ញុំ ពីគុម្ពោតព្រៃដែលឆេះ ហើយបញ្ជូនខ្ញុំឱ្យ ដឹកនាំពួកអ្នកត្រឡប់ទៅទឹកដីរបស់ឰយុកោយើង វិញ ។ នេះគឺជាទីសំគាល់មួយ ។


ឃើ!
ដំបងរបស់គាត់
ក្លាយទៅជាពស់!
ចូរកុំខ្លាចឡើយ ។


មើលនេះនែ៎ !


បាទ ការនោះនឹងបង្ហាញ ឱ្យផារ៉ោនភ្ញាក់ខ្លួន !
ព្រះអម្ចាស់បានបញ្ជូនអ្នកជួយរំដោះមកហើយ!


វាជាការអស្ចារ្យមួយ !
ឥឡូវយើងទៅ
ជួបផារ៉ោន !
ព្រះរបស់
អ័ប្រាហាំ !
និក្ខមនំ ៤:១៧, ៣០


វាគ្មានការខុសប្លែកអ្វីទេ
តាំង ពីខ្ញុំបានចាកចេញពីទីនេះនៅ៤០ឆ្នាំ មុន។
ចូរចងចាំហើយត្រូវនិយាយ នូវអ្វីដែលខ្ញុំបានប្រាប់បង។


ព្រះនៃអ៊ីស្រាអែលបានមានបន្ទូលមក
ម៉ូសេថា ចូរឱ្យឯងអនុញ្ញាតឱ្យប្រជាជនហេព្រើរ
ធ្វើដំណើរទៅកាន់វាលរហោស្ថាន៣ថ្ងៃ ដើម្បី
ថ្វាយបង្គំនិងថ្វាយដង្វាយទៅព្រះ ។
ហ៎ ! ព្រះនៃអ៊ីស្រាអែល ?
ហាស់ហ៎.. អញមិនស្គាល់ព្រះរបស់ឯងទេ
ព្រះនេះវាជាអ្នកណា ដែលអញគួរតែគោរពវា
? នោះគួរឱ្យអស់សំណើច
អញមិនអនុញ្ញាតឱ្យទាសកររបស់អញធ្វើដំណើរ
៣ថ្ងៃទៅវាលរហោស្ថានទេ ។


អញបានឮនូវអ្វីដែលឯងធ្វើឱ្យទាសកររបស់អញបះបោរ បណ្ដាលឱ្យគេឈប់ធ្វើការ ។ ហើយឥឡូវនេះពួកគេចង់ធ្វើដំណើរ ៣ថ្ងៃ ដើម្បីថ្វាយបង្គំព្រះដែលអញមិនស្គាល់ អញនឹងធ្វើឱ្យពួកវាមានការងារកាន់តែច្រើនទៀត ។


និក្ខមនំ ៥:១-៧
ចាប់ពីពេលនេះទៅ ពួកគេនឹងត្រូវរកចំបើងដោយ ខ្លួនឯងដើម្បីធ្វើឥដ្ឋ។ ឥឡូវចេញពីមុខអញ កុំឱ្យអញឃើញ ហើយឯងមកពីកន្លែងណាទៅកន្លែងនោះវិញ។


តើឯងជឿការគ្មានកោតក្រែងរបស់វាទេ ?
នោះគួរឱ្យអស់សំណើច ពួកវាដើរព្រមជើងគ្នាមកទីនេះ នឹងធ្វើដូចជាព្រះនិយាយតាមរយៈមាត់ពួកវា ។


ឯងកំពុងប្រាប់យើងថា អ្វីដែលឯងសម្រេចបានជោគជ័យ គឺធ្វើឱ្យការងាររបស់យើងមានការលំបាកទ្វេដង។ នេះជាការរំដោះដ៏ធំឡែក ហើយឯងគិតថាព្រះអម្ចាស់បញ្ជូនឯងមកឬ?
តើវាគិតថាវាជាអ្នកណា ?
ខ្ញុំមិនជឿថាយើងធ្លាក់ក្នុងល្បិចរបស់វាទេ។
វាជាមនុស្សនិយមជ្រុល !


ឯងចង់ទៅថ្វាយបង្គំព្រះរបស់ឯង ឯងគ្មានអ្វីគ្រប់គ្រាន់ធ្វើឬ ? យើងនឹងប្រដៅឯងកុំឱ្យខ្ជិលច្រអូស ។


ព្រះយេហូវ៉ា
តាំងពី ទូលបង្គំមកនិយាយក្នុងព្រះ
នាមរបស់ទ្រង់ អ្វីៗដែលកើត
ឡើងកាន់តែអាក្រក់ជាងមុន។
ហេតុអ្វីទ្រង់បញ្ជូនទូលបង្គំ មកទីនេះ?


អញជាព្រះយេហូវ៉ា
ជាព្រះរបស់ពួយុកោងង
អញបានទតឃើញការឈឺចាប់និងបានឮ
សំរែកយំនៃប្រជារាស្ត្រអ៊ីស្រាអែលរបស់អញ ។
វាដល់ពេលដែលអញ
បំពេញកិច្ចសន្យារបស់អញ ចំពោះអ័ប្រាហាំ
ហើយនាំ ប្រជាជននេះទៅកាន់ទឹកដី
កាណាន ។ ម៉ូសេ ឯង
នឹងនាំពួកគេទៅ ។


ប៉ុន្តែ ទូលបង្គំនិយាយមិនបានល្អ
ផារ៉ោន នឹងមិនស្ដាប់ទូលបង្គំទេ ។
អើរ៉ុន នឹងនិយាយជំនួស
ឯងគ្រាន់តែស្ដាប់អញ ហើយ
ប្រាប់អើរ៉ុននូវអ្វីដែលត្រូវនិយាយ ។
នៅដំបូងផារ៉ោននឹងមិនស្ដាប់ឯង
ប៉ុន្តែអញនឹងបង្ហាញវានូវទីសំគាល់ធំទៅៗរហូតដល់ជនជាតិ
អេស៊ីព្ទដឹងថា អញជាព្រះពិតតែមួយ ។


ហាស់ហាំ.. តើឯងត្រឡប់ មកធ្វើអ្វីទៀត ?
ព្រះយេហូវ៉ាមានបន្ទូលថា “ចូរ ដោះលែងប្រជារាស្ត្ររបស់អញទៅ” ។


នេះជាទីសំគាល់មួយ ដែល ព្រះយេហូវ៉ាបានមានបន្ទូល ។
ហាស់ហាំ.. នោះគឺ គ្រាន់តែល្បិចមន្តអាគមមួយប៉ុណ្ណោះ ! អញមិនភ័យខ្លាចទេ ចូរហៅពួកគ្រូមន្តអាគមរបស់យើងមក ។




និក្ខមនំ ៥:១០-២៣, ៧:៧-១១


គ្រូមន្តអាគមមកឱ្យលឿន!
ហើយយកដំបងរបស់អ្នក ធ្វើឱ្យក្លាយទៅជាពស់។


ព្រះណោសឹ៊តជាព្រះនៃពោះ
បាន បញ្ជូនយើងឱ្យប្រាប់ឯង
ឱ្យធ្វើឥដ្ឋកាន់ តែច្រើនថែមទៀត
ហាស់ហ៊ាំ...!




និក្ខមនំ ៧:១១-១២


មើលន៎ ពស់របស់វា
ចង់ប្រយុទ្ធជាមួយពស់ របស់យើង ។


ពស់របស់វា កំពុង លេបពស់របស់យើង មួយហើយ !


វាលេបពស់របស់
យើងទាំងអស់ !


ខ្ញុំមិនជឿថា វានឹងព្យាយាម
ស៊ីមួយទៀត ! ព្រះណេសឹតនៃពោះ
នឹងក្រោធជាមិនខាន ។


អញមិនជឿ ! ពស់របស់វាស៊ីពស់របស់យើងទាំងអស់នោះទេ ។
តើនេះអាចកើត ឡើងយ៉ាងម៉េច ?


ព្រះយេហូវ៉ា គឺជាព្រះនៃការ
បង្កើតលោក ទ្រង់មានបន្ទូលថា “**ចូរ
ដោះលែងប្រជារាស្ត្ររបស់អញទៅ**”។
និក្ខមនំ ៧:១២


អញមិនដឹងឯងធ្វើការនោះនូវរបៀបណាទេ។ ការសំដែងរបស់ឯងល្អមែន ប៉ុន្តែអញមិនឱ្យទាសករមួយលាននាក់របស់អញរួចទេ។ **ចេញទៅ កុំឱ្យអញឃើញ!**
គម្ពីរនិក្ខមនំ ៧:១៣ “**នោះផារ៉ោនកើតមានព្រះទ័យរឹងទទឹងមិនព្រមស្តាប់តាមលោកឡើយ ដូចជាព្រះយេហូវ៉ាបានមានបន្ទូលប្រាប់ហើយ**”។


ហេតុអ្វីព្រះយេហូវ៉ាបានបញ្ជូនពួកយើងមកធ្វើទីសំគាល់ ដែលពួកមន្តអាគមរបស់ផារ៉ោនអាចធ្វើបានដែរ ? រយៈពេលមួយភ្លែតនោះយើងដូចជាទាល់គំនិត ។


ខ្ញុំអត់ដឹងទេ ប៉ុន្តែព្រះអម្ចាស់មានបន្ទូលថា ទ្រង់នឹងធ្វើឱ្យចិត្តផារ៉ោនមានះ ការនោះវាពិតជាធ្វើឱ្យផារ៉ោន មានះមែន។ តើបងបានឃើញថា គាត់មានកំហឹងយ៉ាងខ្លាំង នៅពេលដំបងរបស់ខ្ញុំស៊ីពស់របស់គាត់ ?
ខ្ញុំត្រូវទៅរកកន្លែងមួយ ដើម្បីទូលទៅព្រះយេហូវ៉ា។ ខ្ញុំមិន ដឹងត្រូវធ្វើអ្វីបន្ទាប់ទៀតទេ។



ព្រះអម្ចាស់បានជួបម៉ូសេម្ដងទៀត
ហើយប្រាប់គាត់នូវអ្វីដែលត្រូវធ្វើ ។
ជនជាតិអេស៊ីព្ទបានចំអកឱ្យម៉ូសេ
ហើយជនជាតិផ្ទាល់របស់គាត់ក៏បានច្រានចោលគាត់ដែរ
ពីព្រោះផារ៉ោនបានធ្វើឱ្យពួកទាសករមានការ
លំបាកជាងមុន ។ ប៉ុន្តែម៉ូសេបានជឿព្រះហើយស្ដាប់បង្គាប់
ទោះបីគាត់អត់យល់ក៏ដោយ ។


ព្រះយេហូវ៉ាមានបន្ទូលថា ដោយសារឯងបដិសេធមិនព្រមដោះលែងប្រជារាស្ត្ររបស់អញទៅ ដូច្នេះឯងនឹងដឹងថា អញជាព្រះដ៏ពិត អញនឹងធ្វើទឹកទាំងអស់ នៅក្នុងប្រទេសអេស៊ីព្ទ ឱ្យក្លាយទៅជាឈាម ។


ការនោះគួរឱ្យចាប់
អារម្មណ៍មែន។ តើគេ
ធ្វើការនោះយ៉ាងម៉េច ?
ទៅនាំពួកមន្តអាគម
មក ព្រះនៃទន្លេនីលនឹង
បញ្ឈប់ការនេះ។

និក្ខមនំ ៧:១៥-២១


ឃើញទេ
ពួកមន្តអាគមរបស់ អញក៏អាចធ្វើដូច្នេះដែរ។
ឯងមិន អាចបញ្ចុះបញ្ចូលអញដោយល្បិច
មន្តអាគមរបស់ឯងទេ។


ខ្ញុំមិនដែលឃើញអ្វីដូច្នេះទេក្នុងជីវិតរបស់ខ្ញុំ
សូម្បីប្រភពទឹកនឹងត្រពាំងតូចក្លាយជាឈាម
តើគេបាន និយាយថា
ព្រះរបស់គេមានឈ្មោះអ្វី?
មិនដែលឮពួកគេនិយាយទេ។
តើវាមាន ប្រយោជន៍អ្វីដល់យើង ?
យើងមានព្រះរាប់ពាន់ អង្គ
ព្រះនៃទន្លេនីលរបស់យើងពិតជាក្រោធ ។


ម៉ូសេនោះនិយាយថា ព្រះរបស់គាត់ជាព្រះតែមួយគត់។
ព្រះតែមួយ? នោះ មិនគួរឱ្យជឿទេ។


ប្រាំពីរថ្ងៃក្រោយទឹកបានក្លាយទៅជាឈាម ម៉ូសេ បាននាំការជំនុំជំរះរបស់ព្រះមកអេស៊ីព្ទម្តងទៀត។
ចូរឱ្យមានសត្វ កង្កែបជាច្រើនចេញ ពីទឹកនេះមក។

រំពេចនោះសត្វកង្កែបជាច្រើនលានក្បាលបានកើតចេញពីទឹកដែលក្លាយជាឈាមមានក្លិនស្អុយនោះ ។



និក្ខមនំ ៧:២១-២៥, ៨:៦


ផ្ទះរបស់ខ្ញុំពោរពេញ
ដោយកង្កែប ។


ទូទាំងប្រទេសអេស៊ីព្ទ ពោរពេញដោយកង្កែប ។ ព្រះទាំងអស់របស់យើង បានក្រោធ !
តើពួកសង្ឃរបស់យើង នៅឯណា ?តើពួកគេអាច ធ្វើអ្វីចំពោះការនេះបាន ខ្លះឬអត់?


ឦ.!


ហេតុអ្វីក៏ធ្វើកង្កែបថែមទៀត?
តើម៉ូសេម្នាក់ នោះឱ្យមិនទាន់គ្រប់គ្រាន់ទេឬអី ?
ឥឡូវនេះផារ៉ោន ឱ្យយើងមានកង្កែបថែមទៀត ។
សូមព្រះអម្ចាស់ទតមើល
ពួកមន្តអាគមយើងក៏អាច
ធ្វើកង្កែបបានដែរ ។


ហេតុអ្វីទ្រង់មិនអនុញ្ញាតឱ្យពួកគេទៅវាលរហោស្ថានដូចដែលគេសុំ ? យើងពិបាកទ្រាំតទៅទៀត ។


ចូរហៅម៉ូសេមក ប្រាប់វា អញត្រូវការចរចា។
ព្រះករុណា ព្រះអម្ចាស់ ដូចទ្រង់មានបន្ទូល។


សុំយេហូវ៉ាឱ្យយកកង្កែបចេញ ប្រសិនបើព្រះរបស់ឯងធ្វើបានអញយល់ព្រមឱ្យជនជាតិរបស់ឯងទៅទីវាលរហោស្ថាន ដើម្បីថ្វាយយញ្ញបូជា។
ចូរទ្រង់កំណត់ពេលដែលទ្រង់ចង់ឱ្យកង្កែបងាប់អស់ ហើយវានឹងកើតឡើងដូច្នោះ។


ព្រឹកស្អែក ។
អាស្រ័យដោយបន្ទូលរបស់ទ្រង់ ដូចនេះ វានឹងអាចសម្រេចបាន ដើម្បីឱ្យមនុស្សទាំងអស់ដឹងថា គ្មានព្រះណាដូចព្រះយេហូវ៉ាទេ ។

និក្ខមនំ ៨:៧-១០


នៅពេលផារ៉ោនឃើញថា កង្កែបងាប់អស់ ហើយ តាមពេលដូចទ្រង់បានកំណត់ ទ្រង់នៅតែមានព្រះទ័យរឹងរូសដដែល ហើយមិនព្រមឱ្យសាសន៍ហេព្រើរទៅទេ ។
តើយេហូវ៉ាជាព្រះដូចម្ដេចដែលទ្រង់អាចធ្វើ កង្កែបទាំងនេះពាសពេញទឹកដីរបស់យើង?
តើអ្វីធ្វើឱ្យអ្នកគិតថា មានព្រះ ធ្វើការទាំងអស់នេះ ? ប្រហែលវាគ្រាន់តែ ជាបាតុភូតធម្មជាតិប៉ុណ្ណោះ ។


ប៉ុន្តែម៉ូសេដឹងថាវានឹងកើតឡើងយ៉ាងម៉េច ដើម្បីគាត់អាចទាយមុន ? ហើយយ៉ាងម៉េចក៏គាត់បានដឹងពេលវេលាច្បាស់ដែលវាទាំងអស់នឹងងាប់ដែរ ?
បិទមាត់ ហើយចូកវាចោលទៅ ! ក្រែងលោយើងធ្វើវាមិនហើយ ។

រួចព្រះយេហូវ៉ាមានបន្ទូលទៅកាន់ម៉ូសេ
“ប្រាប់អើរ៉ុនថា ចូរបងលើកដំបងវាយធូលីដីទៅ
ដើម្បីឱ្យបានក្លាយទៅជាចៃនៅពេញទឹកដីអេស៊ីព្ទ” ។




ហើយធូលីដីទាំងអស់ក៏ក្លាយទៅជាចៃ ។
អឺយ៊ា...


តើឯងនិយាយមានន័យយ៉ាងម៉េច ឯងមិនអាចធ្វើ ចៃបានទេ ?
ប្រជារាស្ត្រនឹងគិតថា ព្រះរបស់វាមាន អំណាចច្រើនជាងព្រះរបស់យើង !
អ្វីទាំងអស់ដែលឯង អាចធ្វើបានគឺសុទ្ធតែល្បិចមន្តអាគម ។
ព្រះករុណាព្រះអង្គ នេះពិតជាស្នាព្រះហស្តរបស់ព្រះ ។ គ្មានអ្នកណាអាចធ្វើការដូចពីរនាក់នេះបានធ្វើទេ ។ យើង គ្មានអំណាចទប់ទល់ ។


និក្ខមនំ ៨:១៣-១៩
នោះពិតជាមានមូលហេតុពីធម្មជាតិ ប៉ុន្តែយើងមិនអាចទ្រាំចំពោះការនេះទៀតទេ។ យកពាក្យអញ ទៅប្រាប់ម៉ូសេថា ប្រសិនបើព្រះរបស់វានឹងយកចៃចេញ នោះ អញនឹងព្រមឱ្យពួកហេព្រើរទៅថ្វាយបង្គំព្រះរបស់ពួកវា។


ចៃបានទៅអស់តែអញមិន
ព្រមឱ្យទាសកររទៅ ។ បន្ទាប់ពីបណ្តាសានេះ
តើព្រះរបស់វាអាចធ្វើអ្វីទៀត ?


ព្រះអម្ចាស់មានបន្ទូលទៅកាន់ម៉ូសេថា
“អញនឹងបញ្ជូនហ្វូងរុយមកលើប្រទេស
អេស៊ីព្ទ ។ ផ្ទះរបស់ឯងនឹងពេញដោយសត្វ
រុយ ។ ប៉ុន្តែពេលនេះអញនឹងធ្វើឱ្យមាន
ការខុសគ្នារវាងជនជាតិអេស៊ីព្ទ...
...និងជនជាតិហេព្រើរ នោះនឹងគ្មាន
សត្វរុយនៅកន្លែងប្រជាជនរបស់អញ ។
ដោយសារការនេះអ្នករាល់គ្នានឹងដឹងថា
អញជាព្រះនៃផែនដីទាំងមូល !”


ប៉ា ហេតុអ្វីពួកសង្ឃរបស់យើង មិនអាចបញ្ឈប់បុរសម្នាក់នេះ ? ឯណាទៅអំណាចរបស់ពួកសង្ឃ?
ប៉ាមិនខ្វល់ខ្វាយអ្វីពីសាសនានោះទេ ។ ប៉ាគិតតែពីមុខជំនួញរបស់ប៉ាប៉ុណ្ណោះ ។


ដូចវានិយាយមែន គឺគ្មានរុយ
នៅកន្លែងជនជាតិហេព្រើរទេ ! នេះ
ពិតជាកិច្ចការព្រះរបស់ពួកវាមែន។
ចូរទៅហៅ ម៉ូសេមក។


ទៅ !
ទៅថ្វាយបង្គំដល់ព្រះរបស់ ឯងចុះ
ប៉ុន្តែកុំចេញពីទឹកដីអេស៊ីព្ទឡើយ ។
យើងត្រូវតែទៅ យ៉ាងតិច
ណាស់ក៏ធ្វើដំណើរ៣ថ្ងៃដែរ ។
អញប្រាប់ឯងថា ឯងអាចទៅបាន
ប៉ុន្តែឯងមិនអាចទៅឆ្ងាយពេកទេ ។ ឥឡូវ
ចូរប្រាប់ដល់ព្រះរបស់ឯងឱ្យបំបាត់សត្វរុយ
ចង្រៃទាំងនេះចេញភ្លាម ។


គ្មានសល់សត្វរុយណាមួយ ដែលនៅរស់ក្នុងប្រទេសអេស៊ីព្ទទេ ។ នេះពិតជាការអស្ចារ្យមែន ។
បិទមាត់ ! ឯងនិយាយដូចជាឯងចាប់ផ្តើម ជឿលើអាមនុស្សមាត់ឥតគំរបនោះហើយ ។
ផារ៉ោន មានចិត្តរឹងទទឹងម្តងទៀត ហើយ បដិសេធមិនឱ្យប្រជាជនអ៊ីស្រាអែលចេញទៅ ។

និក្ខមនំ ៨:២០-៣២


ព្រះអម្ចាស់ បានបញ្ជូនសេចក្ដីវេទនាមួយទៀតមក
លើទឹកដីអេស៊ីព្ទ។ ហ្វូងសត្វទាំងអស់របស់គេ ទាំង
ហ្វូងគោ ចៀម សេះ អូដ្ឋ បានឆ្លងជំងឺហើយងាប់។
ប៉ុន្តែហ្វូងសត្វរបស់ហេព្រើរមិនបានឆ្លងជំងឺទេ។


សត្វរបស់យើងទាំងអស់បានងាប់ ហើយសត្វរបស់ឯងមានសុខភាពល្អ ។ តើឯងអាចពន្យល់បានទេ ?
ម៉ូសេ និយាយថា នេះគឺជាព្រះនៃព្ទយុកោរបស់យើង ដែលមករំដោះពួកយើងចេញពីភាពទាសករនេះ ។ ប៉ុន្តែខ្ញុំជាមនុស្សធម្មតា ខ្ញុំមិនសូវដឹងអំពីរឿងនេះទេ ។


ពួកសង្ឃរបស់យើងកំពុងតែថ្វាយយញ្ញបូជាទៅព្រះរបស់យើង ។ ព្រះគោដ៏ស័ក្តិសិទ្ធិរបស់យើងនឹងក្រោធហើយនឹងបញ្ឈប់ការនេះ ។


តើព្រះទាំងអស់របស់
ជនជាតិអេស៊ីព្ទនៅឯណា ? តើ
ព្រះនៃយើងគ្មានអំណាចទេឬ?
ចូរប្រាប់ផារ៉ោនថា
វាយឺតពេលហើយ ព្រះគោ
ស័ក្តិសិទ្ធិទាំងអស់របស់យើងបានសុគត ។
ប្រជាជននឹងខឹងនៅ ពេលដឹងថា
ព្រះរបស់ពួកគេមិនអាចការពារខ្លួនពីព្រះរបស់
ហេព្រើរ
ដែលមនុស្សគ្រប់គ្នាមើលមិនឃើញ ។


ប៉ុន្តែ ផារ៉ោន នៅតែ
មានចិត្តរឹងទទឹងដដែល។
និក្ខមនំ ៩:៦-៧


ព្រះអម្ចាស់មានបន្ទូលទៅកាន់ម៉ូសេ ហើយប្រាប់គាត់ម្ដងទៀតថា “ចូរឱ្យបាចផេះទៅលើទីក្រុង ហើយប្រជាជនអេស៊ីព្ទទាំងអស់នឹងបានកើតបូសរលកធ្លាយជាដំបៅ” ។
ព្រះអម្ចាស់មានបន្ទូលថា “ដោយសារឯងមិនព្រមឱ្យប្រជាជនរបស់អញទៅ អញនឹងបង្កើតបូសដ៏អាក្រក់មកលើពួកឯង និងសត្វទាំងអស់របស់ឯង” ។
អ៊ូ ! សូមកុំឱ្យមានទៀត !


ហៅពួកមន្ដអាគមមក ! ប្រាប់ពួកគេឱ្យប្រមូលផ្ដុំគ្រប់ទាំងអំណាចរបស់គេ ហើយថ្វាយយញ្ញបូជាទៅព្រះទាំងអស់របស់យើងដើម្បីបញ្ឈប់ការនេះ ។


ព្រះអម្ចាស់ដ៏ឧត្តម ទ្រង់ហៅទូលបង្គំមកឬ ?
ឯងក៏មានបួសដែរ ? តើ ឯងគ្មានអំណាចទប់ស្កាត់ព្រះ របស់ម៉ូសេនេះឬ ?


ចេញពីមុខអញ អាក្រុមបន្លំ គ្មានបានការសោះ ! ឯង បានស្ថិនភ្នែកហើយបំភាន់ប្រជារាស្ត្រ ប៉ុន្តែអញដឹងថា ឯងជាអ្នកបោកបញ្ឆោត ។ ឯណាព្រះរបស់ឯង ?


ចូរក្រោកពីព្រលឹមទៅឈរនៅមុខ ផារ៉ោន ហើយនិយាយថា “ព្រះនៃសាសន៍ហេព្រើរទ្រង់មានបន្ទូលថា ចូរបើកឱ្យរាស្ត្រអញចេញទៅ ដ្បិតម្តងនេះរោគពិសនឹងអាក្រក់ជាងមុនខ្លាំង វានឹងនាំមកសេចក្តីវិនាសដែលសម្លាប់ប្រជាជនរបស់ឯងជាច្រើន។ ដោយការនេះឯងនឹងដឹងថា គ្មានព្រះណាដូចអញឡើយ។ ឯងមិនដឹងទេថា អញជាអ្នកលើកឯងធ្វើជាស្តេចផារ៉ោន។ ឯងត្រូវយល់ថា អញបានដឹងមុនដែលឯងមានចិត្តរឹងហើយបដិសេធមិនព្រមឱ្យប្រជាជនរបស់អញទៅ។


ភាពចចេសរបស់ឯង ធ្វើឱ្យអញមានឱកាសបង្ហាញ
នូវអំណាចនឹងនាំសេចក្តីជំនុំជំរះមកលើអេស៊ីព្ទ ពីព្រោះ
ពួកឯងប្រព្រឹត្តយ៉ាងឃោរឃៅមកលើប្រជាជនរបស់អញ។ ឯង
គិតតែប្រយោជន៍ផ្ទាល់ខ្លួន ហើយជំទាស់នូវបំណងរបស់អញ ដូច្នេះស្អែកនៅម៉ោងនេះ
អញនឹងបញ្ជូនភ្លៀងជាដុំទឹកកក និងភ្លើង ដែលលោកិយមិនធ្លាប់មាន”


ម៉ូសេ អញប្រាប់ឯង ដូច្នេះឯងអាចព្រមានដល់អ្នក រាល់គ្នាឱ្យដឹងមុន ដើម្បីកុំឱ្យពួកគេនិងសត្វរបស់ពួកគេចេញទៅ ក្រៅ ព្រោះអ្នកណាដែលនៅខាងក្រៅនឹងស្លាប់ ។
និក្ខមនំ ៩:៨-១៩


សូមឱ្យកើតមាន ឡើងដូចព្រះយេហូវ៉ា មានបន្ទូល ។


តើអាចកើតឡើង
យ៉ាងម៉េចភ្លើងនិង
ទឹកកកលាយគ្នា ?
ឱព្រះសេតដ៏ខ្លាំងពូកែអើយ
សូមជួយយើងផង !
អ្អ៊ា!
អស់អ្នកណាដែលមិនព្រមស្ដាប់ការព្រមាន
ហើយនៅខាងក្រៅផ្ទះបានស្លាប់ ។


ប៉ា តើ ម៉ូសេ ធ្វើការនេះយ៉ាងម៉េច ? តើព្រះរបស់គាត់មានអំណាចខ្លាំងជាងព្រះសេត ដែលជាម្ចាស់លើព្យុះនិងភាពអាសន្នឬ ?
វាអះអាងថា មានព្រះ តែមួយ ហើយថាជនជាតិ ហេព្រើរទាំងនេះជាកូន ចៅរបស់ព្រះនោះ ។


ប៉ុន្តែគ្មាននរណាម្នាក់បានឃើញព្រះរបស់វាទេ
សូម្បីតែជនជាតិហេព្រើរក៏អត់ដែរ ។ ព្រះរបស់វាដែល
អះអាងថា ជាវិញ្ញាណ កំពុងព្យាយាមធ្វើឱ្យផារ៉ោនប្រែចិត្ត
ដោះលែងពួកគេទៅកាន់ទីរហោស្ថានដើម្បីថ្វាយបង្គំ ។


ឱ ! ព្រះសេតដ៏ខ្លាំងពូកែ
ដែលជាម្ចាស់ នៃភាពរីកវររនិងខ្យល់ព្យុះអើយ
ពួកយើងសូមអង្វរដល់ទ្រង់ ឱ្យបញ្ឈប់ព្យុះដ៏អាក្រក់នេះ ។
ពួកទូលបង្គំជឿថា ទ្រង់ខ្លាំង
ជាងព្រះដែលមើលមិនឃើញរបស់ម៉ូសេជាមិនខាន ។

និក្ខមនំ ៩:២៣-២៦


ឱ ! ព្រះសេតដ៏ខ្លាំងពូកែ ដែលជាម្ចាស់ នៃភាពរីកវរនិងខ្យល់ព្យុះអើយ ពួកយើងសូមអង្វរដល់ទ្រង់ ឱ្យបញ្ឈប់ព្យុះដ៏អាក្រក់នេះ ។ ពួកទូលបង្គំជឿថា ទ្រង់ខ្លាំងជាងព្រះដែលមើលមិនឃើញរបស់ម៉ូសេជាមិនខាន ។
និក្ខមនំ ៩:២៣-២៦


មើលទ៌ វាមិនមកជិតយើងទេ
វាគ្រាន់តែ ធ្លាក់នៅកន្លែងជនជាតិអេស៊ីព្ទប៉ុណ្ណោះ។
ប៉ា ខ្ញុំខ្លាចណាស់ តើភ្លើងនិង
ទឹកកកធ្លាក់លើយើងដែរឬទេ?


ទេកូន ព្រះយេហូវ៉ា កំពុង ដាក់ទណ្ឌកម្មជនជាតិអេស៊ីព្ទ ចំពោះការមិន ស្ដាប់បង្គាប់ទ្រង់ ។ ទ្រង់កំពុងបង្ហាញពួកគេថា ព្រះសេតរបស់ពួកគេដែលជាម្ចាស់ព្យុះនោះ គ្មានអំណាចជួយដល់ពួកគេបានទេ ។
វាគួរឱ្យ រន្ធត់ណាស់ ។


អញបានធ្វើបាបទាស់នឹង ព្រះយេហូវ៉ា ។ ព្រះរបស់ជនជាតិហេព្រើរគឺសុចរិត ហើយអញនឹង រាស្ត្ររបស់អញគឺអាក្រក់ ។ ចូរសុំព្រះយេហូវ៉ា បញ្ឈប់ភ្លើងនិងទឹកកកទៅ ហើយអញនឹងយល់ ព្រមឱ្យជនជាតិរបស់ឯងចាកចេញភ្លាម ។


នៅពេល ផារ៉ោន បានឃើញព្យុះផុតរលត់អស់ ទ្រង់បានធ្វើបាបហើយមានចិត្តមានះទៀត ។ ព្រះអង្គមិនឱ្យជនជាតិហេព្រើរទៅដដែល ។
ពេលខ្ញុំចេញពីទីក្រុង ខ្ញុំនឹងលើក ដៃទៅឋានសួគិ ហើយគ្រោះកាចនឹងឈប់ ។ ដោយ ការនេះផារ៉ោននឹងដឹងថា ផែនដីជារបស់ព្រះយេហូវ៉ា ប៉ុន្តែ ផារ៉ោននឹងមិនរក្សាបន្ទូលរបស់ទ្រង់ ។ ផារ៉ោនមិនទាន់ខ្លាច ព្រះអម្ចាស់នៅឡើយទេ ។


ព្រះអម្ចាស់បានបញ្ជូនគ្រោះកាចផ្សេងទៀត គឺកណ្ដូប
មកពាសពេញលើស្រុកអេស៊ីព្ទទាំងមូល ។ ហើយវាក៏
ស៊ីដំណាំទាំងអស់ដែលព្យុះមិនបានបំផ្លាញអស់
បន្ទាប់ មកកណ្ដូបកកេរផ្លូវចូលទៅក្នុងផ្ទះទៀត ។
និក្ខមនំ ៩:២៦-៣៥, ១០:១៣-១៩


ច៉ាក់! ច៉ាក់!
ផ្ង៎...!
ផាច់ !
ដាប់ទៅ !




ផារ៉ោន បានហៅ
ម៉ូសេមកហើយបានសន្យាព្រមឱ្យជនជាតិហេព្រើរ ទៅ ប៉ុន្តែនៅពេលព្រះអម្ចាស់បំបាត់កណ្ដូបចេញ ផារ៉ោនមានចិត្តរឹងម្ដងទៀតហើយបដិសេធមិនឱ្យទាសកររបស់ទ្រង់ចេញទៅទេ។

និក្ខមនំ ១០:១៤-២០


បន្ទាប់មកព្រះអម្ចាស់
ធ្វើឱ្យងងឹតយ៉ាងខ្លាំងគ្របដណ្ដប់ លើអេស៊ីព្ទ។
អស់រយៈពេល៣ថ្ងៃវាងងឹតជាងយប់
ដែលមានពពកច្រើនទៅទៀត
ប៉ុន្តែនៅក្នុងផ្ទះជនជាតិហេព្រើរគ្មានភាពងងឹតទេ។
អញគួរតែសម្លាប់ឯងយូរហើយ
ប៉ុន្តែបើធ្វើដូច្នេះនោះនឹងបង្ហាយថា
ព្រះរបស់អញគ្មានអំណាចទាស់
នឹងព្រះរបស់ឯងទេ។


ចេញពីមុខអញទៅ ។ អញមិន ចង់ឃើញមុខឯងទៀតទេ បើអញជួបឯងម្តងទៀតឯងនឹងងាប់ ។
ម្តងនេះទ្រង់មានបន្ទូល ត្រូវ ។ ការពិតយើងនឹង ឈប់ជួបមុខគ្នាទៀត ។


ព្រះ រ៉ា ដ៏ខ្លាំងនៃព្រះអាទិត្យអើយ ! សូមទ្រង់ជ្រាបផង អស់រយៈពេល៣ថ្ងៃដែលមិនបានបង្ហាញអង្គទ្រង់។ តើព្រះអង្គមិនអាចឈ្នះព្រះនៃជនជាតិហេព្រើទេឬអី ?


នេះគឺជាគ្រោះកាចមួយចុងក្រោយ ! ផារ៉ោន នឹងសប្បាយ
ដោយឃើញពួកយើងចាកចេញពីប្រទេសអេស៊ីព្ទ ។ យប់នេះនៅកណ្ដាលអាធ្រាត
ព្រះអម្ចាស់នឹងឆ្លងកាត់ទឹកដីអេស៊ីព្ទ ។ នោះអស់ទាំងកូនប្រុសច្បងនៅស្រុក
អេស៊ីព្ទនឹងស្លាប់ ។ ព្រះនឹងកាត់ទោសអំពើបាបនៅយប់នេះ ។


តើមានអ្វីនឹងកើតឡើង
ចំពោះកូនប្រុសច្បងរបស់យើង ?
ពួកគេនឹងស្លាប់ដែរឬ ?
ព្រះអម្ចាស់បានផ្តល់សេចក្តីសង្គ្រោះ
ដល់អស់អ្នកណាដែលជឿ ព្រមទាំងជនជាតិ អេស៊ីព្ទផងដែរ ។
ឥឡូវនេះសូមទៅយកកូនចៀម ឬពពែឈ្មោលសម្លាប់វានៅល្ងាចនេះ រួចយក
ឈាមវាលាបនៅលើគ្រោងទ្វារទាំងសងខាង ។


និក្ខមនំ ១០:២២-២៩, ១១:៤-៥, ១២:៣-៧
ព្រះយេហូវ៉ាមានបន្ទូលថា “នៅពេលអញឆ្លងកាត់ទឹកដីអេស៊ីព្ទយប់នេះនឹងសម្លាប់គ្រប់កូនប្រុសច្បងទាំងអស់នោះ អញនឹងរំលងផ្ទះទាំងអស់នៅពេលអញឃើញឈាមបានលាបនៅក្រោងទ្វារខាងក្រៅនោះ ហើយកូនប្រុសដំបូងនឹងមិនត្រូវស្លាប់។ ចូរកុំចេញទៅក្រៅផ្ទះរបស់អ្នកនៅយប់នេះ ហើយបរិភោគចៀមដែលអ្នកសម្លាប់ចុះ”។


ឥឡូវចូរទៅជួបចៅហ្វាយ
អេស៊ីព្ទរបស់អ្នក
ហើយខ្ចីគ្រឿងអល័ង្កា
មាន មាស ប្រាក់និងពេជ្រ ។
ព្រះអម្ចាស់បានប៉ះពាល់ចិត្តរបស់ពួកគេ
ហើយពួកគេនឹងឱ្យមកអ្នក
ដោយឥតជំទាស់ ។
ចូររៀបចំរបស់របររបស់អ្នកឱ្យរួចជាស្រេច
ដើម្បី ចាកចេញនៅព្រឹកស្អែក ។
អ្នករាល់គ្នានឹងមិនត្រឡប់មកវិញទេ
នេះជាការលាចេញពីស្រុកអេស៊ីព្ទរហូត ។
នេះជាថ្ងៃដំបូងសម្រាប់ អ្នករាល់គ្នា
គឺជាថ្ងៃដើមឆ្នាំ ។


ប៉ា នេះគឺជាកូនចៀមតែមួយរបស់យើង ។ តើយើងអាចនឹងប្រើថ្នាំក្រហមឬអ្វីផ្សេងជំនួសឈាមបានទេ ?
កូន ព្រះអម្ចាស់បានប្រាប់ឱ្យសម្លាប់ចៀមហើយលាបឈាមវាលើមាត់ទ្វារ ។ យើងត្រូវតែធ្វើដូចអ្វីដែលទ្រង់មានបន្ទូល ។ ឯងបានឃើញនូវអ្វីដែលទ្រង់កាត់ទោសពួកដែលមិនស្ដាប់បង្គាប់ទ្រង់ ។ ចៀមនេះនឹងសង្គ្រោះឯងឱ្យរួចពីស្លាប់ ។


ទូងៗ...
ដូច្នេះ ចៀមនេះ បានស្លាប់ជំនួសខ្ញុំឬ?
ហើយខ្ញុំក៏អញ្ចឹងដែរ ខ្ញុំគឺកូនប្រុសកើតដំបូងដែរ ។


និក្ខមនំ ១២:២៦-២៨, ៣៥-៣៦
ម៉ាក់ ហេតុអីប៉ា លាបឈាមនៅទ្វារផ្ទះយើង ?
ព្រះយេហូវ៉ាមានបន្ទូលថា “នៅពេលអញឃើញឈាម នៅលើទ្វាររបស់ឯង នោះអញនឹង ដឹងថា ឯងជឿអញ ហើយអញនឹង មិនសម្លាប់អ្នកណាដែលនៅ ខាងក្នុងផ្ទះឡើយ”។


ហេតុអ្វីពូមិនសម្លាប់ចៀម ហើយ លាបឈាមនៅលើមាត់ទ្វារ?
ហាំ ឯងជឿរបស់ដែលឆ្វេងនិយមទាំងអស់នេះឬ ? តើឈាមបន្តិចនៅលើទ្វារនឹងអាចបញ្ឈប់ការស្លាប់បានយ៉ាងម៉េច? កូនប្រុស របស់ខ្ញុំមិនខ្លាចទេ តើឯងខ្លាចទេ ចូគីម ?


ពិតជាមិនខ្លាចទេ ឯងគិតថា ខ្ញុំជា មនុស្សឆាប់ភ័យខ្លាចដូចស្រីឬ ? សាសនា គឺសម្រាប់តែមនុស្សទន់ខ្សោយ ។ ព្រះល្អនឹងមិនសម្លាប់មនុស្សដោយគ្រាន់តែមិនបានលាបឈាម នៅមាត់ទ្វារនោះទេ ។ ចុះមនុស្សដែលមិនបានឮវិញយ៉ាងម៉េចដែរ ?


ប៉ា ហេតុអ្វីយប់នេះ ដូចជា
ខុសប្លែកពីយប់ផ្សេងៗម្ល៉េះ ?
ពីព្រោះយប់នេះ
ព្រះអម្ចាស់ នឹងបញ្ជូនមេបំផ្លាញ
ដើម្បីសម្លាប់គ្រប់កូនប្រុសច្បងទាំងអស់ដែលមិនជឿទ្រង់
ប៉ុន្តែនៅពេលទ្រង់បានឃើញឈាម ទ្រង់នឹងរំលងផ្ទះនោះ ។
នេះគឺជាថ្ងៃចាប់ផ្តើមចំពោះយើង ជារៀងរាល់ឆ្នាំនៅ
ចំថ្ងៃនេះយើងនឹងធ្វើបុណ្យរំលង ដើម្បីរំឭកចំពោះព្រះដែល
បាននាំយើងចេញពីកណ្តាប់ដៃរបស់ ផារ៉ោន ។


អ៊ូ ! ប៉ា សូមស្តាប់ សំលេងស្រែកយំ ។ មេបំផ្លាញ ពិតជាមកដល់ទីនេះហើយ ។
កុំភ័យខ្លាចអី យើងបានស្តាប់បង្គាប់ ព្រះអម្ចាស់ ។ យើងបានលាបឈាមចៀមនៅ លើគ្រោងទ្វារ ហើយក៏កំពុងហូបសាច់វាដែរ ។


កូនប្រុសរបស់ខ្ញុំស្លាប់!
លោកអើយ! សូមជួយផង
សូមហៅម៉ូសេមក!
និក្ខមនំ ១២:២៨


អីយ៊ា...!
ទេ...!
ទេ ព្រះអម្ចាស់ សូមកុំសម្លាប់ កូនខ្ញុំអី!


ពេលដែលព្រះអម្ចាស់បានឆ្លងផុតទីក្រុងនៅយប់នោះ មាន
មនុស្សរាប់ពាន់នាក់ដែលបានស្លាប់ ។អស់អ្នកដែលជឿហើយ
បានលាបឈាមចៀមនៅលើគ្រោងទ្វារបានរួចផុតពីស្លាប់ ។
ខ្ញុំសោកស្ដាយណាស់
ប៉ុន្តែវាហួសពេលហើយ ។ អ្នកបានដឹងមុនតែអ្នកបដិសេធមិនជឿ ។
ខ្ញុំខ្លាចថា នឹងមានមុនស្សច្រើនស្លាប់ទៀតនៅយប់នេះ ។


កូនប្រុសរបស់ យើងស្លាប់ហើយ!
ប្រញាប់ នាំម៉ូសេ មកទីនេះភ្លាម !


ស្អី?
ព្រះអង្គ វាជាកូនច្បងក្នុងគ្រួសារវា !
និក្ខមនំ ១២:២៩-៣១


ផារ៉ោន បានហៅ
ម៉ូសេមកម្ដងទៀត។


ប៉ុន្តែ ផារ៉ោន
មិនបានមើលមុខម៉ូសេទេ ។
ខ្ញុំបានធ្វើបាបសូមនាំជនជាតិ
ហេព្រើរទាំងអស់ចាកចេញពី
អេស៊ីព្ទ ខ្ញុំមិនអាចស៊ូទ្រាំនឹង
ព្រះយេហូវ៉ារបស់អ្នកទេ ។
សូមអ្នកប្រសិទ្ធិពរដល់ខ្ញុំផង
មុននឹងចេញទៅ ។


ដូចដែលព្រះអម្ចាស់បានសន្យាជាមួយព្ធយុកោរបស់ពួកគេ។ បន្ទាប់ពី
៤00ឆ្នាំ ពួកគេបានចាកចេញពីស្រុកអេស៊ីព្ទ។ ជនជាតិអស៊ីព្ទបាន
ផ្តល់គ្រឿងអលង្ការ មាស ពេជ្រ និង ម្ហូប ហើយអ្វីៗផ្សេងទៀត
ដែលគេអាចយកទៅជាមួយបាន។ ថ្ងៃនេះជាថ្ងៃសប្បាយសម្រាប់
ជនជាតិហេព្រើរ ហើយគឺថ្ងៃដំបូងរបស់ប្រជាជាតិថ្មីនេះ។




និក្ខមនំ ១២:២១-២២, ៣១-៣៨



ជំពូក ៤

# និក្ខមនំ


ពួកគេបានតាមព្រះរហូតដល់បានចូលកន្លែងដែលមានភ្នំច្រើន
ហើយទល់នឹងសមុទ្រក្រហម ។ នៅទីនោះពួកគេបានបោះជំរុំ
ហើយបានពិភាក្សាពីវិធីដែលពួកគេនឹងឆ្លងផ្ទៃទឹកដ៏ធំនេះ ។

បន្ទាប់ពីផារ៉ោន បានកើតទុក្ខពីបុត្ររបស់ទ្រង់។
ទ្រង់មានសេចក្តីក្រោធយ៉ាងខ្លាំងជាងមុនៗទៅទៀត ហើយផារ៉ោនបានគិតថា
ហេតុអ្វីទ្រង់អនុញ្ញាតឱ្យ ពួកទាសកររបស់ទ្រង់ចាកចេញ ?






និក្ខមនំ ១៤:៥-៧


មើលន៎ ទ័ពអេស៊ីព្ទកំពុង មកហើយ! យើងជាប់នៅ វាលរហោស្ថាន! តើយើង ត្រូវធ្វើយ៉ាងម៉េច?
ម៉ូសេ បាននាំយើងមកស្លាប់នៅទីនេះ ។ បើធ្វើ ជាទាសកររហូតដល់ស្លាប់ នោះវាប្រសើរជាង ស្លាប់នៅទីកន្លែងនេះដែលព្រះបោះបង់ចោល ។


នៅពេលពួកអេស៊ីព្ទបានឃើញពួកហេព្រើរដែលមិនអាច
ការពារខ្លួនបាន ហើយបាននឹកឃើញនូវការឈឺចាប់ដែល
ម៉ូសេបានធ្វើនៅស្រុកអេស៊ីព្ទផងនោះ ពួកគេត្រៀម
ខ្លួនជាស្រេចដើម្បីសម្លាប់ពួកហេព្រើរចោល ។
គ្មានអ្វីដែលព្រះទ្រង់អាចធ្វើ
ដើម្បីនឹងសង្គ្រោះពួកយើងបាន
ទេនៅពេលនេះ ។
មានភ្នំនៅទាំងសងខាង
និងទឹកនៅពីមុខយើង ។ យើង
ជាប់នៅទីនេះហើយ ។


កុំចេញពីកន្លែងដែលអ្នក
កំពុងឈរឡើយ ។ ព្រះជាម្ចាស់នឹង
សង្គ្រោះយើងតាមរបៀបមួយដែល
មានអំណាចដ៏អស្ចារ្យ ។
ព្រះជាម្ចាស់
បានធ្វើឱ្យផារ៉ោនមានចិត្ត មានះម្តងទៀត ។
បន្ទាប់ពីថ្ងៃនេះ អ្នកនឹងលែង
ឃើញកងទ័ពអេស៊ីព្ទទៀតជាដរាប ។
និក្ខមនំ ១៤:៥-១៣



នៅពេលកងទ័ពអេស៊ីព្ទហាក់ដូចជាបានជិតមកដល់ពួកហេព្រើរ
រំពេចនោះបង្គោលភ្លើងយ៉ាងធំបានធ្លាក់ចុះពីឋានសួគ៌ ហើយបាន
បាំងផ្លូវរបស់ពួកគេ ។ អំឡុងពេលយប់នោះពួកហេព្រើរមានពន្លឺភ្លើង
ប៉ុន្តែពួកអេស៊ីព្ទបានស្ថិតក្នុងភាពងងឹតយ៉ាងខ្លាំង ។


ម៉ូសេ បានលើកដំបងរបស់គាត់ទៅលើ សមុទ្រ ហើយខ្យល់យ៉ាងធំបានមកពី ឋានសួគ៌ បក់ផាត់ញែកទឹកសមុទ្រចេញ ពីគ្នាទៅជាផ្លូវគោកនៅបាតសមុទ្រ ។
និក្ខមនំ ១៤:១៥-២២
នេះជាការមហាអស្ចារ្យដ៏ធំមួយ ។ ប្រជារាស្ត្រ អ៊ីស្រាអែលបានឆ្លងកាត់សមុទ្រដោយដើរលើដីស្ងួត ។
នៅថ្ងៃខាងមុខពួកគេនឹងច្រៀងសរសើរព្រះ ដែល បានបង្កើតផ្លូវឆ្លងកាត់សមុទ្រ ។ មនុស្សទាំងអស់ នឹងដឹងថា នោះមានព្រះតែមួយអង្គ ហើយ ព្រះនាមរបស់ទ្រង់គឺ ព្រះយេហូវ៉ា ។


ការនេះប្រសើរជាងអ្វីៗទាំងអស់ដែលយើងបានឃើញនៅអេស៊ីព្ទ។
អូ៎ ! ព្រះរបស់យើងជាព្រះដ៏ល្អបំផុតលើទាំងអស់។ យើងដើរនៅកណ្ដាលសមុទ្រ។


យ៉ូសៀស ឯងឆ្កួតទេឬ? ចេញឱ្យឆ្ងាយពីនោះ! ឯងមិនចេះហែលទឹកទេ!


ខ្ញុំគ្រាន់តែចង់ស្ទាបត្រីដ៏ស្អាតនេះ ។


នៅពេលជនជាតិហេព្រើរឆ្លងជិតផុតហើយ
ព្រះអម្ចាស់បានលើកបង្គោលភ្លើងដែល
បាំងពួកអេស៊ីព្ទចេញ ។ ពួកគេមិនបាន
ឃើញសមុទ្រញែកជាពីរទេ ។ ដូច្នេះហើយ
ពួកគេប្រញាប់ដេញតាមពួកហេព្រើរ ។
ទៅមុខទៀត សម្លាប់ ពួកហេព្រើរចោល !
និក្ខមនំ ១៤:២២-២៣


ថ្ងៃនេះពួកអ្នកបានឃើញ
អំណាចរបស់ព្រះយេហូវ៉ា ។
ចូរមើល!
ទឹកកំពុងធ្លាក់ គ្របផ្លូវវិញ
ពួកគេទាំងអស់
នឹងលង់ទឹកស្លាប់ ។


ពួកទាហានអេស៊ីព្ទទាំងអស់បានលង់ទឹកសមុទ្រ។ ព្រះរបស់
ពួកគេដែលធ្លាក់ពីឈើនិងថ្មមិនអាចសង្គ្រោះពួកគេបានឡើយ។
និក្ខមនំ ១៤:២៧-២៨


ចូរក្រឡេកមើលសមុទ្រ ពេញទៅដោយសាកសព ទាហានអេស៊ីព្ទ ។
តាមពិត ព្រះយេហូវ៉ា ជាព្រះ អម្ចាស់តែមួយ ។ គ្មានព្រះណាផ្សេង ទៀតដែលអាចធ្វើបែបនេះបានទេ ។ យើងនឹងចងចាំថ្ងៃនេះរហូត ។


ពួកហេព្រើរចាកចេញពីឆ្នេរសមុទ្រដែលមានសាកសពទាហាន
អេស៊ីព្ទជាច្រើន ។ ហើយទៅតាមលោក ម៉ូសេ និងដុំពពក
ទៅវាលរហោស្ថានដ៏ធំ ។ ពួកគេបានបន្តដំណើរដោយបរិភោគ
អាហារនិងទឹកដែលពួកគេបានយកពីអេស៊ីព្ទមក ។


បន្ទាប់ពីធ្វើដំណើរបានពីរបីថ្ងៃ
ពពកបាននាំពួកគេឈប់នៅកន្លែងអណ្តូងទឹក ។
ពួកហេព្រើរបានបោះជំរុំនៅទីនោះរហូតដល់អាហាររបស់គេអស់ ។
គ្មានទី កន្លែងណាដែលគេអាចរកអាហារទៀតទេ
វាទំនងជាគ្មានសង្ឃឹមសោះ ។


យើងអាចនៅស្រុកអេស៊ីព្ទ ហើយរស់នៅទីនោះប្រសើរ ជាងនេះ ។ ទោះជាធ្វើទាសករ យើងក៏មានអាហារគ្រប់គ្រាន់បរិភោគដែរ ។ នៅទីនេះ គ្មានអ្វីសោះ ។
មែន៎ ! ឯងបាននាំយើងឱ្យស្លាប់នៅទីនេះដោយការស្រេកឃ្លានឬ ?


សូមស្ដាប់ខ្ញុំ អ្នកមិនបាន ត្អូញត្អែរទាស់នឹងខ្ញុំទេ ប៉ុន្តែទាស់នឹង ព្រះជាម្ចាស់ដែលយើងតាមវិញ ។
ព្រះយេហូវ៉ាមានបន្ទូលថា ទ្រង់នឹង ទម្លាក់នំប៉័ងពីឋានសួគ៌រៀងរាល់ព្រឹក អ្នកនឹងឃើញ នំប៉័ងនៅពាសពេញដី ។ អ្នកទាំងអស់គ្នាគ្រាន់ តែរើសយកទៅបរិភោគប៉ុណ្ណោះ ។


តើម៉ូសេបាននិយាយអ្វី ? តើយើងនឹងរកអាហារយ៉ាងម៉េច ? ក្មេងកំពុងតែអត់អាហារ ។
គាត់និយាយថា ព្រះយេហូវ៉ា នឹងទម្លាក់នំប៉័ងពីឋានសួគ៌ រៀងរាល់ព្រឹក !


វាជិតដល់ពេលព្រះអាទិត្យរះហើយ តើបងជឿថា មាននំប៉័ងធ្លាក់មកលើដីដូចម៉ូសេនិយាយឬទេ?
បើសិនអត់មាន យើងនឹងស្លាប់ ។
តើបងធ្លាប់ឮពីនំប៉័ង ធ្លាក់ពីលើមេឃឬទេ ?


ទេ ប៉ុន្តែបងមិនដែលឃើញផ្លូវកាត់តាមសមុទ្រដែរ ។
ព្រះរបស់ម៉ូសេនេះពិតជាអ្នកបង្កើតសកលលោកមែន ។
បងគិតថា វាមិនពិបាកចំពោះទ្រង់ធ្វើឱ្យនំបុ័ងធ្លាក់ពីលើមេឃទេ ។
តោះ ដល់ ពេលហើយ ក្រោកឡើងឥឡូវយើងទៅមើល ។
និក្ខមនំ ១៤:២១-២២, ៣០, ១៦:២-៣, ១៦:៧-៨


នំប៉័ងពីឋានសួគ៌
ដូច ម៉ូសេនិយាយមែន !
ហេតុអ្វីបានជា
យើងសង្ស័យ ?


មើលនែ៎!
វាមានគ្រប់ទីកន្លែង !
អ៊ូំ វាឆ្ងាញ់ណាស់ !
មានរសជាតិដូចទឹកឃ្មុំ ។
ព្រះយេហូវ៉ា ទ្រង់ជាព្រះពិត
ហើយម៉ូសេគឺជាហោរារបស់ទ្រង់ ។


ដរាបណាពួកគេនៅវាលរហោស្ថាន ព្រះអម្ចាស់បាន
ចិញ្ចឹមពួកគេដោយអាហារពីឋានសួគ៌នៃពួកទេវតា ។
នៅពេលពពកសំកាំងនៅលើជំរុំរបស់ពួកគេ
ពួកគេនៅក្បែរអណ្តូងទឹក ហើយបរិភោគនំបុ័ងពីឋានសួគ៌
ប៉ុន្តែពពកចាប់ផ្តើមរសាត់ ពួគគេបានរៀបចំ តង់
ហើយតាមពពកទៅទីវាលរហោស្ថានដែលពួកគេមិនស្គាល់ ។


មានពេលមួយមកដល់ ពួកគេបានអស់ទឹកប្រើ ។
ទ្រង់ប្រទាននំប៉័ងឱ្យយើង តើមានប្រយោជន៍អីឥឡូវនេះ ទ្រង់នឹងសម្លាប់យើងដោយ ឥតមានទឹកផឹក ។
កូនស្រីតូចរបស់ខ្ញុំនឹង ស្លាប់ ប្រសិនបើយើងគ្មាន ទឹកក្នុងពេលឆាប់ៗនេះ ។




និក្ខមនំ ១៦:១៤-១៥, ១៧:២-៤, ទំនុកដំកើង ៧៨:២៤-២៥


ព្រះអម្ចាស់បានប្រាប់ម៉ូសេនូវអ្វីដែលត្រូវធ្វើ ។
ចូរមក
នឹងឃើញអំណាច
របស់ព្រះយេហូវ៉ា
ពួកអ្នកមិនជឿ
ទ្រង់ហើយរអ៊ូរទាំរហូត ។


ទ្រង់បានផ្តល់នំបុ័ងដល់ពួកអ្នកហើយ ឥឡូវទ្រង់ផ្តល់ទឹកចេញពីថ្មដ៏ស្ងួតនេះទៀត។


ផាំង !
អឺយ៉ា...!
និក្ខមនំ ១៧:៥-៦


ទឹកក៏បានហូរចេញ ដូចជាទឹកស្ទឹង។


ពពកក៏រសាត់ម្តងទៀត ហើយពួកហេព្រើរ
ក៏បានរៀបចំទៅវាលរហោស្ថានដល់ភ្នំស៊ីណៃ។


នៅទីនោះ ម៉ូសេ បានអធិដ្ឋានហើយព្រះអម្ចាស់ បានមានបន្ទូលមកគាត់ម្ដងទៀតថា...
ចូររំឭកពួកគេពីការទាំងអស់ដែលអញ បានធ្វើទៅលើពួកអេស៊ីព្ទ ពីរបៀបដែលអញ បានរំដោះពួកគេចេញពីទាសករ ព្រមទាំង ផ្ដល់អាហារនិងទឹកចេញពីថ្ម។
និក្ខមនំ ១៧:៦, ១៩:១-៦, ៩


ចូរប្រាប់ពួកគេថា ប្រសិនបើពួកគេ គោរពត្រឹត្យវិន័យរបស់អញ ពួកគេនឹងធ្វើ ជាប្រជាជាតិដ៏វិសេសលើសជាងប្រជាជាតិ ផ្សេងទៀតនៅលើផែនដី ។ ប្រសិនបើ ពួកគេគោរព ពួកគេនឹងធ្វើជានគរដល់អញ ដែលសុទ្ធតែជាសង្ឃ ។


ម៉ូសេ អញនឹងមកក្នុងពពកយ៉ាងក្រាស់ នៅពេលអញនិយាយជាមួយឯង ដូច្នេះមនុស្ស អាចឃើញហើយពួកនឹងដឹងថា នោះគឺអញ។


ម៉ូសេ បានចុះពីភ្នំហើយបាន ប្រាប់មនុស្សទាំងអស់នូវអ្វីដែល ព្រះអម្ចាស់បានមានបន្ទូល ។
យើងនឹងស្តាប់បង្គាប់ ។ យើងនឹងធ្វើអ្វីគ្រប់យ៉ាង ដែលព្រះមានបន្ទូល ។
ចូរទៅជម្រះកាយនិង សំលៀកបំពាក់ ហើយរៀបចំខ្លួន ថ្វាយបង្គំព្រះ ពីពេលនេះរហូត ទៅ៣ថ្ងៃ បន្ទាប់មកព្រះអម្ចាស់ នឹងមកជួបអ្នកទាំងអស់គ្នា ។

ដូចព្រះអម្ចាស់បានបង្គាប់ នៅថ្ងៃទី៣មនុស្សទាំងអស់បាន
ប្រមូលគ្នានៅមុខភ្នំ ដើម្បីរងចាំព្រះអង្គមានបន្ទូល។
ពពកចំឡែកបានចុះសន្សឹមៗពីលើភ្នំហើយបន្ទាប់មក...




ម៉ូសេ អញជាយេហូវ៉ា ជាព្រះ ដែលនាំឯងចេញពីស្រុកអេស៊ីព្ទមក។ នៅពេលឯង ចុះពីភ្នំនេះទៅ ចូរដាក់របងព័ទ្ធជុំវិញភ្នំនេះ។
បើអ្នកផ្សេងទៀតប៉ះភ្នំនេះ នោះ ពួកគេនឹងស្លាប់។ អញនឹងឱ្យឯងនូវ ក្រឹត្យវិន័យដប់ប្រការដែលឯងត្រូវតែប្រាប់ ដល់ជនជាតិហេព្រើរទាំងអស់នោះ។
និក្ខមនំ ១៩:៧-២៥


កុំឱ្យមានព្រះឯណាទៀតនៅ
ចំពោះអញឱ្យសោះ
កុមឱ្យឆ្លាក់ថេរិរុបនាសរមាប់ងៃ
ថវាយបង្គមឱ្យសោហ
កុមឱ្យចេញរបបហនាមរបស់របហយេហុវ៉ា
ចារបហនៃងៃចាងសារឥតការលើយ
តេថ្ងៃតិ៧នោហកឺចាថ្ងៃឆប់សរមាក
ថវាយបង្គមរបបហនៃងៃវិញ
ចុរកោរបរបតិបត្តិដល់ឪបុកម្តាយ
កុំឱ្យសម្លាប់មនុស្សឱ្យសោះ
កុមឱ្យផិតក្នាឱ្យសោហ
កុមលយចប្លន់ឱ្យសោហ
កុមឱ្យថេរិចាបន្ទាល់ក្លេងតាស់នឹង
ង្នកចិតខាងខ្លួនឱ្យសោហ
កុមឱ្យលោផលន់ចង់បានរបស់
ង្នកចិតខាងខ្លួនឱ្យសោហ


កុំឱ្យមានព្រះឯណាទៀតនៅ
ចំពោះអញឱ្យសោះ
កុំឱ្យឆ្លាក់ធ្វើរូបសម្រាប់នឹង
ថ្វាយបង្គំឱ្យសោះ
កុំឱ្យចេញព្រះនាមរបស់ព្រះយេហូវ៉ា
ជាព្រះនៃឯងជាឥតការឡើយ
តែថ្ងៃទី៧នោះគឺជាថ្ងៃឈប់សម្រាក
ថ្វាយបង្គំព្រះនៃឯងវិញ
ចូរគោរពប្រតិបត្តិដល់ឪពុកម្តាយ


កុំឱ្យសម្លាប់មនុស្សឱ្យសោះ
កុំឱ្យផិតក្បត់ឱ្យសោះ
កុំលួចប្លន់ឱ្យសោះ
កុំឱ្យធ្វើជាបន្ទាល់ក្លែងទាស់នឹង
អ្នកជិតខាងខ្លួនឱ្យសោះ
កុំឱ្យលោភលន់ចង់បានរបស់
អ្នកជិតខាងខ្លួនឱ្យសោះ

និក្ខមនំ ២០:៣-១៧


នៅពេល ម៉ូសេ បានចុះមកពីភ្នំ គាត់បានប្រមូល អ្នកដឹកនាំ៧០នាក់របស់អ៊ីស្រាអែល ហើយបាន ប្រាប់គេពីក្រឹត្យវិន័យរបស់ព្រះអម្ចាស់ ។
យើងនឹងធ្វើតាម
វាជាក្រឹត្យវិន័យដ៏ល្អ
បុរសទាំង៧០នាក់ត្រូវត្រឡប់ ទៅភ្នំជាមួយខ្ញុំវិញ ។ ព្រះអម្ចាស់នឹងជួបអ្នកទាំង អស់ដូចទ្រង់ជួបខ្ញុំ អ្នកនឹងឃើញទ្រង់ផ្ទាល់ តែមុន ដំបូងខ្ញុំត្រូវតែសរសេរក្រឹត្យវិន័យក្នុងសៀវភៅ ដែលព្រះមានបន្ទូលមកកាន់ខ្ញុំសិន ។

ម៉ូសេ បានយកចិត្តទុកដាក់ ហើយសរសេរយ៉ាងប្រយ័ត្ន
នូវអ្វីៗទាំងអស់ដែលព្រះបានមានបន្ទូលប្រាប់គាត់ ។
ព្រះវិញ្ញាណរបស់ព្រះបានជួយគាត់មិនឱ្យមានកំហុស ។





នៅពេល ម៉ូសេ បានសរសេរបន្ទូលចប់ គាត់បានប្រមូលមនុស្ស ហើយអានបន្ទូល នៃព្រះឱ្យពួកគេស្ដាប់ ។
គ្រប់ទាំងអស់ដែលព្រះ មានបន្ទូលគឺល្អ ហើយយើង នឹងគោរពតាម ។



ដូច្នេះប្រជាជាតិអ៊ីស្រាអែលបានធ្វើកិច្ចសន្យាជាមួយព្រះ។ ទ្រង់នឹងប្រទានពរ
និងផ្តល់ជីវិតដល់ពួកគេ ហើយរំដោះចេញពីពួកសត្រូវដែរ ហើយពួកអ៊ីស្រាអែល
វិញនឹងគោរពក្រឹត្យវិន័យរបស់ទ្រង់ទាំងអស់និងដើរក្នុងសេចក្តីសុចរិត។

ព្រះអម្ចាស់បានបង្គាប់ ម៉ូសេ ឱ្យថ្វាយដង្វាយ
ឈាម ហើយប្រោះឈាមដាក់មនុស្សទាំងអស់។



ពួកគេទាំងអស់មានបាប ដែលសមនឹងទទួល សេចក្ដីស្លាប់ សូម្បីតែលោកម៉ូសេ
និង អើរ៉ុនដែរ ប៉ុន្តែព្រះមានមេត្តាករុណា។ ទ្រង់បានផ្ដល់នូវផ្លូវ មួយឱ្យជៀសចេញ
គឺសម្លាប់កូនចៀមដ៏ល្អឥតខ្ចោះ ហើយប្រោះឈាមនោះលើប្រជាជាតិ។



ព្រះអម្ចាស់នឹងគ្របបាំងអំពើបាបរបស់គេ ហើយមិនសម្លាប់គេដូចគេសមនឹងទទួល។
ចៀមដែលមិនសមនឹងស្លាប់ បានស្លាប់ជំនួស មនុស្សជាច្រើនដែលមានអំពើបាប
ដែលសមនឹង ទទួលការស្លាប់ទៅវិញ។




និក្ខមនំ ២៤:១-៨


ដូច្នេះពួកចាស់ទុំ៧០នាក់របស់
អ៊ីស្រាអែលបានតាម ម៉ូសេ ឡើងភ្នំ
ដែលជាកន្លែងព្រះអម្ចាស់បានមាន
បន្ទូលមកកាន់ ម៉ូសេ ។

ភ្លាមនោះ នៅពីមុខពួកគេក៏មាន
បល្ល័ង្ករបស់ព្រះលេចឡើង។




ចាស់ទុំទាំង៧០នាក់បានឃ្លាំមើល ម៉ូសេ
ឡើងភ្នំ ហើយគាត់បានបាត់នៅក្នុង
ពន្លឺចាំងនៃសិរីរុងរឿងរបស់ព្រះ។
ស្អាតអស្ចារ្យណាស់!
សិរីរុងរឿង !
គ្មានមនុស្សណាដូច
ម៉ូសេ ដែលនិយាយទល់មុខ
ជាមួយព្រះទេ។
និក្ខមនំ ២៤:៩-១០


ម៉ូសេ ឯងត្រូវឱ្យប្រជារាស្ត្រធ្វើរោងថ្វាយបង្គំ បណ្ដោះអាសន្ន។ វានឹងមានអាសនៈមួយសម្រាប់ថ្វាយយញ្ញបូជាដល់អញ នឹងមានទីកន្លែងបរិសុទ្ធមួយដែលអញអាចជួបជាមួយសម្ដេចសង្ឃមួយ ឆ្នាំម្ដង គ្រប់ជំនាន់របស់ឯងទាំងអស់។


អញនឹងប្រាប់ឯងយ៉ាងច្បាស់នូវរបៀបធ្វើរោង
ថ្វាយបង្គំបណ្ដោះអាសន្ន។ ពួកកុលសម្ព័ន្ធរបស់លេវី
នឹងធ្វើជាសង្ឃអញ ហើយអើរ៉ុននិងកូនប្រុសរបស់គាត់
បន្ដពីគាត់នឹងធ្វើជាសម្ដេចសង្ឃ។ ពួកគេនឹង
អប់រំមនុស្សឱ្យបានសុចរិត ហើយនឹងថ្វាយ
យញ្ញបូជានៅពេលមនុស្សធ្វើបាប។


ម៉ូសេបានបាត់ខ្លួន នៅលើភ្នំយូរថ្ងៃ នៅក្នុងជំរុំវិញ ប្រជាជនកំពុង ពិភាក្សាគ្នាថា...
ជាច្រើនសប្ដាហ៍បានកន្លងផុតទៅ ដែលគាត់បាត់ខ្លួនក្នុងភ្លើងលើភ្នំនោះ ។ គាត់ពិតជាស្លាប់ហើយ ។
បាទ យើងមិនអាចនៅ ទីរហោស្ថាននេះរហូតទេ ។
យើងត្រូវការព្រះមួយ ដើម្បីដឹកនាំយើង ដូច ម៉ូសេដែរ ។
ចូរឱ្យយើងធ្វើរូបចម្លាក់ ពីមាសជាតំណាងព្រះ របស់យើង ។


ម៉ូសេ បានស្លាប់ហើយ ។ អើរ៉ុននឹងធ្វើរូបព្រះមួយពីមាស សម្រាប់ពួកយើង ដើម្បីនាំពួកយើង ត្រឡប់ទៅស្រុកអេស៊ីព្ទវិញ ។
សូមឱ្យមាសរបស់ ឯងមកយើង ។




និក្ខមនំ ២០:៤, ២៥:៨-៩, ២៨:១-៣, ៣២:១-៤, អេសេគាល ១:១០, ១០:១១, ២៨:១៤


អើរ៉ុនបានធ្វើការនេះហាក់ដូចជាឆោតល្ងង់
ព្រោះគាត់បានដឹងថារូបចម្លាក់នោះមិនមែនជាព្រះទេ
តែគាត់ខ្លាចជនជាតិរបស់គាត់។
នេះជាព្រះរបស់ឯង
ដែលបាននាំឯងចេញ ពីប្រទេសអេស៊ីព្ទ។
ស្អែកយើងនឹងធ្វើយញ្ញបូជា យ៉ាងធំអស្ចារ្យ
ហើយថ្វាយបង្គំព្រះយេហូវ៉ា។
ព្រះអម្ចាស់បានបង្គាប់ពួកគេរួចទៅហើយ
មិនឱ្យធ្វើរូប ចម្លាក់សម្រាប់ថ្វាយបង្គំ
ប៉ុន្តែពួកគេកំពុងធ្វើតាមការ
ស្រមើស្រមៃរបស់ពួកគេ។

# និក្ខមនំ ៣២:៥-១០

ប្រជាជនហេព្រើរបានរាំហើយសំរាតខ្លួន ។ ពួកគេ
ស្រវឹងហើយប្រព្រឹត្តកាមតណ្ហា ។ ព្រះអម្ចាស់
បានរៀបចំរួចស្រេចដើម្បីបំផ្លាញពួកគេទាំងអស់
ហើយបញ្ជូនពួកគេទៅក្នុងបឹងភ្លើងដែលទ្រង់
បានរៀបចំសម្រាប់ពួកអារក្សនិងទេវតារបស់វា ។




ម៉ូសេ បានខឹងនៅពេលគាត់ឃើញថា ពួកគេបានបំភ្លេច
ព្រះអម្ចាស់ ហើយបានធ្វើរូបចម្លាក់ព្រះដោយខ្លួនគេ។
ពួកឯងបំពានក្រឹត្យវិន័យ
របស់ព្រះអម្ចាស់ !


ម៉ូសេ បានបំបែកផ្ទាំងសិលា
ដែលបានចារឹកពីក្រឹត្យវិន័យ ។


និក្ខមនំ ២០:៣-៤, ៣២:១៥-២០
ម៉ូសេ បានបំផ្លាញរូបគោមាស ហើយ វាយកំខ្ទេចវាឱ្យម៉ដ្តដូចជាម្សៅ ។
តើទ្រង់មិនបានមានបន្ទូលថា កុំឱ្យមានព្រះដទៃផ្សេងទៀតក្រៅពីយេហូវ៉ាទេឬ? តើរូបចម្លាក់ដែលឯងធ្វើដោយដៃផ្ទាល់របស់ឯង អាចធ្វើជាអ្នកបង្កើតឯងយ៉ាងម៉េច ?


បើពួកឯងនៅខាង ព្រះយេហូវ៉ា ចូរមកឈរជាមួយខ្ញុំ បើពួកឯងចង់ថ្វាយ បង្គំព្រះរបស់អេស៊ីព្ទ ចូរឯងនៅកន្លែងដែលឯងឈរចុះ ។
ខ្ញុំគួរតែតាមព្រះ ដែលញែក សមុទ្រក្រហមជាពីរ ទោះបីទ្រង់ ឥតមានរូបក៏ដោយ ។
ពួកយើងនឹងតាម ព្រះនៃ អ័ប្រាហាំ អ៊ីសាក និង យ៉ាកុប ។


ទោសនៃអំពើបាបគឺសេចក្ដី
ស្លាប់! ព្រះយេហូវ៉ាមានបន្ទូលថា
ពួកគេ ត្រូវតែស្លាប់។
ឥឡូវចូរយកដាវរបស់ឯង
ហើយសម្លាប់ពួកគេទាំងអស់ដែលប្រើ
រូបចម្លាក់ដើម្បីថ្វាយបង្គំ។


នៅថ្ងៃនោះមនុស្ស៣០០០នាក់ដែលគោរពរូប
ចម្លាក់និងអ្នកប្រព្រឹត្តកាមត្រូវបានសម្លាប់ ។
ទេ...!
សូម
អាណិតខ្ញុំផង !
និក្ខមនំ ៣២:២៦-២៨


ម៉ូសេ ក៏បានឡើងភ្នំម្តងទៀត ហើយទ្រង់ក៏ចារឹកក្រឹត្យវិន័យ
ទាំង១០ប្រការនៅលើសិលាទាំងពីរផ្ទាំងនោះ ។ រួចហើយម៉ូសេ
ត្រឡប់ចុះមកវិញ គាត់បានបង្ហាញប្រជាជនទាំងអស់អំពីក្រឹត្យវិន័យ
របស់ព្រះ ហើយពួកគេយល់ព្រមធ្វើតាមក្រឹត្យវិន័យនោះដែរ ។


ព្រះអម្ចាស់មានបន្ទូលថា
ពួកឯងមាន ចិត្តរឹងហើយជាមនុស្សបះបោរ ។
ពេលឯងធ្វើបាបទ្រង់បាន ប្រាប់ខ្ញុំ
ទ្រង់នឹងសម្លាប់ពួកឯងទាំងអស់ ប៉ុន្តែខ្ញុំអធិដ្ឋាន
សំរាប់ពួកឯង
ហើយទ្រង់នឹងលោះបាបរបស់ឯងចេញ ។ ព្រះ យេហូវ៉ា
គឺពិតជាមានមេត្តាករុណានិងការអត់ទោស ។


ព្រះអម្ចាស់បានផ្ដល់ការណែនាំ
ដើម្បីសង់រោងថ្វាយបង្គំបណ្ដោះអាសន្ន ។ បើយើង សង់វាទៅតាមការបង្ហាញរបស់ទ្រង់
ទ្រង់នឹងមកជួបយើងនៅទីនោះ ។ ព្រោះយើង ទាំងអស់មានបាប
ទ្រង់បានរៀបផ្លូវមួយដែលធ្វើឱ្យយើងអាចចូលមកឯទ្រង់ ។


ពួកលេវីនឹងថ្វាយដង្វាយឈាមជារៀងរាល់ថ្ងៃ។ មួយឆ្នាំម្ដងត្រូវយកឈាមដាក់លើហឹបនៃសេចក្ដីសន្យា។ នៅពេលព្រះអម្ចាស់ទតឃើញឈាមនៅលើហឹបនោះ ទ្រង់នឹងលោះអំពើបាបរបស់យើងចេញហើយយើងនឹងមិនស្លាប់ ដូចដែលទ្រង់បានធ្វើនៅអេស៊ីព្ទ។ វាជាផ្លូវនៃការលើកលែងទោសរបស់ព្រះ។


នៅពេលរោងថ្វាយបង្គំបណ្ដោះអាសន្នត្រូវ
បានធ្វើរួចរាល់ហើយ ពួកសង្ឃក៏បានចាប់ផ្ដើម
ធ្វើយញ្ញបូជារៀងរាល់ថ្ងៃ។ នៅពេលព្រះ
អម្ចាស់បានឃើញសេចក្ដីជំនឿរបស់ពួកគេ
ដែលថ្វាយឈាមសត្វ
ទ្រង់លោះអំពើបាប របស់គេចេញ។
ប៉ុន្តែមនុស្សទាំងឡាយមិនសប្បាយ
ដោយរស់នៅវាលរហោស្ថាន ដូច្នេះ
ពួកគេបានត្អូញត្អែរគ្រប់ពេល។
មានថ្ងៃមួយបានមកដល់ការត្អូញត្អែរនិងភាពគ្មានសេចក្ដីជំនឿ
បានបណ្ដាលឱ្យព្រះដាក់សេចក្ដីជំនុំជំរះមកលើពួកគេ។




ព្រះអម្ចាស់ បានធ្វើឱ្យពស់មានពីសជាច្រើនចូលក្នុងជំរុំ ហើយបានចឹកពួកគេ។
ព្រះអម្ចាស់គឺមានមេត្តាករុណា ប៉ុន្តែទ្រង់មិនអនុញ្ញាតឱ្យមានអំពើបាបបន្តរហូតទេ។

និក្ខមនំ ៣៤:២៨-៣២, ៣៩:៣២, ជនគណនា ២១:៥-៦


ភ្លាមនោះក្នុងជំរុំពោរពេញដោយពស់ពឹស ។


ព្រះជាម្ចាស់
ជួយខ្ញុំផង !


ពស់ក៏ចូលរកពួកគេនៅក្នុងតង់នៅពេលយប់ដែរ ។
ឆីត...!


ជួយខ្ញុំផង ! ពស់
ចឹកហើយ !


ទេ...!




សូម្បីតែកូនក្មេងក៏មានការឈឺចាប់
ចំពោះបាបពីឪពុកម្ដាយរបស់គេដែរ។

ជនគណនា ២១:៦



គ្រប់ទីកន្លែងទាំងអស់ក្នុងជំរុំពួកគេ
បានឮសំលេងស្រែកដោយសារការឈឺចាប់ ។
ឈ្នួលនៃអំពើបាបដែលពួកគេកំពុងទទួល
គួរឱ្យខ្លាចណាស់ ។
វាកើតឡើងគ្រប់ទីកន្លែងក្នុង
ជំរុំ ហើយវាអាក្រក់ខ្លាំងទៅៗ ។
មនុស្សជាច្រើនបានស្លាប់ ។
យើងត្រូវតែទៅរកម៉ូសេ ។
នេះពិត ជាកិច្ចការរបស់ព្រះ ។
ទ្រង់កំពុងក្រោធជាមួយ
មនុស្សចំពោះអំពើបាបរបស់គេ ។
ផាច់ !


លោក ត្រូវតែអធិដ្ឋានទៅ ព្រះ។ យើងសមតែទទួលទណ្ឌកម្មនេះ តែសុំទ្រង់ផ្តល់មេត្តាករុណាផង។
តើពេលណាពួកគេនឹងដឹងថា ព្រះស្អប់អំពើបាប ? ពួកគេត្រូវតែ ស្តាប់បង្គាប់ក្រឹត្យវិន័យហើយ ធ្វើជាប្រជាជាតិដ៏បរិសុទ្ធ។


ឱ ព្រះជាម្ចាស់ ! សូមផ្ដល់មេត្តាករុណាដល់រាស្ត្ររបស់ទ្រង់និងអត់ទោសអំពើបាបរបស់គេផង ។
ចូរទៅធ្វើពស់មួយពីលង្ហិន ឱ្យដូចពស់ដែលចឹកមនុស្សហើយដាក់វា នៅលើបង្គោល ដើម្បីឱ្យមនុស្សទាំងអស់មើលឃើញ ។ ប្រាប់ពួកគេឱ្យក្រឡេកមើលពស់លង្ហិននោះនឹងបានជាភ្លាម ។

ជនគណនា ២១:៧-៨


ព្រះអម្ចាស់បានផ្ដល់ផ្លូវមួយ
គ្រាន់តែក្រឡេកមើលពស់លង្ហិន
ហើយឯងនឹងបានជា !


គាត់ជិតស្លាប់ហើយ
ទេ !
ព្រះអម្ចាស់បានផ្តល់
ផ្លូវមួយ
អ្នកគ្រាន់តែបើកភ្នែក មើល
បើមើលអ្នកនឹងរស់។


វាជាការ អស្ចារ្យ!
យើងត្រូវតែប្រាប់ អ្នកផ្សេងៗទៀត
ខ្ញុំបានជាដោយគ្រាន់តែមើល ! ខ្ញុំនឹងជួយប្រាប់អ្នកផ្សេងៗដែរ ។




ជនគណនា ២១:៩


ហេតុអ្វីអ្នកចំអកដាក់គាត់ ដោយគ្មានសង្ឃឹមពិតអញ្ចឹង ?
អត់ទេ អ្នកផ្សេងបានក្រឡេកមើល ហើយបានជា !
តើឯងឃើញឬទេ ខ្ញុំជិតស្លាប់ហើយ ហេតុអីឯងនិយាយអញ្ចឹង ?


គាត់ស្លាប់ហើយ
ខ្ញុំសោកស្តាយដោយ
គាត់មិនជឿ
គាត់មានអំនួតជាខ្លាំង


ពួកគេបានឃើញអំណាចរបស់ព្រះម្តងទៀត។
ការបោះ ជំរុំត្រូវបានរើចេញឆ្ងាយពីពស់ដ៏សាហាវ
ហើយជីវិតរបស់ ពួកគេវិលមកធម្មតាវិញ។
ពួកគេបានបន្តធ្វើតាមចិត្តរបស់គេ ជារឿយៗ
មិនគោរពក្រឹត្យវិន័យរបស់ទ្រង់។


រាស្ត្រអ៊ីស្រាអែលបានតាមពពក ព្រះអម្ចាស់បានចិញ្ចឹមពួកគេ
ដោយនំម៉ាន៉ាពីឋានសួគ៌ហើយផ្តល់ទឹកចេញពីថ្មផងដែរ។
ជនគណនា ២១:៩, ៣២:១៣
ទ្រង់ចង់នាំពួកគេទៅកាន់ទឹកដីសន្យា ប៉ុន្តែពួកគេមិនស្តាប់បង្គាប់ព្រះ
ហើយមិនគោរពក្រឹត្យវិន័យរបស់ទ្រង់ ដូច្នេះទ្រង់បណ្តាលឱ្យពួកគេ
ដើរតត្រុកក្នុងវាលរហោស្ថានអស់រយៈពេល៤០ឆ្នាំ។


ម៉ូសេ ឯងគិតថាឯងជាមនុស្សតែម្នាក់ជិតស្និទ្ធជាមួយព្រះ ។ យើងក៏បរិសុទ្ធដូចឯងដែរ តាមពិតប្រជារាស្ត្រទាំងមូលគឺបរិសុទ្ធ ។ ក្នុងចំណោមពួកយើងគ្មាននរណាម្នាក់ដែលមាន បាបទេ ហើយព្រះអម្ចាស់គង់នៅជាមួយពួកយើង ។ ពួកយើងមិនត្រូវការឯងនិងអើរ៉ុនបញ្ជា យើង ឬធ្វើជាអ្នកកាត់ក្តីលើយើងទេ យើងក៏អាចធ្វើជាអ្នកកាត់ក្តីល្អដូចឯងដែរ ។


បាទ ខ្ញុំធុញទ្រាន់ពីការ ដើរតត្រុកនៅវាលរហោស្ថាន
ហើយព្រះកំពុងសម្លាប់យើង ដោយសាររឿងបន្តិចបន្តួច ។
បាទ វាជាកំហុសរបស់ម៉ូសេ ។
ម៉ូសេ តឹងតែងពេក គ្មាន
អ្នកណាធ្វើតាមបានទេ ។


ម៉ូសេ បានទៅកាន់រោងថ្វាយបង្គំបណ្ដោះ
អាសន្ន ហើយទូលសុំព្រះនូវអ្វីដែលត្រូវធ្វើ ។


ព្រះមានបន្ទូលថា ពួកឯងជាពូជពង្សរបស់លេវី
បានយកការទទួលខុសត្រូវដាក់លើខ្លួនច្រើនពេក ។
ពួកឯងចង់ជ្រើសរើសមនុស្សខ្លះឱ្យធ្វើជាសង្ឃ
នៅពេលព្រះមិនទាន់តែងតាំងពួកគេ ។
ជនគណនា ១៦:២-៦


ស្អែក ព្រះអម្ចាស់ នឹងជំនុំជំរះរវាងយើងទាំងអស់គ្នា ហើយយើងនឹងដឹងថា អ្នកណាជាសង្ឃនៃព្រះ អ្នកណាបរិសុទ្ធហើយអ្នកណាមិនបរិសុទ្ធ ។ នៅព្រឹកស្អែកពួកឯងត្រូវតែមករោងថ្វាយបង្គំបណ្ដោះអាសន្ន ហើយយកពានដែលដុតគ្រឿងក្រអូបមកជាមួយផង ។


ថ្ងៃបន្ទាប់មក
ចូរមកជិតអ្នកដែលតាំងខ្លួនថាជាបរិសុទ្ធ ។ អ្នកដែលចង់ធ្វើជាសង្ឃ ហើយចង់ត្រួតត្រាលើមនុស្ស ។


ព្រះអម្ចាស់នឹងជួបពួកយើងនៅទីនេះ
ហើយនឹងជ្រើសរើសអ្នក ដែលទ្រង់តែងតាំង ។
យើងនឹងឃើញអំណាចនិងសិរីល្អរបស់ទ្រង់ ។


ចូរថយចេញពីមនុស្សអាក្រក់ទាំងនេះ
អញនឹងសម្លាប់ពួកវាក្នុងមួយពព្រិចភ្នែក ។




ជនគណនា ១៦:១៩-២៤


នេះជាការល្បងមើល បើមនុស្សទាំងនេះស្លាប់ តាមធម្មតា នោះអ្នកអាចដឹងថា ខ្ញុំជាហោរាក្លែងក្លាយហើយព្រះមិនមានបន្ទូលតាមខ្ញុំទេ។
ប៉ុន្តែបើសិនថ្ងៃនេះអ្នកឃើញ ផែនដីបើកចំហររួចលេបពួកគេ និងរបស់របរទាំងអស់របស់គេ ទៅដល់ឋាននរក អ្នកនឹងដឹងថា ពួកគេមានបាបប្រឆាំងនឹងព្រះ ហើយខ្ញុំជាហោរារបស់ទ្រង់។


ជួយផង...!
អីយ៉ា...!
ទេ...!

ជនគណនា ១៦:២៨-៣៣



ពួកគេទាំងអស់ដែលចង់ធ្វើជាសង្ឃ ផែនដីបាន លេបពួកគេទាំងរស់ទៅក្នុងភ្លើងនៃឋាននរក ដែល បានរៀបទុកសម្រាប់អារក្សនិងទេវតារបស់វា។


ចូររើសពានគ្រឿងក្រអូបរបស់គេឡើង
ហើយយកទៅធ្វើគំរបសម្រាប់អាសនៈ ។
នៅពេលអ្នកឃើញគំរបអាសនៈដែលធ្វើពីពានលង្ហិននោះ
អ្នកនឹងចងចាំនៅថ្ងៃនេះ ដែលពួកគេមិនគោរពក្រឹត្យវិន័យរបស់
ព្រះនឹងបានព្យាយាមធ្វើជាសង្ឃដោយខ្លួនឯង ។



នោះជាថ្ងៃដែលជនជាតិអ៊ីស្រាអែលនឹងចងចាំរហូត ។
ព្រះអម្ចាស់បានធ្វើឱ្យដឹងច្បាស់ថា ម៉ូសេ គឺជាហោរា
របស់ទ្រង់ ហើយគ្មានអ្នកណាម្នាក់ដែលអាច
ធ្វើជាសង្ឃក្រៅពីទ្រង់តែងតាំងឡើយ ។


សិរីរុងរឿងរបស់ព្រះតែងតែស្ថិតនៅលើរោងថ្វាយបង្គំ
បណ្តោះអាសន្ន ហើយប្រជារាស្ត្រមានចិត្តតាមម៉ូសេធ្វើដំណើរ
ទៅវិញទៅមក នៅវាលរហោស្ថានអស់រយៈពេល៤០ឆ្នាំ។
ជនគណនា ១៦:៣៧-៣៨


សិរីរុងរឿងរបស់ ព្រះអម្ចាស់
គង់នៅជាមួយយើងហើយទ្រង់ផ្តល់
នំបុ័ងពីឋានសួគ៌ដល់យើង ។
ព្រះអម្ចាស់ បានបន្ទម្លាក់នំបុ័ងពីឋានសួគ៌ ហើយផ្តល់ទឹកចេញ
ពីថ្ម ។ ពួកគេមានបង្គោលភ្លើងបំភ្លឺនៅពេលយប់និងមានពពក
ដែលបាំងធ្វើជាម្លប់នៅពេលថ្ងៃ ។ ពួកគេបានស្ងប់ចិត្តហើយបាន
ស្វែងយល់ដើម្បីគោរពតាមក្រឹត្យវិន័យរបស់ព្រះ ។


ពួកសង្ឃបានថែរក្សារោងថ្វាយបង្គំ
បណ្ដោះអាសន្ន ហើយបានថ្វាយដង្វាយ
រាល់ថ្ងៃដូចម៉ូសេបានបង្គាប់ ។


បន្ទាប់ពី៤០ឆ្នាំនៅវាលរហោស្ថាន នៅពេលប្រជាជនទាំងអស់គ្នា
កំពុងរៀបចំចូលទៅទឹកដីសន្យា ព្រះបានហៅម៉ូសេឡើងភ្នំ នៅ
ទីនោះបន្ទាប់ពីគាត់បាននិយាយជាមួយព្រះជាលើកចុងក្រោយ
ម៉ូសេបានផ្តេកខ្លួនហើយស្លាប់ដោយភាពស្ងប់ស្ងាត់ ។




( ប្រហែលឆ្នាំ១៤៥១ មុន គ.ស.) ចោទិយកថា ៣៤:៤-៥


ជិត៥០០ឆ្នាំកន្លងផុតទៅ តាំងពីព្រះយេហូវ៉ាបានហៅ
អ័ប្រាហាំចេញពីបងប្អូនរបស់គាត់ ហើយធ្វើដំណើរ
គ្រប់ទីកន្លែង នៅលើទឹកដីដែលព្រះនឹងប្រទានឱ្យគាត់ ។
ការសន្យារបស់ព្រះចំពោះ អ័ប្រាហាំ និង សារ៉ា
ធ្វើឱ្យមានប្រជាជាតិមួយយ៉ាងធំពីកូនប្រុស របស់ពួកគេគឺ អ៊ីសាក
ត្រូវបានបំពេញរួចហើយ ។ យ៉ាកុប ដែលហៅថា អ៊ីស្រាអែលមានកូនប្រុស
១២នាក់ បានក្លាយជាកុលសម្ព័ន្ធទាំង១២ ដែលមានប្រជាជនយ៉ាងច្រើន ។



ពួកគេបានរួចពីទាសករ នឹងធ្វើដំណើរតត្រុកនៅវាលហោស្ថានជាមួយម៉ូសេ
ហើយបានទទួលក្រឹត្យវិន័យរបស់ព្រះ ឥឡូវនេះនៅទីបំផុតក៏បានចូល
ទៅដល់ទឹកដីនៃការសន្យា ។ នៅពេលពួកគេធ្វើដំណើរនៅវាលរហោស្ថាន
មានយុវជនម្នាក់នៅក្បែរម៉ូសេរហូត តែងតែឃ្លាំមើលហើយស្វែងយល់នូវ
របៀបដឹកនាំប្រជាជាតិអ៊ីស្រាអែល ។


នៅពេលយុវជននោះធំឡើង
ធ្វើជាអ្នកចំបាំងម្នាក់ដ៏មានអំណាច
ហើយមានឈ្មោះថា យ៉ូស្វេ ។


បន្ទាប់ពី ម៉ូសេ បានទៅនៅជាមួយព្រះ ព្រះបាន
ជ្រើសរើសឱ្យ យ៉ូស្វេ នាំមនុស្សចូលទៅក្នុងទឹកដី
ដែលព្រះអម្ចាស់បានសន្យានឹងឱ្យអ័ប្រាហាំ។
ពួកមនុស្សបានរំឭកគិតពីបទទំនាយដែលបានថែងថា
ពួកគេនឹងរស់នៅទឹកដីរបស់អ្នកដទៃអស់រយៈពេល
៤00ឆ្នាំ បន្ទាប់មកពួកគេនឹងត្រឡប់ទៅទឹកដីនៃ
ព្វយុកោរបស់គេ។ ព្រះបានធ្វើតាមបន្ទូលរបស់ទ្រង់។

នៅថ្ងៃដែលពួកគេឆ្លងទន្លេយ័រដាន់
ព្រះអម្ចាស់ឈប់ប្រទាន នំម៉ាន៉ាពីឋានសួគ៌
ហើយគេបានហូបអាហារស្រស់ៗពីទឹកដីនោះ។






ចោទិយកថា ៣៤:៩,
យ៉ូស្វេ ៥:១២



# ជំពូក ៩

# ហោភ




ពួកមនុស្សដែលរស់នៅទឹកដីភិលីស្ទីន ដែលប្រជាជាតិអ៊ីស្រាអែលបានចូលមក ពួកគេជាមនុស្សអាក្រក់ណាស់ ។ ពួកគេជាពួក កាណាន ហើយមានភាសា ខុសគ្នាពីពួកអ៊ីស្រាអែល ។ ពួកគេបានយកមនុស្សមកថ្វាយជាដង្វាយ ហើយ ឱនក្រាបចំពោះមុខព្រះដែលធ្វើពី មាស ប្រាក់ លង្ហិន និង ឈើ ។

ព្រះអម្ចាស់បានបញ្ជូនហោរានិងពួកសង្ឃ
ដើម្បីប្រាប់ពួកគេឱ្យ ប្រែចិត្ត
ប៉ុន្តែពួកគេនៅតែបន្តអំពើបាបរបស់ខ្លួន ។
ដូចជាព្រះអម្ចាស់ បានបំផ្លាញមនុស្សនៅសម័យ
ណូអេ និងបំផ្លាញទីក្រុង សូដុម និង កូម៉ូរ៉ា
ព្រះនឹងបំផ្លាញពួកកាណានដែរ ។



ចោទិយកថា ១៨:៩-១១


ថ្ងៃណាមួយប្រហែលយើងនឹងធ្វើជាសម្តេចសង្ឃ ហើយយើងនឹងធ្វើជាអ្នកថ្វាយយញ្ញបូជា ។
វាគួរឱ្យស្អប់ខ្ពើមតែយើង ត្រូវតែធ្វើ ។ ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប ។



ពួកថ្វាយបង្គំរូបចម្លាក់ដែលរស់នៅទឹកដីនៃការសន្យា
តស៊ូជាមួយប្រជាជាតិអ៊ីស្រាអែល ហើយបានវាយ
ប្រយុទ្ធដើម្បីរក្សាទឹកដីរបស់ខ្លួន ប៉ុន្តែព្រះអម្ចាស់បាន
ផ្តល់អំណាចឱ្យប្រជាជាតិអ៊ីស្រាអែលវាយឈ្នះពួកគេ។


យ៉ាងម៉េចបានជាឯងហ៊ាន
ចូលវិហារដ៏ស័ក្តសិទ្ធនេះ!
ឯងបានសម្លាប់កូនង៉ែត
ជាលើកចុងក្រោយ ។


នៅពេលសង្គ្រាមដ៏សាហាវបានបញ្ចប់ ពួកហេព្រើរបានឈ្នះលើសត្រូវរបស់គេ ហើយពួកគេបានធ្វើជាម្ចាស់នៅលើទឹកដីរបស់សត្រូវនោះ លោក យ៉ូស្វេ បានប្រកាសប្រាប់ពួកគេថា...
ឥឡូវចូរទៅ ហើយតាំងទីលំនៅលើ ទឹកដីនោះ ។ កុំធ្វើបាបតាមពួកគេដែលបានរស់នៅក្នុងទឹកដីនេះមុនអ្នក ដ្បិតព្រះនឹងជំនុំជំរះពួកអ្នកដូចពួកគេដែរ ។


យ៉ូស្វេ ២៤:២-១៤
ព្ធយុកោរបស់យើងពីដំបូងគឺ អ័ប្រាហាំ បានមកពីពួកមនុស្សគោរពរូបចម្លាក់ព្រះ ។ ព្រះអម្ចាស់មានបន្ទូលទៅកាន់គាត់ ហើយបានសន្យាធ្វើឱ្យគាត់ទៅជាប្រជាជាតិដ៏ខ្លាំងមួយ ។ ព្រះអម្ចាស់ក៏មានបន្ទូលទៀតថា ប្រជាជាតិរបស់ទ្រង់នឹងចុះទៅប្រទេសអេស៊ីព្ទ ហើយរស់នៅទីនោះ៤០០ឆ្នាំ ។ បន្ទាប់មកទ្រង់នឹងនាំពួកគេចេញ ហើយត្រឡប់ទៅកាន់ទឹកដីដែលយើងទើបតែមកដល់ ។ ជាង៥០០ឆ្នាំក្រោយមក យើងបានមកដល់ថ្ងៃដែលព្រះបានបំពេញកិច្ចសន្យារបស់ទ្រង់ទៅអ័ប្រាហាំ ។


នៅក្នុងទឹកដីថ្មីពួកគេមានសន្តិភាព មានកសិដ្ឋានផ្ទាល់ ហើយមានអាហារហូបគ្រប់គ្រាន់ ។ ព្រះអម្ចាស់ ប្រទានពរដល់ពួកគេលើសប្រជាជាតិផ្សេងៗ ។
បង ដល់ពេល ហូបបាយហើយ ។
យកថ្មនេះចេញសិន


ដូចព្រះបានសន្យា
ពួកហេព្រើរបានចំរើនរហូតដល់ពួកគេ
ពេញទឹកដីនោះ
ទីក្រុងរបស់ពួកគេមានសភាពរស់នៅល្អ
និងប្រកបដោយយុត្តិធម៌ ។
ប្រជាជាតិថ្មីនេះបានហៅថា អ៊ីស្រាអែល ។
ជំរាបសួរ
សុខសប្បាយទេ ប្អូនស្រី ។
ថ្ងៃនេះត្រីរបស់ប្អូន
យ៉ាងម៉េចដែរ ?
វាស្រស់ៗ
ទើបតែ យកមកពីសមុទ្រ


ព្រះយេហូវ៉ា បានវាយឈ្នះលើខ្មាំងសត្រូវរបស់យើង ប៉ុន្តែនៅតែមានការគោរពរូបចម្លាក់ក្នុងទឹកដីនេះ ។ នៅថ្ងៃនេះ ចូរពួកអ្នកជ្រើសរើសព្រះមួយណាដើម្បីថ្វាយបង្គំ ថាតើព្រះក្លែងក្លាយ របស់មនុស្សនៅទឹកដីនេះឬព្រះរបស់អ័ប្រាហាំ ។ ចំពោះខ្ញុំនិងក្រុម គ្រួសាររបស់ខ្ញុំ យើងនឹងថ្វាយបង្គំព្រះអម្ចាស់ ។


សូមព្រះអម្ចាស់ឃាត់កុំឱ្យពួកទូលបង្គំ លះបង់ទ្រង់ចោល ហើយទៅថ្វាយបង្គំព្រះផ្សេង ពីព្រោះទ្រង់បានប្រើអំណាចព្រះចេស្ដាដើម្បីនាំ យើងចេញពីទាសករនៅស្រុកអេស៊ីព្ទ ហើយបាន ថែទាំយើងនៅវាលរហោស្ថានដែរ ។
យើងសន្យាបំរើព្រះអម្ចាស់!


ហើយទ្រង់បានដេញមនុស្សដែលនៅទឹកដីនេះចេញពីមុខយើង ព្រមទាំងពួកអាម៉ូរី ដែលធ្លាប់នៅទឹកដីនេះ។ ដូច្នេះយើងនឹងថ្វាយបង្គំព្រះអម្ចាស់ព្រោះទ្រង់ជាព្រះរបស់យើង។
ព្រះអម្ចាស់ ជាព្រះដ៏បរិសុទ្ធ ទ្រង់ជាព្រះដែលប្រចណ្ឌ បើសិនពួកអ្នកលះបង់ទ្រង់ហើយគោរពតាមរូបចម្លាក់ ទ្រង់នឹងប្រែមកធ្វើឱ្យមានសេចក្ដីវេទនានិងបំផ្លាញពួកអ្នក។


ពួកអ្នកធ្វើសាក្សីជំទាស់នឹងខ្លួនឯងថា ពួកអ្នក បានជ្រើសរើសនឹងថ្វាយបង្គំព្រះអម្ចាស់ ។
ពួកយើងធ្វើជាសាក្សី!
ខ្ញុំនឹងកត់ទុកកិច្ចសន្យាក្នុង សៀវភៅ ដែលពួកអ្នកបានធ្វើ ជាមួយព្រះនៅថ្ងៃនេះ ។


ដូចអ្វីៗដែលពួកយើងធ្លាប់ស្ដាប់ម៉ូសេ
យើងនឹងស្ដាប់ បង្គាប់អ្នកដែរ ឱ្យតែព្រះអម្ចាស់គង់ជាមួយអ្នក
ដូចទ្រង់ គង់នៅជាមួយម៉ូសេ ។ អ្នកណាដែលប្រឆាំងនឹងក្រឹត្យវិន័យ
នៃព្រះអម្ចាស់ អ្នកនោះត្រូវតែសម្លាប់ចោល ។


និក្ខមនំ ២១:២៨-២៩, យ៉ូស្វេ ២៤:១៥-២៤
បន្ទាប់ពីយ៉ូស្វេបានស្លាប់ពួកគេត្រូវបានគ្រប់គ្រងដោយចៅហ្វាយផ្សេងៗ ដែលពោលទៅកាន់ព្រះអម្ចាស់ ហើយអានពាក្យរបស់លោក ម៉ូសេ ។ ពួកគេបានពន្យល់ក្រឹត្យវិន័យរបស់ព្រះទៅមនុស្ស ហើយណែនាំពួកគេឱ្យស្តាប់បង្គាប់ព្រះ ។



ម៉ូសេ បាននិយាយថា ម្ចាស់គោត្រូវទទួលខុសត្រូវពីការខូចខាត ហើយគោនោះត្រូវសម្លាប់ ។
តើក្រឹត្យវិន័យរបស់ព្រះនិយាយយ៉ាងម៉េចអំពីគោដែលបានជល់នរណាម្នាក់ ?


នៅមួយរយៈនោះពួកមនុស្សបាន ចងចាំនូវភាពអស្ចារ្យដែលព្រះ
បានធ្វើតាមរយៈលោកម៉ូសេ និង យ៉ូស្វេ ។ ពួកគេមានអំណរគុណ
ដោយបានរួចពីទាសកររបស់ពួក អេស៊ីព្ទ ។ ពួកគេបានថ្វាយបង្គំ
ព្រះយេហូវ៉ា ហើយថ្វាយ យញ្ញបូជាដូចដែល ទ្រង់បានបង្គាប់ ។


ប៉ា ហេតុអ្វីពួកសង្ឃ នឹងសម្លាប់កូនចៀមរបស់យើង ? តើមេបំផ្លាញរបស់ព្រះនឹងយាងមក ដូចដែលទ្រង់បានធ្វើនៅពេលព្ធយុកោ របស់យើងនៅអេស៊ីព្ទឬ ?
ទេ កូនប្រុស មេបំផ្លាញ នឹងមិនមកទេ ប៉ុន្តែឈាមរបស់ កូនចៀមនឹងគ្របបាំងអំពើបាបយើង ហើយធ្វើឱ្យយើងបានគាប់ក្នុង ព្រះនេត្ររបស់ទ្រង់។


ពួកគេធ្លាប់បានសន្យាជាមួយយ៉ូស្វេថា ពួកគេនឹងថ្វាយបង្គំ
ព្រះអម្ចាស់ ហើយគោរពតាមក្រឹត្យវិន័យរបស់ទ្រង់
ប៉ុន្តែមនុស្សគ្រប់គ្នាមិនបន្តថ្វាយបង្គំព្រះយេហូវ៉ាទេ។
នៅពេលឈប់មានការអស្ចារ្យទៀត នោះពួកមនុស្ស
ជំនាន់ក្រោយបានភ្លេចពីព្រះដ៏មានព្រះជន្មរស់
ហើយពួកគេបានថ្វាយបង្គំរូបចម្លាក់ដែលគ្មាន
ជីវិតនិងថ្វាយបង្គំជីដូនជីតារបស់ពួកគេដែរ។


ដូច យ៉ូស្វេ បានព្រមានពួកគេជាមុន ព្រះអម្ចាស់បាន
បញ្ជូនពួកសាសន៍ដទៃមកបំផ្លាញអ៊ីស្រាអែល ។
ទេ! សង្គ្រោះខ្ញុំផង ព្រះបាល!
យ៉ា..!
ពួកចៅហ្វាយ ៣:៧-៨, ១២-១៣, ៤:១-២, ១០:៦-៧


នៅពេលសេចក្ដីជំនុំជំរះបានធ្លាក់លើប្រជាជន
របស់ទ្រង់ ពួកគេបានចងចាំនូវក្រឹត្យវិន័យរបស់
ព្រះ ហើយបានលន់តួនូវអំពើបាបរបស់ខ្លួន។
ឱ ! ព្រះយេហូវ៉ា សូមអត់
ទោសបាបយើងផង នឹងផ្ដល់នូវ
ភាពសុខសាន្ដដល់យើងវិញ។
ពេលពួកគេបានសារភាពនូវអំពើបាប
របស់ខ្លួន ទ្រង់បានអត់ទោសឱ្យពួកគេ
ហើយផ្ដល់ឱ្យទឹកដីរបស់គេវិញ។


ពួកមនុស្សក៏ធុញទ្រាន់ពីការណែនាំរបស់ចៅហ្វាយ
ដែលស្វែងរកព្រះ ហើយណែនាំពួកគេដោយគម្ពីរ
របស់ព្រះ ។ ដូច្នេះពួកគេបានសម្រេចចិត្តតែងតាំង
ស្តេចមួយអង្គដើម្បីគ្រប់គ្រងលើពួកគេ ។
ដីចំការរបស់ឯងនឹងត្រូវរឹបអូសសម្រាប់
នគរនេះប្រើ ។ អ្នកអាចទុកកូនស្រីរបស់អ្នក
នៅទីនេះ យើងនឹងថែរក្សានាង ។



សាំយូអែល គឺជាហោរាហើយក៏ជាចៅហ្វាយ គាត់បានព្រមានពួកគេថា
នៅពេលពួកគេតែងតាំងស្តេច ពួកគេបដិសេធព្រះអម្ចាស់ដែលជាអ្នក ដឹកនាំរបស់ពួកគេ
ពួកគេមិនចង់ដើរតាមសេចក្តីជំនឿទេ ។ ស្តេចសូល បានធ្វើទុក្ខទោសពួកគេ
ដោយយកលុយ ទ្រព្យសម្បត្តិ ហើយកូនប្រុសនិងកូនស្រីពួកគេធ្វើជាអ្នកបំរើក្នុងវាំង ។


ពេលស្តេចសូលកាន់តែចាស់ វិញ្ញាណ
អាក្រក់មកសណ្ឋិតក្នុងទ្រង់ ហើយព្រះអង្គ
មិនអាចគ្រប់គ្រងអារម្មណ៍បានទេ។
ថ្ងៃមួយទ្រង់បានព្យាយាមចាក់សម្លាប់ក្មេង
ប្រុសដាវីឌ ដែលកំពុងលេងពិណថ្វាយទ្រង់។



សូល បានប្រព្រឹត្តអំពើបាបកាន់តែច្រើនឡើង ទ្រង់បាន
ឈ្នានីសមនុស្សគ្រប់គ្នាហើយទ្រង់ក៏ភ័យខ្លាច ។ វិញ្ញាណ
អាក្រក់បានសន្យាផ្តល់អំណាចនិងទ្រព្យសម្បត្តិដល់ទ្រង់
តែវានាំតែសេចក្តីវិនាសនិងការឈឺចាប់នៃព្រលឹង ។

សាំយូអែលទី១, ៨


ខ្ញុំមើលឃើញភាពងងឹត
វាមិន មែនជាការល្អទេ ។
ទ្រង់នឹងសុគត
ក្នុងសមរភូមិហើយអ្នកផ្សេងនឹង
សោយរាជ្យជំនួសទ្រង់ ។
សូល បានលះបង់ចោលព្រះ
ដែលមានព្រះជន្មរស់ ហើយបាន
ពិគ្រោះជាមួយមេធ្មប់ ។
សូល បានសុគតក្នុងសមរភូមិ ហើយ
ព្រលឹងរបស់ទ្រង់ធ្លាក់ទៅក្នុងឋាននរក ។


ព្រះអម្ចាស់ជ្រើសរើសយុវជនម្នាក់ដើម្បីសោយរាជ្យ
ជំនួសស្ដេច សូល ។ គាត់ជាអ្នកគង្វាលចៀម ដែលបាន
ស្រឡាញ់និងគោរពក្រឹត្យវិន័យរបស់ព្រះ គាត់ជា
យុវជនម្នាក់ដែលសូលបានព្យាយាមសម្លាប់ ។
ព្រះយេហូវ៉ា ទ្រង់ជាអ្នក
គង្វាលខ្ញុំ ខ្ញុំនឹងមិនខ្វះអ្វីសោះ ។
ទ្រង់ឱ្យខ្ញុំដេកសម្រាកនៅទីមាន
ស្មៅខៀវខ្ចី ទ្រង់កែព្រលឹង
ខ្ញុំឡើងវិញ ។
ដាវីឌ ជាមនុស្សសុចរិត
ហើយជាទីស្រឡាញ់របស់ ព្រះ ។
តើគាត់ជាមនុស្សម្នាក់ដែលនឹងសង្គ្រោះមនុស្ស
ពីអំពើបាបនិងសេចក្ដីស្លាប់ឬ ? តើ ដាវីឌ
ជាមនុស្ស ម្នាក់ដែលព្រះបានសន្យាឬ ?

# សាំយូអែលទី១, ១៨:១០-១១, ៣១:៤, ១៦:១-១៣, ទំនុកដំកើង ២៣:១-៣



មានពរហើយអ្នកណាដែលមិនដើរតាមដំបូន្មាន
មនុស្សអាក្រក់ ក៏មិនឈរនៅក្នុងផ្លូវរបស់មនុស្ស មានបាប
ឬអង្គុយនៅជាមួយនឹងពួកមនុស្សដែល មើលងាយ
អ្នកនោះត្រេកអរតែនឹងក្រឹត្យវិន័យរបស់ព្រះ យេហូវ៉ាវិញ
ក៏រំពឹងគិតក្នុងក្រឹត្យវិន័យទ្រង់ ទាំងយប់ទាំងថ្ងៃដែរ

អ្នកនោះនឹងដូចជាដើមឈើដែលដុះនៅក្បែរផ្លូវ
ទឹក ដែលបង្កើតផលតាមរដូវកាល ហើយស្លឹក
ក៏មិនចេះស្រពោនឡើយ ឯការអ្វីដែលអ្នក
នោះធ្វើ នោះនឹងចំរើនឡើងទាំងអស់



ចំណែកមនុស្សអាក្រក់មិនដូច្នោះទេ គឺគេដូចជា
អង្កាមវិញ ដែលខ្យល់ផាត់ខ្ចាត់ខ្ចាយទៅ
ដូច្នេះពួកមនុស្សអាក្រក់នឹងមិនធន់ក្នុងការជំនុំជំរះ
ទេ ឯពួកមានបាបក៏ឈរក្នុងពួកជំនុំមនុស្សសុចរិត
មិនបានដែរ

ដ្បិតព្រះយេហូវ៉ាទ្រង់ជ្រាបផ្លូវរបស់មនុស្សសុចរិត
តែផ្លូវរបស់មនុស្សអាក្រក់នឹងវិនាសទៅវិញ។

នៅពេល សូល សុគត
ដាវីឌក៏បានក្លាយទៅ
ជាស្ដេចរបស់អ៊ីស្រាអែល
ហើយបានដឹកនាំ
ពួកមនុស្សថ្វាយបង្គំព្រះអម្ចាស់ និង
ដើរតាមក្រឹត្យវិន័យរបស់ទ្រង់។




ក្រោមការសោយរាជ្យរបស់ ដាវីឌ ប្រជាជាតិ
បានរីកចំរើន ហើយបានរស់នៅដោយយុត្តិធម៌។

សាំយូអែលទី២, ២:៤ ទំនុកដំកើង
១, កិច្ចការ ១៣:២២-២៣


ព្រះអម្ចាស់មានបន្ទូលទៅកាន់ដាវីឌ
ហើយបានបង្ហាញ រឿងជាច្រើននៅថ្ងៃអនាគត ។
ស្តេច ដាវីឌ បានសរសេរ
នូវបទទំនាយទាំងនោះក្នុងសៀវភៅទំនុកដំកើង ។
បទទំនាយជាច្រើនត្រូវបានបំពេញរួចរាល់ហើយ ។
ស្តេចដាវីឌ គឺសុចរិត
ប៉ុន្តែទ្រង់ក៏មាន បាបដែរ
ដូច្នេះទ្រង់មិនអាចធ្វើជាអ្នក
សង្គ្រោះ ។ ទ្រង់បានសរសេរប្រាប់
ពីអ្នកសង្គ្រោះដែលនឹងយាងមក ។

ឱ្យព្រះរាជបុត្រាបានគ្រប់គ្រងលើរាស្ត្ររបស់ព្រះដោយសុចរិត ហើយលើ
ពួកក្រីក្រដោយទៀងត្រង់ ហើយជួយសង្គ្រោះដល់ពួកកូនរបស់មនុស្ស
ក្រីក្រ ព្រមទាំងវាយពួកអ្នកសង្កត់សង្កិនឱ្យខ្ទេចខ្ទីទៅ។
នៅក្នុងគ្រាព្រះរាជបុត្រា នោះមនុស្សសុចរិតនឹងមានសេចក្ដីចំរើនឡើង
ហើយនឹងមានសេចក្ដីសុខជាបរិបូរ ដរាបដល់ព្រះច័ន្ទរលត់សូន្យទៅ។
ទ្រង់នឹងមានអំណាច ចាប់តាំងពីសមុទ្រម្ខាងទៅសមមុទ្រម្ខាង
ហើយពី ទន្លេរហូតដល់ទីបំផុតផែនដី។

អើ ពួកក្សត្រទាំងអស់នឹងផ្តួលខ្លួនក្រាបចុះនៅចំពោះទ្រង់
ហើយ អស់ទាំងនគរនឹងចំណុះទ្រង់ ទ្រង់នឹងលោះជីវិតគេ
ឱ្យរួចពីការ សង្កត់សង្កិននិងការច្រឡោត ទ្រង់នឹងគង់នៅ។
មនុស្សទាំងឡាយនឹងអធិដ្ឋានឱ្យទ្រង់ជានិច្ច ហើយនឹងថ្វាយពរដល់
ទ្រង់ជាដរាបរាល់ថ្ងៃ នាមទ្រង់នឹងស្ថិតស្ថេរនៅជាដរាប
គឺនឹងមាននៅអស់អំឡុងដែលនៅមានព្រះអាទិត្យភ្លឺតទៅ
ហើយមនុស្សទាំងឡាយនឹងបានពរដោយសារទ្រង់អស់ទាំងសាសន៍
នឹងហៅទ្រង់ថា ព្រះអង្គដ៏មានពរ។

ព្រះអម្ចាស់ មានបន្ទូលទៅកាន់ដាវីឌ **ក្រោយពីឯង ស្លាប់ អញនឹងប្រគល់ឱ្យនគររបស់ឯងទៅកូនរបស់ឯង វានឹងសង់វិហារមួយ។ ដែលគេនឹងថ្វាយបង្គំអញ ហើយអញធ្វើឱ្យនគររបស់វាគង់វង្សជារៀងរហូត។**



សាំយូអែលទី២, ៧:១២-១៦, ទំនុកដំកើង ២២:១៤-១៨, ៧២:១-២០



បន្ទាប់ពីស្ដេច ដាវីឌ សុគតកូនប្រុសរបស់ទ្រង់ សាឡូម៉ូនបានឡើង
សោយរាជ្យ(ឆ្នាំ៩៧១មុន គ.ស.)សាឡូម៉ូនបានសាងសង់វិហារដែល
ព្រះអម្ចាស់បានផ្ដល់ប្លង់ដល់ ស្ដេចដាវីឌ (ឆ្នាំ៩៦៦មុន គ.ស. )
ដើម្បី ជំនួសវិហារបណ្ដោះអាសន្ន ដែលគេប្រើនៅវាលរហោស្ថាន។
ពួកមនុស្សនៃអ៊ីស្រាអែលបានចំរើនឡើងខ្លាំងជាងមុនទៅទៀត។
ព្រះអម្ចាស់ ពិតជាបានបំពេញកិច្ចសន្យារបស់ទ្រង់ ដើម្បីនាំពួកគេ
ចូលទៅកាន់ទឹកដីហើយប្រទានពរពួកគេនៅទីនោះ។



ប៉ុន្តែមានកិច្ចសន្យាមួយដែលព្រះមិនទាន់បំពេញនៅឡើយ គឺការយាងមកនៃអ្នកសង្គ្រោះ ដែលនឹងបំផ្លាញកិច្ចការរបស់អារក្សសាតាំង ។ ពួកមនុស្សនៅតែប្រព្រឹត្តអំពើបាប ហើយគេនៅតែថ្វាយឈាមសត្វ ដើម្បីលុបលាងបាប ។ ប៉ុន្តែពួកគេបានថ្លែងអំណរគុណ ដែលព្រះអម្ចាស់ បានផ្តល់ឱ្យពួកគេនូវផ្លូវមួយ ដើម្បីគ្របបាំងអំពើបាបរបស់គេ រហូតដល់ពេលកំណត់អ្នកសង្គ្រោះនឹងយាងមក ហើយលុបអំពើបាបរបស់ពួកគេចេញរហូត ។

ប្រជាជនហេព្រើរបានមកវិហារ ដើម្បីស្តាប់ការ
បង្រៀនពីព្រះគម្ពីរបរិសុទ្ធ ជាពិសេសពួកគេរីករាយ
នូវបទទំនាយនៃអ្នកសង្គ្រោះដែលនឹងយាងមក ។




ដាវីឌ
បានទាយជាច្រើនអំពីអ្នកសង្គ្រោះដែលនឹងយាងមក
ព្រះយេហូវ៉ា
ទ្រង់មានបន្ទូលដល់ព្រះអម្ចាស់នៃទូលបង្គំថា
ចូរឱ្យឯងអង្គុយនៅខាងស្តាំអញ
ទាល់តែអញដាក់ពួកខ្មាំង សត្រូវឯង
ឱ្យធ្វើជាកំណល់កល់ជើងឯង ។
ទំនុកដំកើង ១១០:១ ឱព្រះអង្គអើយ




បល្ល័ង្កទ្រង់នៅស្ថិតស្ថេរអស់កល្បជានិច្ច
រៀងរាបតទៅ
ឯព្រះដំបងពេជ្ររបស់រាជ្យទ្រង់នោះជាដំបង
សុចរិត ទ្រង់បានស្រឡាញ់សេចក្តីសុចរិត
ហើយស្អប់ទុច្ចរិត ហេតុនោះបានជាព្រះ
គឺជាព្រះនៃទ្រង់ បានចាក់ប្រេងតាំងទ្រង់
ជាប្រេងនៃសេចក្តីត្រេកអរសាទរ
លើសជាងពួកសំលាញ់នៃទ្រង់ ។ ទំនុកដំកើង
៤៥:៦-៧

# បទទំនាយទៀតពីអ្នក
# សង្គ្រោះដែលនឹងយាងមក




ទូលបង្គំត្រូវច្រួចចេញដូចជាទឹក
ហើយអស់ទាំងឆ្អឹង
នៃទូលបង្គំសណ្តកចេញពីគ្នា
ចិត្តទូលបង្គំទុកដូចជា
ក្រមួនដែលរលាយនៅក្នុងខ្លួនហើយ
កំលាំងទូលបង្គំ
ហួតខ្សោះទៅដូចជាអំបែងឆ្នាំង
អណ្តាតទូលបង្គំជាប់ នៅក្រអូមមាត់
ទ្រង់បាននាំទូលបង្គំចុះទៅក្នុងធូលី
នៃសេចក្តីស្លាប់
ហើយមានពួកមនុស្សអាក្រក់ដើរ
ក្រវែលជុំវិញទូលបង្គំ
គេបានចាក់ទំលុះដៃជើង នៃទូលបង្គំ
គេយកសំលៀកបំពាក់ទូលបង្គំចែកគ្នា
ឯអាវវែងរបស់ទូលបង្គំ
គេក៏ធ្វើឆ្នោតចាប់យក ។
តមនុកដមកើង ២២:១៤-១៨


សាឡូម៉ូន បានសោយរាជ្យជាយូរអង្វែង ហើយមានការរីកចំរើនជាច្រើន
ប៉ុន្តែបន្ទាប់ពីទ្រង់សុគត នគរបានចែកជាពីរ គឺខាងជើងនិងខាងត្បូង ។
ភាគខាងជើងបានបែកចេញ ហើយបានតែងតាំងមនុស្សអាក្រក់ម្នាក់ឈ្មោះ
យេរ៉ូបោម ធ្វើជាស្តេចរបស់ពួកគេ ( ឆ្នាំ៩៣១មុន គ.ស. )
នេះជាព្រះដែលបាននាំឯងចេញពីអេស៊ីព្ទ
ហើយនេះជាសង្ឃរបស់ទ្រង់ ។




ពង្សាវតាក្សត្រទី១, ១២:២០,២៨-២៩, ទំនុកដំកើង ២:៧, ១២, ២២:៦, ១៤-១៨, ៤០:៨, ៧៨:២, ៨៩:៦-៧, ៨៩:២៦-២៧, ១១០:១, ៤, ១៣២:១១


នគរភាគខាងជើងឆ្ងាយពីវិហារដែលនៅយេរូសាឡិម ដូច្នេះពួកគេសង់កន្លែងផ្ទាល់របស់ពួកគេ សម្រាប់ថ្វាយបង្គំរូបចម្លាក់គោដែលធ្វើពីមាស ។
មានផ្លូវជាច្រើនទៅព្រះអម្ចាស់ មនុស្សខ្លះ ហៅទ្រង់ថា យេហូវ៉ា ខ្លះហៅថា អាឡ្ឡា ខ្លះហៅ កេម៉ូស ប៉ុន្តែពួកយើងហៅទ្រង់ថា បាល ។
ប៉ុន្តែអ្វីអំពីព្រះគម្ពីរបរិសុទ្ធ ដែលព្រះបានឱ្យហោរា របស់ទ្រង់ ? ព្រះគម្ពីរបរិសុទ្ធបង្គាប់យើងថា កុំឱ្យមាន ព្រះណាផ្សេង ។ ព្រះគម្ពីរចែងថា មានតែព្រះមួយ ហើយមានតែផ្លូវមួយទៅទ្រង់ ។


តើឯងគិតថា ព្រះមាន ព្រះទ័យចង្អៀតឬ?
អញនឹងឈប់ស្ដាប់ការនេះ ឥឡូវនេះ
ការថ្វាយបង្គំព្រះបាលគឺជាសាសនាជាតិនៃទឹកដីនេះ
អ្នកដែលមិនជឿនឹងត្រូវសម្លាប់ចោល ។

នៅពេលសង្ឃបានជ្រើសរើសរូបចម្លាក់គោឈ្មោលដើម្បីថ្វាយបង្គំ គេមិនបានដឹងថា
ពួកគេបានជ្រើសរើសរូបចម្លាក់ លូស៊ីហ្វឺ មុនមានបាបវាជាចេរូប៊ីនរបស់ព្រះ។
ពួកគេកំពុងថ្វាយបង្គំអារក្សសាតាំង ហើយវាសប្បាយចិត្តណាស់
ពីព្រោះវាបានបង្វែរចិត្តមនុស្សឱ្យឃ្លាតឆ្ងាយពីសេចក្ដីសន្យារបស់ព្រះអំពីអ្នកសង្គ្រោះដែលនឹងយាងមក។




ឱ !
ព្រះបាល សូម
ទទួលការបូជាពីដៃដ៏ទាប
របស់ពួកទូលបង្គំ ។
ពង្សាវតារក្សត្រទី១,
១២:២៨, ១៣:១-២,
យេរេមា ៤៤:១៧-២៥
មានពរហើយម្ចាស់ក្សត្រិយ៍
នៃឋានសួគ៌ជាមាតានៃព្រះបាល
អើយ សូមស្តាប់ការអធិដ្ឋានហើយ
នឹងអត់ទោសបាបពួកទូលបង្គំ ។


តើឯងកំពុងធ្វើអ្វី
នៅ កន្លែងស័ក្ដសិទ្ធិនេះ ?
នៅក្នុងព្រះនាមព្រះយេហូវ៉ា
ដែលអ្នកបាន បែកចេញ ចូរស្ដាប់បន្ទូលនៃព្រះ ។
កូនម្នាក់នឹងកើតពីពូជដាវីឌ ឈ្មោះរបស់កូននោះគឺ យ៉ូសៀស ។
ហើយនៅលើអាសនៈនេះ គាត់នឹងដុតសង្ឃរបស់ព្រះបាល ។
ហើយអ្នកសង្គ្រោះនឹងកើត មកតាមពូជនៃកូននេះដែរ ។


តើអ្នកនិយាយដូចនេះយ៉ាងម៉េច? គ្មានអ្នកណាដែលអាចប្រាប់ពីអនាគតបានក្រៅពីពួកព្រះឡើយ ។
ដោយសារព្រះបន្ទូល របស់ព្រះ ខ្ញុំប្រាប់អ្នកថា ឆ្អឹងនៃសង្ឃ និមួយៗនេះ យ៉ូសៀសនឹងដុតលើ អាសនៈនេះ ។


ព្រះនឹងប្រទានទីសំគាល់មួយ
ដែលខ្ញុំនិយាយ ពីបន្ទូលទ្រង់។
នៅថ្ងៃនេះអាសនៈដ៏ស្អាតដែលអ្នកបានធ្វើ
ដើម្បីថ្វាយយញ្ញបូជាដល់រូបព្រះដែលគនេះ
នឹងបែកជាពីរ
ហើយផេះដែលនៅក្នុងនឹងបានធ្លាក់ចេញ។


ហាស់ហា៎... ចូរស្តាប់អាចង្រៃដែលជឿ យេហូវ៉ាកំពុងតែព្រុស ។ វាគិតថាវាត្រូវ ហើយអ្នកផ្សេងៗទៀតជាអ្នកខុស ។
ចាប់វាសម្លាប់ចោលទៅ ! យ៉ាងម៉េចបានជាឯងមានចិត្តក្លាហានហ៊ានប្រឆាំងនឹងសាសនារបស់អ្នកផ្សេង !

នៅពេលស្ដេចយេរ៉ូបោមចង្អុលទៅ ហោរា
ព្រះអម្ចាស់ធ្វើឱ្យព្រះហស្ត របស់ស្ដេចស្វិត។




ព្រះជាម្ចាស់អើយ សូមឱ្យពួកគេ
ស្គាល់ទ្រង់នៅថ្ងៃនេះ។ សូមព្យាបាល
ព្រះហស្ដរបស់ស្ដេចយេរ៉ូបោម។




ពង្សាវតារក្សត្រទី១, ១៣:២-៦


នុលល
គ្រាំង...!
អឺយា...!
ទេ...!
ព្រះយេហូវ៉ា
អីក៏ឆាប់ម្ល៉េះ ?


អ្នកពិតជាអ្នកសំណប់របស់ព្រះអម្ចាស់ ! ហោរានៃព្រះបាលមិនដែលធ្វើដូច
នេះទេ។ មកតាមខ្ញុំ យើងនឹងទៅបរិភោគអាហារជាមួយគ្នា ហើយបន្ទាប់មកខ្ញុំនឹង
ឱ្យទ្រព្យសម្បត្តិនឹងផ្តល់កិត្តិយសចំពោះការបំរើព្រះដ៏ល្អអស្ចារ្យនៅថ្ងៃនេះ។
ទេ ទូលបង្គំមិនអាចទៅជាមួយទ្រង់ទេ។ ព្រះមានបន្ទូល
ប្រាប់ថា មិនឱ្យហូបអាហារឬផឹកទឹកនៅពេលទូលបង្គំបាននៅ អ៊ីស្រាអែល
ហើយទូលបង្គំមិនអាចត្រឡប់ទៅវិញតាមផ្លូវ ដែលទូលបង្គំបានមកនោះដែរ។


ពង្សាវតារក្សត្រទី១, ១៣:៥, ៧-៩
វាបានបំផ្លាញសាសនារបស់ខ្ញុំ គ្មានសល់អ្វីសោះ ។
ប៉ុន្តែ អ្នកបាននិយាយថា ឆ្អឹងរបស់សម្តេចសង្ឃត្រូវបានបូជានៅលើអាសនៈនេះ ។ ប៉ុន្តែអាសនៈនេះបានខូចអស់ ហើយគ្មានអ្នកណាស្លាប់ទេ ។
នេះជាបន្ទូលរបស់ព្រះ មិនមែនរបស់ទូលបង្គំទេ ។



ដូចដែលព្រះបានបង្គាប់ ហោរារបស់ព្រះត្រឡប់ទៅវិញតាមផ្លូវផ្សេង
គាត់មិនបានផឹកទឹកឬហូបអាហារពីរថ្ងៃហើយ គាត់ស្រេកទឹកនិងហេវ
យ៉ាងខ្លាំង។ មានយុវជនពីរនាក់ដែលបានថ្វាយបង្គំរូបចម្លាក់គោធ្វើពី
មាសនៅថ្ងៃនោះដែរ គេបានឃ្លាំមើលគាត់នឹងដើរទៅផ្លូវណា។


ពុក ខ្ញុំមិនជឿ បើខ្ញុំមិន ឃើញដោយផ្ទាល់ភ្នែក របស់ខ្ញុំ។ វាដូចហោរា របស់អ៊ីស្រាអែលនៅ ជំនាន់មុនមែន !
លឿនឡើង ! ដាក់កែប នៅលើខ្នងលា ! ពុកត្រូវការ ទៅរកគាត់ !
ពុក តើពុកគិតថាអ្វីដែលគាត់ បាននិយាយពិតឬ ? តើព្រះយេហូវ៉ា គឺជាព្រះមួយអង្គដែលមានព្រះជន្មគង់ នៅឬ ? តើរូបចម្លាក់របស់យើងគ្រាន់ តែជាឈើហើយនឹងមាសឬ ?



គាត់បានឃើញហោរារបស់
ព្រះយេហូវ៉ា អង្គុយនៅក្រោមដើមឈើ
គាត់ចង់ទៅជិតអ្នកដែលមានអំណាចខ្លាំងដូចនេះ។
ពីមុនគាត់បានធ្វើ ជាហោរារបស់ ព្រះយេហូវ៉ាដែរ
ប៉ុន្តែនៅពេលនគរបានចែកជាពីរ គាត់
បានថ្វាយបង្គំរូបចម្លាក់តាមអ្នកស្រុករបស់គាត់
គាត់មានហេតុផលថា
"សាសនាទាំងអស់គឺប្រហាក់ប្រហែលគ្នា"។


អ្នកពិតជាអ្នកសំណប់របស់ព្រះមកពីយូដា
អ្នកមើលដូចជាអស់កំលាំងណាស់ ។ សូមមកផ្ទះខ្ញុំ
ខ្ញុំនឹងទទួលអ្នកឱ្យបរិភោគអាហារ ។
ខ្ញុំមិនអាចទេ
ព្រះបានបង្គាប់ខ្ញុំមិនឱ្យហូបអាហារ
ឬផឹកនៅទីនេះទេ ។


អរគុណព្រះជាម្ចាស់ ខ្ញុំស្រេកទឹកខ្លាំង ។
ប៉ុន្តែខ្ញុំជាហោរាដូចអ្នកដែរ ហើយព្រឹកមិញ ទេវតារបស់ព្រះ យេហូវ៉ាបានប្រាប់ខ្ញុំថា ឱ្យនាំអ្នកទៅ ផ្ទះរបស់ខ្ញុំ ដើម្បីបរិភោគអាហារ ។


អាហារនោះឆ្ងាញ់ណាស់ ប៉ុន្តែ ខ្ញុំត្រូវត្រឡប់ទៅយូដាវិញ។
ព្រះយេហូវ៉ាមានបន្ទូលថា “ពីព្រោះឯងមិនស្ដាប់ការបង្គាប់អញ ហើយឯងបានហូបនិងបានផឹកនៅទីនេះ សាកសពរបស់ឯងមិនត្រឡប់ទៅយូដាវិញ ដើម្បីបញ្ចុះសពនៅទីកន្លែងក្រុមគ្រួសាររបស់ឯងទេ”។


ប៉ា ប៉ាកំពុងទាយ ។ តើព្រះ
មានបន្ទូលមកប៉ាទេ ?
មែនហើយកូនប្រុស របស់ប៉ា
ជាច្រើនឆ្នាំមក ហើយ នេះជាលើកទីមួយ
ដែលប៉ាបានទាយ ។


ពង្សាវតារក្សត្រទី១,
១៣:១០-២២
ប៉ា មានន័យថា
គាត់នឹងស្លាប់ឬ ?
គាត់ពិតនឹងស្លាប់មែន
ហើយវាជាកំហុសរបស់ប៉ា។


ហោរាបានចាកចេញទៅដោយពិបាកចិត្ត ដោយដឹងថា ព្រះតែងតែបំពេញ បន្ទូលរបស់ទ្រង់រហូត ។ គាត់ដឹងខ្លួនថា គាត់នឹងស្លាប់ តែគាត់មិននឹក ស្មានថា ការនេះកើតឡើងយ៉ាងឆាប់រហ័សដោយរបៀបនេះ ។
អឺយា...!


នោះគឺជា ហោរា មកពីយូដា!
វាគួរឱ្យចំឡែកមែន ដែលសត្វតោនិងសត្វលាអង្គុយជិតគ្នា ដូចជាពួកវាកំពុងតែយាមសាកសព ។
ខ្ញុំមិនដែលបានឃើញអ្វីដូចនេះទេ ។ តោបានសម្លាប់គាត់ ហើយអង្គុយនៅទីនោះ ប៉ុន្តែវាមិនស៊ីគាត់ទេ ។


ហោរា
ក្លែងក្លាយបានយកសាកសពអ្នកសំណប់របស់ព្រះ
ហើយបានបញ្ចុះនៅក្នុងផ្នូររបស់គាត់ផ្ទាល់
ក្នុងចំណោមផ្នូរហោរា
របស់ព្រះបាលជិតកន្លែងដែលព្រះបានបំផ្លាញអាសនៈ ។
ព្រះបានសម្លាប់គាត់ ដោយ គាត់មិនស្តាប់បង្គាប់ទ្រង់ ។ តាមពិតអ្វីៗដែលគាត់បានទាយនឹងកើតឡើងដូច្នោះមែន ។



គេបានបញ្ចុះសពអ្នកសំណប់របស់ព្រះ
ហើយមិនយូរប៉ុន្មានមនុស្ស ទាំងអស់បានភ្លេច
ប៉ុន្តែនៅសល់មួយចំនួនបានចាំ ។ ពួកគេបានជួសជុល
អាសនៈ ហើយជិត៣00ឆ្នាំក្រោយមក
ពួកគេនៅតែប្រើវាដើម្បីថ្វាយ
យញ្ញបូជាទៅព្រះបាល
ប៉ុន្តែគ្មានអ្នកណាដែលធ្លាប់បានដុតឆ្អឹងសង្ឃរបស់
ព្រះបាលនៅលើអាសនៈ
ដូចដែលអ្នកសំណប់របស់ព្រះបានទាយនោះទេ ។

ពង្សាវតារក្សត្រទី១, ១៣:២៣-៣១, ពង្សាវតារក្សត្រទី២,
២១:២៤, ២២:៨-១១, ២៣:១-៣

៣០០ឆ្នាំក្រោយមក ស្ដេចមួយអង្គមានឈ្មោះថា យ៉ូសៀសបានគ្រងរាជ្យបល្ល័ង្កនៅនគរយូដាប៉ែកខាងត្បូង (៦៤០ឆ្នាំមុន គ.ស.) ។ ស្ដេចបានឡើងទៅព្រះវិហារហើយរកឃើញព្រះគម្ពីរចំលង ។ វាបានធ្វើឱ្យប៉ះពាល់ព្រះទ័យស្ដេចនៅពេលដឹងថា ប្រជារាស្ត្របានបំភ្លេចព្រះដែលមានព្រះជន្មគង់នៅហើយគោរពរូបចម្លាក់ ។ ដូច្នេះស្ដេចបានបង្គាប់ចាស់ទុំ ហោរា សម្ដេចសង្ឃ ហើយអ្នកស្រុកយេរូសាឡិមទាំងអស់មកជួបជុំគ្នាស្ដាប់ការអានព្រះគម្ពីរ ។



មនុស្សទាំងអស់បានខ្មាសនូវអំពើបាបរបស់ពួកគេ ហើយបានយល់ព្រមស្ដាប់បង្គាប់ទាំងអស់ដែលមាននៅក្នុងព្រះគម្ពីរ ។


ព្រះមាតាដ៏បរិសុទ្ធ
អើយជួយយើងផង !
ប្រជារាស្ត្របានស្តាប់បង្គាប់ក្រឹត្យវិន័យរបស់ព្រះ
ហើយបានបំផ្លាញរូបចម្លាក់ទាំងអស់នៅក្នុងទឹកដី ។
ពួកគេបាន សម្លាប់សម្តេចសង្ឃទាំងនោះ
ដែលដុតធូបថ្វាយទៅព្រះអាទិត្យ ព្រះច័ន្ទ
ភពផ្សេងៗនិងម្ចាស់ក្សត្រិយនៃឋានសួគ៌ ។


ក្រឹត្យវិន័យដែលព្រះប្រទានឱ្យតាមរយៈលោក ម៉ូសេ
មិនឱ្យរួមរ័កភេទដូចគ្នា ដូច្នេះអ្នកដែលរួមភេទខុស
ពីធម្មតាត្រូវបណ្តេញចេញពីទឹកដី។
អាពួកចំកួតគ្មានមេត្តា!



ពង្សាវតារក្សត្រទី២, ២៣:៥, ៧, ១០


ពួកគេបានបំផ្លាញអាសនៈ និង
បានបំផ្លាញរូបចម្លាក់ ហើយនិងបាន
កាប់ដើមឈើចោលក៏កិនទាំងអស់
ឱ្យម៉ដ្ឋទៅជាម្សៅ ។
ស្ដេចយ៉ូសៀស បានឡើងទៅបំផ្លាញ
អាសនៈ ចំកន្លែងដែលហោរាបានឈរ
ទល់មុខយេរ៉ូបោមជាស្ដេចទី១នៃនគរ
ប៉ែកខាងជើងកាលពី៣០០ឆ្នាំមុន ។
មានព្រះតែមួយអង្គ ហើយ
មិនត្រូវថ្វាយបង្គំទ្រង់ដោយរូបចម្លាក់ទេ ។
សម្ដេចសង្ឃក្លែងក្លាយនេះបាននាំឱ្យមនុស្ស
ឃ្លាតឆ្ងាយពីព្រះយេហូវ៉ា !


អ្នកត្រូវតែស្លាប់!
អាសនៈបានបែកម្តងទៀត
ហើយផេះបានធ្លាក់ចេញ។


សម្ដេចសង្ឃក្លែងក្លាយទាំងអស់បាន
សម្លាប់ចោល និងសពរបស់ពួកគេបាន
ដុតនៅលើអាសនៈដែលបែកបាក់នេះ ។
នៅជិតនោះមានទីកន្លែងបញ្ចុះសពសង្ឃក្លែងក្លាយ
របស់ព្រះបាល ។ ដើម្បីកុំឱ្យមនុស្សគោរពឬសែន
ផ្នូររបស់ពួកគេ យ៉ូសៀសបានជីកយកឆ្អឹងរបស់
ពួកគេឡើង ហើយដុតចោលលើអាសនៈ ។
ពង្សាវតារក្សត្រទី២, ២៣:១៥-១៦


ដុតឆ្អឹង ទាំងអស់។
ប៉ុន្តែព្រះអង្គ នេះគឺជាផ្នូរអ្នកសំណប់ របស់ព្រះ ដែលមកពីយូដាជិត៣០០ ឆ្នាំមុន ហើយនឹងបានទាយអំពីថ្ងៃនេះ។ គាត់បាននិយាយថា មាន មនុស្សម្នាក់ឈ្មោះ យ៉ូសៀស គឺទ្រង់ ហ្នឹងហើយ ដែលនឹងមកហើយធ្វើអ្វីៗ ទាំងអស់ ដូចទ្រង់បានធ្វើនៅថ្ងៃនេះ។


អញ្ជឹងទុកឆ្អឹងគាត់នៅទីនេះ ដុតអាផ្សេង ។ ការគោរពរូបចម្លាក់នេះត្រូវឈប់ ទើបព្រះប្រទានពរឱ្យយើង ។
ដូច្នេះបទទំនាយមានចំណាស់៣០០ឆ្នាំត្រូវបានបំពេញហើយ ដូចអ្នកសំណប់នៃព្រះធ្លាប់បានទាយ ។


ឥឡូវនេះការគោរពរូបចម្លាក់បានចប់ហើយ ស្ដេច យ៉ូសៀស បានបង្គាប់មនុស្សទាំងអស់ឱ្យគោរពបុណ្យរំលងដោយការចងចាំ ពីព្រះយេហូវ៉ា បាននាំព្ឋយុកោរបស់ពួកគេចេញពីអេស៊ីព្ទ ហើយនឹងបានឱ្យទឹកដីនេះដល់ពួកគេ។
មានពរហើយ ព្រះអម្ចាស់ របស់យើង ស្ដេចនៃសកលលោក ដែលប្រទាននំប៉័ងចេញពីដី។




បន្ទាប់មកឪពុករបស់ពួកគេបានប្រាប់ពីប្រវត្តិរឿងដ៏យូរមកហើយ ។
នូវរបៀប ដែលព្រះអម្ចាស់រំដោះពួកគេចេញពីទាសភាពនៃអេស៊ីព្ទ
ហើយបានឱ្យ ក្រឹត្យវិន័យដល់ពួកគេ និងរោងថ្វាយបង្គំបណ្ដោះអាសន្ន ។ គាត់ប្រាប់ពួកគេអំពី
ឈាមដែលលាបលើគ្រោងទ្វារត្រូវបានសង្គ្រោះកូនប្រុសច្បងរួចពីមេបំផ្លាញ
របស់ព្រះ ។ នេះគឺជាបុណ្យរំលងដែលល្អជាងគេ ។



## ជំពូក ៦

# អេលីយ៉ា



មានបុត្រាទន់ខ្សោយមួយអង្គព្រះនាម
អ័ហាប់ សោយរាជ្យនៅអ៊ីស្រាអែល
ដែលជានគរភាគខាងជើង( ឆ្នាំ៩១៨មុន គ.ស.
) ។ ទ្រង់បានគង់នៅ សាម៉ារីដែលនៅជិតស៊ីដូន។
ពួកស៊ីដូនបានថ្វាយបង្គំព្រះបាល
អ័ហាប់បាន អភិសេកជាមួយយេសិបិល
ជាបុត្រីរបស់ស្តេចស៊ីដូនព្រះនាម អេតបាល។


ម្ចាស់ក្សត្រិយ៍យេសិបិល
បាន ល្បីល្បាញដោយការខំប្រឹង
ប្រតិបត្តិតាមសាសនាយ៉ាង
ខ្លាំង ។ ហើយបានមើលងាយព្រះ
អ៊ីស្រាអែលខ្លាំងណាស់ ព្រះនាង
បានលើកដំកើងការថ្វាយបង្គំព្រះ
បាលពេញទាំងទឹកដីអ៊ីស្រាអែល ។


ទៅរកហោរារបស់ យេហូវ៉ា ហើយសម្លាប់ពួក វាទាំងអស់ ។ ព្រះបាលនឹង ធ្វើជាព្រះរបស់យើង ។
ស្តេចមានឧកញ៉ាម្នាក់ឈ្មោះ អូបាឌា ដែលមានជំនឿលើព្រះយេហូវ៉ា ។
ខ្ញុំត្រូវការរកហោរារបស់ ព្រះនិងប្រាប់ពួកគេមុន ។




ពង្សាវតារក្សត្រទី១, ១៦:២៨, ៣១, ១៨:៤


ប៉ុន្តែមានហោរាម្នាក់នៃ
ព្រះអម្ចាស់ដែលមិនបាន
លាក់ខ្លួនគឺ អេលីយ៉ា ។


ព្រះអង្គអ័ហាប់ !
ដោយសារទ្រង់ចោល ព្រះអម្ចាស់នៃព្ធយុកោរបស់ទ្រង់
ហើយនឹងដើរ តាមមហេសីរបស់ទ្រង់
ក្នុងការប្រព្រឹត្តអំពើបាប ព្រះយេហូវ៉ាមានបន្ទូលថា នោះនឹងគ្មានភ្លៀង
ឬទឹកសន្សើមនៅលើដីអ៊ីស្រាអែលទៀត រហូតដល់ទូលបង្គាប់ឱ្យមាន។


ហាស់ហាំ !តើឯងគិតថាឯងជាហោរាមែនឬអី ? អញមានហោរា ១000នាក់ ហើយគេមិននិយាយអ្វីអំពីភាពរាំងស្ងួតទេ ។ យើងមានភ្លៀងគ្រប់គ្រាន់ប៉ុន្មានឆ្នាំមុននេះ ចេញពីផ្លូវ អញអាជំនឿជ្រុលនិយមក្លែងក្លាយ ។

នៅពេលគ្រោះទុរភិក្សកាន់តែខ្លាំងទៅៗ មនុស្សចាប់ផ្តើមខ្វះ អាហារ។
ហោរាក្លែងក្លាយបានទូលអង្វររកព្រះបាល ប៉ុន្តែព្រះ បាលមិនអាចឆ្លើយតប។
ភាពរាំងស្ងួតកំពុងតែបន្តដោយគ្មាន ភ្លៀងឬសន្សើមមួយដំណក់។
ព្រះបញ្ជូនអេលីយ៉ាឱ្យទៅផ្ទះ ស្រីមេម៉ាយ ព្រះមានបន្ទូលប្រាប់អេលីយ៉ាថា
នាងនឹងផ្តល់ បន្ទប់ស្នាក់នៅនិងម្ហូបអាហាររហូតដល់ផុតភាពរាំងស្ងួត។




ខ្ញុំសុំនំប៉័ងនិងទឹកបន្តិចបន្តួចហូបផងបានឬទេ ?
ខ្ញុំប្រាប់អ៊ំពិតថា ខ្ញុំនៅសល់ម្សៅនិងប្រេងដើម្បីធ្វើនំប៉័ងតូចពីរដុំ ។ ខ្ញុំហៀបនឹងចំអិនសម្រាប់ខ្ញុំនិងកូនយើងនឹងបរិភោគរួចហើយដេករងចាំស្លាប់ ។ គ្មានសង្ឃឹមទៀតទេ ព្រះដាក់ទោសសម្រាប់ បាបយើង ។


កុំភ័យ ព្រះនឹង ថែរក្សាក្មួយ ។
ចំអិននំបុ័ងដែលក្មួយបាននិយាយ យកវាមកឱ្យខ្ញុំមុន បន្ទាប់មកក្មួយនិងកូន អាចហូបបាន ។សម្រាប់ការនេះព្រះយេហូវ៉ា នៃអ៊ីស្រាអែលមានបន្ទូលថា **ធុងម្សៅ និងក្រឡប្រេងរបស់ក្មួយមិនចេះអស់រហូត ដល់ថ្ងៃព្រះប្រទានទឹកភ្លៀងមកលើ ទឹកដីអ៊ីស្រាអែលវិញ ។**




ពង្សាវតារក្សត្រទី១, ១៧:១, ១០-១៦


យើងចាក់វាមិនអស់
មានប្រេងចេញមករហូត!
វាគឺជាការអស្ចារ្យ!
ព្រះអង្គ ពិតជាល្អមែន។
ពីរឆ្នាំទៅមុខទៀត អ្នក ទាំងបីនោះ
ហូបនំប៉ុងធ្វើពី ម្សៅនៅក្នុងធុងដដែលនោះ។


ថ្ងៃមួយអេលីយ៉ា ត្រឡប់មកបន្ទប់របស់គាត់វិញ នៅក្នុងផ្ទះស្រីមេម៉ាយ ហើយគាត់បានឃើញកូនប្រុសរបស់នាងបានស្លាប់ ។
វាបានកើត ជំងឺគ្រុនក្តៅ ហើយស្លាប់ ។


តើខ្ញុំបានធ្វើអ្វីខុសចំពោះអ៊ំ ? តើអ៊ំមកផ្ទះខ្ញុំដើម្បីរំឭកអំពីបាបខ្ញុំ ហើយឱ្យព្រះសម្លាប់កូនខ្ញុំឬ ?
នោះនៅមានព្រះគង់នៅអ៊ីស្រាអែល ដែលមានអំណាចអាចជួយបាន ។


ឱ! ព្រះយេហូវ៉ា សូម អនុញ្ញាតឱ្យព្រលឹងក្មេងនេះវិលត្រឡប់ មករូបកាយរបស់គេវិញ។


ទ្រង់ជ្រាបការអធិដ្ឋានរបស់
អេលីយ៉ា ហើយបញ្ជូនព្រលឹង
វិញ្ញាណរបស់ក្មេងប្រុសចូលទៅ
ក្នុងរូបកាយដែលស្លាប់វិញ ។




ពង្សាវតារក្សត្រទី១, ១៧:១៧-២៤

គ្រោះទុរភិក្សបានបន្តអស់រយៈពេល៣ឆ្នាំ ។ មនុស្សទាំងអស់កំពុងអត់អាហារ ហើយ
មានរូបកាយស្គមស្គាំង ប៉ុន្តែពួកគេនៅតែបន្តថ្វាយបង្គំព្រះបាលជាព្រះក្លែងក្លាយ ។



ស្ដេចអ័ហាប់ និង ក្សត្រិយ៍យេសិបិល
បានបន្ទោសអេលីយ៉ា ចំពោះគ្រោះទុរភិក្ស
ទ្រង់បានបញ្ជូនពួកទាហានឱ្យទៅពេញទឹកដី
ហើយចូលទៅក្នុងប្រទេសអ្នកជិតខាងដើម្បីរកអេលីយ៉ា ។
ទ្រង់បានបញ្ជាទាហានឱ្យសម្លាប់គាត់នៅពេលរកឃើញ ។




ព្រះអង្គតើទ្រង់កំពុង ស្វែងរកទូលបង្គំឬ ?
តើឯងជាអ្នកធ្វើឱ្យ អ៊ីស្រាអែលមានវេទនា ដោយគ្រោះទុរភិក្សឬ ?
គឺទ្រង់និងវង្សានុវង្ស បិតាទ្រង់ទេតើ ដែលធ្វើឱ្យមាន វេទនាដល់អ៊ីស្រាអែលព្រមទាំង រូបចម្លាក់របស់ទ្រង់ ។ សូមទ្រង់ អនុញ្ញាតឱ្យមានការប្រកួតរវាង ព្រះ យេហូវ៉ា និង ព្រះបាល ។ សូមហៅ ហោរា៨៥០នាក់របស់ទ្រង់មក ជួបទូលបង្គំនៅភ្នំកើមែល ។
ឯងនិយាយថាប្រកួតឬ? គួរឱ្យចាប់អារម្មណ៍ អញនឹង ជួបឯងនៅទីនោះ ។


បីបួនថ្ងៃក្រោយមកនៅភ្នំកើមែល ។
តើរយៈពេលប៉ុន្មានទៀតដែលអ្នកទាំងអស់គ្នាស្ទាក់ស្ទើរ នៅកណ្ដាលគំនិតពីរនេះ ? មានព្រះតែមួយអង្គ បើសិនយេហូវ៉ា គឺជាព្រះ ចូរថ្វាយបង្គំទ្រង់ចុះ បើសិនបាលជាព្រះ ចូរថ្វាយបង្គំ បាលចុះ ចូរសម្រេចចិត្តឱ្យច្បាស់ ។
ខ្ញុំហៅហោរាទាំងអស់របស់ព្រះបាល មកប្រកួតតទល់ជាមួយខ្ញុំ យើងនឹង ឃើញថា អង្គណាជាព្រះពិត ។


ពង្សាវតារក្សត្រទី១, ១៨:១, ៤, ១៧-២១
បាន ល្អ ការប្រកួតរវាងព្រះទាំងពីរ តើយើងគួរធ្វើយ៉ាងម៉េច ?


ពួកអ្នកសាងសង់អាសនៈមួយថ្វាយទៅព្រះបាល
ហើយខ្ញុំ នឹងសាងសង់មួយថ្វាយទៅព្រះយេហូវ៉ា ។ យើងនឹងដាក់អុស
នៅលើអាសនៈ ហើយយើងដាក់យញ្ញបូជានៅលើអុស
ប៉ុន្តែយើងមិនដុតភ្លើងទេ ។


ពួកអ្នកនឹងអធិដ្ឋានទៅ ព្រះបាល ហើយខ្ញុំអធិដ្ឋាន ទៅព្រះយេហូវ៉ា។
ព្រះមួយណាឆ្លើយតបដោយបញ្ជូនភ្លើងមកឆេះយញ្ញបូជា នោះ
ពិតជាព្រះមែន ហើយយើងទាំងអស់គ្នានឹងថ្វាយបង្គំតែទ្រង់។
ពួកអ្នកមានគ្នាច្រើនជាងខ្ញុំត្រូវធ្វើមុន។


ឱ ! ព្រះបាល សូមស្តាប់ ទូលបង្គំទាំងអស់គ្នា
នៅថ្ងៃនេះ ទូលបង្គំទាំងអស់គ្នាឧទ្ទិសយញ្ញ
បូជានេះក្នុងព្រះនាមដ៏ អស្ចារ្យរបស់ទ្រង់។


ឱ !
ព្រះបាលដ៏អស្ចារ្យ
ហើយខ្លាំងពូកែ ។
ឱ
! ម្ចាស់ក្សត្រិយ៍នៃ
ឋានសួគិ សូមយាងមកជួយ
ព្រះបាលនៅថ្ងៃនេះ ។


បើសិនបាលជាព្រះ
បាលមិនចាប់អារម្មណ៏ពួកអ្នកទេ។
ប្រហែលជាកំពុងជាប់រវល់ហើយស្តាប់ពួកអ្នកមិនឮ
ឬប្រហែលជាកំពុងធ្វើដំណើរ ឬកំពុងផ្ទំ។
អាកញ្ចាស់អេលីយ៉ា!
ឯងមិន អាចធ្វើអ្វីល្អជាងយើងទេ។
ពង្សាវតារក្សត្រទី១, ១៨:២២-២៧


មែនហើយ ! បាលកំពុង ផ្ទំលក់
ហើយអ្នកត្រូវតែស្រែក ឱ្យកាន់តែខ្លាំងជាងនេះ ដូច្នេះពួកអ្នក
អាចធ្វើឱ្យទ្រង់តើនឡើង ។
ពួកយើងមិនត្រូវចុះចាញ់ទេ
បើសិនយើងឆ្វូតខ្លួនបង្ហូរឈាម ព្រះ
បាលនឹងបានគាប់ព្រះហឫទ័យ ។


ហោរារបស់ព្រះបាលអស់សង្ឃឹម ហើយ ចាប់ផ្ដើមបោកខ្លួនទៅលើដី ឆូតដៃរបស់គេ ហើយស្រែកដើម្បីឱ្យព្រះបាលជួយពួកគេ ។
ឃ្រុ...!
យ៉ា...!
យ៉ា...អ៊ឺ...!
ឱ ! ព្រះបាល ទូលបង្គំថ្វាយឃោម ទៅទ្រង់ សូមស្ដាប់ទូលបង្គំផង! សូម បញ្ជូនភ្លើងមក ! សូមបង្ហាញអង្គទ្រង់ !


ហាស់ហាំ ! ដូចជាល្អមើល អស់រយៈពេល ៩ម៉ោងពួកអ្នកបានទូលអង្វរទៅបាល នោះបាលមិនឆ្លើយតប ។ បើសិនជាព្រះពិតនោះ បាលនឹងយកឱកាសនេះដើម្បីបង្ហាញថា បាលជាព្រះមែន ។
ឥឡូវនេះដល់វេនរបស់ខ្ញុំម្តង មកជិតនឹងមើលឱ្យច្បាស់នូវអ្វីដែលខ្ញុំធ្វើ ។
ឱ ! ព្រះបាល ហេតុអ្វី ទ្រង់មិនឆ្លើយតប ?
ពង្សាវតារក្សត្រទី១, ១៨:២៨-៣០


ហេតុអ្វីវាជីករណ្ដៅ ជ្រៅយ៉ាងនេះ ?
វាគ្រាន់តែធ្វើការ នេះ ដើម្បីពន្យាពេល សង្ឃឹមថាវានឹងងងឹត ។
ឯងនឹងចាប់ផ្ដើមអធិដ្ឋាននៅពេលណា ? នេះមិនមែនប្រកួតជីករណ្ដៅទេ ។


ខ្ញុំអត់មានគ្នាចូរពួកអ្នកជួយ យកទឹកបួនធុងចាក់វានៅលើយញ្ញបូជា ហើយនៅលើអុសដែរ ។
ទឹកមែនឬ ? បើអ្នកធ្វើឱ្យ សើម វាមិនអាចដុតឆេះទេ ។

ពង្សាវតារក្សត្រទី១,
១៨:៣២-៣៤




ហាស់ហា៏... តើមានអ្វីពិបាកចំពោះព្រះដែលមានព្រះជន្មគង់នៅឬ ? ចាក់ទឹកបួនធុងទៀត អ្នកនឹងដឹងថាមានព្រះមួយអង្គគង់នៅក្នុងប្រទេសអ៊ីស្រាអែល ហើយព្រះនាមទ្រង់គឺមិនមែនជាបាលទេ ។
ព្រះអង្គអ័ហាប់ នឹងកាត់ក្បាលវាចំពោះការនេះ ។


ថយក្រោយ
ថយឱ្យឆ្ងាយ
ថយទៅក្រោយទៀត។


ឱព្រះយេហូវ៉ា
ជាព្រះនៃ អ័ប្រាហាំ អ៊ីសាក
និងអ៊ីស្រាអែល ចូរឱ្យពួកគេដឹងនៅថ្ងៃនេះថា
ទ្រង់ជាព្រះពិត តែមួយ
ហើយឱ្យគេដឹងថាទូលបង្គំជាអ្នកបំរើរបស់ទ្រង់
ហើយ ទ្រង់បានបង្វែរចិត្តពួកគេឱ្យមករកទ្រង់វិញ។


ឈុល...!
អ៊ូយយ៉ា...!
ឱយ៉ា...!
ក្រាក...!
ពង្សាវតារក្សត្រទី១, ១៨:៣៥-៣៨


ព្រះនៃអ័ប្រាហាំ !
វាឆេះក្តៅ
យ៉ាងខ្លាំង!
ភ្លើងមកពីឋានសួគ៌!
ជួយផង!


ព្រះនៃអ័ប្រាហាំ និង អ៊ីសាក បានឆ្លើយតបដោយភ្លើង។
សូម្បីតែថ្មនិងដីក៏ឆេះដែរ !
តើនេះជាព្រះដូចម្ដេច ដែលគ្មានរូបរាង ហើយធ្វើការនេះបានដូច្នេះ ?



ពង្សាវតារក្សត្រទី១, ១៨:៣៨-៤០


សម្លាប់ពួកគេទាំង ៨៥០នាក់ចោលទៅ !
ប៉ុន្តែយើងមិនដឹង !
យកដាវសម្លាប់វាភ្លាម!
នៅថ្ងៃនោះហោរារបស់ព្រះបាលទាំងអស់ត្រូវបានសម្លាប់ ។


ឱ ព្រះអង្គ ទ្រង់ ត្រូវការសោយព្រះស្ងោយ ហើយ បន្ទាប់មកប្រញាប់យាងទៅដំណាក់ ។ ទូលបង្គំឮសំលេងភ្លៀងយ៉ាងធំ ។


បីឆ្នាំកន្លះមុន អេលីយ៉ា បានប្រាប់ស្ដេចអ័ហាប់ថា
វ៉ាមិនមានភ្លៀង ទៀតទេនៅក្នុងអ៊ីស្រាអែល
លុះត្រាតែអេលីយ៉ាបានបង្គាប់ឱ្យមាន ។
ដោយហោរារបស់ព្រះបាលបានស្លាប់
ហើយប្រជារាស្ត្រថ្វាយបង្គំ ព្រះដ៏ពិតវិញនោះ
អេលីយ៉ាបានបង្គាប់ឱ្យមានភ្លៀងធ្លាក់ ។


ភ្លៀងមួយមេយ៉ាងធំនឹងធ្វើឱ្យទឹកទន្លេឡើង
ហើយធ្វើឱ្យអាក់ខានដល់ពួកគេក្នុងការវិល
ត្រឡប់ទៅដំណាក់វិញ ដូច្នេះពួកគេត្រូវប្រញាប់
ដើម្បីកុំឱ្យអាក់ដំណើរដោយសារភ្លៀងយ៉ាងធំនេះ។
ព្រះអម្ចាស់ប្រទានកំលាំងដល់ អេលីយ៉ា
ឱ្យរត់ពីមុខរាជរថក្នុងការធ្វើដំណើរត្រឡប់
ទៅវាំងរបស់ស្តេចវិញចំងាយ៣០គ.ម.។


អញគិតថា
ឯងបានសម្លាប់អេលីយ៉ាហើយ
អញឃើញថាព្រះបាលកំពុង
បញ្ជូនភ្លៀងមកហើយ ។
អត់ទេ ព្រះមហេសី អេលីយ៉ា
ចាំនៅខាងក្រៅ គាត់បានរត់ពីមុខ
រាជរថពីភ្នំកើមែលមកដល់ទីនេះ ។


ពង្សាវតារក្សត្រទី១, ១៨:៤០-៤១, ៤៤-៤៦, ១៩:១
នោះគួរឱ្យអស់សំណើចណាស់
គ្មាននរណាម្នាក់អាចរត់នៅពីមុខរាជរថដ៏ឆ្ងាយ
ដូចនេះទេ ។ ឯណាសង្ឃរបស់ព្រះបាល ? យើងត្រូវតែ
ធ្វើពិធីអបអរទឹកភ្លៀងដែលកំពុងធ្លាក់ ។


បងបានបញ្ជាឱ្យគេសម្លាប់អស់ហើយ ។ ពួកគេជាមនុស្សកុហកបោកប្រាស់ ។


ឯងថាយ៉ាងម៉េច ? អាភ្លើ !
ឯងគួរតែសម្លាប់អេលីយ៉ាវិញ !


ប៉ុន្តែព្រះរបស់គាត់បានឆ្លើយតបដោយភ្លើង វាជាការអស្ចារ្យ ។ សង្ឃរបស់យើងគ្មានអំណាចទេ រាស្ត្រទាំងអស់បានបែរទៅរកព្រះយេហូវ៉ាវិញ ។


ប៉ុន្តែព្រះមហេសីអូន
បង ខ្លាចប្រជារាស្ត្រណាស់ ! តើមាន
អ្វីផ្សេងទៀតឱ្យបងធ្វើ ?
ឯងបានសម្លាប់
សង្ឃរបស់អញ ។
ឯងល្ងង់ណាស់ !


គ្មានឫទ្ធិបារមីណានឹងការពារ
អេលីយ៉ា ពីកំហឹងរបស់ព្រះបាលទេ ។
បើសិនអញមិនសម្លាប់អេលីយ៉ា
ចំពោះការនេះទេ សូមព្រះទាំងអស់
សម្លាប់ខ្ញុំម្ចាស់វិញចុះ ។
ខ្ញុំត្រូវតែគេចចេញ
ឱ្យឆ្ងាយ ។




ពង្សាវតារក្សត្រទី១, ១៩:១-៤


ឱព្រះជាម្ចាស់ ទូលបង្គំមិនអាចទ្រាំ បានទៀតទេ សូមឱ្យទូលបង្គំស្លាប់មុន យេសេបិលរកទូលបង្គំឃើញចុះ ។
ទូលបង្គំខ្មាសខ្លួនឯងណាស់ ទូលបង្គំ បាត់ទំនុកចិត្តលើទ្រង់ ទូលបង្គំមិនប្រសើរជាង ព្ធយុកោរបស់ទូលបង្គំដែលមានបាបនោះទេ ចូរឱ្យទូលបង្គំស្លាប់ចុះ ។



អេលីយ៉ា បានគេចចេញទៅទីវាលរហោស្ថានយ៉ាងឆ្ងាយ អស់រយៈពេល៤០ថ្ងៃ ហើយលាក់ខ្លួននៅក្នុងរូងភ្នំ។ គាត់បានទៅដល់ភ្នំ ស៊ីណាយ ជាភ្នំដែលម៉ូសេ បានទទួលក្រឹត្យវិន័យ ១០ប្រការ នៅទីនោះព្រះបានមានបន្ទូលទៅកាន់គាត់។



អេលីយ៉ា
តើឯងកំពុង
ធ្វើអ្វីនៅទីនេះ ?
មនុស្សទាំងអស់គ្នា
បានបោះ
បង់ក្រឹត្យវិន័យរបស់ទ្រង់ចោល
លើកលែងតែទូលបង្គំ ។ ហោរា
ទាំងអស់របស់ទ្រង់ ត្រូវបានគេ
សម្លាប់ចោល ។ សល់តែទូលបង្គំ
ម្នាក់ដែលថ្វាយបង្គំទ្រង់ ហើយ
ពួកគេកំពុងស្វែងរកជីវិត
របស់ទូលបង្គំទៀត ។
ចូរទៅឈរនៅលើភ្នំ
ចំពោះព្រះអម្ចាស់នៃឯង ។


ពង្សាវតារក្សត្រទី១. ១៩:៤. ៨-១២
នៅពេលអេលីយ៉ា បានឈរចំពោះទ្រង់ នោះមានខ្យល់យ៉ាងខ្លាំង ប៉ុន្តែព្រះមិនមែនគង់នៅក្នុងខ្យល់ទេ។
បន្ទាប់មកមានរំញ្ជួយដីមួយ ប៉ុន្តែព្រះមិនគង់នៅក្នុងការរំញ្ជួយដីទេ។
នៅចុងបញ្ចប់មានភ្លើងមកពីឋានសួគ៌ ប៉ុន្តែព្រះមិនគង់នៅក្នុងភ្លើងនោះដែរ។
ព្រះបានព្យាយាមបង្ហាញអេលីយ៉ាឱ្យដឹងថា គឺទ្រង់ទេដែលគួរឱ្យខ្លាចជាងម្ចាស់ក្សត្រិយ៍យេសេបិលទៅទៀត។


បន្ទាប់ពីខ្យល់ រំញ្ជួយដី ហើយនិងភ្លើងបានបញ្ឈប់ អេលីយ៉ា
បានឮព្រះមានបន្ទូលដោយសំលេងតូចរហៀងៗ ទ្រង់បានសួរ
អេលីយ៉ានូវសំណួរដដែលៗ ដូចទ្រង់ធ្លាប់បានសួរមុនថា...
អេលីយ៉ា តើឯងកំពុង ធ្វើអ្វីនៅទីនេះ ?
អេលីយ៉ា មិនទាន់យល់ឡើយ គាត់
នៅតែមានអារម្មណ៍តូចចិត្តខ្លួនឯង
ដូច្នេះគាត់នៅតែឆ្លើយដូចពីមុនអញ្ចឹង ។


អេលីយ៉ា មិនទាន់យល់ឡើយ គាត់
នៅតែមានអារម្មណ៍តូចចិត្តខ្លួនឯង
ដូច្នេះគាត់នៅតែឆ្លើយដូចពីមុនអញ្ចឹង ។
មនុស្សទាំងអស់គ្នាបានបោះ
បង់ក្រឹត្យវិន័យរបស់ទ្រង់ចោល លើកលែងតែ
ទូលបង្គំ ។ ហោរាទាំងអស់របស់ទ្រង់ ត្រូវបានគេសម្លាប់
ចោល ។ សល់តែទូលបង្គំម្នាក់ដែលថ្វាយបង្គំទ្រង់ ហើយ
ពួកគេកំពុងស្វែងរកជីវិតរបស់ទូលបង្គំទៀត ។


បានហើយ បើសិនឯងមាន ដំណោះស្រាយដូចនេះ ចូរទៅចាក់ប្រេងតាំងឱ្យ អេលីសេ ធ្វើជាហោរារបស់អញជំនួសឯង ។
ហើយឯងមិនដឹងទេ នោះនៅមានមនុស្ស ៧,០០០នាក់ក្នុងប្រទេសអ៊ីស្រាអែលដែលមិនទាន់បានលុតជង្គង់ថ្វាយបង្គំរូបចម្លាក់របស់បាល ហើយ មិនបានថើបជើងវា ។ ឥឡូវចូរបន្តដំណើរទៀតចុះ ហើយពូជពង្សទាំងអស់របស់អ័ហាប់នឹងស្លាប់ ។


អេលីយ៉ា បានរកឃើញ អេលីសេ កំពុងភ្ជួរស្រែ ហើយបានចាក់ប្រេង តាំងឱ្យគាត់ធ្វើជាហោរា ។
ព្រះបានមានបន្ទូលថា ឯងត្រូវបានធ្វើជាហោរា របស់ទ្រង់ ។
ខ្ញុំនឹងគោរបស់ខ្ញុំថ្វាយ យញ្ញបូទៅព្រះជាម្ចាស់ ហើយទៅតាមលោកភ្លាម ។
ពង្សាវតារក្សត្រទី១, ១៩:១២-២១

នៅក្បែររាជវាំងរបស់ ស្ដេចអ័ហាប់ មានចំការ
ទំពាំងបាយជូររបស់ ណាបោត ដែលមានសម្រស់
ល្អណាស់។ ជាញឹកញាប់ ទ្រង់បានទតទៅ
ចំការនោះតាមមាត់បង្អួច ហើយបានកោត
សរសើរពីសម្រស់របស់វា។ ពេលទ្រង់បាន
គិតអំពីចំការនោះកាន់តែច្រើន ទ្រង់ចង់បាន
ទ្រព្យសម្បត្តិរបស់អ្នកជិតខាងកាន់តែខ្លាំង
ដែរ។ ក្រឹត្យវិន័យបានចែងថា “**កុំឱ្យលោភ
ចង់បាន**” ប៉ុន្តែស្ដេចអ័ហាប់មិនខ្វល់ខ្វាយ
ចំពោះព្រះយេហូវ៉ាទេ។




ស្តេចអ័ហាប់មានលុយ ច្រើន ដូច្នេះទ្រង់សម្រេច ចិត្តថា ទ្រង់នឹងទិញ ចំការទំពាំបាយជូរនោះ ។
លក់ចំការទំពាំងបាយជូរ នេះឱ្យខ្ញុំ ។ វានៅជិតវាំង របស់ខ្ញុំ ហើយខ្ញុំនឹងឱ្យ ចំការទំពាំងបាយជូរល្អជាង នេះនៅកន្លែងផ្សេង ។
ព្រះមិនអនុញ្ញាតឱ្យធ្វើអញ្ចឹងទេ


ដីនេះរបស់ព្ធយុកោទូលបង្គំជាង
៥០០ឆ្នាំហើយ ។
ក្រឹត្យវិន័យមិនឱ្យលក់
ដីនេះក្រៅពីបងប្អូនសាច់ញាតិទេ ។


ប្រាប់ខ្ញុំម្ចាស់មក ព្រះស្វាមី ហេតុអ្វីមិនសោយព្រះស្ងោយ ? ហេតុអ្វីព្រះភក្ត្រដូចជាក្រៀមក្រំ ?
ព្រោះណាបោត មិនព្រមលក់ចំការឱ្យយើង។

និក្ខមនំ ២០:១៧, ពង្សាវតារក្សត្រទី១, ២១:១-៧




អញនឹងឱ្យលុយឯងថែមទៀត
ពេលឯងធ្វើការនេះចប់ ឥឡូវនេះ ត្រូវស្ងៀមស្ងាត់
ប្រយ័ត្នឯងនឹង ទទួលលទ្ធផលដូចវាដែរ ។
នៅយប់នោះ ព្រះនាងយេសិបិល បានជួល
មនុស្សពីរនាក់ឱ្យទៅចោទប្រកាន់ ណាបោត ។


ក្រឹត្យវិន័យរបស់ម៉ូសេនិយាយថា “កុំឱ្យធ្វើ
ទីបន្ទាល់ក្លែងទាស់នឹងអ្នកជិតខាងឱ្យសោះ” ។
ឆ្វឹកៗ


នុ៎ះ អាមួយហ្នឹង
បាទ វាថា ស្ដេច ត្រូវតែសុគត ។
មែនហើយ ! វាថា
ព្រះបានបញ្ជូនអារក្សឱ្យ ចូលស្ដេចដែរ ។
បើអញ្ចឹងវា ត្រូវតែស្លាប់ ។
គេយក ណាបោត ទៅសម្លាប់ចោល ។


មើលន៎ ព្រះស្វាមី ឥឡូវនេះ ចំការទំពាំងបាយជូរក្លាយជារបស់ទ្រង់ ហើយ ។ បើសិនព្រះអង្គចង់រីកចំរើនបាន នៅក្នុងលោកិយនេះ ទ្រង់ត្រូវតែគ្មាន មេត្តាធម៌ មានតែអំណាចដែល សម្រេចបានជោគជ័យ ។
វាគួរឱ្យស្រឡាញ់ បងសមនឹងទទួលចំការ នេះមែន ។
ព្រះនាងយេសេបិល ដឹងថាព្រះបាលមិនអាចមើល ឃើញទេ ប៉ុន្តែមានព្រះមួយអង្គគង់នៅឋានសួគ៌ ដែលទតឃើញអ្វីៗទាំងអស់ហើយមិនចេះភ្លេច ។
និក្ខមនំ ២០:១៦, ពង្សាវតារក្សត្រទី១, ២១:១០-១៦


អេលីយ៉ា អ័ហាប់កំពុងចុះទៅ
ចំការទំពាំងបាយជូរបស់ណាបោតធ្វើជាម្ចាស់វា ។
ចូរទៅជួបស្តេចនៅកន្លែងនោះ
ហើយនឹងយកបន្ទូល អញទៅប្រាប់អ័ហាប់ ។


ព្រះអង្គអ័ហាប់ ព្រះមានបន្ទូលថា ឯងបានសម្លាប់មនុស្សដែលឥតមានទោស ហើយយកដីចំការរបស់គាត់ ។ ចំពោះការនេះ នឹងអំពើបាបផ្សេងៗរបស់ឯង ឆ្កែនឹងលិត ឈាមរបស់ឯងនៅត្រង់កន្លែងដែលឆ្កែបាន លិតឈាមរបស់ណាបោតដែរ ។
តើសត្រូវរបស់អញ បានរក ឃើញអញនៅកន្លែងនេះឬ ?


ឯងមិនអាចលាក់ខ្លួនពីអញបានទេ។
ពីព្រោះឯងបានលក់ព្រលឹងរបស់ឯង
ដើម្បី ទ្រព្យសម្បត្តិ
អញនឹងដាក់អំពើអាក្រក់មក
លើពូជពង្សរបស់ឯង។ កូនទាំងអស់និង
សាច់ញាតិរបស់ឯងនឹងត្រូវស្លាប់
សូម្បីតែ កូនក្មេងក៏មិនទុកដែរ។


ឯងបានធ្វើឱ្យអញមានសេចក្ដីក្រោធ
ឆ្កែនឹងស៊ីយេសិបិលនៅក្បែរជញ្ជាំងដំណាក់
របស់ឯង ។ នៅពេលសាច់ញាតិរបស់ឯងស្លាប់ម្នាក់
នៅក្នុងទីក្រុង ឆ្កែនឹងស៊ីសាច់អ្នកនោះ ។ បើគេស្លាប់
នៅទីវាលត្មាតនឹងស៊ីគេ គ្មាននរណាដែល
បានបញ្ចុះសពដោយសមរម្យទេ ។


នេះជាបន្ទូលនៃព្រះ វានឹង
កើតឡើងដូច្នេះមែន។
សូមមេត្តា
ខ្ញុំនឹងចាប់ ផ្ដើមថ្វាយយញ្ញបូជាទៅ
ព្រះយេហូវ៉ាវិញ។
ពង្សាវតារក្សត្រទី១, ២១:១៧-២៦


អ្វីៗទាំងអស់ដែល
អេលីយ៉ាធ្លាប់បានប្រាប់ខ្ញុំ
បានកើតឡើងដូច្នេះមែន។
ឥឡូវនេះស្ដេចអ័ហាប់
ថ្វាយយញ្ញបូជាទៅព្រះ យេហូវ៉ា ប៉ុន្តែស្ដេច
មិនតាមទ្រង់ដោយមាន ចិត្តស្មោះត្រង់ទេ។


អស់ពេលជាយូរក្រោយមក ហោរាក្លែងក្លាយដែលសំដែងជាហោរាពិត
របស់ព្រះយេហូវ៉ាផ្ដល់ប្រឹក្សាដល់ស្ដេចអ័ហាប់អំពីស្ថានការណ៍កងទ័ព ។
សូមយាងទៅ ហើយច្បាំងគ្នា
នៅរ៉ាម៉ូតកាឡាត ហើយព្រះអម្ចាស់
នឹងឱ្យទ្រង់មានជ័យជំនះដ៏ធំ ។
តើហោរាទាំងអស់
គិតអញ្ចឹងដែរឬទេ ?


មីកាជាហោរាពិតរបស់ព្រះយេហូវ៉ាទាយថា...
ព្រះអង្គ ព្រះយេហូវ៉ាមានបន្ទូលមកទូលបង្គំថា ទ្រង់នឹងយាងទៅរ៉ាម៉ូតកាឡាត ហើយទ្រង់នឹងសុគតនៅសមរភូមិនោះដែរ ។
សូមកុំព្រួយព្រះទ័យអំពី មីកា គាត់មិនមែនជាហោរាតែម្នាក់នៃព្រះយេហូវ៉ាទេ ។ មានហោរា ៤00នាក់ទៀតដែលថា ទ្រង់នឹងមានជ័យជំនះ និងជ័យភ័ណ្ឌដ៏ច្រើននៅរ៉ាម៉ូតកាឡាត ។
អញស្អប់ មីកា អ្វីៗទាំងអស់ ដែលវានិយាយគឺជំទាស់រហូត ។


ព្រះអង្គ ទ្រង់បានប្រព្រឹត្តអំពើអាក្រក់
នៅចំពោះព្រះនេត្រព្រះយេហូវ៉ា ។ ទ្រង់ប្រឹក្សាជាមួយ
ហោរាក្លែងក្លាយ ដែលស៊ីសំណូកចំពោះការប្រឹក្សារបស់
ពួកគេ ដែលតែងតែថ្លែងពាក្យភូតកុហក ។
មីកាក៏ប្រាប់ទៀតអំពីរឿង
កើតឡើងនៅឋានសួគ៌ ។


ទូលបង្គំឃើញព្រះជាម្ចាស់គង់នៅលើបល្ល័ង្ក
ហើយទេវតា នៃឋានសួគ៌បានឈរនៅខាងមុខទ្រង់។ ទ្រង់សួរថា
តាំងពី អេលីយ៉ាបានប្រាប់អ័ហាប់ថា វានឹងស្លាប់ វាប្រុងប្រយ័ត្នណាស់
ដើម្បីកុំឱ្យប៉ះពាល់ជីវិតវា។ ឥឡូវនេះវាត្រូវមានគេបបួលទៅ ច្បាំង
តើអ្នកណាអាចបបួលអ័ហាប់ទៅច្បាំងនៅរ៉ាម៉ូតកាឡាត
ដើម្បីឱ្យវាស្លាប់នៅទីនោះបានទេ ?
ទេវតាមួយអង្គថាយ៉ាងនេះ ហើយ
មួយអង្គទៀតក៏ថាយ៉ាងនោះ។
បន្ទាប់ពីពិភាក្សាគ្នារួច ទេវតា
មួយអង្គផ្សេងទៀតទូលថា...


ទូលបង្គំនឹងយាងចុះ នឹងធ្វើវិញ្ញាណបោកបញ្ឆោតក្នុងមាត់ហោរាក្លែងក្លាយទាំងអស់របស់ អ័ហាប់ ទូលបង្គំនឹងប្រាប់ពួកគេថា អ័ហាប់ ត្រូវតែទៅច្បាំង។
ល្អមែន ពួកគេនឹងទាយថា អ័ហាប់នឹងមានជ័យជំនះ។ ប៉ុន្តែនៅពេលវាទៅដល់សមរភូមិប្រយុទ្ធគ្នា អញនឹងឱ្យគេសម្លាប់វា ឥឡូវនេះចូរទៅចុះ !
ពង្សាវតារក្សត្រទី១, ២១:២៧, ២២:៦-២២


តើឯងគិតថា
វិញ្ញាណរបស់ ព្រះយេហូវ៉ាប
ានចេញពីអញ ហើយ ប
ានមានបន្ទូលទៅកាន់ឯងឬ?
ផាច់ !


អ្នកនឹងដឹងព្រះវិញ្ញាណរបស់ព្រះយេហូវ៉ាគង់នៅជាមួយអ្នកណា នៅថ្ងៃ ដែលអ្នកចូលទៅបន្ទប់ខាងក្នុង ដើម្បីលាក់ខ្លួន ពីព្រោះអ្នកខ្លាចគេសម្លាប់ ។
ហាស់ហាំ... នេះគឺជាអ្វី ? ជាបទទំនាយមួយទៀតឬ ?


យកម្នាក់នេះទៅដាក់គុក
ហើយឱ្យ ចំណីបន្តិចបន្តួចល្មមគ្រាន់វានៅរស់
រហូតដល់អញមកពីច្បាំងវិញ នោះ
យើងនឹងសម្លាប់វាចោល ។
បើសិនទ្រង់បានត្រឡប់មកពីច្បាំង វិញ
នោះទូលបង្គំគឺជាហោរា ក្លែងក្លាយហើយសមតែស្លាប់ ។




ពង្សាវតារក្សត្រទី១, ២២:២៤-៣០

ទាហានម្នាក់បានបាញ់បំប្លែងគ្រាប់ព្រួញ ឡើងលើ ដោយមិនបានតម្រង់ទៅលើ
សត្រូវរបស់គេ តែមានសង្ឃឹមនឹងត្រូវ សត្រូវណាម្នាក់។












ភុង !
ស្អីអញ្ចេះ ?
អ្ហ៎...!




ពង្សាវតារក្សត្រទី១, ២២:៣៤


ខ្ញុំសង្ស័យថាទ្រង់ សុគតហើយ ។
គ្រាប់ព្រួញត្រូវចំចន្លោះតូចមួយនៃអាវក្រោះ ខ្ញុំគិតថាដល់សង្ខារបស់ទ្រង់ ។
ព្រះអម្ចាស់អើយ! មិនសមមានរឿងដូច្នេះទេ !


ចូរដាក់សពទ្រង់នៅក្នុង ចំការទំពាំងបាយជូររបស់ណាបោត រហូតដល់យើងមានពេលទំនេរ ដើម្បីបញ្ចុះសព។



ដូចពាក្យសំដីរបស់អេលីយ៉ាថា
ឆ្កែបានលិតព្រះលោហិតរបស់ស្ដេចអ័ហាប់
នៅក្រោមបង្អួចរបស់ព្រះនាងយេសិបិល ។
ទ្រង់ជាអ្នកសុគតដំបូងក្នុង ពូជពង្សរបស់ទ្រង់
នោះមានអ្នកផ្សេងៗដែលនឹងសុគតជាបន្ដបន្ទាប់ទៀត ។

ក្រោយពីលាងលោហិតចេញពីរទេះចម្បាំងរបស់
ស្ដេចអ័ហាប់ ទាហានបានយកវាត្រឡប់មក
រាជវាំងវិញ ហើយបានជួបមេហោរាក្លែងក្លាយ។




ពង្សាវតារក្សត្រទី១, ២២:៣៧-៣៨,
ពង្សាវតារក្សត្រទី២, ៩:៨-១០


អាល្ងង់ !
ឯងមិនមែនជាហោរារបស់ព្រះយេហូវ៉ាទេ
ឯងគឺជាអ្នកកុហក ! ទ្រង់សុគតហើយ ដូចមីកាជា
ហោរារបស់ព្រះយេហូវ៉ាបានទាយពិតមែន ។
ប៉ុន្តែមិនសមសុគតទេ !
ពួកហោរាបានទស្សទាយព្រម
គ្នាទាំងអស់ថា ព្រះអង្គ នឹង
មានជ័យជំនះ ។


មិនមែនទាំងអស់ទេ
មីកា ដែលឯងបានទះហើយ
យកគាត់ដាក់គុកមិនឯកភាពទេ
នៅពេលប្រជារាស្ត្រ ឮពីការនេះ
ពួកគេនឹងកាត់ក្បាលរបស់ឯង។


ឥឡូវនេះ
អ្នកអាច ទៅបាន ស្តេចអ័ហាប់
សុគតហើយ ។
បាទខ្ញុំដឹងហើយមិនត្រូវសង្ស័យឡើយ
ព្រមទាំងមានឆ្កែបានលិតឈាមរបស់ទ្រង់
ដូចព្រះ បានមានបន្ទូល ។
ព្រះនាងយេសិបិលនឹងសុគតជា បន្ទាប់ទៀត
ព្រមទាំងពូជពង្សរបស់ស្តេចអ័ហាប់
ព្រះមានបន្ទូលរួចហើយ ។


ខ្ញុំត្រូវតែ លាក់ខ្លួន !


អុំ មីកាបាននិយាយថា ខ្ញុំនឹងដឹង អ្នកណាមានវិញ្ញាណរបស់ព្រះនៅថ្ងៃដែល ខ្ញុំលាក់ខ្លួននៅក្នុងបន្ទប់តូច ។

ព្រះបុត្រានឹងសោយរាជ្យជំនួសស្តេចអ័ហាប់
ព្រះនាងយេសេបិល
នឹងបន្តធ្វើជាម្ចាស់ក្សត្រិយ៍១២ឆ្នាំទៀត។
អ៊ីស្រាអែលនឹងបន្ត
ថ្វាយបង្គំព្រះក្លែងក្លាយនិងបំពានក្រឹត្យវិន័យរបស់ព្រះ។



ព្រះមានបន្ទូលជំទាស់ទៅពូជពង្សអ័ហាប់ថា
**"ពេលវេលាបានមកដល់ហើយ**
**គ្រួសារទាំងអស់របស់អ័ហាប់នឹងស្លាប់**
**សូម្បីតែកូនក្មេងក៏ស្លាប់ដែរ គ្មានទុក**
**អ្នកណាម្នាក់ឱ្យរួចជីវិតសោះ។**
**ឆ្កែនឹងស៊ីយេសិបិលហើយនឹងគ្មាននរណា**
**ម្នាក់កាន់ទុក្ខ ឬបញ្ចុះសពរបស់នាង។"**

១២ ឆ្នាំក្រោយមក




ពង្សាវតារក្សត្រទី២, ៩:៣០


ខ្ញុំនឹងឈរនៅកន្លែងនេះ ដើម្បី ឱ្យគេដឹងថា ខ្ញុំជាអ្នកគ្រប់គ្រង ។


នរណាគាំទ្រខ្ញុំ?


យើងគាំទ្រ លោកមេទំព!
បោះ យេសេបិល ចុះមកក្រោម ។
ឯងមិនអាចធ្វើដូច្នេះទេ អញជាម្ចាស់ក្សត្រិយ៍ !




ពង្សាវតារក្សត្រទី២, ៩:៣២-៣៣


ទុកសពនៅកន្លែងហ្នឹងទៅ


ឆ្កែបានស៊ីព្រះនាងយេសិបិល ហើយបានលិតព្រះលោហិតនៅត្រង់កន្លែងដែលវាបានលិតព្រះលោហិតព្រះស្វាមីរបស់ព្រះនាង ដូចហោរារបស់ព្រះយេហូវ៉ាបានទាយ ។
ន,លល


ប៉ុន្តែឆ្កែមិនស៊ីដៃដ៏កខ្វក់ដែលបាន
ប្រព្រឹត្តអំពើបាបយ៉ាងច្រើនទេ ។
ពង្សាវតារក្សត្រទី២, ៩:៣៣-៣៧
ដូចហោរាបានទាយមុនថា កូនចៅរបស់ស្តេចអ័ហាប់
ទាំងអស់ត្រូវបានសម្លាប់ដោយមនុស្សនៅក្នុងទីក្រុង
សូម្បីតែម្នាក់ក៏គ្មានសល់ដែរ ។
ពួកគេដែលស្លាប់នៅទីវាលត្រូវបានសត្វត្មាតស៊ី ហើយពួកដែលស្លាប់
ក្នុងទីក្រុងត្រូវបានឆ្កែស៊ី គ្មានអ្វីសល់ពីសាកសពដើម្បីបញ្ចុះឡើយ ។
ឈ្នួលនៃអំពើបាបគឺជាសេចក្តីស្លាប់ពិតមែន !


នៅពេលអេលីយ៉ាកំពុងអធិដ្ឋាន មានសិស្សរបស់ហោរា
មករកអេលីសេដើម្បីជូនដំណឹងដល់គាត់ ។
ព្រះបានមានបន្ទូលទៅពួកសិស្សរបស់ហោរាខ្លះ
តើលោកដឹងទេថ្ងៃនេះគ្រូរបស់លោកគឺ អេលីយ៉ា
ព្រះនឹងលើកគាត់ឡើងទៅឋានសួគ៌ ?
បាទព្រះមានបន្ទូល
ប្រាប់ខ្ញុំដែរ ប៉ុន្តែអ្នកត្រូវ
ស្ងាត់កុំនិយាយអ្វីទៀត ។


អេលីសេ អ្នកត្រូវរងចាំនៅ ទីនេះ ខ្ញុំនឹងទៅទីក្រុងយេរីខូរ ។
ដោយព្រះយេហូវ៉ាមានព្រះជន្មគង់នៅ ខ្ញុំមិនឱ្យលោកឃ្លាតពីភ្នែករបស់ខ្ញុំទេ ខ្ញុំនឹងទៅកន្លែងណាដែលលោកទៅដែរ ។


តើលោកដឹងថា
គ្រូរបស់ លោកអេលីយ៉ានឹងបានឡើង ទៅឋានសួគ៌ថ្ងៃនេះឬទេ ?
បាទ ខ្ញុំដឹងហើយឥឡូវនេះ
កុំរំខានយើងហើយកុំប្រាប់គេ ខ្ញុំមិន
ត្រូវឱ្យគាត់ឃ្លាតពីភ្នែកខ្ញុំទេ។


ឯងចាំនៅយេរីខូរ
ខ្ញុំត្រូវការទៅទន្លេ យ័រដាន់មួយភ្លែត ។
ដោយព្រះដ៏មានព្រះជន្មគង់នៅ
ខ្ញុំនឹងមិនឃ្លាតពីលោកទេ ។


មើលន៎ សិស្សរបស់ហោរា
ដើរតាមយើងទៀតហើយ ។
តើយើងនឹងឆ្លងទន្លេយ៉ាងម៉េច?
ថ្ងៃនេះវាហូរខ្លាំងណាស់ ។
យើងឆ្លងទន្លេ តាមដីស្ងួត
ពង្សាវតារក្សត្រទី២, ២:៣-៧


ផាច់ !
អ្ហ៊ា...!
តើអ្នកបានឃើញឬទេ
? ទឹកបានញែកជាពីរ
ដូច្នេះគេ អាចឆ្លងបាន។
បាទ
ដូចលោក ម៉ូសេដែរ។
ទោះបីមានរឿងអ្វីកើតឡើងក៏ដោយ
ខ្ញុំត្រូវតែមកមើលការនេះដែរ។
ខ្ញុំចង់ឱ្យហោរារបស់ព្រះ
ចាល់បានឃើញការនេះ !


តើអ្នកចង់ឱ្យខ្ញុំធ្វើអ្វីសម្រាប់ អ្នក មុនយើងបែកគ្នា ?
សូមឱ្យវិញ្ញាណដែលមាន លើលោកបានមកសណ្ឋិត លើខ្ញុំទ្វេដង ។
អ្វីដែលអ្នកសុំជាការពិបាក ប៉ុន្តែនោះនឹងបានដូចប្រាថ្នា បើសិនអ្នកឃើញខ្ញុំ នៅពេល ខ្ញុំឡើងទៅឋានសួគ៌ ។

ពង្សាវតារក្សត្រទី២,
២:៨-១១







វ្វឹ..
រាជរថភ្លើងបានញែក
អេលីយ៉ា ចេញពី អេលីសេ ។


អេលីយ៉ា បានឡើងទៅឋានសួគ៌
ដោយសារខ្យល់កួច ។




ពង្សាវតារក្សត្រទី២, ២:១១-១៣


ព្រះរបស់អេលីយ៉ា នៅឯណា ?


វិញ្ញាណរបស់អេលីយ៉ា
បានសណ្ឋិតនៅអេលីសេ!
ថ្ងៃនេះពិតជា
អស្ចារ្យមែន !


អេលីសេ បានធ្វើការអស្ចារ្យច្រើនជាងអេលីយ៉ាពីរដង
គាត់ មានជំនឿលើព្រះយ៉ាងខ្លាំង
ប៉ុន្តែអ៊ីស្រាអែលមិនផ្លាស់ប្រែចិត្ត ទាំងស្រុងទេ
ពួកគេនៅតែថ្វាយបង្គំរូបចម្លាក់ដែរ ។
តើ អេលីយ៉ា ទៅណាបាត់ហើយ ?
យើងត្រូវការ ទៅរកគាត់ !
មិនបាច់រកគាត់ទេគាត់ ទៅឋានសួគិហើយ ។
ពង្សាវតារក្សត្រទី២, ២:១៤-១៦



# ជំពូក ៧

# បទទំនាយអំពីព្រះគ្រីស្ទ


បន្ទាប់ពី អេលីសេ ព្រះបានតែងតាំងហោរាផ្សេងទៀតដូចជា
អេសាយ យេរេមា ហើយ អេម៉ុស
ដើម្បីធ្វើឱ្យមនុស្សប្រែចិត្តពីការគោរពរូបចម្លាក់ និងអំពើបាប ។
ព្រះបានមានបន្ទូលដល់អ៊ីស្រាអែលតាមរយៈហោរាទាំងអស់ នេះ
ហើយព្រះបានឱ្យពួកគេកត់ទុកបទទំនាយនៃថ្ងៃអានាគតយ៉ាងច្រើន ។


អេសាយ បានធ្វើជាហោរាក្នុងរជ្ជកាលនៃស្តេច
អ៊ូសៀស យ៉ូថាម អេហាស និង ហេសេគា
(ប្រហែលជាឆ្នាំ៧០០-៧៦០មុន
គ.ស.) ព្រះមានបន្ទូលតាមរយៈ
អេសាយថា “**អញបានចិញ្ចឹមគេ**
**ប៉ុន្តែពួកគេបានបះបោរប្រឆាំងនឹងអញ ។**
**សត្វគោឆ្កួតក៏ស្គាល់ម្ចាស់វាដែរ**
**ប៉ុន្តែអ៊ីស្រាអែលមិនស្គាល់អញសោះ ។**
**ឯងជាប្រជាជាតិមួយពេញដោយអំពើបាប**
**មនុស្សពេញដោយអំពើទុច្ចរិត**
**ពួកឯងជាពូជរបស់អ្នកប្រព្រឹត្តអំពើអាក្រក់...**

...បើសិនអ្នកឈប់ប្រព្រឹត្តអំពើអាក្រក់ ហើយជួយការពារអ្នកដែលគេជិះជាន់ ថែរក្សាក្មេងកំព្រា និងផ្គត់ផ្គង់ស្ត្រីមេម៉ាយ អញនឹងព្យាបាលឯងឱ្យជាសះស្បើយ ប៉ុន្តែបើសិនឯងមិនបែរមករកអញ ឯង នឹងត្រូវស្លាប់ដោយសារដាវ ។
ទឹកដីទាំងអស់របស់ឯង ត្រូវបានបំផ្លាញខ្ទេចខ្ទី ហើយទីក្រុងរបស់ឯងត្រូវបានគេ ដុតបំផ្លាញអស់ ហើយគេនឹងយកកូនប្រុសរបស់ឯង ទៅក្រុងបាប៊ីឡូននៅទីនោះគេនឹងក្រៀវកូនរបស់ឯង ដើម្បីឱ្យបំរើនៅរាជវាំងរបស់ស្តេចបាប៊ីឡូន” ។





## អេសាយ ១:២-៤, ៧, ១៦, ២០, ៣៩:៧, យេរេមា ២១:៨-១០

យេរេមាបានធ្វើហោរា ក្នុងរជ្ជកាលស្តេច យ៉ូសៀស យ៉ូយ៉ាគីម និង សេដេគា ( ប្រហែលជាឆ្នាំ៥៩០-៦៣០មុន គ.ស.) **"ព្រះមានបន្ទូលថា**

**មើលអញដាក់ផ្លូវជីវិតនិង ផ្លូវស្លាប់នៅមុខឯង**
**អ្នកណាដែលនៅជាប់ក្នុងក្រុងនេះនឹងត្រូវស្លាប់ដោយដាវ**
**ដោយគ្រោះទុរភិក្ស ហើយដោយអាសន្នរោគ**
**តែឯអ្នកណាដែលចេញទៅពួកខាល់ដេ**
**ជាខ្មាំងដែលឡោមព័ទ្ធឯងរាល់គ្នា នោះនឹងរស់នៅវិញ**
**ប៉ុន្តែអ្នកនោះនឹងធ្វើទាសករនៅបាប៊ីឡូន**
**ត្បិតព្រះយេហូវ៉ាទ្រង់មាន បន្ទូលថា**
**អញបានតាំងមុខទាស់នឹងទីក្រុងនេះចំពោះការអាក្រក់**
**ទីក្រុងនេះនឹងត្រូវប្រគល់ទៅក្នុង**
**កណ្តាប់ដៃនៃស្តេចបាប៊ីឡូន**
**ស្តេចនោះនឹងដុតចោលដោយភ្លើង" ។**


ព្រះអម្ចាស់មានបន្ទូលតាមរយៈ
យេរេមា ថា
"ហើយខ្លួនអញក៏ច្បាំងតនឹងឯងរាល់គ្នា
ដោយដៃលូកចេញ នឹងដើមដៃខ្លាំងពូកែ
គឺដោយសេចក្តីកំហឹងសេចក្តីក្រោធ
នឹងសេចក្តីគ្នាន់ក្នាញ់ជាខ្លាំង ។
អញនឹងប្រហារពួកអ្នកនៅក្រុង
នេះ ទាំងមនុស្សនិងសត្វផង
គេនឹងត្រូវស្លាប់ដោយ
អាសន្នរោគយ៉ាងធំ ។

ហើយព្រះយេហូវ៉ាទ្រង់មានបន្ទូលថា
លំដាប់នោះ អញនឹងប្រគល់សេដេគា
ជាស្តេចយូដា ហើយពួកមហាតលិក
នឹងបណ្តាជនទាំងឡាយ គឺអស់អ្នក នៅទីក្រុងនេះ
ដែលសល់ពីអាសន្នរោគ ពីដាវ ហើយ ពីគ្រោះទុរភិក្ស
ទៅក្នុងកណ្តាប់ដៃនៃ នេប៊ូក្នេសា ជាស្តេច
បាប៊ីឡូន គឺក្នុងកណ្តាប់ដៃនៃពួកខ្មាំងសត្រូវគេ
ជាពួកអ្នក ដែលស្វែងរកជីវិតគេ
ស្តេចនោះនឹងប្រហារគេដោយមុខដាវ ឥតប្រណី
ឥតមេត្តា ឥតអាណិតអាសូរឡើយ ។ ក្រែង
សេចក្តីក្រោធរបស់អញចេញទៅដូចជាភ្លើង
ហើយឆេះជាខ្លាំង
ដល់ម្ល៉េះបានជាគ្មានអ្នកណាអាចនឹងពន្លត់បានឡើយ ។
ពួកគេនឹងយកពួកឯងទៅធ្វើជាទាសករនៅក្នុងទីក្រុងបាប៊ីឡូន
ហើយនឹងសម្លាប់ពួកឯងដោយដាវ ។
មនុស្សជាច្រើនដែល បានទៅទីក្រុងបាប៊ីឡូននឹងស្លាប់
ហើយនឹងបានបញ្ចុះសព នៅទីនោះដែរ" ។

យេរេមា ២១:៥-១០,១២


អេម៉ុស បានធ្វើជាហោរាក្នុងរជ្ជកាលនៃស្តេច អូសៀស និងយេរ៉ូបោមទី២( ប្រហែលជាឆ្នាំ៧៥០-៧៦៥មុន គ.ស.)
ព្រះមានបន្ទូលស្តីបន្ទោសអ៊ីស្រាអែលតាមរយៈ អេម៉ុសថា “ស្ត្រីរបស់ឯងដូចជាមេគោ ដែលត្រូវការប្តីឲ្យរក្សាពួកគេ ឱ្យផឹកគ្រប់គ្រាន់។ ពួកគេនឹងមិនបានគ្រប់សង្កត់លើប្តីរបស់ ខ្លួនទៀតទេ ពួកសត្រូវនឹងដឹកអូសនាំពួកឯងដោយថ្នក់ជាប់ នឹងសាច់របស់ខ្លួនដើម្បីទៅធ្វើជាទាសករនៅបាប៊ីឡូន”។



"ឯងដេកនៅលើគ្រែដ៏មានតំលៃ

ហើយហូបអាហារដ៏ល្អប្រណិតស្រស់ៗ សំបូរជាតិខ្លាញ់

ឯងបានស្តាប់តន្ត្រីហើយផឹកស្រាទំពាំងបាយជូរដោយចានគោម ។

ឯងបានបោះសេចក្តី សុចរិតចោលទៅដី

ពួកឯងរាល់គ្នាតែងញាំញីពួកអ្នកក្រីក្រ កៀបសង្កត់មនុស្សសុចរិត

ស៊ីសំណូក ហើយមិនផ្តល់យុត្តិធម៌ដល់អ្នកក្រីក្រ ។

ឯងនឹងដាំចំការទំពាំងបាយជូរ

ប៉ុន្តែសត្រូវរបស់ឯងនឹងផឹកស្រាដែលមកពីចំការនោះ ។

គេនឹងបំផ្លាញទាហានរបស់ឯង

ហើយគេនឹងយកឯងទៅធ្វើជាទាសករនៅទឹកដីបរទេស" ។

ព្រះមានបន្ទូលទៀតថា
“អញនឹងបំផ្លាញអាសនៈ
ថ្វាយបង្គំនៅបេតអែល
ហើយរុះរើវីឡារដូវរងារ
និងវីឡារដូវក្តៅរបស់ឯងដែរ ។ ឯងគាបសង្កត់
អ្នកក្រីក្រ ឯងស៊ីសំណូកហើយនឹងសង្កត់សង្កិន
អ្នកក្រ ។ អញបានឃាត់ភ្លៀងបញ្ជូនការស្រេក
ឃ្លាននិងអាសន្នរោគ ។
ប៉ុន្តែឯងនៅតែមិនកែប្រែចិត្ត
ឯងដាំចំការទំពាំបាយជូរដើម្បីធ្វើស្រាទៀត
ប៉ុន្តែឯងនឹងមិនបានផឹកស្រានោះទេ” ។




ឆ្នាំ៧៥៣មុន គ.ស.


ដាក់ឱ្យ
ហូសេ បានធ្វើហោរាក្នុងរជ្ជកាលនៃស្ដេច អូសៀស យ៉ូថាម និងអេហាស (ប្រហែលជាឆ្នាំ៧២៥-៧៨៥មុន គ.ស.) **“ឯអ៊ីស្រាអែលគេនឹងជួលស្លាប់ដោយដាវ កូនខ្ចីរបស់គេនឹងបោកខ្ទេចខ្ទីទៅលើដី ហើយពួកស្រីៗដែលមានគភ៌នឹងត្រូវវះពោះចោល”** ។

“មានថ្ងៃមួយនឹងមកដល់ដែលអ លើកលែងទោសអំពើបាបរបស់ អ៊ីស្រាអែល
នឹងស្រឡាញ់គេស្មោះ ពីចិត្ត ។ អ៊ីស្រាអែលនឹងរីកម្តងទៀត ដូចផ្កាច័ន្ទ
គេនឹងរីកចំរើនដូចដើម អូលីវ ហើយមានក្លិនក្រអូបដូច ថ្លៃដើមស៊ីដានៅស្រុកល្បាណូន” ។




"ជាច្រើនឆ្នាំបន្ទាប់ពីបាប៊ីឡូន ពួកឯងនឹង ត្រូវបែកខ្ញែកទៅប្រទេសផ្សេងៗ
ហើយ នៅទីនោះគេនឹងធ្វើទុក្ខបុកម្នេញដល់ពួកឯង
នឹងយកទឹកដីរបស់ពួកឯង ធ្វើឱ្យពួកឯង នឹងរកកន្លែងសំរាកគ្មាន" ។


ច្បាប់នេះនិយាយថា ជនជាតិយូដាទាំងអស់ត្រូវចេញ ពីប្រទេសក្នុងពេល៣ថ្ងៃ !
ពួកគេកំពុងយកទ្រព្យសម្បត្តិ ទាំងអស់របស់យើង ហេតុអ្វី មិនឈប់ប៉ះពាល់យើង ?
ម៉ាក់ យើងនឹងរស់ នៅកន្លែងណា ?




អេសាយ ៣៩, ១០:២១, ៥១:១១, យេរេមា ៣០:១១, អេសេគាល ១៧:២១,
យ៉ូអែល ៣:២, ហូសេ ១៣:១៦, ១៤:១-៦


តាមសេចក្ដីប្រកាសនេះ ជនជាតិ
យូដាទាំងអស់ត្រូវចាកចេញពីប្រទេស ហើយមិនអាចយកសម្ភារៈអ្វី ទៅជាមួយទេ។
ខ្ញុំចង់បានគោ
នេះយូរហើយ
ពីព្រោះប្រជាជាតិអ៊ីស្រាអែលបានបដិសេធបន្ទូលរបស់ព្រះ
ពួកគេនឹងបែកខ្ញែកទៅកាន់ប្រទេសទាំងអស់នៅលើផែនដី។
ប៉ុន្តែពួកគេមិនអាចរកកន្លែងសម្រាករហូតដល់ព្រះបាននាំពួកគេមកទឹកដីនៃព្ធយុកោរបស់ពួកគេវិញ។

"ដូច្នេះប្រទេសអ៊ីស្រាអែលទាំងមូលទៅជាស្ងាត់ជ្រងំ
សាសន៍ទាំងនេះ នឹងត្រូវបំរើស្តេចបាប៊ីឡូនអស់ពេល៧០ឆ្នាំ។
លុះដល់៧០ឆ្នាំ ហើយ នោះអញនឹងធ្វើទោសស្តេចបាប៊ីឡូន
និងពួកសាសន៍នោះ ដោយព្រោះអំពើទុច្ចរិតរបស់គេ។ ហើយបន្ទាប់មកអញនឹងនាំពួក
សំណល់អ៊ីស្រាអែលមកកាន់ទឹកដីនេះដើម្បីសាងសង់វាឡើងវិញ"។




បទទំនាយនេះបានកើតឡើងរួចជាស្រេច សត្រូវ
បានភ្ជួរដីនៅយេរូសាឡិមមែន ប៉ុន្តែនៅថ្ងៃ
ចុងក្រោយ គេនឹងសង់វិហារឡើងវិញ
ហើយមនុស្សនឹងមកចូលរួមជាច្រើន។
ហោរា មីកា មានជីវិតរស់នៅពីឆ្នាំ ៦៨៦-៧៥០មុន
គ.ស. ហើយបានទាយពីថ្ងៃអនាគតថា...

“ហើយសាសន៍ជាច្រើននឹងទៅដោយពាក្យថា
ចូរមក យើងឡើងទៅឯភ្នំនៃ ព្រះយេហូវ៉ា
គឺទៅឯព្រះវិហារនៃព្រះរបស់យ៉ាកុបចុះ ។
ទ្រង់នឹងបង្រៀនយើង រាល់គ្នាស្គាល់ផ្លូវរបស់ទ្រង់
នោះយើងនឹងដើរតាមអស់ទាំងផ្លូវច្រករបស់ទ្រង់ ។
ដ្បិតក្រឹត្យវិន័យនឹងផ្សាយចេញពីក្រុងស៊ីយ៉ូនទៅ
គឺព្រះបន្ទូលរបស់ព្រះយេហូវ៉ា ពីក្រុងយេរូសាឡិម” ។





"ទ្រង់នឹងធ្វើជាចៅក្រមដល់សាសន៍ជាច្រើន ហើយនឹង
សម្រេចសេចក្តី ពីដំណើរប្រទេសមានអំណាចផ្សេងៗ
ដែលនៅទីឆ្ងាយ ។ នោះគេនឹងដំដាវរបស់គេធ្វើជាផាល
ហើយលំពែងគេធ្វើជាដង្កាវវិញ ។

អស់ទាំងនគរនឹងលែង
លើកដាវច្បាំងគ្នាទៀត
ក៏មិនរៀនវិជ្ជាចម្បាំងទៀត តទៅ
គឺគ្រប់គ្នានឹងអង្គុយក្រោមដើមទំពាំងបាយជូរ
ហើយក្រោមដើមល្វារបស់ខ្លួន
ឥតមានអ្នកណាបំភ័យ គេឡើយ ។
ដ្បិតព្រះឱស្ឋរបស់ព្រះយេហូវ៉ានៃពួកពល
បរិវារបានចេញវាចាហើយ” ។



យេរេមា ២៥:១១-១២, មីកា ៣:១២, ៤:១-៧



"យើងរាល់គ្នានឹងប្រព្រឹត្តតាមព្រះនាមនៃព្រះយេហូវ៉ា ជាព្រះនៃយើង
ជាដរាបរៀងតទៅវិញ ។ ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា នៅថ្ងៃនោះ
អញនឹងប្រមូលផ្តុំអស់អ្នកដែលបានត្រូវបណ្តេញចេញ ហើយអញនឹង
បង្កើតនគរដ៏ខ្លាំងមួយ ។ នោះព្រះយេហូវ៉ាទ្រង់នឹងសោយរាជ្យលើគេ
នៅលើភ្នំស៊ីយូន ចាប់តាំងពីគ្រានោះជាដរាបតទៅ" ។


ឆ្នាំ៥៨៦-៦២៧មុន គ.ស.
យេរេមា បានទាយថា...
ឱស្ដេចសេដេគាឯងនិងប្រជារាស្ត្របានធ្វើអំពើអាក្រក់នៅចំពោះអញជាព្រះអម្ចាស់នៃឯង ។ ឯងមិនស្លាប់ទេ ឯងនឹងទៅក្រុងបាប៊ីឡូន ហើយនៅទីនោះឯងនឹងរស់នៅជាមួយប្រជារាស្ត្ររហូតដល់អស់មួយជីវិត ។ ប៉ុន្តែឯងមិនបានឃើញបាប៊ីឡូនទេ ព្រោះគេបានចាក់ភ្នែកឯងឱ្យខ្វាក់ ប្រជារាស្ត្រនឹងរស់នៅបាប៊ីឡូន៧០ឆ្នាំ ។

លុះផុត៧០ឆ្នាំ នឹងមានពួកទាហានមកពីខាងជើង
បាប៊ីឡូន គេនឹងបំផ្លាញបាប៊ីឡូន ហើយប្រជារាស្រ្ត
ទាំងអស់នឹងត្រឡប់ទៅយេរូសាឡិមព្រមទាំងសង់ទីក្រុងនិងវិហារឡើងវិញ។




ក្រោយពេលជំនុំជំរះនៅថ្ងៃខាងមុខទៀត អញនឹងអត់ទោសនូវអំពើបាបរបស់
អ៊ីស្រាអែល ហើយយេរូសាឡិមនឹងមាន មនុស្សរស់នៅគ្រប់ដំណាតរៀងទៅ ។
ចូរយកគម្ពីរនេះទៅបាប៊ីឡូនហើយអានឱ្យ
ប្រជារាស្ត្រអ៊ីស្រាអែលនៅទីនោះស្ដាប់
ឱ្យគេដឹង នូវអ្វីទាំងអស់
ដែលគេត្រូវស៊ូទ្រាំមុនគេអាច
ត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ ។
អញនឹងលើកបល្ល័ង្ករបស់ដាវីឌឡើងវិញ ហើយពួកឯងនឹង
ត្រឡប់មកធ្វើជាម្ចាស់ទឹកដីទាំងអស់របស់ខ្លួនវិញ ។




យេរេមា ៣៨:៣, ៥១:៦០-៦១, ៥២:១១, យូអែល ៣:២០-២១, អេម៉ុស
៩:១១-១៥, អេសេគាល ១២:១៥-១៦


ព្រះសន្យាជាមួយលោកអ័ប្រាហាំថា
ពូជរបស់លោកអ័ប្រាហាំនឹងទទួលទឹកដីជាមរតក
អស់កល្បជានិច្ច ។
ព្រះអម្ចាស់មិនដែលបំភ្លេចកិច្ចសន្យារបស់ទ្រង់ទេ
ប៉ុន្តែនៅពេលពួក អ៊ីស្រាអែលប្រព្រឹត្តអាក្រក់
ព្រះបញ្ជូនគេទៅធ្វើជាទាសករនៅគ្រប់ប្រទេស
នៅកន្លែង នោះគេនឹងគោរពព្រះរបស់អ្នកដទៃ
ប៉ុន្តែនៅពេលចុងក្រោយទ្រង់នឹងនាំគេមកវិញ ។


ព្រះមានបទទំនាយពី
ប្រទេសផ្សេងៗទៀតថា...
“បាប៊ីឡូននឹងបានថ្កោលទោសប្រទេសអេស៊ីព្ទ ហើយ៤០ឆ្នាំ
ទៀតប្រទេសអេស៊ីព្ទស្ថិតនៅដោយភាពសោះកក្រោះ ។ បន្ទាប់
មកពួកគេនឹងត្រឡប់មកពីនគរបាប៊ីឡូនវិញ នគរអេស៊ីព្ទនឹងបាន
ទាបថោកជាងនគរទាំងអស់ ។ អេស៊ីព្ទនឹងមិនខ្លាំងដូចមុនទេ អញនឹងធ្វើឱ្យគេថយតិចទៅៗ
ប៉ុន្តែប្រទេសអេស៊ីព្ទនឹងបន្ត រហូតដល់ថ្ងៃចុងបញ្ចប់ ហើយនៅថ្ងៃជិតចុងបញ្ចប់នោះ
ប្រទេសអេស៊ីព្ទនិងប្រទេសអាសស៊ើរនឹងរួមគ្នាជាមិត្តជាមួយ ប្រជាជនអញអ៊ីស្រាអែល
ស្ថិតក្នុងកិច្ចព្រមព្រៀងបីប្រទេស ហើយអញនឹងប្រទានពរឱ្យគេ”។


"ភីលីស្ទីននឹងត្រូវបានគេបំផ្លាញ ហើយឈប់មានបន្តទៀត។ ក្រុង
អាសដូឌ អេក្រុន អាំម៉ូននិងស្រុកអេដុមត្រូវស្ងាត់ជ្រងំ។ ក្រុង
ទីរ៉ុនឹងបានបំផ្លាញចោល ដុំថ្មនិងដើមឈើត្រូវបោះចូលក្នុងសមុទ្រ
ហើយបន្ទាប់មកគ្មានអ្នកណារស់នៅរហូត ហើយដីត្រូវស្មើដូចថ្ម
ជាកន្លែងសម្រាប់អ្នកនេសាទហាលអួនរបស់គេ"។


"ប៉ុន្តែសាសន៍ ពើស៊ី (អ៊ីរ៉ង់) ទួគី អេធីយ៉ូពី
និង លីប៊ី នឹងនៅរហូតដល់ថ្ងៃទីបញ្ចប់ នៅ
ពេលនោះពួកគេនឹងព្យាយាមជ្រៀតជ្រែកទឹកដី
នៃប្រទេសអ៊ីស្រាអែល ប៉ុន្តែពួកគេនឹងស្លាប់នៅ
លើភ្នំនៃប្រទេសអ៊ីស្រាអែល"។


បទទំនាយទាំងអស់ដែលនៅក្នុងព្រះគម្ពីរតែងតែកើតមានឡើងយ៉ាងពិតប្រាកដ ទីក្រុងទាំងឡាយនិងប្រជាជាតិទាំងអស់ដែលបទទំនាយបានទាយថានឹងត្រូវកំទេចចោលអស់ បានកំទេចចោលអស់ហើយ ។ ប្រជាជាតិណាដែលបានទ្រាំរហូតដល់ចុងបញ្ចប់ នោះគឺនៅតែមាននៅថ្ងៃនេះ ។
អេសេគាល ២៥, ២៦:១៥-១៩, ២៩:១២-១៦, ៣០:១-៨, យេរេមា ២៥:១៥-១៦, អេម៉ុស ១


នៅឆ្នាំ៦០៥មុន គ.ស. បាប៊ីឡូន
បានវាយឈ្នះ អ៊ីស្រាអែល
ដូចហោរាបានទាយ ។
ព្រះជាម្ចាស់អើយ
ទូលបង្គំបានទទួលទោស
ដោយសារបាបមកពីព្ធយុកោរបស់ទូលបង្គំ
សូមជួយពួកទូលបង្គំដើរតាមក្រឹត្យវិន័យរបស់
ទ្រង់នៅក្នុងទឹកដីចំឡែកនេះផង ។


ជនជាតិយូដាជាង៥០០០នាក់ ត្រូវបានយកទៅបាប៊ីឡូនដូចជាឈ្លើយសឹក ។ ពួកគេបាននាំយុវជនដែលមានចំណេះដឹងមក ដើម្បីឱ្យពួកគេធ្វើការនៅក្នុងនគរបាប៊ីឡូន ។ ក្នុងក្រុមពួកនោះមានបុរសម្នាក់ឈ្មោះ ដានីយ៉ែល គាត់បានគោរពតាមក្រឹត្យវិន័យ ហើយដើរតាមការបង្គាប់នៃព្រះរបស់អ័ប្រាហាំ ។


ទូលបង្គំសូមថ្លែងអំណរគុណដល់ព្រះនៃឋានសួគ៌ ផែនដី និង ស្ដេចនៃសកលលោក ដែលប្រទាននំប៉័ងចេញពីដី ។
ដានីយ៉ែល ជាឈ្លើយសឹកនៅទឹកដីចំឡែក ។ ប៉ុន្តែគាត់បានសម្រេចចិត្តថា នឹងស្មោះត្រង់ចំពោះព្រះរបស់គាត់ អ្នកដែលចាប់បង្ខាំងគាត់បានឃើញថា គាត់មានគុណសម្បត្តិល្អ ដូច្នេះគេដាក់គាត់នៅកន្លែងដ៏ពិសេសជាមួយអ្នកប្រាជ្ញនៃបាប៊ីឡូន ។


នេប៊ូក្នេសា ស្តេចនៃបាប៊ីឡូនបាន
ភ្ញាក់ខ្លួនដោយសារសុបិននិមិត្តចំឡែក ។
តើនេះមានន័យយ៉ាងដូចម្តេច?
សុបិននិមិត្តនេះប្រហែលមកពីព្រះ
ណាមួយដើម្បីឱ្យខ្ញុំដឹងពីថ្ងៃអនាគត ។




ដានីយ៉ែល ១:២-៧, ១៧-២១, ២:១-១១


អញដឹងថា
ពួកឯងទាំងអស់ក្លែងក្លាយពួក
ព្រះមិនដែលនិយាយទៅពួកឯងទេ។ អញនឹង
សម្លាប់ពួកឯងចោលព្រមទាំងគ្រួសារ ហើយ
ផ្ទះរបស់ពួកឯងក្លាយជាគំនរអាចម៍។


មេទ័ពរក្សាអង្គបានប្រាប់ ដានីយ៉ែលថា...
ខ្ញុំសោកស្ដាយ ដានីយ៉ែល នៅថ្ងៃស្អែក អ្នកនិងពួកអ្នកប្រាជ្ញដែលមានវិជ្ជាជ្រៅជ្រះទាំងអស់របស់បាប៊ីឡូននឹងត្រូវស្លាប់ ទ្រង់មិនជឿសង្ឃផ្ទាល់ របស់ទ្រង់ដែរ ។
ប៉ុន្តែព្រះយេហូវ៉ា អាចបង្ហាញ សុបិននិមិត្តរបស់ទ្រង់និងអត្ថន័យដែរ ។ ខ្ញុំត្រូវការទៅកន្លែងដែលស្ងៀមស្ងាត់ម្នាក់ឯង ដើម្បីអធិដ្ឋាន សូមលោកទៅសុំការអនុញ្ញាតពីទ្រង់ឱ្យពន្យាពេលបានមួយថ្ងៃសិន ។


ព្រះទ្រង់គឺជាព្រះតែមួយ ហើយ ជាស្តេចនៃសកលលោក ។ សូមបង្ហាញ ដល់ទូលបង្គំនូវអ្វីដែលនឹងកើតមក គ្មានព្រះណាផ្សេងដូចទ្រង់ឡើយ ។
ដានីយ៉ែល ចូរស្តាប់អញ...


សូមលោក ប្រញាប់នាំខ្ញុំទៅគាល់ព្រះអង្គ !
បើសិនអ្នកមិនអាច បកស្រាយពីសុបិននិមិត្តរបស់ ទ្រង់ ទ្រង់នឹងសម្លាប់ខ្ញុំចោល នៅកន្លែងហ្នឹង។


ឱ ព្រះករុណា
ព្រះអម្ចាស់នៃ
ឋានសួគ៌បានប្រទានរាជ្យព្រះចេស្ដា
ឱ្យទ្រង់ធ្វើជាស្ដេច លើអស់ទាំង
ស្ដេច ។ ព្រះអម្ចាស់ឱ្យទ្រង់សុបិន
និមិត្តឃើញអំពីអ្វីដែលនឹងកើត
ឡើងនៅថ្ងៃចុងបញ្ចប់ ។
ដានីយ៉ែល
២:១២-៣០


កុំចំណាយពេលច្រើន តើអាចប្រាប់អញអំពីសុបិន្តរបស់អញបានឬអត់ ?
ព្រះពិតដែលបង្កើតសកលលោកបាន បង្ហាញពីសុបិន្តរបស់ទ្រង់ មកដល់ទូលបង្គំ ។


ឱព្រះករុណាជាម្ចាស់ ទ្រង់បាន និមិត្តឃើញរូបចម្លាក់ដ៏ធំមួយរូប ចម្លាក់នេះតំណាងនគររបស់ទ្រង់ ហើយនគរបីទៀតដែលនឹងមកបន្ទាប់ពីនគររបស់ទ្រង់។
វាជាការពិត! អញមិនបាន ប្រាប់អ្នកណាទេ ព្រះរបស់ឯងគឺជា ព្រះតែមួយពិតមែន។


ទ្រង់ជាសិរសាមាស ជាស្ដេចលើអស់
ទាំងស្ដេច ។ មុនទ្រង់វាយឈ្នះយូដា ហោរា
របស់សាសន៍យូដាបានប្រាប់ពួកទូលបង្គំថា
ព្រះជាម្ចាស់នឹងកាត់ទោសចំពោះបាបពួក ទូលបង្គំ
ហើយនឹងឱ្យនគររបស់ពួកទូលបង្គំ ទៅទ្រង់
ឥឡូវរាជ្យរបស់ទ្រង់នឹង រុងរឿងឡើង ។


ដើមទ្រូងដែលធ្វើពីប្រាក់តំណាង
នគរសាសន៍មេឌី និង សាសន៍ពើស៊ី ។
ក្រោយពីទ្រង់សុគតគេនឹងធ្វើសង្គ្រាម
ដណ្ដើមយកបាប៊ីឡូន គេនឹងតាំងរាជ្យ
លើពិភពលោកដូចទ្រង់ដែរ ។


ឱព្រះអង្គ
បន្ទាប់ពីសិរសាជាមាស
និងដើមទ្រូងជាប្រាក់ ទ្រង់បានឃើញពោះ
ធ្វើពីលង្ហិន លង្ហិននោះតំណាងឱ្យនគរទី៣ដែល
ជាសាសន៍ក្រេក វានឹងមកបន្ទាប់ពីសាសន៍ពើស៊ី
ពួកគេនឹងរហ័សហើយសាហាវ ។
ដានីយ៉ែល ២:៣១-៣៣, ៣៩-៤៣


នគរទី៤ខុសប្លែកពីគេ
ជើងធ្វើពីដែក ហើយវា
នឹងជាន់ប្រទេសជាច្រើនឱ្យបែកខ្ទេច ។
ប៉ុន្តែទ្រង់ឃើញម្រាម ជើងដែកលាយជាមួយដីឥដ្ឋ
នៅថ្ងៃចុងបញ្ចប់នគរនោះនឹង
ញែកបែកគ្នាជា១០ផ្នែក
ហើយវានឹងខ្សោយ ។


បន្ទាប់មកទ្រង់បានឃើញថ្ម
ដែលបានដាច់ផ្តាច់ចេញពីភ្នំ ប៉ុន្តែមិនមែន
ដោយសារដៃមនុស្សទេ។ វារមៀលចុះពីលើភ្នំ
នឹងបុកជើងរូបចម្លាក់ ហើយបានបំផ្លាញនគរ
ទាំងអស់នោះក្នុងមួយប៉ប្រិចភ្នែក។


ថ្ងនោះតំណាងរាជ្យបុត្រារបស់
ព្រះ ដែលនឹងយាងមកផែនដី
ដើម្បីតាំងនគរដ៏រុងរឿងមួយ ។
នៅពេលចុងបញ្ចប់អ្នកដែលស្លាប់
ទាំងអស់នឹងបានរស់ឡើង
ដើម្បីឈរក្នុង សេចក្តីជំនុំជំរះ ។
អ្នកដែលបានប្រព្រឹត្តអំពើអាក្រក់
នឹងទទួលសេចក្តីខ្មាសអៀន និងមើលងាយមើល
ថោកអស់កល្បជានិច្ច អ្នកដែលបានប្រព្រឹត្តល្អ
នឹងបានទទួលជីវិតអស់កល្បជានិច្ច ។




ដានីយ៉ែល
បានរស់នៅក្រុងបាប៊ីឡូនអស់រយៈពេល ៦៨ឆ្នាំ
គាត់បានបកស្រាយអំពីសុបិន្តជាច្រើន ហើយ
បានប្រាប់ពីថ្ងៃអនាគតជាច្រើនដង ។ ក្រោយមក
ស្តេចនេប៊ូក្នេសាបានសុគត ហើយបុត្រារបស់ទ្រង់
បេលសាសារ បានសោយរាជ្យជំនួសទ្រង់ ។

នៅយប់មួយស្ដេចបេលសាសារកំពុងធ្វើពិធីជប់លៀង
ហើយ ដៃដែលអាថ៌កំបាំងនឹងបានលេចមក
ហើយសរសេរនៅលើ ជញ្ជាំង
គេហៅដានីយ៉ែលមកបកប្រែវា ព្រះយេហូវ៉ា
ធ្វើឱ្យគាត់យល់ភាសាដ៏ចំណាស់នេះ ។



សាស្តា ១២:១៣-១៤, អេសាយ ៩:៦-៧,
៤៥:១, ដានីយ៉ែល ២:៣៤-៣៥, ៤៤-៤៨,
៥:១-២៩. វិវរណៈ ២០:១១-២១:៥



ហោរារបស់ព្រះបានទាយមុនថា
សត្រូវនេះនឹងវាយឈ្នះបាប៊ីឡូន
ដោយការលួចចូលយ៉ាងស្ងៀមស្ងាត់តាមទ្វារទឹកពីរ
ដែលនាំទឹកហូរ ចូលទីក្រុង ។
ពួកក្រុងបាប៊ីឡូននឹងស្រវឹងស្រាយ៉ាងខ្លាំង
មិនបាន សំគាល់អ្វីឡើយ ។
ប្រវត្តិសាស្ត្របានកត់ត្រាថា ក្រុងបាប៊ីឡូនបាន
ធ្លាក់ចុះតាមរបៀបនោះយ៉ាងពិតប្រាកដ ។

បន្ទាប់ពីសាសន៍មេឌីនិងសាសន៍ពើស៊ី បានវាយឈ្នះបាប៊ីឡូន
ដានីយ៉ែលបានរកឃើញសៀវភៅចាស់មួយដែលហោរាយេរេមាបានសរសេរ
សៀវភៅនោះជា កណ្ឌមួយនៃព្រះគម្ពីរ ។
នៅពេលគាត់កំពុងអានគាត់ឆ្ងល់ពីព្រោះគាត់ឃើញថា
កាលពីមុនព្រះបានទាយថា បាប៊ីឡូននឹងបង្ខាំងពួកគេអស់រយៈពេល៧០ឆ្នាំ ។



បន្ទាប់មកមនុស្សដែលនៅសល់ នឹងត្រឡប់ទៅទីក្រុងយេរូសាឡិម
វិញ ហើយនឹងសាងសង់កំពែងទីក្រុងនិងវិហារឡើងវិញ ។ នៅ
ពេលគាត់អានបន្តទៀត គាត់បានឃើញថា កាលពី២០០ឆ្នាំមុន
ហោរាអេសាយបានប្រាប់ដោយចំឈ្មោះផ្ទាល់របស់ស្តេច
សាសន៍ពើស៊ី ដែលនឹងបញ្ជាឱ្យពួកគេត្រឡប់ទៅវិញ ។


ឥឡូវនេះជិតចប់៦៩ឆ្នាំហើយ
សល់តែមួយឆ្នាំទៀតទេ។ បទទំនាយទាយថា
ស្តេចស៊ីរូស បំរើព្រះដោយសម្រេចតាម គំរោងការណ៍ព្រះ
ស្តេចនឹងបង្គាប់ឱ្យយើងវិលត្រឡប់ទៅស្រុកកំណើត វិញ !
មានពរដល់ទ្រង់ ឱព្រះនៃយើង ស្តេចនៃសកលលោក។




អេសាយ ៤៤:២៨, យេរេមា ២៥:១១-១២, ២៩:១០, ដានីយ៉ែល ៩:១-២


ដូចព្រះបានសន្យាជាមួយ អ័ប្រាហាំ ទ្រង់បានប្រទានដីនេះឱ្យ យើងជាកម្មសិទ្ធិអស់កល្បជានិច្ច ។ ទ្រង់បានប្រាប់ព្ធយុកោយើងថា បើសិន យើងគោរពព្រះក្លែងក្លាយទ្រង់នឹងឱ្យសត្រូវឈ្នះលើយើង ប៉ុន្តែទ្រង់សន្យា ទៀតថា ទ្រង់មិនបំភ្លេចប្រជាជាតិរបស់ទ្រង់ទេ ។ ព្រះបានធ្វើតាមបន្ទូលរបស់ ទ្រង់ ឥឡូវនេះយើងបានត្រឡប់មកវិញ យើងត្រូវតែគោរពទ្រង់ ។


យើងត្រូវចាត់ចែងឱ្យបានស្រួល ហើយ សាងសង់ជញ្ជាំងឡើងវិញមុន នឹងបន្ទាប់ មកយើងអាចសាងសង់វិហារ ។
ឱព្រះអម្ចាស់នៃព្រះ អ័ប្រាហាំ ទ្រង់ បាននាំពួកទូលបង្គំត្រឡប់មកវិញ ដូចទ្រង់បានសន្យា សូមបង្រៀនពួក ទូលបង្គំដើរតាមទ្រង់ ។
ខ្ញុំបានយកទឹកមកដល់ហើយ ចូរយើងចាប់ផ្តើមធ្វើការ ។

ដានីយ៉ែល កាន់តែចាស់ហើយដូច្នេះគាត់មិនវិលទៅស្រុកកំណើតវិញជាមួយពួកគេទេ។
ដានីយ៉ែលជាមនុស្សសំខាន់ ព្រោះគាត់ជា
អ្នកផ្ដល់យោបល់ដល់ស្ដេចនៃចក្រភពមេឌីនិងពើស៊ីដែលសោយរាជ្យនៅក្នុងទីក្រុងបាប៊ីឡូន។ ព្រះជ
ានឱ្យសុបិននិមិត្តឃើញពីថ្ងៃអនាគត រហូតដល់ថ្ងៃចុងបញ្ចប់ នូវសុបិននិមិត្តមួយគឺបិសាចដែលធ្វើពីដែក
មានទេវតា១អង្គបានប្រាប់គាត់អំពីអត្ថន័យរបស់វា។




ព្រះបានបង្ហាញឱ្យអ្នកឃើញនូវអ្វីនឹងកើតឡើងនៅថ្ងៃចុងបញ្ចប់។ ទ្រង់បានបង្ហាញប្រាប់ទៅនេប៊ូក្នេសាថានឹងមាននគរ៤។ ឥឡូវនេះ មាន២រួចហើយ បន្ទាប់ពីចក្រភព មេឌី និងពើស៊ី ហើយមាននគរក្រេក វានឹងដណ្ដើមយកជ័យយ៉ាងឆាប់រហ័ស ប៉ុន្តែនគរនោះវានឹងឆាប់ ដួលរលំ ហើយនឹងបែកជានគរបួន ដែលនឹងច្បាំងគ្នារហូតសល់តែ២។ គេនឹងច្បាំងគ្នាទៅវិញទៅមកជាច្រើនឆ្នាំ រហូតដល់នគរទី៤ច្បាំង ឈ្នះគេ បិសាចដែលធ្វើពីដែកតំណាងឱ្យនគរទី៤។

## ដានីយ៉ែល ៧:១៧-២៨,
## ម៉ាថាយ ២៤:៤-២៥



នគរទី៤នឹងដូចជាដែកដែលមានអំណាចកាចសាហាវជាងនគរ
មុនទាំងអស់ ។ នគរទី៤នឹងវាយឈ្នះនគរផ្សេងទាំងអស់ ប៉ុន្តែ
នៅថ្ងៃចុងបញ្ចប់ នគរនេះនឹងញែកបែកជាប្រទេស១០ ។ ប៉ុន្តែនឹងមាន
បុរសម្នាក់ដែលនិយាយពីសន្តិភាព គាត់គឺជាស្នែងដែលលូតក្រោយគេចេញពី
ក្បាលបិសាច ។ នៅក្នុងថ្ងៃចុងបញ្ចប់គាត់នឹងបញ្ឆោរមនុស្សហើយនឹងសន្យាថានឹងមាន
មេត្រីភាព ប៉ុន្តែគាត់នឹងវាយបំផ្លាញ បន្ទាប់មកគាត់នឹងដាក់របស់ដែលគួរឱ្យស្អប់ខ្ពើម
ក្នុងកន្លែងទីបរិសុទ្ធនៅវិហារសាសន៍យូដា ដែលធ្វើឱ្យខូចដល់ទីបរិសុទ្ធ ដូច្នេះគេ
ឈប់ថ្វាយដង្វាយនៅកន្លែងនោះ ។ ក្រោយមកនឹងមានសេចក្តីទុក្ខវេទនាយ៉ាងខ្លាំង
នៅលើផែនដីទាំងមូល ប៉ុន្តែមនុស្សដែលសុចរិតនឹងត្រូវបានសង្គ្រោះ ។

ទេវតាក៏មានបន្ទូលទៅដានីយ៉ែល ទៀតថា...

ដានីយ៉ែល ព្រះត្រូវការឱ្យអ្នកដឹងពីអ្វីដែលនឹងកើតឡើងនៅថ្ងៃខាងមុខ
ហើយពេលវេលាដែលវានឹងកើត ឡើងដែរ ។

ពីពេលដែលគេបានបង្គាប់ឱ្យសាងសង់វិហារឡើងវិញវានឹងមាន៤៨៣ឆ្នាំ
ក្រោយមកគេនឹង សម្លាប់ព្រះមែស៊ីសម្រាប់លោះបាបមនុស្សលោក
នឹងបន្ទាប់មកគេនឹងបំផ្លាញវិហារម្តងទៀត ។






"ព្រះមែស៊ី គឺជាភាសាហេព្រើរដែលមានន័យថា ព្រះសង្គ្រោះ" ដានីយ៉ែល ៩:២៥-២៦, ម៉ាថាយ ២៤:១-២, ហេព្រើ ២:៩

ព្រះមែស៊ីបានចូលក្នុងទីក្រុងយេរូសាឡិមដូចជាថ្ងៃជ័យជំនះរបស់ទ្រង់
នៅចំថ្ងៃដែល៤៨៣ឆ្នាំនោះគ្រប់កំណត់ដូច ដានីយ៉ែល
បានកត់ត្រាទុក ។ ព្រះបានមានបន្ទូលប្រាប់ អ័ដាម និង
អេវ៉ា ថា ពូជនៃស្ត្រីនឹងបានបំផ្លាញមេអារក្សសាតាំង ។
ទ្រង់បានប្រាប់ ណូអេថា ព្រះមែស៊ីនឹងយាងមកតាមពូជ សិម មិនមែនតាមពូជ
យ៉ាផែត ឬ ហាំ ទេ ។ ព្រះអម្ចាស់មាន បន្ទូលប្រាប់អ័ប្រាហាំទៀតថា
ព្រះសង្គ្រោះនឹងយាងមកតាមវង្សត្រកូលរបស់គាត់តាមរយៈអ៊ីសាក ព្រះក៏បាន
ប្រាប់អ៊ីសាកថា ព្រះសង្គ្រោះដែលទ្រង់បានសន្យានឹងយាងមកតាមរយៈ យ៉ាកុប
ហើយទ្រង់បាន ប្រាប់យ៉ាកុបថា ព្រះគ្រីស្ទនឹងយាងមកតាមរយៈ យូដា ។

នោះមានបទទំនាយជាច្រើនដែលព្រះបានប្រទានឱ្យហោរាផ្សេងៗ
ពួកគេបានទាយអំពីជីវិតរបស់ ព្រះសង្គ្រោះ ដែលព្រះបានសន្យានឹងយាងមក។
នៅខាងក្រោមនេះមានបទទំនាយខ្លះៗដូចជា ...

**សាការី ៩:៩** ទ្រង់ក៏សុភាព ទ្រង់គង់លើខ្នងសត្វលា **មីកា ៥:២**
ដើមកំណើតរបស់អ្នកនោះបានចាប់តាំង ពីបុរាណគឺពីអស់កល្បរៀងមក
**លោកុប្បត្តិ ៤៩:៩-១០** ស៊ីឡូរ កូនប្រុសរបស់យូដា
**អេសាយ ៧:១៤** ស្ត្រីព្រហ្មចារីមានគភ៌ដោយព្រះវិញ្ញាណបរិសុទ្ធ
**អេសាយ ៩:១-២** ខេត្តកាលីឡេរបស់សាសន៍ដទៃ (គេចាប់ផ្ដើម
ហៅថាខេត្តកាលីឡេនៅគ្រាដែលព្រះគ្រីស្ទយាងមក)

**ទំនុកដំកើង ២២** ការឈឺចាប់របស់ព្រះមែស៊ី **អេសាយ ៥៣** ទ្រង់ត្រូវបានគេបោះបង់ចោលហើយនឹងសុគត ដោយព្រះហស្ថនិងព្រះបាទរបស់ទ្រង់ត្រូវគេដំទម្លុះ ទ្រង់ត្រូវ គេឆ្កាងដោយអាក្រាត ទ្រង់បានស្រេកទឹក ប៉ុន្តែគេឱ្យទឹកខ្មេះផឹកជំនួស ទ្រង់នឹងសុគតនៅកណ្ដាលនៃពួកចោរ ហើយនឹងបានបញ្ចុះសពនៅក្នុងផ្នូររបស់អ្នកមាន ។

**អេសាយ ៤២:១** ដាក់វិញ្ញាណអញលើទ្រង់ ទ្រង់នឹងយកការកាត់ក្ដីទៅសាសន៍ដទៃ **អេសាយ ៤៩:៦** ទ្រង់នឹងធ្វើជាពន្លឺដល់សាសន៍ដទៃ ហើយទ្រង់នឹងនាំសេចក្ដីសង្គ្រោះ ដល់មនុស្សនៅលើផែនដី **អេសាយ ៥៣:២-៣** ទ្រង់បន្ទាបខ្លួនក្នុងការបង្ហាញខ្លួន ។

បទទំនាយរបស់ ដានីយ៉ែល អំពីនគរទាំង៤ឬ
ានកើតមកដូចជាដានីយ៉ែលបានទាយប្រាកដមែន ។ នៅឆ្នាំ៣៣០មុន
គ.ស. អាលិចសេនឌឺ ទ្រង់ជាអ្នកល្បីល្បាញដែលមកពីប្រទេសក្រេក
ចាប់ផ្ដើមធ្វើយុទ្ធនាការតទៅដល់គំរប់៧ឆ្នាំ
ក្នុង៧ឆ្នាំនោះទ្រង់បានវាយឈ្នះប្រទេសទាំង
អស់នៅលើពិភពលោកដែលទ្រង់ស្គាល់ រួមទាំងចក្រភព មេឌី និង
ពើស៊ីដែរ ប្រទេសក្រេកបានគ្រប់គ្រងរហូតដល់ប្រហែលឆ្នាំ១៦៧មុន
គ.ស. ។

នៅឆ្នាំនោះនគរទី៤ គឺរ៉ូម ចាប់ផ្ដើមមានជ័យជំនះទន្ទ្រានយក
នគរផ្សេងៗទៀតក្នុងពិភពលោក
នគររ៉ូមបានតំណាងក្នុងសុបិន៍និមិត្តរបស់ នេប៊ូក្នេសា
ដូចជាបាតជើងនិងជើងធ្វើពីដែក ហើយបានតំណាងក្នុងសុបិន្តរបស់
ដានីយ៉ែល ដូចជាបិសាចដែលធ្វើពីដែក
បានរីកចំរើនក្នុងអំណាចនឹងទឹកដីដូចហោរាបានទាយ ។
ដល់ឆ្នាំទី៩មុន គ.ស.
នគររ៉ូមគ្រប់គ្រងអ៊ីស្រាអែលដោយកណ្ដាប់ដៃដែក។

# ៥០០ឆ្នាំក្រោយមក

ចាង៥០០ឆ្នាមបានកន្លងផុតតោតាមងបិហោរាដានិយ៉េលបានតាយ ។ នោ៦ឆ្នាមមុន ក.ស. ចនចាតិរ៉ុមបានឱ្យសាសន៍យុដា មានសេរិផាបក្នុងការកោរបសាសនារបស់កេ ប៉ុន្តេកេរតុវការបង់បន្ទខ្ពស់ ។ របហរិហាររតុវបានសាងសង់លើងវិញ ហើយវាក្លាយចា មច្ឈមន្ទលចិរិតនៃចនចាតិយុដា មនុស្សផាករេចិនបានផ្លេចបិបតតមនាយនៃការយាងមករបស់របហាមេសិ ប៉ុន្តេខ្លួហនោដេរតាមរកឹត្យវិន័យហើយរងចាមមើលរបហារកិស្ត ។ ក្នុងចមនោមបយកកេមានបុរសចមនាស់ម្នាក់ឆ្មោហស៉ិម្មាន កាត់កីចាមនុស្សបរិសុត្ឋម្នាក់ ដេលរងចាំមហើយនឹងចង់ខេិញម្នាក់ដេលហោរាបានតាយ កាត់បានងានបតតមនាយចាយុរឆ្នាមមកហើយ កាត់ដឹងថា ចិតដល់បេលរបហាមេសិយាងមក ។ ប៉ុន្តេឥលវ៉នេហកាត់កាន់តេចាស់នាស់តោហើយ របហោលមិនងាចរស់បានយុរតៀតតេ ។ ៤០០០ឆ្នាមបានក់ន្លងផុតតោ តាមងបិរបហងម្ចាស់បានសន្យាចាមយយ ងេវ៉ា ថា បុចរបស់នាងនឹងមក ហើយបមផ្លាញការរបរបឹត្តិនៃមេងារកសសាតាមង ។

**បិតចាដល់បេលហើយ ។ បន្តិចតៀតចាង៣៥០បតតមនាយនឹងបានបមបេញ ។**



## ជំពូក ៨

# សញ្ញាថ្មីការប្រសូត្រ-របស់ព្រះគ្រីស្ទ និង-ការល្បួងរបស់ទ្រង់


៦ឆ្នាំមុន គ.ស.
ព្រះនៃអ័ប្រាហាំ អ៊ីសាក និង យ៉ាកុប ខ្ញុំបានរងចាំ អ្នកសង្គ្រោះ ប៉ុន្តែខ្ញុំមិនរស់យូរទៀតទេ។
ពិតមែនឯងមិនរស់នៅរយៈពេលយូរទៀតទេ ប៉ុន្តែឯងនឹងបានឃើញអ្នកសង្គ្រោះមុនពេលស្លាប់។


ស៊ីម្មានបានស្រាវជ្រាវក្នុងគម្ពីរ ហើយបានឃើញ
បទទំនាយជាច្រើនដែលនិយាយអំពីព្រះគ្រីស្ទ ។
ស៊ីម្មាន អ្នកមកនេះរាល់ថ្ងៃ ខ្ញុំចង់ឱ្យ
សម្តេចសង្ឃផ្សេងទៀតជឿស៊ប់ដូចអ្នកដែរ ។


អ្នកគិតយ៉ាងដូម្ដេចពីបទទំនាយក្នុងគម្ពីរអេសាយ
អំពីព្រះគ្រីស្ទ ?
ព្រហ្មចារិនីម្នាក់នឹងមានគភ៌ នឹង
ប្រសូត្របានបុត្រាមួយនេះហើយគឺជាពូជនៃស្ត្រី
ដូចដែលព្រះមានបន្ទូលទៅអេវ៉ា ។
បាទ គម្ពីរអេសាយបានថែងទៀតថា
ទ្រង់ត្រូវ បានហៅថា
ព្រះដ៏មានព្រះចេស្ដា ប៉ុន្តែបទទំនាយ
ជាច្រើនហាក់ដូចជាពិបាកយល់ណាស់ ។


តាមគម្ពីរមីកា ៥:២
ព្រះរាជបុត្រាគ្មានកំណត់ដូចជា
ព្រះដែរ ហើយយ៉ាងម៉េចដែរអំពី
បទទំនាយនៅក្នុងគម្ពីរទំនុកដំកើង
៤៥:៦ ដែលព្រះវរបិតាហៅ
ព្រះរាជបុត្រាជាព្រះដែរ ?
នោះមានមនុស្សតិចតួចណាស់
ដែលយល់ព្រមជាមួយអ្នក នេះជាហេតុ
ដែលអ្នកមិនត្រូវនិយាយនៅសាធារណៈទេ
ប្រយ័ត្នគេសម្លាប់អ្នកគប់នឹងដុំថ្ម ។
អ្នកនឹងឃើញ ។ ព្រះមែស៊ីនឹងយាងមកកាន់វិហារ នេះ
ហើយខ្ញុំនឹងឃើញទ្រង់មុនពេលខ្ញុំស្លាប់ ។


គាត់ប្រហែលជា និយាយត្រូវ ។
ឯងជានរណា ? តើឯង ដឹងអ្វីអំពីរឿងទាំងនេះ ?


ខ្ញុំបានឮលោកនិយាយគ្នា។
ខ្ញុំបានរៀនគម្ពីរច្រើនដែរ ហើយ
៥០០ឆ្នាំមុនដានីយ៉ែលបាននិយាយ
ខ្លះៗដែលគួរឱ្យចាប់អារម្មណ៍ ពីពេល
ដែលព្រះមែស៊ីនឹងយាងមក។
លោកុប្បត្តិ ៣:១៥,
ទំនុកដំកើង ៤៥:៦, អេសាយ
៧:១៤, ៩:៦, ដានីយ៉ែល
៩:២៥-២៦, មីកា ៥:២,
លូកា ២:២៥-២៦
តើលោកអាចដឹងរឿង
ទាំងនេះយ៉ាងម៉េចកើត?


ឪពុករបស់ខ្ញុំជាអាចារ្យដែរ ហើយគាត់បានបង្ហាញខ្ញុំពីបទទំនាយនោះ ។ ព្រះបានមានបន្ទូលប្រាប់ដានីយ៉ែលថា ពីពេលបញ្ជាឱ្យសាងសង់ក្រុង យេរូសាឡិមឡើងវិញ រហូតដល់ព្រះមែស៊ីត្រូវផ្ដាច់ចេញគឺ៤៨៣ឆ្នាំ ។
តាំងពីបានបង្កើតព្រះរាជក្រឹត្យឱ្យ សាងសង់យេរូសាឡិមវិញវាអស់៤៤៩ឆ្នាំ ហើយ នៅសល់តែ៣៤ឆ្នាំទៀត នេះមាន ន័យថា ប្រហែលព្រះមែស៊ីកំពុងយាង តាមផ្លូវទីក្រុងយើងឥឡូវនេះ ។


ទេ មិនទាន់ទេ ព្រះវិញ្ញាណបានបង្ហាញឱ្យខ្ញុំឃើញថា មុនខ្ញុំស្លាប់ ខ្ញុំនឹងឃើញព្រះឱរសមែស៊ី នៅក្នុងវិហារនេះ។
តើឯងដឹងអ្វីដែលពួកអាចារ្យមិនដឹង ?
ឯងនឹងឃើញ

សុីម្មានកាន់តែមានវ័យចាស់ ហើយ
គាត់កំពុងរង់ចាំព្រះគ្រីស្ទដែលបាន
សន្យានឹងយាងមកនៅក្នុងវិហារ ។
សង្ឃមួយអង្គដែលមានឈ្មោះថា
សាការី បានចូលទៅក្នុងវិហារដើម្បី
អធិដ្ឋាន គាត់និងប្រពន្ធរបស់គាត់
មានវ័យចំណាស់ទៅហើយ
ប៉ុន្តែពួក គេមិនដែលមានកូនទេ ។


រំពេចនោះ ទេវតាមួយអង្គបាន លេចមកនៅខាងស្តាំនៃអាសនៈ ។
កុំភ័យខ្លាចអី ការអធិដ្ឋានរបស់ លោកទ្រង់បានព្រះសណ្តាប់ហើយ ប្រពន្ធរបស់លោក អេលីសាបិត នឹងបង្កើតកូនប្រុសមួយ ហើយត្រូវ ឱ្យឈ្មោះថា យ៉ូហាន ។
មនុស្សជាច្រើននឹងមានអំណរនៅពេលវាកើតមក ពីព្រោះវាគឺជាម្នាក់ដែលនឹងរៀបចំមនុស្សសម្រាប់ការ យាងមករបស់ព្រះមែស៊ី ។ វាឥតផឹកស្រាឬអ្វីដែលស្រវឹង ហើយវានឹងទទួលវិញ្ញាណនិងអំណាចរបស់អេលីយ៉ា ។


តើខ្ញុំអាចដឹងយ៉ាងម៉េចនូវអ្វីដែលលោកនិយាយនឹង
កើតឡើងពិតប្រាកដ ? ប្រពន្ធខ្ញុំនិងខ្ញុំចាស់ណាស់ហើយ
នាងជាស្រីអារពេញមួយជីវិតរបស់នាង ។
ខ្ញុំជា កាព្រីយ៉ែល ដែលឈរនៅចំពោះ
ព្រះភក្ត្រទ្រង់ ហើយព្រះបានបញ្ជូនខ្ញុំឱ្យប្រាប់
លោកពីដំណឹងនេះ ។ ដោយលោកមិនជឿ
ពាក្យខ្ញុំ មើល លោកនឹងគរហូតដល់បាន
ឃើញអ្វីៗទាំងនេះនឹងកើតមក ។


អូននឹងសប្បាយចិត្ត នៅពេលយើងអាចនិយាយគ្នាអំពីរឿងនេះ ។ ផ្ទះនេះស្ងាត់ណាស់ បងមិនគួរតមាត់ជាមួយទេវតាទេ ។
ដឹងទេ បងសាការី នេះនៅតែពិបាកជឿ ដូចសារ៉ាមាតា នៃប្រជាជាតិយើង ព្រះបានឮការអធិដ្ឋានរបស់យើង ហើយ ឥឡូវនេះអូននឹងធ្វើជាមាតារបស់ហោរាដ៏អស្ចារ្យ ។

អស់រយៈពេល៤០០០ឆ្នាំ ហោរាបានប្រាប់មុនអំពី
ការយាងមករបស់ព្រះមែស៊ី ។ ៧០០ឆ្នាំមុនហោរា
អេសាយបាននិយាយថា “**មើលនាងព្រហ្មចារី
នឹងមានគភ៌ប្រសូត្របានបុត្រា១
ហើយនឹងថ្វាយព្រះ នាមថា
អេម៉ាញូអែល ដែលមានន័យថា ព្រះអង្គ
គង់នៅជាមួយនឹងយើងខ្ញុំ**” ។





ម៉ារា ជាស្រីក្រមុំព្រហ្មចារីម្នាក់
នៅភូមិណាសារ៉ែត ស្រុកកាលីឡេ
បានភ្ជាប់ពាក្យដើម្បីរៀបការជាមួយយ៉ូសែប
នាងមិនដែលបាន
ស្និទ្ធស្នាលស៊ីជម្រៅជាមួយបុរសណាម្នាក់ទេ
នាងបានគោរពតាម
ក្រឹត្យវិន័យទាំងអស់របស់លោក ម៉ូសេ។


រំពេចនោះទេវតាមួយអង្គបានលេចមកជួបនាងម៉ារា !
ម៉ារាអើយ នាងបានគាប់ព្រះហឫទ័យ ចំពោះព្រះ នាងនឹងមានគភ៌ ហើយ ប្រសូត្របានរាជបុត្រារបស់ព្រះ ។
តើវាកើតឡើងដូចម្ដេច ព្រោះខ្ញុំមិនធ្លាប់ ទាក់ទងជាមួយបុរសណាម្នាក់សោះ?


ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះបានសណ្ឋិតលើនាង
ទារកដ៏បរិសុទ្ធដែល
នឹងចាប់ផ្ដើមមានកំណើតក្នុងផ្ទៃរបស់នាង
គឺជាព្រះរាជបុត្រារបស់ព្រះ ។
បងជីដូនមួយរបស់នាងអេលីសាបិត
គេធ្លាប់ហៅថាស្រីអារនោះ ឥឡូវមានគភ៌
ហើយនេះគឺជាខែទី៦របស់នាង ។

"ព្រះមែស៊ី គឺជាភាសាហេព្រើរដែលមានន័យថា ព្រះសង្គ្រោះ" អេសាយ ៧:១៤,
ម៉ាថាយ ១:២៣, លូកា ១:៥-២០, ២៦-៤០




បងអេលីសាបិត !
ម៉ារាប្អូនស្រីអើយ!


ក្នុងបណ្ដាពួកស្រីៗ នាងមានពរច្រើន ជាងគេ ព្រមទាំងកូននៅក្នុងផ្ទៃនាងផង ។ ខ្ញុំជានរណា បានជាមាតារបស់ព្រះក៏មកលេងដែរ ? ពេលខ្ញុំឮសំលេងរបស់នាងនោះកូនដែលនៅក្នុងផ្ទៃរបស់ខ្ញុំក៏បម្រះឡើងដោយក្ដីរីករាយ ។
ព្រលឹងរបស់ខ្ញុំលើកដំកើងព្រះ ហើយវិញ្ញាណ របស់ខ្ញុំក៏រីករាយនឹងព្រះ ដ៏ជាព្រះសង្គ្រោះនៃខ្ញុំ ពីនេះទៅមុខគ្រប់ទាំងដំណមនុស្សនឹងរាប់ខ្ញុំថា ជាអ្នកមានពរ ពីព្រោះទ្រង់បានប្រោសសេចក្ដីយ៉ាងល្អវិសេសដល់ខ្ញុំ ។


ម៉ារា បានស្នាក់នៅជាមួយ
អេលីសាបិតអស់រយៈពេល៣ខែ ។
ទ្រង់បានលើកដំកើងយើង ដែលយើងជាមនុស្សទាបថោក ។ ដូច
ទ្រង់មានបន្ទូលទៅអ័ប្រាហាំ ទ្រង់បាន នឹកចាំយើងក្នុងក្តីមេត្តាករុណា ។


ដល់ពេលអេលីសាបិតប្រសូត្របុត្រហើយ
សាការី ដឹងច្បាស់ថា កូនរបស់គាត់នឹងពិតជាប្រុស គាត់និយាយថា ទេវតាមួយអង្គ បានប្រាប់គាត់ដូច្នេះ ។
បើសិនវាជាប្រុស ខ្ញុំគិត ថាគេនឹងដាក់ឈ្មោះ សាការី តាមឪពុករបស់វា ។
គាត់មកដល់ហើយ សូមសួរគាត់ ។


គាត់បាននិយាយថា ទេវតាបានធ្វើ ឱ្យគាត់គ ពីព្រោះគាត់មិនជឿ ។
តើកូនរបស់លោក ដាក់ឈ្មោះអ្វី ?
គាត់ចង់បានក្ដារឆ្នួនសរសេរ ។


គាត់ថា
ឈ្មោះកូនរបស់គាត់ត្រូវហៅថា យ៉ូហាន
ដូចដែលទេវតាបានប្រាប់ ។
ប៉ុន្តែវង្សដំណគាត់គ្មានអ្នកណា
ម្នាក់ឈ្មោះយ៉ូហានទេ ។


វាជាក្មេងប្រុស
ដែលមានរោមច្រើន ។


ឈ្មោះរបស់វាគឺ យ៉ូហាន តាមបន្ទូល របស់ព្រះជាម្ចាស់ វានឹងណែនាំប្រជាជន អ៊ីស្រាអែលឱ្យស្គាល់ព្រះមែស៊ី ។
អ៊ូំ គាត់និយាយ...! គាត់គអស់រយៈពេលជាច្រើនខែ ឥឡូវបាននិយាយរួចវិញ !
តើទារកនេះអាចជាអេលីយ៉ា ដែលបទទំនាយបានទាយ មែនឬ

# លូកា ១:៤១-៦៤


នៅគ្រានោះ យ៉ូសែបបានដឹងថា ម៉ារាមានគភ៌
ហើយគាត់ដឹងថា វាមិនមែនជាកូនរបស់គាត់ទេ។
ម៉ាក់ ខ្ញុំនៅតែពិបាកជឿ
គ្មានបុរសណានៅក្បែរនាងទេ
នាងបាននៅជាមួយក្រុមគ្រួសារ
របស់នាងគ្រប់វិនាទី ខ្ញុំមិនបាន
ប្រព្រឹត្តការនេះទេ ! ប៉ុន្តែការ
ពិតនាងមានគភ៌ ។


អូ៎ យ៉ូសែប តើ
កូនគិតយ៉ាងម៉េច ?
ឥឡូវនេះខ្ញុំមិនអាចរៀបការជាមួយនាង
ប៉ុន្តែខ្ញុំមិនចង់ឱ្យរឿងនេះលេចឮជាសាធារណៈ
ទេ នាងអាចនឹងត្រូវគេគប់សម្លាប់នឹងដុំថ្ម
ចំពោះការផិតក្បត់ ។ ប្រហែលយើងអាច
ផ្ដាច់ពាក្យដោយស្ងៀមស្ងាត់វិញ ។


តើនាងបានប្រាប់ថា អ្នកណាជាឪពុក ?
ម៉ារានិយាយថា បុត្រដែលមកចាប់ទំក្នុងផ្ទៃនាងគឺកើតពីព្រះវិញ្ញាណបរិសុទ្ធ ដោយគ្មានការទាក់ទងខាងសាច់ឈាមទេ។


អ៊ូ! នាង ឡប់សតិឬ?
នាងនិយាយថា ក្មេងនេះ ត្រូវបានធ្វើជាអ្នកសង្គ្រោះ នៃមនុស្សលោក គឺព្រះ រាជបុត្រារបស់ព្រះ ។
នោះគឺជាការប្រមាថចំពោះស្ត្រីណាដែល និយាយដូចនេះ ។ យើងត្រូវផ្តាច់ពាក្យយ៉ាងឆាប់ រហ័សដោយស្ងៀមស្ងាត់ដែលអាចធ្វើបាន ។


នៅយប់នោះពេលយ៉ូសែបកំពុងដេកលក់ មានទេវតាមួយអង្គបានបង្ហាញដល់គាត់ ។
យ៉ូសែប
ពូជរបស់ហ្លួងដាវីឌអើយ កុំខ្លាច
យកនាងម៉ារាធ្វើជាប្រពន្ធរបស់អ្នកឡើយ
ដ្បិតបុត្រនោះកើតឡើងដោយព្រះវិញ្ញាណ
បរិសុទ្ធ នាងនឹងប្រសូត្របានបុត្រាមួយអង្គ
ហើយអ្នកត្រូវថ្វាយព្រះនាមថា យេស៊ូវ
ព្រោះបុត្រនោះនឹងជួយសង្គ្រោះរាស្ត្រ
របស់ទ្រង់ឱ្យរួចពីអំពើបាប ។


នេះជាការបំពេញនៃបទទំនាយ
របស់ហោរាអេសាយ "ស្រីក្រមុំ
ព្រហ្មចារីម្នាក់នឹងមានគភិ ប្រសូត្រ
បានបុត្រាមួយអង្គដែលត្រូវហៅថា
អេម៉ាញូអែល ដែលមានន័យថា
ព្រះអង្គគង់ជាមួយយើង"។


ម៉ារា បងមានការសង្ស័យ លើអូន តើអូនអាចអត់ទោស ឱ្យបងបានទេ ?
អ៎ូមិនអីទេបង នេះគួរឱ្យអស្ចារ្យណាស់ ក្នុងចំណោមស្ត្រីទាំងអស់ទូទាំងអ៊ីស្រាអែល និង គ្រប់សតវត្សមកហើយ ព្រះអម្ចាស់បានជ្រើសរើស អូនដើម្បីនាំព្រះមែស៊ីមកកាន់ពិភពលោក ។


តើទារកនឹងមានលក្ខណៈដូចម្ដេច
? ពីព្រោះវាជា ព្រះដែលគង់ក្នុងសាច់ឈាម
តើវានឹងកើតមកចេះ និយាយឬ ?
តើវាចេះអានអក្សររួចហើយឬ ?
អ៊ុំ យ៉ូសែប
អូនមិន ដឹងទេ ប៉ុន្តែព្រះដឹង យើង
នឹងរងចាំមើល ។

លោកុប្បត្តិ ៣:១៥, អេសាយ ៧:១៤, ៩:៧, ម៉ាថាយ ១:១៨-២៣, លូកា ១:៣២-៣៣




ចូរស្តាប់ៗ អ្នកទាំងអស់គ្នា នេះជារាជសារ ជាផ្លូវការ
ប្រកាសពីស្តេច រ៉ូម សេសា បានស្នាព្រះហស្ថរបស់ទ្រង់ផ្ទាល់ ។
នគររ៉ូមនឹងជំរឿនមនុស្សទាំងអស់នៅអ៊ីស្រាអែល
ឱ្យវិលត្រឡប់ ទៅទីក្រុងកំណើតរបស់ពួកគេវិញ
ដើម្បីចុះបញ្ជីបង់ពន្ធ ។


យ៉ូសែបនិងម៉ារាបានរស់នៅណាសារ៉ែត ស្រុកកាលីឡេ ប៉ុន្តែមានបទទំនាយពី បុរាណបានទាយថា ព្រះមែស៊ីត្រូវបាន ចាប់កំណើតនៅទីក្រុងបេថ្លេហិមនៃ ស្រុកយូដា ( មីកា ៥:១) ពួកគេមិនដឹង ពីបទទំនាយនោះ នឹងគ្មានមូលហេតុធ្វើ ដំណើរឆ្ងាយទៅបេថ្លេហិមទេ បើសិន គ្មានសភាពការណ៍កើតឡើង ដែលធ្វើ ឱ្យពួកគេត្រូវទៅបេថ្លេហិម ម៉ារានឹង ប្រសូត្របុត្រនៅទីក្រុងខុសពីបទទំនាយ ។


បងយ៉ូសែបនោះមានន័យថា បងត្រូវទៅទីក្រុងបេថ្លេហិម ហើយ បងនឹងនៅទីនោះ នៅពេលបុត្រ ប្រសូត្រមក ។
បើសិនបងមិននៅ ពេលដែលបុត្រ ប្រសូត្រមក មនុស្សទាំងអស់នឹងរិះគន់ ដូច្នេះបងនឹងយកអូនទៅជាមួយ ។


ម៉ារាអូន
បងមិនគួរ
នាំអូនធ្វើដំណើរជាមួយ
បងទេ ប្រហែលយើង
គួរតែត្រឡប់ទៅវិញ។
ទេ អូនត្រូវតែនៅជាមួយ
បង ពេលទារកកើតមក គ្មាន
នរណាផ្សេងទៀតយល់អំពី រឿងយើងទេ។


ប្រញាប់ឡើងបង បើសិនបងអាចទៅឱ្យលឿនបាន អូនគិតថាដល់ពេលហើយ ។
ត្រូវចំណាយពេលជាងមួយសប្តាហ៍ ដើម្បីធ្វើដំណើរប្រហែល១៦០ គ.ម.
បងនឹងទៅផ្ទះសំណាក់ប្រហែលបងអាចរកបន្ទប់មួយ ។


ម៉ារាអូន បងបានរកឆ្មប ដែលអាចនឹងជួយអូនបាន ។
ផ្ទះសំណាក់ គ្មានបន្ទប់ទេឬ ?
គ្មានទេ វា ពេញហើយ ។


នាងពិតជាសម្រាលកូនដំបូងបានល្អមែន ។ គួរឱ្យអាណិតណាស់ដែលវាបានកើតមកក្នុងក្រោលសត្វ ។
កុំខ្វល់ពីរឿងនេះ វានឹងគ្រប់គ្រងពិភពលោកនៅថ្ងៃណាមួយ ។
ថាម៉េច...! ខ្ញុំឃើញវាដូចជាកូនង៉ែតធម្មតា ។

លូកា ២:១-៧



នៅពេលដដែលនោះអ្នកគង្វាលចៀមបានឃើញមាន
ទេវតានៃព្រះអម្ចាស់បានលេចមកដោយមានសិរីល្អ
របស់ទ្រង់ភ្លឺឆ្វាត់ជុំវិញ ធ្វើឱ្យពួកគេភ័យខ្លាចយ៉ាងខ្លាំង ។
អីយ៉ា ! មានទេវតា រាប់ពាន់ !


នេះជាទីសំគាល់ដល់អ្នករាល់គ្នា
អ្នកនឹង ឃើញព្រះឱរសដែលរុំដោយសំពត់ស្នប
ហើយកំពុងផ្ដេកក្នុងស្នូកសត្វមួយ ។
សិរីល្អមានដល់ព្រះដ៏ខ្ពស់បំផុត!
ព្រះនាំសេចក្ដីសុខសាន្តដល់ផែនដី
ព្រោះទ្រង់មានព្រះហឫទ័យល្អ
ចំពោះមនុស្សលោក ។


អ្នកទាំងអស់ជឿទេ ? ទេវតា បានលេចមកឱ្យយើងឃើញ !
តើអ្នកឮអ្វីដែលពួកទេវតាមានបន្ទូលទេ ? ព្រះមែស៊ីបានចាប់កំណើតនៅអ៊ីស្រាអែលហើយ ។
ប្រពន្ធរបស់ខ្ញុំនឹងឆ្ងល់ នៅពេលខ្ញុំប្រាប់ !
ខ្ញុំចង់ទៅមើលដែរ !
ព្រះសង្គ្រោះ ! សេចក្តីសុខសាន្ត ដល់មនុស្សលោក ! ព្រះឱរស ឬ ? ចូរយើងទៅមើល !


លូកា ២:៨-២០
សូមទោស ពួកយើងរំខានដល់ អ្នក ប៉ុន្តែទេវតាមួយអង្គបានប្រាប់ យើងឱ្យមកទីនេះ ។
ព្រះមែស៊ី !
គ្មានអ្នកណានឹកស្មានដល់ថា ព្រះ ជាម្ចាស់នឹងកើតជាព្រះឱរស ។


ម៉ារានិងយ៉ូសែបនាំព្រះឱរសទៅជួបសម្ដេច សង្ឃហើយថ្វាយយញ្ញបូជា
ដែលក្រឹត្យវិន័យ បានចែងតាមទម្លាប់របស់ជនជាតិយូដា ។
បងយ៉ូសែប
នេះជាលើកដំបូង
ដែលយើងនាំកូនមកវិហារ ហើយ
នៅទីនោះគ្មានអ្នកណាម្នាក់ដឹងថា
យេស៊ូវគឺជាព្រះគ្រីស្ទ ។
ហើយបងគិតថា យើង
មិនគួរប្រាប់អ្នកណារហូត
ដល់កូនធំដឹងក្ដី ។


ស៊ីម្មាន តែងតែនៅក្នុងវិហារដូចធម្មតា ។
នោះគឺជាទ្រង់ ! យើងបាន
រងចាំយូរណាស់មកហើយ ។
ម៉ារាអូន
គាត់ជាអ្នកណា ?
អូនមិនដឹង នៅ
ទីនេះគ្មានអ្នកណា
ស្គាល់យើងទេ ។


មានពរហើយឱព្រះជាម្ចាស់នៃយើង ។
ឥឡូវខ្ញុំអាចស្លាប់ ដោយភាពសុខសាន្តក្នុងចិត្ត
ព្រោះខ្ញុំបានឃើញសេចក្ដីសង្គ្រោះ របស់ព្រះអង្គ
ដូចដែលទ្រង់បានសន្យា ។ ទ្រង់នឹងធ្វើជាពន្លឺ ដល់សាសន៍ដទៃ
ហើយជាសិរីល្អនៃអ៊ីស្រាអែលដែរ ។
ប៉ុន្តែលោកតាដឹង
ដោយរបៀបណា ?


ស្តាប់ខ្ញុំ ព្រះឱរសនេះនឹងបណ្តាលឱ្យមនុស្សជាច្រើននៅក្នុងអ៊ីស្រាអែលដួលនិងងើបឡើងវិញ ហើយគេនឹងនិយាយជំទាស់នឹងទ្រង់ផង។
ហើយអ្វីដែលនាងឃើញកើតមានឡើងចំពោះទ្រង់ បានធ្វើឱ្យចិត្តរបស់នាងខូចខ្ទេចខ្ទាំ។


មើលន៎ ! ព្រះមែស៊ី ទ្រង់បាន
យាងមកកាន់វិហាររបស់ទ្រង់ នេះជាអង្គ
ទ្រង់ដែលហោរាបានទាយប្រាប់មុន ។
នោះហើយគឺ យាយអាណ យាយបានចំណាយពេលអស់មួយជីវិត
របស់យាយក្នុងការរងចាំព្រះមែស៊ី ។


ចៅប្រុស ក្មេងនោះគឺជាព្រះគ្រីស្ទ ព្រះ
សង្គ្រោះនៃពិភពលោក ។ ទ្រង់នឹងជួយសង្គ្រោះ
អ៊ីស្រាអែលឱ្យរួចពីអំពើបាបរបស់ពួកគេ ។
ចាប់ពីពេលនេះទៅ យាយអាណេ ថ្លែងពីទ្រង់ប្រាប់
មនុស្សទាំងអស់ដែលរងចាំសេចក្ដីសង្គ្រោះ ។
លូកា ២:២៧-៣៨

ប្រទេសដែលនៅខាងកើតអ៊ីស្រាអែល
នោះមានអ្នកប្រាជ្ញដែលសិក្សាពីបុរាណវិទ្យា
ហើយស្វែងរកដើម្បីយល់ពីព្រះ
ពួកគេបានដឹង
ពីបទទំនាយនៃការយាងមករបស់ព្រះមែស៊ី
ក្នុងសុបិននិមិត្ត ព្រះបានបង្ហាញឱ្យពួកគេ
ឃើញពីការចាប់កំណើតរបស់ព្រះសង្គ្រោះ
ដែលបានសន្យា ។ ក្រោយមកពួកគេបាន
ឃើញផ្កាយមួយខុសពីធម្មតា ដែល
ឆ្ពោះទៅប្រទេសអ៊ីស្រាអែល ។




យើងបានធ្វើដំណើរយ៉ាងឆ្ងាយ ជាច្រើនសប្ដាហ៍ហើយ នេះជាទឹកដី ចំឡែកដែលយើងកំពុងទៅ ។
ផ្កាយនៅតែធ្វើចលនា យើងនឹង តាមវារហូតដល់គោលដៅ ។


អ៊ីស្រាអែលគ្មានស្តេចទេនៅគ្រានោះ ព្រោះពួករ៉ូមបានត្រួតត្រាលើពួកគេ ប៉ុន្តែស្តេចនៃសាសន៍យូដាដែលពួករ៉ូមបានតែងតាំងគឺ ហេរ៉ូឌ សោយរាជ្យ នៅទីក្រុងយេរូសាឡិម ។ ពួកអ្នកប្រាជ្ញបានស្វែងរកស្តេច ហេរ៉ូឌ ដើម្បីសួរ ទ្រង់អំពីស្តេចជាព្រះឱរសដែលទើបតែប្រសូត្រមក ។


ព្រះអម្ចាស់ មានអ្នកមានបីនាក់ មកពីទិសខាងកើត ពួកគេបាននិយាយថា ពួកគេកំពុងស្វែងរកស្តេចថ្មីរបស់ អ៊ីស្រាអែល ជាទារកម្នាក់ ។
ទារកម្នាក់ ? ត្រូវធ្វើជាស្តេច ? អញជាស្តេចហើយ ! ចូរនាំគេចូល មក ហើយហៅសម្តេចសង្ឃនិង អាចារ្យមកជួបអញភ្លាម ។


ឯងនិយាយថា ឯងបានមករកស្ដេចជាទារកដែលទើបតែកើតឬ? តើឯងដឹងរឿងនេះដោយរបៀបណា?
ពួកទូលបង្គំបានឃើញផ្កាយរបស់ទ្រង់នៅទិសខាងកើត ហើយទូលបង្គំមកថ្វាយបង្គំទ្រង់។
ទ្រង់នៅឯណា ?
ទូលបង្គំមិនដឹងច្បាស់ហេតុនេះហើយ ទើបមកគាល់ទ្រង់។
អញបានហៅពួកអ្នកប្រាជ្ញមកដើម្បីនឹងសួរអ្វីដែល ពួកគេដឹងពីរឿងនេះ។ ចូលមកបន្ទប់សម្ងាត់ជាមួយអញ។


ពួកគេបាននិយាយថា គេបានមក ដើម្បីថ្វាយបង្គំស្ដេចនៃយូដា គឺអង្គទ្រង់ដែល បទទំនាយបានទាយនឹងយាងមកសង្គ្រោះ ប្រជារាស្ត្រ ។ តើការទាយរបស់ឯង បាននិយាយពីស្ដេចនោះឬទេ?
មានព្រះករុណា ហោរាជាច្រើនបាន ទាយពីការយាងមករបស់ទ្រង់ ប៉ុន្តែយើង មិនត្រូវជឿបទទំនាយនេះមានអត្ថន័យ ដោយចំៗទេ ។


អញមិនខ្វល់អ្វីចំពោះ យោបល់នៃចំណេះដឹងរបស់ ឯងទេ តាមពិតតើបទទំនាយ ថាយ៉ាងម៉េច ?
រីឯ ហោរាមីកាបាននិយាយថា ព្រះ មែស៊ី ត្រូវបានចាប់កំណើតនៅទីក្រុង បេថ្លេហិម ហើយមកពីពូជយូដា។

ម៉ាថាយ ២:១-៨, មីកា ៥:២




ហេរ៉ូឌមានព្រះទ័យព្រួយបារម្ភដោយពួកគេនិយាយថា
មានស្តេចថ្មីបានចាប់កំណើតដូច្នេះនៅពេលទ្រង់ដឹងថា
ព្រះរាជកុមារនៅកន្លែងណាទ្រង់នឹងទៅសម្លាប់ ។


គួរឱ្យឆ្ងល់ណាស់ ពួកអាចារ្យរបស់ ស្ដេចហេរ៉ូឌដឹងថា ព្រះឱរសត្រូវបានប្រសូត្រ នៅចំកន្លែងណា ប៉ុន្តែពួកគេនៅតែ មិនខ្វល់ពីហោរារបស់គេផ្ទាល់ ។
ការទាយរបស់ហោរា អ៊ីស្រាអែលមិនដូចការទាយរបស់ហោរា សាសនាផ្សេង ខ្ញុំមិនធ្លាប់ឃើញការទាយ យ៉ាងល្អិតល្អន់ដូចនេះទេ ។


មើលន៎ គឺផ្កាយ ដែលយើងធ្លាប់ឃើញ នៅទិសខាងកើត !
ហើយវាមិនដូចផ្កាយទាំងឡាយ ដែលយើងធ្លាប់បានឃើញនោះទេវាមិន ធ្វើចលនាជាមួយផ្កាយផ្សេងៗទៀតទេ ហើយវាភ្លឺជាងគេទាំងអស់ ។
ចំណាំកន្លែងរបស់វា ថ្ងៃស្អែកយើងនឹងតាម វាទៀត ។


ទុ៎ះទ៎ វានៅពីលើផ្ទះនោះ ប៉ុន្តែ នេះមិនមែននៅបេថ្លេហិមទេ ! យើង តាមអស់ជាច្រើនសប្ដាហ៍ ប្រហែល ពួកគេផ្លាស់ទីលំនៅហើយ ។
យើងបានធ្វើដំណើរ អស់រយៈពេលយូរ ឥឡូវ នេះជិតដល់ហើយ ។
តាមពិតវាគឺជាផ្កាយ ចំឡែក វាមិនរះខ្ពស់ ជាងពពកទេ ។


ពួកយើងមិនចង់រំខានលោកទេ ប៉ុន្តែយើងបានធ្វើដំណើរជាច្រើនសប្តាហ៍ ដើម្បីមកជួបហើយថ្វាយបង្គំស្តេចថ្មី ដែលទើបតែប្រសូត្រមក។
តើពួកលោក ដឹងដោយវិធីណា ?
ពួកយើងបានអាននៅក្នុងគម្ពីរបរិសុទ្ធរបស់មនុស្សគ្រប់ជាតិសាសន៍ ហោរាសាសនារបស់លោកបានទាយពីការយាងមករបស់ទ្រង់ ហើយបន្ទាប់មកផ្កាយមួយក៏បានរះឡើង ដើម្បីនាំយើងមកទីនេះឥឡូវនេះវានៅចំពីលើផ្ទះរបស់លោក។


ពួកទូលបង្គំសូមក្រាបថ្វាយបង្គំនិងថ្វាយដង្វាយ
បន្តិចបន្តួច ដើម្បីជាកិត្តិយសដល់ព្រះសង្គ្រោះមនុស្សលោក
ទ្រង់នឹងផ្លាស់ប្រែមនុស្សជាច្រើនឱ្យបានសុចរិត។

នៅយប់នោះព្រះអម្ចាស់មានបន្ទូលទៅកាន់អ្នកប្រាជ្ញក្នុងសុបិនថា “**កុំប្រាប់ពីទីកន្លែងដែលបានឃើញព្រះរាជកុមារដល់ស្តេចហេរ៉ូឌឡើយ ប៉ុន្តែត្រូវត្រឡប់ទៅប្រទេសរបស់អ្នកវិញតាមផ្លូវផ្សេង**”។ ព្រះអម្ចាស់ក៏បានប្រាប់យ៉ូសែបឱ្យគាត់ភៀសខ្លួនទៅប្រទេសអេស៊ីព្ទដែរ ព្រោះហេរ៉ូឌនឹងស្វែងរកសម្លាប់ព្រះកុមារនោះ។



ម៉ាថាយ ២:៩-១២


អាពួកអ្នកប្រាជ្ញដែលមកពីទិសខាងកើត បានបោកបញ្ឆោតអញ ពួកវាបានត្រឡប់ទៅ ផ្ទះវិញតាមផ្លូវផ្សេង នោះមានន័យថាពួកវា បានរកឃើញក្មេងនោះ ហើយបានភ័យខ្លាចពី ការវិលត្រឡប់តាមផ្លូវនេះ ។
បញ្ជូនក្រុមទាហានពិសេសរបស់អញ ទៅបេថ្លេហិម ប្រាប់ឱ្យសម្លាប់ក្មេងប្រុស ទាំងអស់ក្រោមអាយុ២ឆ្នាំ ។


ជាច្រើនឆ្នាំមុនហោរាបានទាយពីព្រឹត្តិការណ៍ដែល
មានទុក្ខវេទនានេះនឹងកើតឡើងនៅបេថ្លេហិម ។


យ៉ូសែបនិងម៉ារាបានយកព្រះឱរសយេស៊ូវទៅអេស៊ីព្ទ ដង្វាយ
ដែលពួកអ្នកប្រាជ្ញបានថ្វាយឱ្យពួកគេមានលទ្ធភាពគ្រប់គ្រាន់
ក្នុងការធ្វើដំណើរ ហើយរស់នៅទីនោះអស់រយៈពេលពីរឆ្នាំ។
ក្រោយពេលស្តេចហេរ៉ូឌបានសុគត ហើយ ព្រះយេស៊ូវមានព្រះជន្មពីរវស្សា ព្រះជាម្ចាស់
បានប្រាប់ពួកគេឱ្យទៅអ៊ីស្រាអែលវិញ។ ការនេះបានបំពេញតាមបទទំនាយដែល
ក្នុងគម្ពីរបានចែងថា **អញបានហៅកូន របស់អញចេញពីអេស៊ីព្ទមក។**


នៅពេលដែលពួកគេត្រឡប់មកពីអេស៊ីព្ទវិញ ទេវតាបានប្រាប់យ៉ូសែបឱ្យទៅក្រុងតូចមួយហៅថា ណាសារ៉ែត
នេះក៏ជាការបំពេញនូវបទទំនាយ១ទៀត ដែលទាយថា “គេនឹងហៅទ្រង់ជាអ្នកស្រុកណាសារ៉ែត”។

យេរេមា ៣១:១៥, ហូសេ ១១:១, ម៉ាថាយ ២:១៣-២៣




ប៉ា តើ ខ្ញុំអាចទៅតាមបង
យេស៊ូវដើម្បីមើលវិហារបានទេ?
យេស៊ូវ ចូរកូន
យកចៀមនេះប្រគល់ឱ្យ សង្ឃ
ពួកគេត្រូវតែពិនិត្យមើលមុនពេលចាប់ផ្តើម
ពិធីថ្វាយដង្វាយនៅថ្ងៃស្អែក យើងនឹងរក
កន្លែងដើម្បីបោះជំរុំសម្រាកយប់នេះ។
នៅពេលព្រះយេស៊ូវមាន ព្រះជន្ម១២វស្សា យ៉ូសែប
បាននាំគ្រួសារគាត់ទៅទីក្រុង យេរូសាឡិម ដើម្បីចូលរួម ពិធីបុណ្យរំលង
គេបានយក ចៀមសម្រាប់ថ្វាយដង្វាយ ដើម្បីនឹងលោះអំពើ បាបពួកគេ។


បន្ទាប់ពិធីថ្វាយយញ្ញបូជារួចហើយ ក្រុមគ្រួសាររបស់យ៉ូសែប
បានធ្វើដំណើរពេញមួយថ្ងៃ ដើម្បីត្រឡប់ទៅផ្ទះវិញ។
បងយ៉ូសែប
អូនរកយេស៊ូវ មិនឃើញទេ
ហើយពេញមួយថ្ងៃនេះ
គ្មានអ្នកណាឃើញដែរ។
បងគិតថាយើងបានចេញមកដោយ
ភ្លេចកូននៅទីក្រុងយេរូសាឡិម។
តែកូនបានដឹងហើយយើងនឹង
ចាកចេញ ដូច្នេះអូនគិតថាកូន
នៅជាមួយនឹងសាច់ញាតិយើង។
យើងត្រូវតែត្រឡប់ ទៅរកកូនវិញ

លោកគ្រូទាំងអស់បានយល់ព្រមថា
ព្រះមែស៊ីត្រូវជាពូជហ្លួងដាវីឌ
ពីព្រោះ ពួកហោរាបានទាយដូច្នេះ ។
លោកគ្រូក៏បាន យល់ព្រមទៀតថា
ដាវីឌបានហៅព្រះមែស៊ីថា ព្រះអម្ចាស់
ហាក់ដូចជាព្រះមែស៊ីគឺជាព្រះរបស់
ស្តេចដាវីឌ ។ ហើយបើព្រះមែស៊ីជាព្រះរបស់
ដាវីឌ អញ្ចឹងតើព្រះមែស៊ីជាពូជហ្លួងដាវីឌនិង
ជាព្រះអម្ចាស់របស់ដាវីឌនៅពេលតែមួយ
យ៉ាងម៉េចកើត ?



អេសាយ ៩:៧, លូកា ២:៤២-៤៦,
ធីម៉ូថេទី២, ៣:១៦-១៧


នែ៎ ក្មេងតូច ត្រូវតែប្រយ័ត្ន ចំពោះការរកហេតុផលនេះ ការសន្និដ្ឋានបែបនេះអាចជាការប្រមាថ ។
ប៉ុន្តែគម្ពីរពិតឬវាមិនពិត ។ តើយើងគ្រាន់តែជឿអ្វីដែលត្រូវនឹងប្រពៃណីទំនៀមទម្លាប់យើងឬ ?


ប៉ុន្តែឯងគិតថា
ការបកស្រាយរបស់ ឯងត្រឹមត្រូវ ។
ពួកចាស់ទុំមានសមត្ថភាព ខ្ពស់ជាងឯង
ក្នុងការយល់ពីសេចក្ដីពិត ដ៏ជ្រៅនេះ ។
យេស៊ូវ
នៅ ទីនោះ !
តើសេចក្ដីពិតជ្រៅយ៉ាងម៉េច ?
តើទ្រង់ប្រទានព្រះគម្ពីរជួយឱ្យ
យើងបានយល់ឬក៏អត់ ?
ប៉ុន្តែឯងមិនអាចប្រកាន់តាមន័យចំៗទាំង
អស់ពេកទេ សៀវភៅបុរាណនិយាយថា...


យេស៊ូវ
ម៉ាក់បានរកកូន គ្រប់ទីកន្លែង
ហេតុអ្វីបាន ជាកូនធ្វើអញ្ចឹង?
ក្មេងតូចនេះបាននៅជាមួយ
យើងអស់រយៈពេល២ថ្ងៃ កូនរបស់
ឯងដូចជាចំឡែកណាស់ ។


ហេតុអ្វីពុកនិងម៉ែរកខ្ញុំគ្រប់ទីកន្លែង ? លោកទាំងពីរ មិនដឹងទេថាខ្ញុំត្រូវធ្វើការងាររបស់ព្រះវរបិតាខ្ញុំឬអី ?


ខ្ញុំមិនធ្លាប់បានឃើញក្មេងប្រុសម្នាក់ដែលចេះគម្ពីរច្រើនដូចនេះទេ។
តើវានិយាយមានន័យយ៉ាងដូចម្ដេចដែលថាវាត្រូវការធ្វើការងារ បិតារបស់វា ? ចុះហ្នឹងមិនមែនជាឪពុក ដែលកំពុងរកវាអំបាញ់មិញនេះឬ?


ព្រះយេស៊ូវបានត្រឡប់ទៅជាមួយ ឪពុកម្ដាយរបស់ទ្រង់វិញ នឹងបាន គោរពដល់ពួកគេ ។ ទ្រង់បន្តធ្វើការ នៅក្នុងរោងឈើ ហើយទ្រង់ចំរើន វ័យឡើងប្រកបដោយប្រាជ្ញាញាណ ដ៏ឧត្តម ។
ពីព្រោះទ្រង់តែងតែដើរតាមផ្លូវសុចរិត ហើយ ព្យាយាមធ្វើល្អទៅលើអ្នកដទៃ មនុស្សទាំងអស់ បានចូលចិត្តទ្រង់យ៉ាងខ្លាំង ។


នៅពេលយុវជន ផ្សេងបានប្រព្រឹត្តអំពើបាប ព្រះយេស៊ូវមិនធ្វើ តាមគេទេ
ទ្រង់បានគោរពតាមក្រឹត្យវិន័យ ទាំងអស់របស់ព្រះដោយអស់ពីចិត្ត។
អ្នកកំលោះមានភាព
ស្មោះត្រង់ជានិច្ច។ នៅក្នុងណាសារ៉ែត
នេះ ឥតមានជាងឈើល្អដូចអ្នកទេ ខ្ញុំនឹង
យកប្រាំមួយទៀតដូចវា។
លូកា ២:៤៦-៥២


ជាច្រើនឆ្នាំក្រោយមក យ៉ូហាន មានអាយុ៣០ឆ្នាំ ហើយគាត់បាន ចាប់ផ្តើមផ្សាយពីនគររបស់ព្រះ ។
ចូរចងចាំថា អេលីសាបិតបានសម្រាលបុត្រ៦ខែមុននាងម៉ារា ។ ទេវតាបានប្រាប់សាការីឱ្យដាក់ ឈ្មោះបុត្រនោះថា យ៉ូហាន ហើយបុត្រនោះនឹងបំផ្លាស់ប្រែចិត្តមនុស្សនិងរៀបចំផ្លូវសម្រាប់ ការយាងមករបស់ព្រះមែស៊ី ហោរាជាច្រើនបានទាយអំពីការនេះកាលពី៥០០ឆ្នាំមុនដែរ ។


អ្នកត្រូវតែបែរចេញពីអំពើ
អាក្រក់ហើយស្តាប់បង្គាប់ព្រះ ព្រោះនគរ
ឋានសួគ៌នឹងជិតមកដល់ហើយ ។ បើសិនអ្នក
នឹងផ្លាស់ប្រែចិត្តរបស់អ្នកដើម្បីទទួល ព្រះមែស៊ី
ខ្ញុំនឹងធ្វើពិធីជ្រមុជទឹកឱ្យ ។


នោះមានព្រះមួយអង្គនឹងយាងមកក្រោយខ្ញុំ ដែលទ្រង់បានត្រឡប់ជាមុនខ្ញុំវិញ ដ្បិតទ្រង់គង់នៅមុនខ្ញុំ ។ ទ្រង់នឹងធ្វើពិធីជ្រមុជឱ្យអ្នក មិនមែនក្នុងទឹកទេ ប៉ុន្តែដោយព្រះវិញ្ញាណបរិសុទ្ធនៃព្រះអង្គទ្រង់ ។ ចូរបែរចេញពីអំពើបាបរបស់អ្នកកុំឱ្យហួសពេល ។
យ៉ូហាន តើយើងគួរធ្វើយ៉ាងម៉េច ? តើព្រះត្រូវការអ្វីដើម្បីឱ្យយើងបានសុចរិត ?


បើសិនអ្នកមានអាវពីរ ហើយជួប
មនុស្សម្នាក់គ្មានអាវសោះ ត្រូវឱ្យអាវរបស់ អ្នកទៅគាត់មួយ ។
បើសិនអ្នកមានអាហារ ហើយនរណាម្នាក់ឃ្លានត្រូវឱ្យគាត់ហូប ។
ចូរស្វែងរកយុត្តិធមិ សម្រាប់មនុស្សទាំងអស់ ។


យ៉ូហាន តើយើងត្រូវធ្វើអ្វីក្នុង រដ្ឋាភិបាល ដើម្បីគាប់ព្រះហឫទ័យ ព្រះ ? ខ្ញុំជាអ្នកយកពន្ធ ហើយ ណេបាល គាត់ជា គយ ។
កុំទទួលសំណូក កុំប្រើអំណាចរបស់ អ្នកទារលុយពីនរណាម្នាក់ ត្រូវស្មោះត្រង់ និងយុត្តិធមិគ្រប់កិច្ចការទាំងអស់ ។


ខ្ញុំមិនមែនប្រជាជនឬសាសនា
របស់អ្នក ប៉ុន្តែខ្ញុំចង់ឱ្យព្រះគាប់ព្រះហឫទ័យ
តើខ្ញុំគួរតែធ្វើយ៉ាងម៉េច ?
កុំប្រព្រឹត្តអំពើហឹង្សាលើមនុស្សដែលនៅ
ក្រោមការត្រួតត្រារបស់អ្នក ។
កុំលួចឬប្រើឋានៈរបស់អ្នក
ដើម្បីយកលុយឬទ្រព្យសម្បត្តិរបស់អ្នកណាឱ្យសោះ ។
អ្នកត្រូវស្កប់ចិត្តជាមួយប្រាក់ខែរបស់អ្នក ។


អ្នកដែលមកបន្ទាប់ខ្ញុំនោះគឺមាន
អំណាចច្រើនជាងខ្ញុំ ខ្ញុំមិនគួរស្រាយខ្សែ
សុព័ណិបាទរបស់ទ្រង់ផង ។ បើអ្នកប្រែចិត្ត
នឹងជឿទ្រង់ ទ្រង់នឹងជ្រមុជអ្នកដោយ
ព្រះវិញ្ញាណបរិសុទ្ធ ។
បើសិនអ្នកបដិសេធទ្រង់ហើយនៅតែធ្វើ
បាបទៀត ទ្រង់នឹងបោះអ្នកចូលក្នុងភ្លើងវិនាស
អស់កល្បជានិច្ច ឥឡូវនេះឈប់ធ្វើអំពើបាប ។
ម៉ាឡាគី ៣:១, លូកា
៣:២-១៨, ៧:២៤, ២៧


លោកជាអ្នកណាមកប្រកាសប្រាប់អំពីព្រះមែស៊ី ? តើលោកមានប្រសាសន៍ថាលោកជាអ្វីដែរ ?
ខ្ញុំមិនមែនជាព្រះមែស៊ីទេ។


តើលោកជាហោរ៉ាដែល ម៉ូសេធ្លាប់បាននិយាយ គឺម្នាក់ ដែលនឹងមកហើយនាំមនុស្ស បែរទៅរកព្រះវិញឬ ?
មិនមែនទេ ដូចហោរ៉ាអេសាយបានពោលថា ខ្ញុំជាសំលេងមនុស្សម្នាក់ដែលស្រែកនៅវាល រហោស្ថានថា ចូររៀបចំផ្លូវទទួលព្រះអម្ចាស់ ។


លោកមានសិទ្ធិអ្វីរំលងអំណាចសាសនា
របស់យើង ហើយជ្រមុជទឹកអ្នកទាំងនេះ ?
ខ្ញុំគ្រាន់តែជាអ្នកនាំសារម្នាក់កំពុងរៀបចំផ្លូវ
ទទួលព្រះមែស៊ី ។ ពួកអ្នកជាពូជពស់វែក អ្នកគិតថា
ពួកអ្នកក៏ជាកូនរបស់ព្រះ គ្រាន់តែជាសាសន៍យូដា និងជាពូជរបស់អ័ប្រាហាំដែរ ។


ពួកអ្នកត្រូវតែបោះបង់ចោលនូវមោទនភាពនិងភាព
ក្រអឺតក្រទមដែលជាអំពើបាបរបស់អ្នក ។ ពូថៅបានដាក់នៅឫស
ដើមឈើ ហើយបើសិនពួកអ្នកមិនប្រែចិត្ត នោះពួកអ្នកនឹងត្រូវ
បានកាប់រំលំហើយបោះទៅក្នុងភ្លើងនៃសេចក្ដីវិនាស ។


យ៉ូហានលោកនិយាយថា
ព្រះមែស៊ីនឹងយាងមកឆាប់ៗនេះ តើ
លោកនឹងស្គាល់ទ្រង់ដោយរបៀបណា
ពេលទ្រង់យាងមក ?
ទេវតារបស់ព្រះបានប្រាប់ខ្ញុំថា អ្នកណាដែលខ្ញុំឃើញ
ព្រះវិញ្ញាណនៃព្រះមកសណ្ឋិតនៅលើដូចជាសត្វព្រាប អ្នកនោះ
គឺជាព្រះមែស៊ីនៃអ៊ីស្រាអែលនិងព្រះសង្គ្រោះមនុស្សលោក។


យ៉ូហាន បានថ្លែងព្រះបន្ទូលអស់រយៈពេល៦ខែហើយ ពេលនោះព្រះយេស៊ូវមានព្រះជន្ម៣០វស្សា។
ម៉ាក់ដឹង ពេលនេះនឹងមកដល់ ទេវតាកាព្រីយ៉ែល បានប្រាប់ម៉ាក់ថា ម៉ាក់នឹងមានការឈឺចិត្តយ៉ាងខ្លាំង។ ម៉ាក់ចង់ឱ្យឪពុកចិញ្ចឹមរបស់កូននៅមានជីវិតរស់នៅត ទៅទៀតដើម្បីឃើញថ្ងៃនេះ។


តើកូននឹងធ្វើអ្វី ?
តើកូននឹងចាប់ផ្តើមដោយ របៀបណា?
តើកូននឹងទៅ ព្រះវិហារឬទេ ?
ខ្ញុំមិនដឹងទេ បិតារបស់ខ្ញុំនឹងបង្ហាញ
ដំបូង ខ្ញុំត្រូវទៅជួបយ៉ូហាន ហើយទទួលជ្រមុជទឹកពីគាត់
គាត់បានរៀបចំមនុស្សជាច្រើនសម្រាប់ថ្ងៃនៃការ កើតជាថ្មី ។


តើកូននឹងត្រឡប់
មកជួបម៉ាក់វិញទេ ?
ពិតជាមក
កូននឹងមិនបោះបង់ចោលម៉ាក់ទេ
ប៉ុន្តែម៉ាក់ត្រូវរឹងមាំឡើង រឿងរ៉ាវដែលនឹងកើតមក
លើកូននោះមិនមែនជាការស្រួលសម្រាប់ម៉ាក់ទេ។
អេសាយ ៤០:៣,
ម៉ាថាយ ៣:១-១២,
លូកា ៣:១៥-១៨, ២៣,
យ៉ូហាន ១:១៩-២៧, ៣៣


ចូររៀបចំខ្លួនទទួលការយាងមករបស់ព្រះមែស៊ី លោកឪពុកទាំងអស់គ្នា ត្រូវប្រែចិត្តទៅឯកូន ត្រូវតែឈ្លាសវៃ ហើយយកពេលវេលានិងកំលាំងរបស់អ្នកដើម្បីបង្រៀនកូនពីក្រឹត្យវិន័យរបស់ព្រះ បើសិនកូនដែលមិនស្តាប់បង្គាប់ឃើញភាពស្មោះត្រង់របស់ឪពុកវា កូននឹងប្រែចិត្តទៅតាម ហើយគ្រួសាររបស់អ្នកនឹងមានសុភមង្គលឡើងវិញ។


បើសិននេះគឺជាចិត្តរបស់អ្នក ហើយអ្នកនឹងមានបំណងតាម
ព្រះមែស៊ីពេលទ្រង់យាងមក អញ្ចឹងសូមចុះមកហើយខ្ញុំនឹង
ធ្វើពិធីជ្រមុជទឹកឱ្យអ្នកចំពោះការប្រែចិត្ត ហើយនៅពេល ព្រះមែស៊ីយាងមក
ទ្រង់នឹងអត់ឱនទោសបាបរបស់អ្នក។


បងយ៉ូហាន តើអាចជ្រមុជទឹកឱ្យខ្ញុំបានទេ ?
បើសិនអ្នកជ្រមុជទឹកឱ្យខ្ញុំទើបត្រឹមត្រូវជាង អ្នកពិតជាមនុស្សសុចរិត ។
បងយ៉ូហាន ខ្ញុំត្រូវតែបំពេញក្រឹត្យវិន័យទាំងអស់របស់ទ្រង់ ខ្ញុំនឹងធ្វើដូចបិតារបស់ខ្ញុំបានបង្គាប់ទៅរាស្ត្ររបស់ទ្រង់ដែរ ។








ម៉ាថាយ ៣:១៣-១៧, លូកា ៣:២១-២២


ទ្រង់ជាព្រះមែស៊ី!
ទូលបង្គំគួរតែដឹងមុន។


នេះគឺជាកូនស្ងួនភ្ងាររបស់អញ
ជាទីដែលគាប់ព្រះហឫទ័យអញ ។
នេះជាកូនចៀមរបស់ព្រះ
ដែលលោះបាបមនុស្សលោក!


ជាអ្នក
បរិសុទ្ធនៃព្រះ!
ព្រះគ្រីស្ទ!
ទ្រង់បានយាងមក!
ទ្រង់នឹងរៀបចំនគរ
របស់ទ្រង់ !
លូកា ៣:២២, យ៉ូហាន ១:២៩-៣៤, យ៉ូហានទី១, ២:១-២


តើទ្រង់ទៅណា? តើទ្រង់នឹងរំដោះប្រជាជាតិមែនទេ ?
បាទ នៅថ្ងៃខាងមុខ តែឥឡូវទ្រង់ត្រូវយកឈ្នះការល្បួងសិន ។
ល្បួងអី..?
ការល្បួងរបស់អារក្ស ដែលអ័ដាមនិងកូនចៅរបស់គាត់ទាំងអស់ បានចុះចាញ់ ។ ទ្រង់ត្រូវតែជួបនឹង មេអារក្សនៃសេចក្ដីងងឹត ។


ព្រះវរបិតា បានប្រាប់ព្រះរាជបុត្រាយេស៊ូវឱ្យតមអាហារ៤០ថ្ងៃ
ទ្រង់មិនបានសោយអាហារទេ ព្រះកាយរបស់ទ្រង់ចុះខ្សោយ
អារក្សសាតាំងព្យាយាមល្បួងទ្រង់ ដើម្បីមិនឱ្យត្រិបត្តិតាម
ព្រះវរបិតា ហើយបំពេញការស្រេកឃ្លានរបស់ទ្រង់ ។
បុរសទីមួយ គឺអ័ដាមមិនស្តាប់បង្គាប់ព្រះហើយបានបាត់បង់
ដំណែងជាម្ចាស់ផែនដីដ៏វិសេសរបស់គាត់ ។ ព្រះយេស៊ូវគឺជាព្រះ
ហើយមានព្រះជន្មអស់កល្បជានិច្ច ប៉ុន្តែឥឡូវទ្រង់ជាមនុស្ស ដែលមានកំណត់ ។
តើទ្រង់នឹងយកឈ្នះការល្បួងដែល មនុស្សទាំងអស់បានចាញ់ឬទេ ?

នៅចុងបញ្ចប់៤០ថ្ងៃនៃការតមអាហារ ព្រះយេស៊ូវបានឃ្លាននឹងខ្សោយ
ឥឡូវនេះទ្រង់បានយល់ពីសភាពជាអ្នកក្រីក្រដែលបានស្រេកឃ្លានយ៉ាងខ្លាំង
រហូតដល់រូបកាយរបស់គេចាប់ផ្តើមចុះទ្រុឌទ្រោម ហើយទ្រង់ក៏យល់នូវភាព
ឯកោ ភាពដែលគេបោះបង់ចោល មានជំងឺ និង ភាពកំសោយផងដែរ ។





ជាច្រើនថ្ងៃសាតាំងបានល្បួងព្រះយេស៊ូវដោយព្យាយាមធ្វើឱ្យចិត្តគំនិតទ្រង់គិត
មន្ទិលសង្ស័យនិងភ័យខ្លាច ។ សាតាំងជាមេល្បួងបានយល់ថា ថ្ងៃនៃការល្បួងជិត
ចប់ហើយ និងព្រះកាយព្រះយេស៊ូវក៏ចុះខ្សោយបំផុតផងដែរ ។ សាតាំងបាន
ធ្វើការមួយដែលវាកម្រនឹងធ្វើ វាបានធ្វើការបង្ហាញខ្លួននៅចំពោះព្រះភក្ត្រទ្រង់ ។




ម៉ាថាយ ៤:១-៣, លូកា ៤:១-៣, រ៉ូម ៣:២៣, ៥:១២-២១, ហេព្រើរ ៤:១៥


សាតាំង បានបោកបញ្ឆោតបុរសទីមួយ អ័ដាម
ឱ្យហូបនូវអ្វីដែលព្រះហាមឃាត់ ឥឡូវវាព្យាយាម
ធ្វើការល្បួងដូចគ្នាទៅលើកូនមនុស្សដែលមាន
ភាពទន់ខ្សោយហើយស្រេកឃ្លាន ។
ការល្បួងទៅលើមនុស្សម្នាក់ដែលមិនបានហូបអាហារ
អស់រយៈពេល៤០ថ្ងៃ វាមិនមែនជាការល្បួងធម្មតាទេ ។


អ្នកអាចធ្វើថ្មមួយដុំនេះ ឱ្យក្លាយ ទៅជានំប៉័ងមួយដុំ ហើយបំពេញភាពស្រេកឃ្លានរបស់អ្នកទៅ ។


ទេ មិនបរិភោគទេ បទគម្ពីរបាន ចែងថា មនុស្សមិនអាចរស់បានដោយសារ តែនំបុ័ងទេ ប៉ុន្តែដោយសារគ្រប់ ព្រះបន្ទូលនៃព្រះវិញ ។
មកតាមខ្ញុំ ខ្ញុំនឹងនាំអ្នក ទៅកន្លែងមួយដែលអ្នក អាចស្តាប់បង្គាប់ព្រះបាន ។


សាតាំងបាននាំព្រះយេស៊ូវ
ទៅលើដំបូលវិហារ ទីក្រុងយេរូសាឡិម ។


បើសិនអ្នកលោតទៅទីនោះទេវតានឹង មកទ្រ មនុស្សទាំងអស់នឹងឃើញ ហើយពួកគេ នឹងទទួលអ្នក ជាព្រះមែស៊ី ហើយខ្ញុំដឹងថា នេះជាហេតុផលដែលអ្នកបានមក ?
អ្នកបានលើកយកគម្ពីរមកនិយាយ ហើយគម្ពីរនិយាយដែរថា **ទេវតានឹងទ្រអ្នកនៅក្នុងដៃ របស់ពួកគេ នឹងថែរក្សាអ្នកកុំឱ្យជើងរបស់អ្នកទង្គិចនិងថ្ម** ឥឡូវនេះដល់ពេលដែលត្រូវបង្ហាញអំណាចរបស់អ្នក ឱ្យគេឃើញហើយ ។
ដ្បិតមានសេចក្តីចែងទុកមកថា **កុំឱ្យឯងល្បួងព្រះនៃឯងឡើយ ។**


បន្ទាប់មកទៀតសាតាំងបាននាំព្រះយេស៊ូវទៅលើភ្នំដ៏ខ្ពស់ដែលអាចមើលឃើញពិភពលោកទាំងមូល ។
ខ្ញុំយល់ថា អ្នកស្រឡាញ់មនុស្សលោក ហើយមកដើម្បីសង្គ្រោះពួកគេ ដូច្នេះខ្ញុំនឹងបង្ហាញ អ្នកនូវរបស់ខ្លះ ខ្ញុំគិតថា អ្នកនឹងចូលចិត្ត ។
ម៉ាថាយ ៤:៣-៧


នុះន៎ យើងអាចមើលពីនេះទៅឃើញនគរដ៏សំខាន់ៗជាច្រើនដែល
ដឹកនាំលើពិភពលោក តើវាពិតជាមានសិរីរុងរឿងមែនឬ ? តាំងតែពី
អ័ដាមបានបែរចេញពីការគ្រប់គ្រងរបស់អ្នក ខ្ញុំបានធ្វើជាម្ចាស់លោកិយ
នេះ ។ ពួកមនុស្សបានប្រគល់វាឱ្យខ្ញុំត្រួតត្រាម្តងហើយម្តងទៀត
ខ្ញុំជាម្ចាស់លើវាទាំងអស់ ខ្ញុំជាព្រះនៃលោកិយមិនមែនជាអ្នកទេ ។


ខ្ញុំនឹងឱ្យវាទាំងអស់ទៅអ្នក តែខ្ញុំមានលក្ខខ័ណ្ឌ
មួយ ។ បើសិនអ្នកគ្រាន់តែលុតជង្គង់ហើយថ្វាយបង្គំខ្ញុំម្តង
នោះខ្ញុំនឹងបោះបង់ការត្រួតត្រារបស់ខ្ញុំលើលោកិយ ហើយ
អ្នកអាចត្រួតត្រាម្តងលើលោកិយព្រមទាំងមនុស្សទាំងអស់
ផងដែរ ។ តើអ្នកមានយោបល់យ៉ាងម៉េចដែរ ?


ព្រះគម្ពីរមានបន្ទូលថា
ឯងត្រូវតែថ្វាយបង្គំ
ព្រះយេហូវ៉ាតែមួយអង្គ ហើយ
គ្មានបំរើនរណាក្រៅពីទ្រង់
ឯងបានបរាជ័យហើយ ឥឡូវ
ចេញពីមុខអញ ។
សាតាំង បានគេចចេញពីព្រះគ្រីស្ទ
នេះជាលើកដំបូងក្នុងប្រវត្តិសាស្ត្រ មនុស្ស ដែលសាតាំងប
ានតទល់នឹងមនុស្សម្នាក់ដែលវាមិនអាចបោក បញ្ឆោតបាន
ព្រះយេស៊ូវបានឈ្នះការល្បួង ឥឡូវនេះនៅលើផែនដី
មានមនុស្សម្នាក់ដែលបានចុះចូលតាមព្រះទាំងស្រុង ។


រយៈពេល៤០ថ្ងៃនៃការល្បួងបានចប់ហើយ
តែព្រះយេស៊ូវក៏មានព្រះកាយទន់ខ្សោយ
យ៉ាងខ្លាំងក្នុងការធ្វើដំណើរបន្តទៀត។

ពេលនោះទេវតាបានយកព្រះស្ងោយ
ថ្វាយទ្រង់ ។ នៅពេលទ្រង់មានកំលាំង
វិញ ទ្រង់បានយាងទៅកន្លែងដែល
យ៉ូហានកំពុងចែកចាយព្រះបន្ទូល ។



ម៉ាថាយ ៤:៨-១១, លូកា ៤:១៤



## ជំពូក ៩

# ការបំរើព្រះដំបូង


មើលន៎ កូនចៀមនៃព្រះ កំពុងយាងមក
ទ្រង់នឹងលោះ បាបមនុស្សលោកទាំងអស់ ។
ទ្រង់ជាព្រះមែស៊ី!
ទ្រង់ជាអ្នកដែល
ហោរាបានទាយ ។
តើទ្រង់នឹងធ្វើអ្វី ?


ខ្ញុំមិនអាចចាកចេញ ពីលោកគ្រូបានទេ ។
ទៅតាម ព្រះយេស៊ូវ
ខ្ញុំមិនមែនជាគ្រូរបស់អ្នកទេ ខ្ញុំត្រូវតែថយចុះ ទៅរហូតដល់សូន្យ ហើយទ្រង់ត្រូវបានចំរើនឡើងរហូតដល់ទ្រង់ជាគ្រប់ទាំងអស់វិញ ។ ទ្រង់ពិតជាព្រះមែស៊ី ជាព្រះសង្គ្រោះនៃពិភពលោក ចូរដើរតាមទ្រង់ចុះ ។


លោកគ្រូអើយ យើងចង់ដើរ
តាមនឹងធ្វើជាសិស្សរបស់លោកគ្រូ
តើលោកគ្រូស្នាក់នៅទីណា ?
ចូរតាមខ្ញុំ ទៅមើល ។


ភីលីព ចូរមកតាមខ្ញុំ
បាទ លោកគ្រូ ពួកយើងបានរងចាំលោកគ្រូជាយូរមកហើយ ប៉ុន្តែខ្ញុំប្រញាប់ទៅហៅ ណាថាណែល សិន។
គាត់បានគោរពក្រឹត្យវិន័យនៃព្រះនឹងបានរងចាំព្រះមែស៊ីយាងមកដែរ។




យ៉ូហាន ១:៣៥-៣៩, ៤៣-៤៥, ៣:៣០-៣១


ណាថាណែល
អ្នកនៅឯណា ?
ភីលីព
ខ្ញុំ នៅទីនេះ
ណាថាណែល យើងបាន
ឃើញព្រះអង្គនោះហើយ ដែលម៉ូសេ
និងហោរាបានកត់ទុកជាមុន ទ្រង់មាន
ព្រះនាមថា យេស៊ូវ នៃភូមិណាសារ៉ែត
ជាបុត្ររបស់ម៉ារី ។


ព្រះមែស៊ីមែនឬ? អ្នកបាននិយាយជាមួយ
ទ្រង់ទេ ? ប៉ុន្តែណាសារ៉ែត...?
មិនដែលមានអ្វីដែលល្អ មកពីណាសារ៉ែតទេ
តើព្រះមែស៊ីអាចមកពីកន្លែងអ្នកខ្សត់
ខ្សោយនិងកន្លែងមនុស្សល្ងិតល្ងង់យ៉ាងម៉េច ? ទ្រង់ត្រូវ
បានកើតនៅក្រុងបេថ្លេហិមនៃស្រុកយូដា។
មក ហើយមើលខ្លួនឯង។
យ៉ូហានបានធ្វើជាសាក្សីឱ្យ
ទ្រង់ហើយនិង អនទ្រេ នៅ
ជាមួយទ្រង់ដែរ។


តាមពិតនេះគឺជា ជនជាតិអ៊ីស្រាអែលដែល មានចិត្តស្មោះត្រង់ ។
ភីលីព តើអ្នក បានប្រាប់ទ្រង់អ្វីខ្លះ អំពីខ្ញុំទេ?
ទេ គ្មានទេ


លោកគ្រូមិនដែលស្គាល់ខ្ញុំផង តើលោកអាចនិយាយថាខ្ញុំមានចិត្ត ស្មោះត្រង់យ៉ាងម៉េចកើត ?
មុនភីលីពបានហៅអ្នក ខ្ញុំបានឃើញអ្នកកំពុងអង្គុយ នៅក្រោមដើមល្វា។
លោកគ្រូឃើញយ៉ាង ដូចម្ដេច ? គ្មានអ្នកណា ដែលដឹងខ្ញុំនៅកន្លែង ណាទេ។


ទ្រង់គឺជាព្រះរាជបុត្រា នៃព្រះ ទ្រង់ជាស្ដេចនៃ អ៊ីស្រាអែល ។
តើនេះធ្វើឱ្យអ្នកចាប់អារម្មណ៍មែនទេ ? អ្នកនឹង ឃើញការអស្ចារ្យច្រើនជាងនេះទៅទៀត អ្នកនឹងឃើញ ផ្ទៃមេឃបើកចំហនឹងឃើញទេវតានៃព្រះហោះឡើងហោះ ចុះលើខ្ញុំ ។ មកយើងមានការច្រើនដើម្បីនឹងធ្វើ ។
យ៉ូហាន ១:៤៥-៥១


អនទ្រេ ក៏បានដើររកបងប្រុសរបស់គាត់
ដើម្បីប្រាប់ពីព្រះយេស៊ូវ ។
បងស៊ីម៉ូន
យើងបានឃើញព្រះមែស៊ី
ដែលយ៉ូហានបាននិយាយប្រាប់ ។
ពេលណា ? នៅទីណា ? តើ
ទ្រង់មានលក្ខណៈដូចម្តេច ? តើមាន
មនុស្សផ្សេងដើរតាមទ្រង់ឬទេ ?
មក បងនឹងឃើញ


អ្នកជា ស៊ីម៉ូន
កូនប្រុស របស់ យ៉ូណាស ប៉ុន្តែអ្នកត្រូវ
បានហៅថា ពេត្រុស វិញ។
ខ្ញុំនឹងប្រគល់ទូកឱ្យទៅ
គ្រួសាររបស់ខ្ញុំវិញ ហើយ
តាមលោកគ្រូ។



មិនយូរប៉ុន្មាន ព្រះយេស៊ូវ បានជ្រើសរើសមនុស្ស១២នាក់ឱ្យដើរ តាមទ្រង់
ហើយស្តាប់ការបង្រៀនរបស់ទ្រង់ ពួកគេត្រូវបាន ហៅថា សាវកទាំង១២
ពួកគេបានធ្វើដំណើរពីទីក្រុងមួយទៅ ទីក្រុងមួយដើម្បីផ្សាយដំណឹងពីនគរព្រះ ។


ព្រះយេស៊ូវនិងសាវករបស់ទ្រង់បានចូលក្នុងវិហារដើម្បីអធិដ្ឋាន
ប៉ុន្តែវាពេញដោយមនុស្សលក់ដូរនិងទំនិញរបស់ពួកគេ ។
តើហេតុអ្វីខ្ញុំត្រូវដូរលុយរបស់ ខ្ញុំ មុនខ្ញុំថ្វាយទៅវិហារ ? អ្នកឯងដូចជាចំណេញច្រើន ។
ពួកសង្ឃពុករលួយគេ បានចំណេញលើអ្វីទាំងអស់ដែលគេលក់ក្នុងវិហារ ។
ពួកសង្ឃអនុញ្ញាតឱ្យធ្វើ ។
យ៉ូហាន ១:៤០-៤២, ២:១២-១៤, ម៉ាកុស ៣:១៦


តើលោកគ្រូកំពុងធ្វើអ្វី ? លោគ្រូបានឈរ នៅមួយកន្លែងស្ទើរតែមួយម៉ោង មិននិយាយស្តីសោះ ហើយវេញខ្សែបញ្ចូលគ្នាដូចជាធ្វើអ្វីមួយ ។
ថ្ងៃនេះយើងចំណេញបាន ច្រើន នេះគឺប្រសើរជាងការងារ ដោយប្រើកំលាំង ។


ខ្សែតី..! លោកគ្រូ កំពុងវេញខ្សែតី..!


ដំណាក់របស់បិតាអញ ត្រូវជា
កន្លែងអធិដ្ឋាន ប៉ុន្តែពួកឯងធ្វើឱ្យទៅ
ជារោងចោរវិញ ។ ឥឡូវយករបស់
ទាំងអស់នេះចេញ !
ដំណាក់បិតារបស់វា!
វាគិតថាវាជានរណា ព្រះមែស៊ីឬ ?


កុំធ្វើឱ្យដំណាក់របស់បិតាអញ
ទៅជាផ្ទះលក់ទំនិញ ពួកឯង
សុទ្ធតែជាចោរទាំងអស់ ។
គ្រាំង !
យ៉ូហាន ២:១៥-១៦


ផាច់ !
ពួកឯងជាពូជពស់វែក ឯងធ្វើឱ្យស្រីមេម៉ាយស្លាប់ ដោយអត់អាហារ ។
អូយ !
វាគិតថា វាជាអ្នកណា ?

ម៉ាថាយ ៦:៥-៧, ១២:៣៤, យ៉ូហាន ២:១៥-១៦, ធីម៉ូថេទី១, ៦:១០




ពេលក្រោយពួកឯងមកឯ
ដំណាក់បិតាអញ ត្រូវតែលន់តួ
ពីអំពើបាបរបស់ឯង។


តើអ្នកចងចាំពីការទាយ
របស់ស្ដេចដាវីឌដែលទាក់ទង
ទៅនឹងព្រះមែស៊ីទេ ?


បាទ "សេចក្ដីឧស្សាហ៍ផល់ដំណាក់ទ្រង់ បានស៊ីបង្ហិនទូលបង្គំ ពីព្រោះសត្រូវរបស់ ព្រះបានបំភ្លេចចោលបន្ទូលនៃព្រះ" ។
អ្នកដឹងទេ អាចារ្យបង្រៀនថា នៅខណៈដែលព្រះមែស៊ីយាងមក ទ្រង់ នឹងយាងមកវិហាររបស់ទ្រង់ភ្លាម ។


អញគិតថា ឯងជាយេស៊ូវ
នៃណាសារ៉ែត ដែលយ៉ូហានបានបញ្ជាក់ ។
ឯងបង្កើតបញ្ហាជាច្រើនថ្ងៃនេះ តើនឹង
សំដែងទីសំគាល់ណាឱ្យពួកអញឃើញ ?
ភស្តុតាងដែលខ្ញុំជាព្រះមែស៊ី
អ្នកទាំងអស់គ្នានឹងបានឃើញនៅ
ពេលអ្នកបំផ្លាញវិហារនេះ ខ្ញុំនឹងសង់
ឡើងវិញក្នុងរយៈពេលពា៍ថ្ងៃ ។


ពួកអញចំណាយពេល៤៦ឆ្នាំ ដើម្បី សាងសង់វិហារនេះ ហើយឯងគិតថា អាច សាងសង់ឡើងវិញក្នុងរយៈពេល៣ថ្ងៃបាន នោះមិនសមហេតុសមផលទេ!
បើសិនឯងមកទីនេះ វិញ អញនឹងឱ្យគេ ចាប់ឯង។




ទំកុនដំកើង ៦៩:៩, ១១៩:១៣៩, យ៉ូហាន ២:១៧-២២

ព្រះយេស៊ូវនិងសាវករបស់ទ្រង់ បានចាកចេញពីយេរូសាឡិម ហើយ
ត្រឡប់មកទិសខាងជើងទៅណាសារ៉ែតវិញ ដែលជាស្រុកកំណើតរបស់ព្រះអង្គ។



ដូចទម្លាប់របស់ទ្រង់ ព្រះយេស៊ូវចូល ទៅសាលាប្រជុំ
ដែលជាកន្លែងថ្វាយបង្គំ របស់សាសន៍យូដានៅថ្ងៃឈប់សម្រាក ។



លូកា ៤:១៦-២១, សាសន៍យូដាបានគោរពថ្ងៃទីប្រាំពីរជាថ្ងៃឈប់សម្រាករៀងរាល់សប្តាហ៍
ហើយពួកគេបានចាត់ទុកជាថ្ងៃបរិសុទ្ធដើម្បីថ្វាយបង្គំព្រះ
ដូចទ្រង់មានបន្ទូលប្រាប់ពួកគេក្នុងក្រឹត្យវិន័យរបស់ទ្រង់ (លោកុប្បត្តិ ២:២-៣, និក្ខមនំ
២០:១០) ។


យើងសប្បាយចិត្តណាស់ ដោយឃើញគ្នាយើងម្នាក់ ត្រឡប់មកវិញជាមួយមិត្តរបស់គាត់ យើងបានឮអំពីរឿងចំឡែកនៅ យេរូសាឡិម ហើយចង់ដឹងទៀតនៅពេលក្រោយ ។
ប៉ុន្តែឥឡូវនេះសូមយេស៊ូវឡើង អានគម្ពីរឱ្យយើងស្ដាប់បានឬទេ ?


ព្រះយេស៊ូវ បានបើកគម្ពីរអេសាយ ហើយឃើញអំពីបទទំនាយរបស់ ព្រះមែស៊ីឬព្រះសង្គ្រោះដែលមនុស្ស ភាគច្រើនបានស្គាល់ ។
“ព្រះវិញ្ញាណរបស់ព្រះសណ្ឋិតលើខ្ញុំ ពីព្រោះទ្រង់ បានចាត់តាំងខ្ញុំដើម្បីថ្លែងដំណឹងល្អដល់អ្នកក្រ ហើយឱ្យមនុស្សខ្វាក់ មើលឃើញ មនុស្សដែលទទួលការឈឺចាប់បានរួច នឹងថ្លែងព្រះបន្ទូល ថា ដល់ពេលដែលព្រះនាំសេចក្ដីសង្គ្រោះមកដល់រាស្ត្ររបស់ទ្រង់”។


ថ្ងៃនេះ បទទំនាយនេះ
បានបំពេញរួចរាល់ហើយ ។



អ្នកឯងប្រមាថ !
អ្នកឯងគ្រាន់តែជាកូនរបស់ជាងឈើ ។
កុំខឹងៗ ពួកយើងកំពុងចាកចេញហើយ ។
យកដុំថ្មគប់វាឱ្យងាប់ទៅ វាតាំងខ្លួនជាព្រះសង្គ្រោះ !

ព្រះយេស៊ូវនិងសាវករបស់ទ្រង់បានចុះទៅទីក្រុង
កាពើណិម នៅឯបឹងជាកន្លែងដែលសាវករបស់
ទ្រង់ខ្លះបានរស់នៅ ព្រះយេស៊ូវនិងសិស្សរបស់
ទ្រង់បានចូលទៅសាលាប្រជុំម្តងទៀត។




ហោរាបាននិយាយថា ព្រះសង្គ្រោះនឹងធ្វើជាពន្លឺដល់សាសន៍ដទៃ ហើយគេនឹងជឿលើទ្រង់ មនុស្សដែលបរិសុទ្ធក្នុងចិត្ត អ្នកនោះត្រូវសប្បាយព្រោះគេនឹងឃើញព្រះ ព្រះមិនចោលមនុស្សដែលមករកទ្រង់ទេ ទោះជាសាសន៍យូដាឬសាសន៍ដទៃក៏ដោយ ។
ព្រះអង្គបរិសុទ្ធ កុំប៉ះពាល់យើង ។


ខ្ញុំស្គាល់ច្បាស់ហើយ ទ្រង់ ជាព្រះអង្គបរិសុទ្ធនៃព្រះ ។
វាគឺជាមនុស្សដែល អារក្សចូល យកវា ចេញពីទីនេះ ។


តើព្រះអង្គមកបំផ្លាញយើង មុនកំណត់ឬអី ? កុំប៉ះពាល់ យើង ។ តើយើងហើយនឹងទ្រង់ មានការអ្វីនឹងគ្នា ?
អ្នកណាឱ្យវាចូលទីនេះ? សូម ប្រយ័ត្នវាគ្រោះថ្នាក់ណាស់!




លូកា ៤:២៨-៣៩


ចេញទៅ!
អ៊ី អ្ហា៎...


តើអ្នកធ្វើអ្វី ទៅលើគាត់ ?
គាត់ស្លាប់ឬ?


មួយរំពេចនោះគាត់បានក្រោកឈរ ។
សូមសរសើរ
ព្រះអង្គ !
អារក្សទាំងអស់បាន
ចេញ អ្នកបានរួចហើយ
ឥឡូវចេញទៅ នឹង
កុំធ្វើបាបទៀត ។
យេស៊ូវមាន
អំណាចលើអារក្សទាំងអស់
អ្នកនោះធម្មតាវិញ ។


ពូពេត្រុស
ប្រពន្ធរបស់ពូ ត្រូវការពូទៅផ្ទះ
ម្តាយក្មេករបស់ពូ ឈឺគ្រុនក្តៅយ៉ាងខ្លាំង ។
យើងនឹងទៅ


អូ៎ បងពេត្រុស អូន
ព្រួយបារម្ភណាស់ជងឺគ្រុន
ក្ដៅកាន់តែខ្លាំងឡើងៗ ។
កុំព្រួយបារម្ភលោកគ្រូ
មកដល់ហើយ ។


ក្រោកឈរឡើងអ៊ំ
ស្រីជាទីស្រឡាញ់ ជំងឺ
របស់អ៊ំបានជាហើយ ។


ម៉ាកុស ១:២៥-៣០,
លូកា ៤:៣៥-៣៨
អ៊ុំ ម៉ាក់កំពុងក្រោក ឈរ ! ម៉ាក់បានជាហើយ ។
អ៊ំស្រីបានក្រោកឡើងពីគ្រែ ហើយបានបំរើដល់ព្រះយេស៊ូវ និងសាវករបស់ទ្រង់ ។


ដំណឹងពីការព្យាបាលនោះត្រូវបានឮទៅដល់កន្លែងជាច្រើន ហើយពួកគេនាំអ្នកជំងឺជាច្រើនទៅឯទ្រង់។
លោកគ្រូ ឪពុករបស់ខ្ញុំបាន ខ្វិនតាំងពីខ្ញុំនៅក្មេងតូច បង្គោល មួយបានធ្លាក់ត្រូវគាត់បាក់ខ្នង សូមទ្រង់ជួយដល់គាត់ផង។
ក្រោកឡើង ហើយដើរទៅ។


សិរីល្អមាន
ដល់ព្រះ !




ម៉ាកុស ១:៣០-៣៤, លូកា ៤:៣៨-៤០


ដូចដែលគម្ពីរបានចែងថា “**មនុស្សខ្វាក់នឹងត្រូវមើលឃើញ**” ឥឡូវកូនស្រីរបស់អ្នកបានមើលឃើញហើយ ។


ប៉ា គឺប៉ាមែនទេ ?


លោកប៉ាអើយ !
កូនមិនដែលឃើញរូបរាងប៉ាយ៉ាងណា
ទេប៉ាសង្ហាជាងកូនស្រមៃទៅទៀត ។


ព្រះយេស៊ូវនិងសាវករបស់ទ្រង់បានទៅទីក្រុង យេរូសាឡិម ក្នុងអំឡុងពេលថ្ងៃបុណ្យ ហើយ ទ្រង់បានបង្រៀននៅក្នុងវិហារ។
ពេលនរណាម្នាក់ជេរអ្នក សូមកុំជេរគេវិញ ប៉ុន្តែអ្នកអធិដ្ឋានសូមព្រះប្រទានពរដល់គេ។ អ្នកគួរតែប្រព្រឹត្ត ទៅលើមនុស្សដទៃ ដូចអ្នកចង់បានឱ្យមនុស្សដទៃប្រព្រឹត្តមក លើអ្នក បើសិនអ្នកជាពួកគេវិញ។


ពេលមនុស្សប្រព្រឹត្តអំពើមិនគប្បីជាមួយ
នឹងអ្នក អ្នកគួរតែលើកលែងទោសឱ្យគេ ។ អ្នកនឹងមានពរ
បើសិនអ្នកមានចិត្តស្មោះត្រង់ព្រោះអ្នកនឹងឃើញព្រះ ។
បើសិនអ្នកធ្វើឱ្យមានសន្តិភាព អ្នកនឹងមានពរដ៏ល្អ ។


ពីមុនអ្នកឮគេនិយាយថា អ្នកគួរតែស្រឡាញ់មិត្តភក្តិរបស់អ្នក ហើយស្អប់សត្រូវរបស់អ្នក ប៉ុន្តែខ្ញុំប្រាប់អ្នកថា អ្នកគួរតែស្រឡាញ់សត្រូវរបស់អ្នក ហើយធ្វើល្អដល់គេវិញ។
តើឱ្យយើងគិតយ៉ាងម៉េចអំពីភ្នែកធួននឹងភ្នែក ធ្មេញធួននឹងធ្មេញ ?


បើសិននរណាម្នាក់ទះកំភ្លៀងអ្នកម្ខាង
សូមបែរឱ្យគេទះម្ខាងទៀតទៅ។
កុំប្រព្រឹត្តអំពើហិង្សា។ បើសិនអ្នកឃើញថា
អ្នកជិតខាងរបស់អ្នកត្រូវការអាវហើយ
អ្នកមានអាវពីរ នោះឱ្យគេមួយទៅ
បើសិនគេឃ្លានសូមឱ្យគេហូបផង។
ព្រះវបិតា របស់អ្នកនៅឋានសួគ៌នឹងឃើញ
នឹងប្រទានពរចំពោះចិត្តសប្បុរសរបស់អ្នក។




ម៉ាថាយ ៥:៤៣-៤៤, ៦:១២, ៥:៨, ៣៨-៤២, ៥:២១-២២, ម៉ាកុស ១:៣៤, លូកា ៤:៣៩-៤១


អ្នកបានឮគេនិយាយកាលពីបុរាណថា មនុស្សមិនត្រូវ ផិតក្បត់ទេ ប៉ុន្តែខ្ញុំប្រាប់អ្នករាល់គ្នាថា បើសិនអ្នកមើលទៅ ស្ត្រីដោយមានការត្រេកត្រអាលសំរើបចង់បាន អ្នកនោះបាន ធ្វើការផិតក្បត់ជាមួយនាងនៅក្នុងចិត្តរួចស្រេចហើយ ។


អ្នកដឹកនាំសាសនា
តាមពិតធ្វើឱ្យ តែល្អមើលខាងក្រៅ
ប៉ុន្តែខាងក្នុងពួកគេ
ពោរពេញដោយភាពអាក្រក់ ។


ពួកគេដូចជាផ្នូរខ្មោចដែលបានលាបពណ៌សនៅខាងក្រៅដូចជាល្អមើល
ប៉ុន្តែមើលខាងក្នុងពោរពេញទៅដោយឆ្អឹងរបស់មនុស្សស្លាប់ ដូចពាក្យចាស់
និយាយថា "ខាងក្រៅអាចារ្យខាងក្នុងអាចោរ" ។ បើសិនអ្នកមិនមានសេចក្ដី
សុចរិតច្រើនជាងពួកគេទេ អ្នកនឹងមិនអាចចូលទៅក្នុងនគររបស់ខ្ញុំបានទេ ។


មានផ្លូវធំមួយដែលនាំ ទៅសេចក្ដីហិនវិនាស ហើយ មនុស្សជាច្រើនកំពុងទៅ តាមផ្លូវនោះ ។
ខ្ញុំគឺជាទ្វារទៅឋានសួគ៌ បើសិនអ្នកចូលតាមខ្ញុំ អ្នកនឹងមានជីវិតអស់កល្ប ជានិច្ច បើសិនអ្នកព្យាយាមចូលតាមផ្លូវផ្សេង អ្នកនឹងស្លាប់ក្នុងអំពើបាបរបស់អ្នក ។


ហេតុអ្វីឯងប្រាប់ឱ្យមនុស្ស ជានៅថ្ងៃឈប់សម្រាក ? ម៉ូសេ បានបង្គាប់ថា យើងមិនត្រូវធ្វើការ នៅថ្ងៃឈប់សម្រាកទេ ។
ព្រះវរបិតារបស់ខ្ញុំ បញ្ជូនខ្ញុំមកលោកិយ នេះ ដើម្បីធ្វើការងាររបស់ទ្រង់ ខ្ញុំធ្វើតាម អ្វីដែលទ្រង់បញ្ជាឱ្យខ្ញុំធ្វើ ។
ឯងលើកខ្លួនឯងស្មើនឹងព្រះ នោះគឺជាការ ប្រមាថ មានទោសប្រហារជីវិត !


នេះគឺជាព្រះហឫទ័យព្រះវរបិតានៃឋានសួគ៌ ដែលមនុស្សទាំងអស់ថ្វាយបង្គំ និងគោរព ព្រះរាជបុត្រាដូចជាព្រះវរបិតាដែរ ។
មានពេលមួយដែលខ្មោច ទាំងអស់នៅក្នុងផ្នូរបានឮសំលេងខ្ញុំ នឹងរស់ ពីស្លាប់ឡើងវិញ ខ្លះមានជីវិតអស់កល្ប ខ្លះ មានទោសអស់កល្បជានិច្ច ។


តាមពិតនេះជាព្រះមែស៊ី ដំបូងមានការអស្ចារ្យ ហើយ ឥឡូវទ្រង់មានការអះអាង យ៉ាងក្លាហាន ។
គាត់គឺខុសប្លែកពីអ្នកដឹកនាំ សាសនារបស់យើង គាត់និយាយដូចមាន អំណាច ខ្ញុំខ្លាចថាគេនឹងសម្លាប់គាត់ ។
ខ្ញុំត្រូវតែទៅ នឹង ប្រាប់ប្រពន្ធខ្ញុំ ។
ម៉ាថាយ ៥:២៧-២៨, ៧:១៣-១៤, ២៨-២៩, ២៣:២៧-២៨, យ៉ូហាន ៥:១៨-១៩, ២៣, ២៩-៣០, ១៤:៦


លោកគ្រូ មានផារិស៊ីម្នាក់មក ជួបលោកគ្រូ គាត់គឺជាអ្នកដឹកនាំនៃសាសន៍យូដាដ៏សំខាន់ ។
ហេតុអ្វីគាត់មកនៅពេលយប់ ? តើគាត់ខ្មាសគេបើសិនគេនឹងឃើញគាត់និយាយជាមួយលោកគ្រូឬ ?
ខ្ញុំនឹងទៅនិយាយជាមួយគាត់តែពីរនាក់ ។
ផារិស៊ីជាសមាជិកនិកាយមួយក្រុមនៅសាសនាយូដា ដែលគោរពព្រពៃណីសាសនារបស់ពួកគេយ៉ាងតឹងរឹង ។


លោកគ្រូ យើងទាំងអស់គ្នាដែលជាអ្នកដឹកនាំជនជាតិយូដាដឹងថា លោកគឺជាគ្រូម្នាក់ដែលមកពីព្រះ ពីព្រោះមនុស្សមិនអាចធ្វើការអស្ចារ្យដូចលោកធ្វើទេ លើកលែងតែព្រះគង់ជាមួយ ។
បើអ្នកមិនកើតជាថ្មី អ្នកមិនអាចឃើញនគររបស់ព្រះទេ ។


តើលោកប្រាប់ខ្ញុំថា ខ្ញុំគួរ ចូលក្នុងផ្ទៃម្ដាយខ្ញុំ ហើយកើតមកជាលើកទីពីរឬ ?
ទេសាច់ឈាមបង្កើតសាច់ឈាម ហើយ វិញ្ញាណបង្កើតវិញ្ញាណ នីកូដេម ចូរស្ដាប់ អ្វីដែលខ្ញុំប្រាប់អ្នក អ្នកត្រូវកើតជាថ្មី ។
តើយើងទទួលការកើតជាថ្មីយ៉ាងម៉េច ?


ដូចម៉ូសេបានលើករូប
ពស់នៅទីរហោស្ថាន ខ្ញុំនឹងត្រូវ
លើកឡើងដូច្នេះដែរ ។
ការកើតជាថ្មីខាងវិញ្ញាណ
ដែលខ្ញុំនិយាយមានអាថិកំបាំងដូចជាខ្យល់
ប៉ុន្តែយើងអាចទទួលឥទ្ធិពលទាំងពីរនោះបាន អ្នក ត្រូវតែមានការកើតជាថ្មីនេះ
ដែលមកពីខាងលើ បើសិនអ្នកនឹងចូលនគររបស់ព្រះ ។

# ជនគណនា ២១:៥-៩, យ៉ូហាន ៣:១-១៤




យេស៊ូវពី ណាសារ៉ែត ស្តេចនៃយូដា
បាទ
ឥឡូវនេះមនុស្សទាំងអស់កំពុងស្លាប់
ដោយ "ការចឹក" នៃអំពើបាប ប៉ុន្តែពេលនេះខ្ញុំនឹង
ត្រូវបានគេលើកឡើងសម្រាប់មនុស្សទាំងអស់មើល
ឃើញ ។ ដូចគេដែលត្រូវបានចឹកនៅទីរហោស្ថាន
បានសង្គ្រោះឱ្យជាដោយគ្រាន់តែមើលទៅពស់លង្ហិន
គេដែលត្រូវចឹកដោយអំពើបាបនឹងស្វែងរក
សេចក្តីសង្គ្រោះដោយជឿលើខ្ញុំ ។


ដ្បិតទ្រង់ស្រលាញ់មនុស្សលោកដល់ម្ល៉េះ
បានជាទ្រង់ប្រទានព្រះរាជ្យបុត្រាទ្រង់តែមួយ ដើម្បីឱ្យ
អ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ
គឺឱ្យមានជីវិតអស់កល្បជានិច្ចវិញ ។ អស់អ្នកណាដែលជឿ
លើខ្ញុំមានជីវិតអស់កល្បជានិច្ច ប៉ុន្តែអស់អ្នកណាដែលមិន
ជឿលើខ្ញុំ នោះត្រូវមានទោសហើយ ។
យ៉ូហាន ៣:១៤-១៨


ដូច្នេះលោកគ្រូនិយាយថា យើង
មានផ្លូវតែមួយគត់ ដើម្បីប្រោសឱ្យជាពី
អំពើបាបនេះគឺការកើតជាថ្មី ហើយគេនឹង
ដាក់លោកនៅបង្គោលឆ្កាងដូចពស់លង្ហិន
ដើម្បីផ្ដល់ការសង្គ្រោះនេះ។


តើការកើតជា ថ្មីនេះ
កើតឡើងនៅ ពេលណា ?
បន្ទាប់ពីគេលើកខ្ញុំ
ឡើងសម្រាប់មនុស្ស
ទាំងអស់ឃើញ ។

ពួកសាម៉ារី បានរស់នៅចន្លោះទីក្រុង
យេរូសាឡិមនិងស្រុកកាលីឡេ
សាសន៍យូដាបានគេចវេះពីពួក
សាម៉ារី ហើយនឹងមិនឆ្លងកាត់
ទីក្រុងគេទេ ពីព្រោះពួកគេបានជឿ
ថា ពួកសាម៉ារីមិនបរិសុទ្ធជាពួក
ស្មោកគ្រោក ។ នៅថ្ងៃមួយព្រះ
យេស៊ូវបានធ្វើឱ្យសិស្សរបស់ទ្រង់
ភ្ញាក់ផ្អើលនៅពេលទ្រង់
មានបន្ទូលថា...




មក ខ្ញុំត្រូវតែ ឆ្លងកាត់សាម៉ារី ។
ព្រះអម្ចាស់ ពួកគេមិន បរិសុទ្ធ ជាមនុស្សល្ងង់ ! ពួកគេ ក្រនិងអសីលធម៌ទៀត ។
វាជាគោលបំណង នៃព្រះវរបិតាដែលខ្ញុំ ត្រូវទៅសាម៉ារី ។


ប្រហែលថ្ងៃត្រង់ ពួកសាវកនិងព្រះយេស៊ូវ
បានមកដល់អណ្តូងមួយនៅខាងក្រៅទីក្រុង ។
អ្នកចូលក្នុងទីក្រុងទិញ អាហារខ្លះ
ខ្ញុំនឹងចាំ នៅក្បែរអណ្តូងនេះ ។
តើទ្រង់នឹងនៅ
ទីនេះម្នាក់ឯងឬ?
បាទ ខ្ញុំត្រូវតែធ្វើការងារ
របស់ព្រះវរបិតាខ្ញុំ ។


ព្រះយេស៊ូវ មានការស្រេកឃ្លាននិងអស់កម្លាំង។
មិនទាន់ដល់ពេលសម្រាប់មនុស្សមកដងទឹកទេ តែ
មានស្ត្រីម្នាក់ជាសាសន៍សាម៉ារីបានមកដងទឹកមុន។
យ៉ូហាន ៤:១-៨


តើនាងអាចឱ្យខ្ញុំសុំ
ទឹកពីធុងរបស់នាងហូបផង បានដែរឬទេ ?
ហ៎ា ! ហេតុអ្វីលោកជាសាសន៍
យូដាមកសុំទឹកពីខ្ញុំជាស្ត្រីសាម៉ារីហូប?
ខ្ញុំគិតថាសាសន៍យូដាគ្មានអ្វីទាក់ទង
ជាមួយនឹងសាសន៍សាម៉ារីទេ ។
បើសិននាងដឹងពីអំណោយទាន
របស់ព្រះ ហើយដឹងថាខ្ញុំជានរណា នាងអាច
សុំខ្ញុំ ហើយខ្ញុំអាចឱ្យទឹកជីវិតទៅនាង ។


លោកឱ្យទឹកខ្ញុំ?
លោកគ្មានអ្វីដង ទឹក ហើយអណ្តូងក៏ជ្រៅ
តើលោក យកទឹកជីវិតមកពីណា ?
សូមលោកឱ្យទឹកជីវិត
នេះមកខ្ញុំ ដើម្បីកុំឱ្យ
ស្រេកទៀត ។
ពេលនាងផឹកទឹកពីអណ្តូងនេះ
នាង នឹងស្រេកម្តងទៀត
ទឹកដែលខ្ញុំឱ្យនាងវិញ
នឹងដូចជាប្រភពនៃជីវិតអស់កល្បជានិច្ច
នៅក្នុងព្រលឹងរបស់នាង ។


ទៅហៅប្ដីរបស់នាង មកជួបខ្ញុំ ហើយខ្ញុំនឹងប្រាប់ នាងអំពីទឹកនេះ ។
ខ្ញុំឥតមានប្ដីទេ
នាងធ្លាប់មានប្ដី៥ហើយ ប៉ុន្តែបុរសដែលរស់នៅ ជាមួយនាង ឥឡូវមិនមែន ជាប្ដីរបស់នាងទេ ។


តាមពិតលោកគឺជា ហោរា ដែលដឹងពីបាប សម្ងាត់របស់ខ្ញុំ ។
ពួកយូដា ថ្វាយបង្គំនៅទីក្រុងយេរូសាឡិម ហើយជីដូនជីតារបស់យើងថ្វាយបង្គំនៅលើភ្នំនេះ តើភ្នំមួយណាជាកន្លែងត្រឹមត្រូវសម្រាប់ថ្វាយបង្គំ?


ព្រះគឺជាវិញ្ញាណ មនុស្សមិនថ្វាយបង្គំទ្រង់ក្នុងវិហារដែលសាងសង់ដោយដៃគេឡើយ ព្រះកំពុងរកមនុស្សដែលជឿលើសេចក្តីពិត នឹងថ្វាយបង្គំទ្រង់ដោយវិញ្ញាណ។
យើងដឹងថា ព្រះមែស៊ី នឹងយាងមក ហើយពេលទ្រង់ យាងមក ទ្រង់នឹងបង្ហាញសេចក្តីពិតដល់យើង។


នាងកំពុងនិយាយ
ជាមួយព្រះមែស៊ី ។


ខ្ញុំត្រូវការទៅរក
មិត្តភក្តិរបស់ខ្ញុំ ហើយ
នឹងប្រាប់ពួកគេ !
ព្រះយេស៊ូវបាននៅសាម៉ារីរយៈ ពេល២ថ្ងៃ
ហើយនឹងបង្រៀន មនុស្សពីបន្ទូលនៃព្រះ ។

យ៉ូហាន ៤:៧-២៩, ៤០


នៅថ្ងៃមួយព្រះយេស៊ូវនិងសាវករបស់ទ្រង់ឈរនៅ
ជើងភ្នំនៅជិតបឹងកាលីឡេ មនុស្សរាប់ពាន់នាក់
ចេញមកពីទីក្រុងដើម្បីស្តាប់ទ្រង់បង្រៀន ។
ពេលអ្នកធ្វើទានទៅអ្នកក្រ
កុំធ្វើនៅកន្លែងទីប្រជុំជនដែលមនុស្ស
ដទៃអាចមើលឃើញ ។
នៅពេលអ្នកធ្វើអ្វីដែលទាក់ទងនឹងសាសនា
ដើម្បីឱ្យមនុស្សផ្សេងបានឃើញហើយសរសើរអ្នក
អ្នក នឹងមិនបានទទួលរង្វាន់ពីព្រះនៅឋានសួគ៌ទេ ។
ដូច្នេះកុំ ឱ្យដៃស្តាំរបស់អ្នកដឹងអ្វីដែលដៃឆ្វេងធ្វើ ។


នៅពេលអ្នកអធិដ្ឋានកុំ
ធ្វើដូចជាពួកមនុស្សលាក់
ពុតខាងសាសនាដែល
អធិដ្ឋាននៅទីសាធារណៈ
ដើម្បីឱ្យមនុស្សទាំងអស់
ឃើញពួកគេ ។
ពេលដែលអ្នកអធិដ្ឋានកុំប្រើពាក្យ
ដដែលៗ ដូចអ្នកដឹកនាំសាសនារបស់អ្នកធ្វើ
ព្រោះពួកគេឈរនៅកន្លែងសាធារណៈ ហើយ ធ្វើខ្លួនដូចជាអ្នកជឿស៊ប់ ។


កុំចំណាយកំលាំងរបស់អ្នកនិងពេលវេលា ដើម្បីស្វែងរកទ្រព្យសម្បត្តិឡើយ អ្នកមានតែងតែ មានបញ្ហាច្រើនជាងគេ ដោយពួកគេស្រឡាញ់ ទ្រព្យសម្បត្តិយ៉ាងខ្លាំងនោះជាការលំបាកសម្រាប់ពួកគេចូលទៅឋានសួគ៌ ។


កុំប្រមូលទ្រព្យសម្បត្តិ
ទុកសម្រាប់ខ្លួននៅផែនដីនេះ ប៉ុន្តែ
ត្រូវប្រមូលទ្រព្យសម្បត្តិទុកសម្រាប់
ខ្លួននៅឋានសួគ៌វិញ ជាកន្លែងដែល
អស់កល្បជានិច្ច អ្នកមិនអាចបំរើម្ចាស់
ពីរបានទេ គឺព្រះហើយនិងលុយ នៅទី
បញ្ចប់អ្នកនឹងស្រលាញ់មួយហើយ
ស្អប់មួយជាមិនខាន។


លោកគ្រូ ឥឡូវថ្ងៃជិតលិចហើយ មនុស្សទាំងអស់បាននៅជាមួយយើង ពេញមួយថ្ងៃ ពួកគេបានឃ្លានហើយ ទីនេះឆ្ងាយពីផ្សារ ពួកគេពិបាករកទិញអាហារបាន។
លោកគ្រូ សូមឱ្យហ្វូងមនុស្សត្រឡប់ទៅវិញ ទៅដើម្បីពួកគេអាចទិញអាហារបាន។


លោកគ្រូ
អាចពិសារ អាហាររបស់ខ្ញុំបាន ម្ដាយរបស់
ខ្ញុំបានទុកនំប៉ុង៥ដុំនិងត្រីតូចពីរ នេះសម្រាប់ខ្ញុំ។




ម៉ាថាយ ១៤:១៥, ៦:១-៧, ៦:១៩-២១


សូមមើលសិន..!
អ៊ូ.. យើង
នឹងហូបត្រីជាមួយនំប៉័ង។
ប៉ុន្តែលោកគ្រូម្ហូបនេះមិនឆ្អែត
សម្រាប់មនុស្សម្នាក់ផង ចុះមនុស្ស
៥០០០នាក់មានអ្វីហូបដែរ។
ចូរទៅខ្ចីកន្ត្រកធំៗ១២
ហើយរៀបចំចែកអាហារ។


មានពរហើយព្រះអម្ចាស់នៃយើងអើយ ជាស្តេចនៃសកលលោក ដែលបានប្រទាននំបុ័ងនេះចេញពីដី ។


តើលោកគ្រូកំពុងយកអាហារបន្តិចបន្តួចចាក់ក្នុងកន្ត្រកធំនេះធ្វើអ្វី ?




ម៉ាថាយ ១៤:១៩-២១, លូកា ៩:១៦-១៧


សរសើរព្រះអង្គ !
ទ្រង់ប្រទាននំប៉ុងឱ្យ
យើងមកពីឋានសួគ៌
ដូចម៉ូសេដែរ ។
នៅពេលខ្ញុំប្រាប់ម៉ាក់ពីការ នេះ
ប្រហែលម៉ាក់មិនជឿ ។


នៅពេលមនុស្សបានយកនំប៉័ង
និងត្រីចេញពីកន្ត្រក វានៅតែ
មានច្រើនឡើងៗ។



លោកគ្រូ
មនុស្សទាំងអស់ បានហូបរួចហើយ
តែអាហារ នៅពេញកន្ត្រក
យើងចែក វាមិនអស់ទេ។
ប្រមូលអ្វីដែលនៅសល់
ហើយអ្នករាល់គ្នាចុះទូកឆ្លងទៅបឹងម្ខាង
នោះមុន ខ្ញុំនឹងជួបអ្នកពេលក្រោយ ខ្ញុំ
ត្រូវការឡើងភ្នំដើម្បីអធិដ្ឋានសិន។

ព្រះយេស៊ូវ បានឡើងលើភ្នំតែម្នាក់ ឯង ហើយសាវករបស់ទ្រង់ទាំងអស់
បានចុះទៅក្នុងទូកចាកចេញទៅ ឯបឹងម្ខាងទៀត។



ព្រះយេស៊ូវតែងតែយាងទៅកន្លែងស្ងាត់ម្នាក់ឯងដើម្បីអធិដ្ឋាន។

ម៉ាថាយ ១៤:២០-២៣


បន្ទាប់ពីសាវកបានចេញទៅដល់ពាក់កណ្ដាលបឹង ព្យុះដ៏កំណាចមួយបានកើតឡើង ហើយពួកគេមានការភ័យខ្លាចលិចទូកយ៉ាងខ្លាំង ។
ខ្ញុំមិនធ្លាប់បានឃើញ ព្យុះធំដូចនេះទេ ។
បើព្យុះនៅតែខ្លាំងដូចនេះ យើងមិនអាចគេចផុតទេ ។


ទូកយើង នឹងលិច !
មើលន៎ ! មានអ្វីនៅលើទឹក !


នោះគឺជាខ្មោច!
វាជាខ្មោចមែន!
មិនមែនទេ ជាមនុស្ស
ម្នាក់ដើរលើទឹក !


ពេត្រុស
គឺខ្ញុំ កុំភ័យខ្លាចអី ។
ព្រះជាម្ចាស់
បើសិនជាទ្រង់ មែន
សូមអនុញ្ញាតឱ្យទូលបង្គំដើរ
ទៅឯទ្រង់នៅលើទឹកផង ដូចដែល
ទ្រង់កំពុងធ្វើ ។
ពេត្រុសមកឯខ្ញុំចុះ

ម៉ាថាយ ១៤:២៨-២៩


ទូលបង្គំកំពុងទៅឯព្រះអង្គ
ទេ ពេត្រុស
កុំទៅ !


ពេត្រុស ពិតជាកំពុងដើរ
លើទឹកទៅឯព្រះយេស៊ូវ ។

នៅពេលពេត្រុសឃើញរលកធំ
បានបាំងលែងឃើញព្រះយេស៊ូវ
គាត់ចាប់ផ្តើមភ័យខ្លាច ។




ដោយសារការភ័យខ្លាច
គាត់បានបាត់បង់ សេចក្ដីជំនឿ
ហើយចាប់ផ្ដើមលិចទឹក។
ព្រះជាម្ចាស់អើយ
ជួយទូលបង្គំផង !

ម៉ាថាយ ១៤:២៩-៣០


ពេត្រុស
អ្នកចាប់ផ្ដើម
សង្ស័យលើខ្ញុំ។


ព្រះយេស៊ូវ នាំពេត្រុសមក លើទូកវិញដោយដើរលើទឹក។
ពេត្រុស អ្នកបាន ដើរនៅលើទឹក!


ចូរស្ងប់ទៅ
ហើយឈប់ចុះ
ព្រះយេស៊ូវ បានបង្គាប់ទៅខ្យល់ព្យុះ
ហើយភ្លាមនោះខ្យល់បានស្ងប់ស្ងាត់វិញ។
ម៉ាថាយ ១៤:៣១-៣៣, ៤:៣៨-៤១


ឱព្រះជាម្ចាស់សូមទ្រង់យាង
ចេញពីទូលបង្គំ ព្រោះទូលបង្គំ
ជាមនុស្សពេញដោយអំពើបាប ។
ទ្រង់ពិតជាព្រះរាជបុត្រា
នៃព្រះមែន ។
ព្រះគ្រីស្ទនៃ
អ៊ីស្រាអែល ។
ព្រះជាម្ចាស់អើយ
ទ្រង់ជាព្រះរបស់ទូលបង្គំ ។


នៅថ្ងៃបន្ទាប់មក...
បុណ្យនេះហាក់ដូចជាមានមនុស្សជាច្រើនមកពីគ្រប់ទីកន្លែង ខ្លះមក ពីឆ្ងាយដូចជារ៉ូម និង អេស៊ីព្ទ។
យើងចុះតាមផ្លូវវាង ជិតអាងទឹក។


តាមអ្វីដែលខ្ញុំ
ចងចាំ ខ្ញុំឃើញគាត់
នៅទីនេះរហូត ។
ព្រះយេស៊ូវជ្រាបគ្រប់កិច្ចការទាំងអស់
ហើយទ្រង់កំពុងមានបន្ទូលថា...


តើអ៊ំចង់ជា
ឬទេ ?
ខ្ញុំគ្មានអ្នកណា
ជួយគ្រាចុះក្នុងទឹកទេ
មានគេចុះមុនរហូត ។


ក្រោកឡើងយក
គ្រែរបស់អ៊ំហើយដើរ ចេញទៅ។
តើអ្នកជាយេស៊ូវ មែនទេ ?
ខ្ញុំធ្លាប់បានឮ ការអស្ចារ្យរបស់អ្នក។

យ៉ូហាន ៥:១-៨


នោះដូចជាលេងសើចជ្រុលពេក
ហើយ បុរសនោះបានពិការជើង
អស់រយៈពេល៣៨ឆ្នាំហើយ ។
នេះជាថ្ងៃឈប់សម្រាកដ៏បរិសុទ្ធ
របស់យើង វាគ្មានសិទ្ធិអ្វីរំខាន
ភាពស្ងប់ស្ងាត់របស់យើងទេ ។


ខ្ញុំបានឮថា មានចលាចលមួយកើតឡើងក្នុងពួកសង្ឃដើម្បី កំចាត់វាចោល ព្រោះមានមនុស្សចាប់អារម្មណ៍លើវាច្រើនពេក ។
តើយេស៊ូវនេះគិតថាវាជានរណា វាជាព្រះមែស៊ីឬ ?
បាទ វាធ្វើឱ្យមនុស្សជឿថា វាអាចធ្វើការអស្ចារ្យបាន ។


ជើងរបស់គាត់កំពុង
តែជាដូចដើមវិញ !


គាត់ក្រោកឈរ!
វាមិនអាចទេ !


សរសើរព្រះអង្គ! អស់រយៈពេលជាច្រើនឆ្នាំហើយ ឥឡូវខ្ញុំដើររួច !
យេស៊ូវគឺជាព្រះមែស៊ី !


ហេតុអ្វីឯងប្រាប់ឱ្យជា នៅថ្ងៃឈប់សម្រាក ?
ម៉ូសេ បានបង្គាប់ យើងឱ្យឈប់សម្រាក នៅថ្ងៃបរិសុទ្ធ។
លូកា ១៤:៥-៦, យ៉ូហាន ៥:៩-១៧


នោះគួរតែទទួលធ្វើនៅថ្ងៃឈប់សម្រាក ដើម្បីទាញគោឈ្មោលរបស់អ្នកចេញពីជង្ហុកជ្រៅ តើខ្ញុំរំលងក្រឹត្យវិន័យនៅពេលខ្ញុំប្រោសមនុស្សជានៅថ្ងៃឈប់សម្រាកឬ ?
ព្រះវរបិតាខ្ញុំធ្វើការនៅថ្ងៃឈប់សម្រាក ហើយជាធម្មតាខ្ញុំធ្វើដូចដែលខ្ញុំឃើញទ្រង់ធ្វើ ។


ចាប់វាឱ្យជាប់! វាគួរតែស្លាប់ដោយចោលនឹងដុំថ្ម ។
វាតាំងខ្លួនស្មើនឹងព្រះ ព្រោះវានិយាយថា ព្រះ គឺជាបិតារបស់វា ។
សម្លាប់វាទៅ!


តើអ្នកនឹងសម្លាប់គាត់ដែលប្រោស ឱ្យគេជានៅថ្ងៃឈប់សម្រាកឬ?
វានិយាយប្រឆាំងនឹង ក្រឹត្យវិន័យរបស់យើង ។
លោកគ្រូខ្ញុំមិនបាន និយាយប្រឆាំងនឹង ក្រឹត្យវិន័យទេ ។
សូមស្តាប់អ្វីដែល គាត់និយាយ ។


ចូរស្ដាប់ខ្ញុំ
អ្នកភ្ញាក់ផ្អើលពីព្រោះ ខ្ញុំធ្វើការអស្ចារ្យមួយនេះ
អ្នកនឹងឃើញការ អស្ចារ្យជាច្រើនធំជាងនេះទៅទៀត ។
ដូចជា ព្រះវរបិតារបស់ខ្ញុំអាចប្រោសអ្នកស្លាប់ឱ្យរស់
ឡើងវិញ ទ្រង់បានប្រទានឱ្យខ្ញុំមានអំណាចដូច
ទ្រង់ដែរ ។ ព្រះវរបិតាបានឱ្យខ្ញុំមានគ្រប់
អំណាចលើពិភពលោកនេះ ។


តើឯងអាចឱ្យជីវិតអស់កល្បជានិច្ចដោយរបៀបណា ?
នេះបើសិនអ្នកមិនគោរពខ្ញុំ អ្នកមិនគោរពព្រះវរបិតាដែរ ។ ខ្ញុំប្រាប់ អ្នកនូវការពិត អ្នកដែលជឿលើខ្ញុំក៏ជឿលើព្រះវរបិតាដែលបញ្ជូនខ្ញុំមកដែរ ហើយអ្នកនោះនឹងមានជីវិត អស់កល្បជានិច្ច ។


នោះនឹងមានពេលមួយដែលអ្នកស្លាប់ទាំងអស់នឹងឮសំលេង
របស់ខ្ញុំ ហើយគេនឹងចេញពីផ្នូរមក អ្នកដែលបានប្រព្រឹត្តអំពើល្អនឹងរស់
ឡើងវិញឱ្យមានជីវិតអស់កល្បជានិច្ច ប៉ុន្តែអ្នកដែលបានប្រព្រឹត្តអំពើ
អាក្រក់នឹងបោះចូលបឹងភ្លើងដែលឆេះអស់កល្បជានិច្ច ។
នោះជាការប្រមាថ
គ្មានអ្នកណាដែលអាចធ្វើឱ្យ
មនុស្សស្លាប់រស់ឡើងវិញ ។ មាន
តែព្រះទេដែលអាចឱ្យជីវិត
អស់កល្បជានិច្ច ។
យ៉ូហាន ៥:១៨-២៩


អ្នកមិនជឿខ្ញុំ ប៉ុន្តែយ៉ូហានបានទាយពីការយាងមករបស់ខ្ញុំ គម្ពីរក៏បានសរសេរដូច្នេះដែរ ចូរមើលក្នុងខគម្ពីរ ពីព្រោះមានបទទំនាយជាច្រើននិយាយអំពីខ្ញុំ ។


នោះជាម្នាក់ដែលពួកគេព្យាយាមសម្លាប់
តែគាត់និយាយយ៉ាងក្លាហាន ហើយពួកគេមិនធ្វើអ្វីគាត់ទេ។
តើពួកអ្នកគ្រប់គ្រងសាសនារបស់យើងដឹងថា នេះពិតជា
ព្រះគ្រីស្ទដែលជាព្រះមែស៊ីនៃអ៊ីស្រាអែលឬ ?


សូមកុំគិតថា ខ្ញុំនឹងប្រកាន់អ្នក ចំពោះព្រះក្រឹត្យវិន័យរបស់ម៉ូសេដែលអ្នកមិនបានគោរពត្រឹមត្រូវនឹងមានទីបន្ទាល់ជំទាស់នឹងអ្នក ។
ពួកអាចារ្យបង្រៀនថាយើងមិនដឹងអ្នក សង្គ្រោះមកពីណាប៉ុន្តែយើងដឹងថាបុរសនេះជាកូនរបស់ជាងឈើម្នាក់មកពីស្រុកកាលីឡេ ។


អ្នកនិយាយថា អ្នកស្គាល់ខ្ញុំ ហើយដឹង ខ្ញុំមកពីណាដែរ ។ ខ្ញុំមិនមែនមកលោកិយនេះ ដោយខ្លួនខ្ញុំទេ បិតារបស់ខ្ញុំបញ្ជូនខ្ញុំមក ប៉ុន្តែអ្នក មិនស្គាល់បិតារបស់ខ្ញុំ តែខ្ញុំស្គាល់ទ្រង់ ហើយ ទ្រង់បញ្ជូនខ្ញុំមកឯអ្នកទាំងអស់គ្នា ។
តើគាត់ឮខ្ញុំ និយាយយ៉ាងម៉េច ?


ទ្រង់ជ្រាបអ្វីៗទាំងអស់ ។
នេះគឺជាព្រះមែស៊ី ដែល ហោរាទាយថានឹងយាងមក!
តើអ្នកគិតថា ព្រះមែស៊ី ធ្វើការអស្ចារ្យច្រើនជាង បុរសនេះបានធ្វើឬ ?




យ៉ូហាន ៥:៣០-៣៩, ៤៥, ៦:៤២-៤៣, ៧:២៥-៣២, ៤០-៤១


មានពរហើយអស់ អ្នកណាដែលស្រេកឃ្លាននូវ សេចក្ដីសុចរិត ត្បិតអ្នកទាំង នោះនឹងបានឆ្អែត ។
មានពរហើយអស់អ្នកដែល ផ្សះផ្សាគេ ដ្បិតអ្នកទាំងនោះនឹងបានហៅ ជាកូនរបស់ព្រះ ។ ត្រូវស្រឡាញ់សត្រូវ របស់អ្នកហើយប្រទានពរឱ្យគេ ។


បើសិនអ្នកណាម្នាក់ស្រេក ចូរឱ្យអ្នកនោះ មកឯខ្ញុំនឹងផឹក ព្រះវិញ្ញាណបរិសុទ្ធនឹងសណ្ឋិត នៅក្នុងអ្នកនោះដូចជារន្ធទឹកដែលផុសឡើង ទៅដល់ជីវិតអស់កល្បជានិច្ច។
វានិយាយមិនដូច ជាឧក្រិដ្ឋជនទេ។
ពួគេនិយាយថា វាជាម្នាក់ ដែលបានបំពេញតាមបទទំនាយ កាលពី៤០០០ឆ្នាំមុន។


ហេតុអ្វីពួកឯងមិនចាប់ វាឱ្យអញ ? វាបានឈរ នៅចំពោះមុខឯង ហេតុអ្វី មិនចាប់វា ?
គ្មានមនុស្សណា ដែលនិយាយដូច គាត់ទេ ។
គាត់និយាយអំពី សេចក្តីស្រឡាញ់និងការ អត់ទោស ។
ហាស់ហ៎ា តើវាបោកបញ្ឆោតពួកឯង ដែរឬ ? តើមានអ្នកដឹកនាំឬផារិស៊ីដែលមាន ចំណេះដឹងខ្ពស់ណាម្នាក់ជឿលើវាទេ ? យេស៊ូវនេះត្រូវតែងាប់ ។


បុរសម្នាក់ឈ្មោះ នីកូដេម ដែលបានជួប
ព្រះយេស៊ូវនៅពេលយប់ បាននិយាយឡើងថា ។
តើក្រឹត្យវិន័យរបស់យើងដាក់
ទោសមនុស្សណា មុនយើងបានស្ដាប់
អ្វីដែលគាត់និយាយឬ ?
នីកូដេម តើអ្នកគឺជាសិស្សរបស់វាមកពី
កាលីឡេដែរឬ ? សូមមើលក្នុងគម្ពីរ ព្រះមែស៊ីអត់
មកពីកាលីឡេទេ ទ្រង់នឹងមកពីបេថ្លេហិមនៃស្រុក
យូដា ហើយត្រូវជាពូជរបស់ ដាវីឌ ។
ម៉ាថាយ ៥:៦, ៩, យ៉ូហាន
៤:១៤, ៧:៤៥-៥២


វាបញ្ឆោតមនុស្ស ធម្មតា ដោយសេចក្ដី កុហករបស់វា ។
វាដូចជាមានចម្លើយ សម្រាប់អ្វីៗទាំងអស់ ។
យើងគួរតែបញ្ជូនមេធាវីដ៏ ចំណានម្នាក់ទៅចាប់កំហុសពេល ដែលវានិយាយ ?


ខ្ញុំស្គាល់មេធាវីដ៏ល្បី ម្នាក់។
គាត់ឈ្លាសវៃ ហើយគ្មានក្តីមេត្តា។


លោកគ្រូ តើខ្ញុំត្រូវធ្វើ យ៉ាងម៉េចដើម្បីទទួលមរតក ជីវិតអស់កល្បជានិច្ច ?
មេធាវីមកបង្ករឿងជាមួយព្រះយេស៊ូវ ។
តើក្រឹត្យវិន័យ និយាយដូចម្ដេច ?
វានិយាយថា អ្នកត្រូវតែស្រឡាញ់ ព្រះនៃយើង ឱ្យអស់ពីចិត្ត ព្រលឹង កំលាំង គំនិត ហើយគួរស្រឡាញ់អ្នកជិតខាង ឱ្យដូចជាខ្លួនរបស់អ្នក ។


នោះជាចម្លើយត្រឹមត្រូវ សេចក្តីស្រឡាញ់បំពេញក្រឹត្យវិន័យ បើសិនអ្នកស្រឡាញ់អ្នកជិតខាងរបស់អ្នកដូចជាខ្លួន នោះអ្នកនឹងគាប់ព្រះហឫទ័យព្រះ ។
បាទ ប៉ុន្តែអ្នកជិតខាងមួយណា ? លោកគ្រូ តាមពិតមានន័យចំពោះមនុស្សទាំងអស់គ្នាឬ ? ដូចជាពួករ៉ូមដែលមិនជឿព្រះដែរទេ ?
ខ្ញុំនឹងលើករឿងមួយមកប្រាប់អ្នក


មានបុរសម្នាក់ដែលបានធ្វើដំណើរ មកពីយេរូសាឡិមទៅយេរីខូ ត្រូវបានវាយប្រហារ ដោយសារចោរហើយបានសម្រាតទាំងអស់ និងទុកឱ្យគាត់ស្លាប់ ។
នៅពេលសម្ដេចសង្ឃម្នាក់បាន ដើរក្បែរបុរសដែលសន្លប់នៅលើផ្លូវ គាត់បានដើរជៀសហើយមិនបាន ឈប់ជួយទេ ។
លូកា ១០:២៥-៣១


ហើយមានបុរសពួកលេវីម្នាក់
ដែលគេបានជ្រើសរើសសម្រាប់
ធ្វើការក្នុងវិហារបានដើរកាត់ទីនោះ
ហើយឈប់មួយភ្លែតសំឡឹង ទៅអ្នកដែលត្រូវរបួស
ប៉ុន្តែគាត់អត់ជួយដែរ ។
តើនោះមានប្រយោជន៍អ្វី
បើសិនអ្នកថា អ្នក មានសេចក្តីស្រឡាញ់
ប៉ុន្តែអត់មានការប្រព្រឹត្តនៃសេចក្តី ស្រឡាញ់?
បើសិនអ្នកអត់ស្រឡាញ់អ្នកជិតខាង
អ្នកក៏មិនស្រឡាញ់ព្រះដែរ ។


បន្ទាប់មកមានជនជាតិសាម៉ារីម្នាក់បាន
ដើរកាត់ផ្លូវនោះ ។ បុរសម្នាក់នេះត្រូវបានសាសន៍យូដា
ប្រមាថគាត់ ហើយគេបានរាប់គាត់ជាស្មោកគ្រោក ។ នៅពេល
គាត់ឃើញអ្នកមានរបួសអាក្រាតហើយសន្លប់នៅលើផ្លូវ គាត់មិន
បានពិចារណាថា បុរសនោះជាសាសន៍យូដាឬសាសន៍អ្វីទេ ។
សាសន៍សាម៉ារីមានសេចក្តីមេត្តាធម៌
ចំពោះគាត់ហើយឈប់ដើម្បីជួយបុរសនោះ ។


សាសន៍សាម៉ារីបានលាងរបួស
ហើយបានជួយរុំរបួសបុរសម្នាក់នោះ សេចក្ដី
ស្រឡាញ់របស់គាត់មិនគ្រាន់តែនៅលើពាក្យសំដី
ទេ ប៉ុន្ដែនៅលើការប្រព្រឹត្តវិញ។


បន្ទាប់មកសាសសន៏សាម៉ារីបាន
ដាក់បុរសដែលមានរបួសច្រើនលើលារបស់គាត់
ហើយយកទៅផ្ទះសំណាក់មួយ ជាកន្លែងដែល
គាត់អាចសម្រាករហូតដល់ជាសះស្បើយ ។
ឥឡូវកុំភ័យ ខ្ញុំជួយបីអ្នកដាក់
នៅលើគ្រែ ។


ខ្ញុំបង់ថ្លៃបន្ទប់នេះនិងអាហារ
សម្រាប់ពីរសប្តាហ៍ បើសិនលើសនេះ
ខ្ញុំនឹងជូនអ្នកថែមទៀតនៅពេលខ្ញុំ
មកតាមផ្លូវនេះពេលក្រោយ ។

លូកា ១០:៣២-៣៩


អ្នកបានសួរខ្ញុំ អ្នកជិតខាង របស់អ្នកជានរណា។
ឥឡូវនេះសូមប្រាប់ខ្ញុំ តើចំណោមអ្នកទាំង៣នោះ មួយណាជាអ្នក
ជិតខាងរបស់បុរសមានរបួសនេះ ?
តាមពិតអ្នកដែល
មានសេចក្តីមេត្តា។
អស្ចារ្យណាស់!


ដូច្នេះបើសិនអ្នកអាចទៅនឹងធ្វើតាមសាសន៏សាម៉ារីនេះ អ្នកអាចស្រឡាញ់អ្នកជិតខាងរបស់អ្នកបាន។


ហៅអាភ្លើមេធាវីនោះចេញមក មុនយេស៊ូវធ្វើឱ្យវាកំប្រែចិត្តតាម។
តើការបង្រៀនឆ្កួតនេះមកពីណា ? វាមិនសមហេតុផល មនុស្សខ្លះមិនទទួលស្គាល់និងធ្វើតាមសេចក្តីស្រឡាញ់ទេ។


ម៉ាថាយ ៥:៤៣-៤៤, លូកា ១០:៣៦-៣៧
អ្នកបានឮគេថា អ្នកត្រូវស្រឡាញ់មិត្តភក្តិរបស់
អ្នក ហើយស្អប់សត្រូវ ប៉ុន្តែខ្ញុំប្រាប់អ្នកថា ត្រូវតែស្រឡាញ់
សត្រូវហើយឱ្យពរអ្នកដែលប្រទេចផ្ដាសាអ្នក ត្រូវប្រព្រឹត្តល្អនិងអ្នក
ណាដែលស្អប់អ្នករាល់គ្នា ហើយត្រូវអធិដ្ឋានឱ្យអ្នកណាដែលធ្វើទុក្ខ
បៀតបៀនដល់អ្នករាល់គ្នាវិញ។




# ជំពូក ១០

# ការអស្ចារ្យ
# និង
# រឿងប្រៀបធៀប


គ្រាដដែលនោះនៅកន្លែងផ្សេងទៀត...
ខ្ញុំអត់មានអ្វីហូបជាច្រើនថ្ងៃហើយ ។
អ្នកនឹងស្លាប់បើសិនអ្នកមិនរៀនស៊ីកណ្តុរនិងកន្លាត វាជាមធ្យោបាយតែមួយដើម្បីរស់ ។


ខ្ញុំគិតថាខ្ញុំគួរតែស្លាប់មុនស៊ីសត្វនោះ ។ មួយឆ្នាំមុនខ្ញុំជាអ្នកមានម្នាក់ មានការគោរពយ៉ាងខ្លាំងពីមនុស្សក្នុងភូមិ តែឥឡូវសូមមើលខ្ញុំ ។
គេមិនគោរពអ្នកទៀតទេ អ្នកជាមនុស្សកើតឃ្លង់ ជាអ្នកដែលគេបោះបង់ចោល ។


ដំបូងខ្ញុំសង្ឃឹមថា ខ្ញុំនឹងជានៅថ្ងៃណាមួយ ហើយខ្ញុំអាចត្រឡប់ទៅរកប្រពន្ធកូន ប៉ុន្តែខ្ញុំបាន នៅទីនេះ១០ឆ្នាំហើយ ។ ខ្ញុំមិនដែលឮអ្នកណាម្នាក់ ជាសះស្បើយហើយត្រឡប់ទៅស្រុកវិញទេ ។


នៅដំបូងប្រពន្ធខ្ញុំបាននាំកូន
មកនិងឈរនិយាយជាមួយខ្ញុំពីចំងាយ
ហើយនៅយូរទៅពួកគេមកម្តងម្កាល
រហូតដល់លែងឃើញសោះ ឥឡូវនេះ
កូនខ្ញុំប្រហែលជាធំអស់ហើយ បើពួកគេ
ឃើញ គេនឹងមិនស្គាល់ខ្ញុំ នេះអាក្រក់
ជាងស្លាប់ទៅទៀត ។


អាំ ឈប់ត្អូញត្អែរ អត់មាន
អ្នកណាដែលខ្វល់ទេ សូម្បីតែ
ព្រះក៏អត់ដែរ យើងទៅសុំទាន
សម្រាប់ហូបទៀត ។


ថ្ងៃនេះយើងចេញទៅផ្លូវធំ ដើម្បីសុំអាហារហូប ប្រហែលយើងអាច ធ្វើឱ្យគេខ្ពើមហើយខ្លាចនិងអាណិត ពួកគេ នឹងប្រញាប់ឱ្យអាហារដល់ពួកយើង ។
យើងនឹងធ្វើដំណើរជាមួយគ្នា ប្រហែលជាមានសុវត្ថិភាពជាង ។


ខ្ញុំឃើញមនុស្សកំពុងធ្វើ
ដំណើរនៅខាងមុខទៀត !


នៅពេលពួកឃ្លង់កំពុង ធ្វើដំណើរ ពួកគេបាន ជួបក្មេងៗដែលធ្លាប់ ធ្វើបាបដល់គេ ។
សូមប្រយ័ត្ន !
វាគឺពួកក្មេងប្រុស ដដែលនោះ ។
ចេញពីនេះ អាពួក
ឃ្លង់ស្មោកគ្រោក
ចូរទៅងាប់ឱ្យ ឆ្ងាយទៅ ។
អាពួកដង្កូវស្មោកគ្រោក !
ព្រះកំពុងដាក់ទោសលើឯង ។
រត់! រត់!


ខ្ញុំស្មោកគ្រោកៗ!
យើងទាំង អស់គ្នាសុទ្ធតែស្មោកគ្រោក ។
វាជាពួកកើតឃ្លង់
កុំឱ្យពួកវាមកជិត
យើងអាច ឆ្លងជំងឺបាន ។


តើលោកមានចិត្តអាណិតខ្ញុំទេ? តើលោកមានអាហារសល់សម្រាប់ យើងហូបម្នាក់មួយម៉ាត់បានទេ?
ឱ្យគេខ្លះទៅ គេនឹង ចេញឆ្ងាយពីយើង។
ថយចេញ ឯង ស្មោកគ្រោកណាស់ !


ថយចេញ
យើង ទុកឱ្យនៅទីនេះ ។
កុំមកជិតទៀត
ចាំ យើងថយចេញសិន ។


នំប៉័ង!
ចែកឱ្យខ្ញុំខ្លះផង!
អាហារ!
កុំយកទាំងអស់!



វាជារបស់ខ្ញុំ !
អាជ្រូក!
ឱព្រះអើយ !
នំបុ័ង!
នំបុ័ង!


មើលន៎ អ្នកធ្វើដំណើរ
ជាច្រើនកំពុងមកទីនេះ ។
យើងត្រូវតែប្រយ័ត្ន
ពួកគេមានគ្នាច្រើន ។
ហើយពួកគេជា
បុរសទាំងអស់ ។


នោះគឺជា យេស៊ូវពីក្រុង ណាសារ៉ែត ខ្ញុំធ្លាប់ឃើញម្តង មុនខ្ញុំកើតជំងឺនេះ គាត់ជាមនុស្សម្នាក់ដែលអាចប្រោសឱ្យជា ។
គាត់តាំងខ្លួនថា គាត់មកពីព្រះ ហើយគាត់និងព្រះវរបិតាគឺតែមួយ ។ ខ្ញុំធ្លាប់ឃើញប្រោសមនុស្សខ្វាក់ឱ្យជា និងមនុស្សពិការឱ្យដើរបាន ។


យេស៊ូវ! សូមជួយពួកយើងផង!
លោកគ្រូ គេជាមនុស្សកើតឃ្លង់។
កុំឱ្យគេមកជិត


អ្នកចង់ឱ្យខ្ញុំធ្វើអ្វី?
សូមមេត្តាអាណិត នឹង ធ្វើឱ្យពួកយើងជាផង ។
បើសិនទ្រង់សព្វព្រះហឫទ័យ ទ្រង់អាចប្រោសទូលបង្គំឱ្យជាបាន ។


ទ្រង់មិនគួរប៉ះ ទូលបង្គំទេ ។
វាមិនអីទេ ។ សូមទៅវិហារ ហើយឱ្យសម្ដេចសង្ឃពិនិត្យមើល គាត់នឹងឃើញថា អ្នកបានជាហើយ នឹងឱ្យអ្នកត្រឡប់ទៅគ្រួសាររបស់អ្នកវិញ ។

## លូកា ១៧:១១-១៤


ទ្រង់មានបន្ទូលថា យើងជាហើយ ។
គេនឹងដេញពួក យើងចេញ មុន ជិតដល់វិហារ ។
ខ្ញុំនឹងធ្វើ តាមទ្រង់
ខ្ញុំនឹងទៅ ជាមួយអ្នកដែរ ។


ព្រះយេស៊ូវមានបន្ទូលថា ពួក យើងបានជាសះស្បើយហើយ ។
ខ្ញុំមានអារម្មណ៍ ល្អជាងមុន ។


ខ្លួនរបស់យើងកំពុងវិល
ទៅរកភាពដើមវិញ!


ព្រះយេស៊ូវប្រោសបាន
មែន ! អ្នកជាអស់ហើយ !
ស្បែកខ្ញុំបានជាហើយ !
អ្នកមិនអាក្រក់
មើលទៀតទេ !
ខ្ញុំត្រូវការទៅ
រកប្រពន្ធខ្ញុំ !


មានពរដល់ទ្រង់ហើយ ព្រះរាជបុត្រានៃព្រះ ស្តេចនៃ អ៊ីស្រាអែល ទ្រង់បានប្រទានជីវិតរបស់ទូលបង្គំវិញ ព្រះអង្គ មានសេចក្តីមេត្តាករុណានិងប្រកបដោយព្រះគុណ ។
តើខ្ញុំបានប្រោសឱ្យជា១០នាក់ឬ ? ប៉ុន្តែមានតែអ្នកទេដែលមកថ្លែងអំណរគុណ ដល់ខ្ញុំ ហើយអ្នកមិនមែនជាសាសន៍យូដា គឺជាសាសន៍សាម៉ារី ។
លូកា ១៧:១៤-១៩

នៅថ្ងៃមួយមានបុរសម្នាក់បានសួរព្រះយេស៊ូវថា
តើមានមនុស្សជាច្រើននឹងទទួលជីវិតអស់កល្ប
ជានិច្ចឬ ? ព្រះអង្គតបថា...




ចូរខំប្រឹងចូលតាមទ្វារដែលចង្អៀតចុះ ដ្បិត
មានមនុស្សជាច្រើនស្វែងរកចូលផ្លូវជីវិតនោះ
ប៉ុន្តែបរាជ័យ ។ នៅពេលដល់ថ្ងៃជំនុំជំរះ
មនុស្សជាច្រើននឹងទូលមកខ្ញុំថា “ព្រះអម្ចាស់
អើយ ! ទូលបង្គំប្រាកដជាកូនរបស់ទ្រង់
ទូលបង្គំជាមនុស្សជឿសាសនា ទូលបង្គំបាន
តមអាហារនិងបានអធិដ្ឋាន ទូលបង្គំបានឧបត្ថម្ភ
ប្រាក់ដើម្បីផ្គត់ផ្គង់សាសនានិងធ្វើបុណ្យយ៉ាង
ច្រើន ។ ទូលបង្គំបានអធិប្បាយក្នុងព្រះនាមរបស់
ទ្រង់និងបណ្តេញអារក្សដែរ” ។




ម៉ាថាយ ៧:១៣-១៤, ២២-២៣, វិវរណៈ ១៤:១១


បន្ទាប់មកព្រះយេស៊ូវបាន
និទានរឿងមួយទៀត...
មានអ្នកមានម្នាក់
គាត់ស្លៀកពាក់យ៉ាងស្អាត និងមានតម្លៃ
តែងតែទទួលទានអាហារថ្លៃៗរាល់ថ្ងៃ ។
គាត់បានស្មោះត្រង់ហើយត្រឹមត្រូវ
មិនមែនជាមនុស្ស អាក្រក់ទេ
ប៉ុន្តែគាត់គិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួន ។
គាត់បានលាក់ ទុកលុយរបស់គាត់ជាគំនរ
ពីមួយថ្ងៃទៅមួយថ្ងៃ កាន់តែមានទៅៗ ។


យកកាកសំណល់ទាំងនេះឱ្យអស់ពីចាន របស់អញ ហើយឱ្យទៅអ្នកសុំទាន ឡាសា ដែលអង្គុយផ្អែកនៅទ្វាររបង អញជាមនុស្ស ដែលមានសេចក្ដីមេត្តាអាណិតអាសូរ ។
បាទ លោកម្ចាស់ ខ្ញុំគិតថា គាត់នឹងសប្បាយចិត្ត ។


ចៅហ្វាយខ្ញុំបាន
ប្រាប់ឱ្យយកកំទេចម្ហូប
ទាំងនេះឱ្យអ្នក ។
សូមសរសើរព្រះជាម្ចាស់!
ទ្រង់បានផ្គត់ផ្គង់កូនចៅរបស់
ទ្រង់ផ្ទាល់ នេះគឺច្រើនជាងដែលខ្ញុំ
សមទទួល សូមអរគុណចំពោះ
ចៅហ្វាយរបស់អ្នកផង ។
ខ្ញុំមានទ្រព្យសម្បត្តិ
ច្រើនណាស់ ខ្ញុំនឹងត្រូវ ការជង្រុកដ៏ធំដើម្បី
ទុកទ្រព្យសម្បត្តិរបស់ ខ្ញុំទាំងអស់ ។


ឯងឆោតណាស់ នៅយប់ នេះ ឯងត្រូវតែស្លាប់ហើយត្រូវតែ ទទួលនូវផលដែលខ្លួនបានប្រព្រឹត្ត សម្រាប់ព្រលឹងរបស់ឯង ។
នៅរាត្រីនោះជីវិតរបស់អ្នកមានក៏មកដល់ ពេលកំណត់ ។
“ហើយដោយព្រោះបានតម្រូវ ត្រូវឱ្យមនុស្សទាំងអស់ស្លាប់ម្ដង រួចសឹមជាប់សេចក្ដីជំនុំជំរះ” ។
ក្រក...ខក់ៗ
(ជិតដាច់ខ្យល់)
លូកា ១៦:១៩-២២, ហេព្រើរ ៩:២៧



នៅពេលដែលគេហែរសពអ្នកមានចេញ
គេ ឃើញអ្នកសុំទានឡាសាបានស្លាប់ដែរ ។
នេះជាអ្នកសុំទានចាស់ម្នាក់
ឡាសា គាត់ក៏បានស្លាប់នៅយប់
មិញដែរ មើលទៅគាត់ដូចជាមាន
ភាពសុខសាន្តស្ងប់ចិត្តណាស់ ។
សពរបស់ ឡាសា គេបានដឹកចេញដោយរទេះ ទៅ
ក្រៅទីក្រុង ជាកន្លែងដែលគេបញ្ចុះសពអ្នកក្រីក្រ
គេអត់ធ្វើបុណ្យសពទេ ហើយគ្មានអ្នកណាកាន់ទុក្ខដែរ ។


ប៉ុន្តែ ទេវតាបានមកនឹងលើក
ឡាសារទៅឋានបរមសុខ។
អ៊ូ ! សប្បាយមែន
! ខ្ញុំមិនដែលគិតថា
នៅពេលខ្ញុំ ស្លាប់
ខ្ញុំសប្បាយដូចនេះទេ។
ប្អូនប្រុសឡាសារអើយ
សូមស្វាគមន៍ចំពោះការមកដល់ឋាននេះ
អ្នកនឹងមិនឃ្លានហើយរូបកាយរបស់អ្នក លែងឈឺទៀតដែរ។
សូមមក ! យើងបាន រៀបចំតុអាហារសម្រាប់ទទួលអ្នក។


គាត់ជាបុរសល្អ ពេលខ្លះគាត់ធ្វើ
ដូចជាតឹងរឹងជាមួយមនុស្សដែលគាត់ស្រឡាញ់ ប៉ុន្តែ
យើងចងចាំថា គាត់ស្រឡាញ់ប្រជាជាតិរបស់គាត់
ហើយស្មោះត្រង់ក្នុងមុខជំនួញរបស់គាត់ដែរ ។
គេបានធ្វើបុណ្យបញ្ចុះសពយ៉ាងល្អសម្រាប់អ្នកមាន ហើយគេបញ្ចុះគាត់នៅក្នុង
ផ្នូរដ៏ស្អាត បងប្អូននិងមនុស្សទាំងអស់ដែលសង្ឃឹមនឹងបានលុយរបស់គាត់
នាំគ្នាមកដើម្បីចង់ដឹងអ្វីដែលគាត់ទុកនៅក្នុងសំបុត្របណ្តាំមរតកដល់ពួកគេ ។


គាត់បានទៅទទួល រង្វាន់របស់គាត់
សូមឱ្យ ព្រលឹងរបស់គាត់ទៅកាន់ សុគតិភពចុះ។




លូកា ១៦:២២


ជួយខ្ញុំផង ! ព្រះអើយ
សូមនរណាម្នាក់ជួយខ្ញុំផង !
ខ្ញុំកំពុងនៅក្នុងភ្លើង !


ឪពុកអ័ប្រាហាំ សូមមានសេចក្ដីមេត្តាមកខ្ញុំផង ខ្ញុំឃើញឡាសានៅទីនោះ ឱ្យគាត់ជ្រលក់ម្រាមដៃរបស់គាត់ចូល ក្នុងទឹក ហើយបន្តក់ទឹកមកលើអណ្ដាតខ្ញុំ ដើម្បីខ្ញុំបានត្រជាក់ ព្រោះខ្ញុំវេទនាយ៉ាងខ្លាំងនៅក្នុងភ្លើងនេះ ។
កូនប្រុស បើសិនខ្ញុំអាចជួយកូនបាន ខ្ញុំនឹងជួយ ប៉ុន្តែមានជ្រោះដ៏ធំនិងជ្រៅនៅ ចន្លោះយើង មានបឹងភ្លើងនៅខាងក្រោម ដែរ យើងមិនអាចឆ្លងទៅជួយកូន ហើយ កូនក៏មិនអាចឆ្លងមកខាងនេះបានដែរ ។


បើដូច្នេះសូមបញ្ជូនឡាសាឱ្យត្រឡប់ទៅផ្ទះ
របស់ឪពុកខ្ញុំ ដើម្បីប្រាប់បងប្អូនទាំង៥នាក់ផង នឹង
កុំឱ្យពួកគេមកកន្លែងដែលវេទនាខ្លាំងដូចនេះ ។


លូកា ១៦:២២-៣១
គេមានគម្ពីររបស់ លោកម៉ូសេ ហើយ នឹងហោរាផ្សេងៗ ចូរឱ្យ គេជឿលើព្រះគម្ពីរចុះ ។
ប៉ុន្តែនោះមិនគ្រប់គ្រាន់សម្រាប់ ពួកគេទេ បើសិនជាគេឃើញការ អស្ចារ្យនៃការរស់ឡើងវិញ ពួកគេ នឹងប្រែចិត្តពីការមិនជឿរបស់គេ ។


បើសិនគេមិនជឿលើព្រះគម្ពីរ គេក៏មិនប្រែចិត្តដែរ ទោះបីគេឃើញនរណាម្នាក់រស់ពីស្លាប់ឡើងវិញក៏ដោយ ។ វាហួសពេលហើយសម្រាប់អ្នក ។ គេត្រូវតែសម្រេចចិត្តដោយខ្លួនឯង ខ្ញុំសោកស្តាយព្រោះគ្មានអ្វីដែលខ្ញុំអាចជួយបាន ។


ព្រះយេស៊ូវនិងសាវក កំពុងធ្វើដំណើរចូលទីក្រុង ហើយបានជួបស្រីផ្កាមាសម្នាក់ដែលពេញដោយវិញ្ញាណអារក្ស ។
អេ៎ បុរសសង្ហារ តើបងត្រូវការសប្បាយទេ ? តម្លៃនៃការសប្បាយជាមួយអូនមិនថ្លៃទេ ។
លោកគ្រូកុំរវល់នឹងនាង វាហួសពេលសម្រាប់មនុស្សណាដូចនាង ។


គម្ពីរបរិសុទ្ធចែងថា
“កុំឱ្យផិតគ្នាឱ្យសោះ” ។
អេ៎ អូនជាអ្នក
កាន់សាសនាដែរ
អូនជឿព្រះ ។
អារក្សសាតាំងបានបោកបញ្ឆោត
នាង នៅចុងបញ្ចប់នៃជីវិតរបស់នាង
គ្មានអ្វីក្រៅពីបឹងភ្លើងទេ ។


លោកបានឮមិត្តភក្តិថា
វាហួសពេលសម្រាប់ខ្ញុំ
ខ្ញុំបានប្រព្រឹត្តការនេះ តាំងពីក្មេងមក ។
វាមិនយឺតពេលទេសម្រាប់ព្រះជាម្ចាស់ ។
បើសិននាងស្វែងរកទ្រង់នាងនឹងឃើញទ្រង់
ទ្រង់នឹងលើកលែងទោសបាបរបស់នាង ហើយទ្រង់
នឹងប្រោសឱ្យព្រលឹងរបស់នាងកើតជាថ្មីវិញ ។


អារក្សជាម្ចាស់ព្រលឹងរបស់ខ្ញុំ ប៉ុន្តែខ្ញុំនឹងប្រទានឱ្យព្រះបើសិនទ្រង់នឹង...




និក្ខមនំ ២០:១៤, លូកា ៨:២, យ៉ូហានទី១, ១:៩


អ៊ីយ៉ា...
ពួកអារក្សសាតាំង ចេញពីនាងភ្លាម !


អញបញ្ជាឱ្យឯងចេញពីនាង
ហើយកុំត្រឡប់មកវិញ !
ដោយសារព្រះយេស៊ូវបានបញ្ជា
អារក្ស ទាំង៧បានចេញពីស្ត្រីនោះ ។


ពួកវាបានចេញហើយ !
លោកជាអ្នកណា?
ខ្ញុំជាយេស៊ូវ


នាងត្រូវតែបញ្ឈប់នូវអំពើបាបរបស់នាង ហើយថ្វាយបង្គំព្រះ បើមិនដូច្នេះទេ អារក្សនឹងមកវិញ នាំគ្នាវាផ្សេងដែលអាក្រក់ជាងមុនទៅទៀត។

លូកា ៨:២, ១១:២៤-២៦


ខ្ញុំចង់បំរើព្រះអង្គ ខ្ញុំនឹងតាមទ្រង់ ហើយ នឹងរៀនទៀត ។
តើមានអ្វីនឹងកើតឡើងចំពោះនាង ?


លោកគ្រូ ខ្ញុំបានឃើញអ្វីដែលកើត ឡើងគឺអស្ចារ្យណាស់ អ្នកដឹកនាំសាសនារបស់ យើងព្រងើយកន្តើយជាមួយ ម៉ារា ម៉ាក់ដាឡា នៅ ពេលថ្ងៃ
ប៉ុន្តែពួកគេខ្លះលួចមកជួបនាងនៅពេល យប់ ។ លោកគ្រូបានឱ្យជីវិតថ្មីដល់នាងមែន ។


តើលោកគ្រូនិងសិស្សអាចមកផ្ទះ
របស់ខ្ញុំ ហើយនឹងទទួលទានអាហារបាន
ឬទេ ? ខ្ញុំត្រូវការឱ្យមិត្រភក្តិរបស់ខ្ញុំស្តាប់
អំពីការនេះថែមទៀត ។
យើងនឹងទៅតាមអ្នក


លោកគ្រូយេស៊ូវ សូមប្រាប់យើងតើបុរសម្នាក់អាចស្មោះត្រង់ហើយបរិសុទ្ធនៅក្នុងសង្គមពុករលួយយ៉ាងម៉េច ? យើងនឹងស្លាប់ដោយអត់អាហារបើសិនយើងមិនលួចបំពានច្បាប់បន្តិចបន្តួច ។
កុំខំស្វែងរករបស់ទ្រព្យដែលចេះខូច ប៉ុន្តែត្រូវស្វែងរកអ្វីដែលនៅអស់កល្បជានិច្ចវិញ ។ កុំខ្វល់ខ្វាយអំពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អ្នក ប៉ុន្តែអ្នកត្រូវគិតនូវអ្វីដែលអាចជួយដល់អ្នកដទៃផង ។


ជីវិតគឺប្រសើរជាងអាហារនិងសំលៀកបំពាក់ទៅទៀត បើទោះជាព្រះជាម្ចាស់បានតុបតែងឱ្យព្រលឹតមានផ្កាសម្រាប់លម្អ ចុះទម្រាំអ្នកវិញព្រះក៏ផ្តល់សំលៀកបំពាក់ឱ្យដល់អ្នកដែរ ។
មានថ្ងៃមួយសេចក្តីជំនុំជំរះនឹងមកដល់ដែលមនុស្សទាំងអស់នឹងឈរចំពោះព្រះភ័ក្ត្រទ្រង់ ដើម្បីឆ្លើយតបពីការប្រព្រឹត្តទាំងអស់របស់ពួកគេទាំងល្អទាំងអាក្រក់ ។


កុំធ្វើដូចអ្នកដឹកនាំសាសនារបស់អ្នក ព្រោះពួកគេរស់នៅផ្ទុយពីការដែលគេនិយាយ ពួកគេដូចជាចានដែលស្អាតខាងក្រៅ តែខាងក្នុងមានភាពកខ្វក់។
បើសិនសេចក្តីសុចរិតរបស់អ្នកមិនល្អជាងពួកគេ អ្នកមិនអាចចូលទៅក្នុងនគរព្រះបានទេ។

សាស្តា ១២:១៤, ម៉ាថាយ ២៣:២៥, ៦:១៩-២១, ២៥, ២៨-៣០, ១២:៣៦, លូកា ១៥:១-៣




មានបុរសម្នាក់មានកូន ប្រុសពីរ កូនពៅមិនស្តាប់បង្គាប់ ហើយចង់ បានជីវិតរស់នៅទៅតាមសេចក្តីប៉ងប្រាថ្នា របស់គេ ។
អ៊ូ៎ ខ្ញុំនឹងចូល ចិត្តរឿងនេះ ។


ដូច្នេះ
គាត់ ទាមទារចំណែកមរតក
របស់គាត់មុន។


ពុក បើសិនឱ្យចំណែកនៃចំការ មកខ្ញុំ ខ្ញុំនឹងទៅរស់នៅទីក្រុងនឹងស្វែង រកសុភមង្គលដោយខ្លួនឯង។
ប៉ុន្តែកូនអើយ អ្វីដែលពុកមានជារបស់កូនហើយ ពុកមិនរស់នៅយូរទៀតទេ ហើយឯងនិងបងប្រុសរបស់ឯង នឹងទទួល នូវអ្វីទាំងអស់នេះ ឯងនឹងមានជីវិតយ៉ាងស្រួលតាំងពីថ្ងៃនេះទៅ ហើយ នឹងមានសត្វចៀមនិងគោជាច្រើន ស្រែរបស់យើងពេញដោយស្រូវ ជារៀងរាល់ឆ្នាំ យើងមានអ្នកបំរើជាច្រើនហើយនឹង...


”ប៉ុន្តែខ្ញុំចង់ចាកចេញពីនេះ ហើយចង់ឃើញពិភពលោកខ្លះ ។ ខ្ញុំមិនចង់រស់នៅចំការហើយនឹងធ្វើការដូចជាទាសករពេញមួយជីវិតរបស់ខ្ញុំទេ មុនខ្ញុំចាស់ ខ្ញុំចង់មានការសប្បាយខ្លះ ។ មិត្រភក្តិរបស់ខ្ញុំ...
មិត្រភក្តិរបស់កូនសុទ្ធតែខ្ជិលមិនដែលធ្វើការ សុទ្ធតែគិតពីការភ្នាល់ប្រណាំងសេះស្រាថ្លៃៗហើយចាប់អារម្មណ៍តែស្រីស្អាតៗ ។


ពុក យល់ដឹងពីជីវិតក្រៅពីចំការនេះយ៉ាងម៉េច?
ពុកតែងតែជាប់នៅក្នុងចំការចាស់នេះរហូត ខ្ញុំចង់បាន
ចំណែកនៃចំការដែលជារបស់ខ្ញុំ ឥឡូវនេះខ្ញុំនឹងទៅទីក្រុង
ហើយរៀបចំជីវិតតាមចំណង់ចិត្តខ្ញុំនៅទីនោះ ។
ពុកឱ្យទៅវាចុះ បើគ្មានវាយើងនៅ
ល្អជាង ។ ទោះជាយ៉ាងណាក៏ដោយ ក៏វាមិន
ដែលធ្វើការងាររបស់វាដែរ ។


ឪពុកបានឱ្យចំណែករបស់កូនគាត់ ដូច្នេះកូន ពៅបានចាកចេញទៅ ឆ្លងកាត់សមុទ្រឆ្ពោះ ទៅទីក្រុងដ៏ធំ ជាកន្លែងដែលគាត់អាច ស្វែងរកសេចក្តីសប្បាយរីករាយ ។
អ្ហូ៎ ខ្ញុំមានសេរីភាព ! គ្មាន អ្នកណាបញ្ជាខ្ញុំឱ្យធ្វើអ្វីទេ។

លូកា ១៥:១១-១៣


នៅពេលកូនពៅទៅដល់ទីក្រុង...
អស្ចារ្យ!
នេះគួរឱ្យចាប់ចិត្តណាស់
មានមនុស្សច្រើននិងអាគារធំៗ ទាំងអស់
នេះហួសពីការដែលខ្ញុំបានស្រមើស្រមៃ
ទៅទៀត ។ នេះជាកន្លែងសប្បាយដែល
មានអ្វីៗគ្រប់បែបយ៉ាងទាំងអស់ ។
ខ្ញុំត្រូវតែរកជួល
បន្ទប់មួយដ៏ស្អាត ។


បាទ នេះមើលទៅដូចជាល្អណាស់ ខ្ញុំនឹងជួលវា
បើសិនលោកត្រូវការអ្វី គ្រាន់តែហៅ យើងមានការបំរើទាំងយប់ទាំងថ្ងៃ។




លូកា ១៥:១៣


អេ៎ តើយើងឃើញអ្វីនៅទីនោះទេ ? អ្នកស្រុកស្រែឬ ? គាត់ប្រហែលជាសង្ហា បើសិនយើងអាចឃើញមុខគាត់ ។
អេ៎ អ្នកកំលោះ បើសិនអ្នក កំពុងរកការសប្បាយ អ្នកគួរតែកោរ ពុកមាត់ចេញ ហើយនឹងទិញខោអាវ ដែលទំនើបជាងនេះ ។


នេះសមជាមនុស្សខូចមែនមើលទៅដូចជាមិនអន់ទេ នៅពេលស្លៀកពាក់ថ្មីបែបនេះ។


យើងសប្បាយដែលអ្នកបានចូលរួមទទួលទានអាហារជាមួយយើង។
ឥឡូវនេះគាត់បានកោររោមអាក្រក់ចេញពីមុខរបស់គាត់ ហើយតើគាត់សង្ហាមែនទេ ?



ជល់កែវទៅមិត្រភក្តិថ្មីយើង ចូរឱ្យ គាត់មានសេចក្តីសប្បាយរីករាយនិង សុភមង្គលជារៀងរហូត ។
ហើយសេចក្តីស្រឡាញ់ដែរ




លូកា ១៥:១៣


តើអូនអាចទៅផ្ទះ
របស់បងតែពីរនាក់បានទេ ?


ហើយកូនពៅនោះបានរស់នៅឆ្ងាយពីផ្ទះឪពុក
អស់រយៈពេលច្រើនខែដូចអ្នកមាន។
នៅពេលលុយរបស់ គាត់មិនទាន់អស់
គាត់នៅតែមានមិត្រភក្តិច្រើន ។
នៅថ្ងៃមួយសេចក្តីសប្បាយភ្លើតភ្លើន
បានធ្វើឱ្យលុយរបស់គាត់អស់ ប៉ុន្តែគាត់នៅតែ
មានមិត្រភក្តិច្រើនដែលជាអ្នកមាន។


អ្នកនិយាយយ៉ាងម៉េច អ្នកអត់មានលុយទៀត ? ខ្ញុំ គិតថា អ្នកជាអ្នកមាន ។
វាអស់លុយច្រើនដើម្បីនៅ ទីនេះ ។ ហើយនឹងលុយសល់ចុងក្រោយ របស់ខ្ញុំបានភ្នាល់ប្រណាំងសេះចាញ់អស់ កាលពីសប្ដាហ៍មុន ។ ខ្ញុំស្មានថាខ្ញុំភ្នាល់ ចំលើសេះល្អហើយខ្ញុំសង្ឃឹមថា...


តើមានន័យថា លុយរបស់បងអស់ ? តើបងនឹងទិញសំពត់ថ្មីឱ្យខ្ញុំដូចដែលបានសន្យាយ៉ាងម៉េច ?
បងនឹងសុំប៉ារបស់អូន ដើម្បីធ្វើការងារជាអ្នកគ្រប់គ្រងចំការ ។
ការងារ ?


ខ្ញុំមិននឹកស្មានថា ខ្ញុំជាអ្នកឱ្យចំណីជ្រូកដែលជាសត្វគួរឱ្យខ្ពើមដូចនេះសោះ ។
ខ្ញុំគិតថា ខ្ញុំមានមិត្តភក្តិ ប៉ុន្តែឥឡូវនេះគេមិននិយាយចូលខ្ញុំទៀតទេ ខ្ញុំនឹងរកការងារល្អជាងនេះ ថ្ងៃណាមួយខ្ញុំនឹងធ្វើជាអ្នកមានលើគេវិញ ។
អ៊ូក អ៊ូក អ៊ូក អ៊ូក
អ៊ូកៗ
អ៊ូកៗ
លូកា ១៥:១៣-១៥


អញមិនខ្វល់ខ្វាយឯងឈឺឬយ៉ាងម៉េចទេ។ ទៅទ្រុងជ្រូកវិញនិងថែជ្រូករបស់អញ។ អញនឹងឈប់ឱ្យឯងធ្វើ ហើយនឹងរកអ្នកផ្សេង។ ទៅទ្រុងជ្រូកវិញភ្លាម !
បាទលោក ខ្ញុំសុំទោស ខ្ញុំនឹងទៅឥឡូវ។


ការងារនេះមិនមានប្រាក់ខែគ្រប់គ្រាន់សម្រាប់
ខ្ញុំហូបអាហារល្អ ។ ខ្ញុំគិតថា
មិត្រភក្តិក្លែងក្លាយរបស់ខ្ញុំ
គេបានស៊ីឆ្អែតរាល់ថ្ងៃ ។


សូមមើលជីវិតខ្ញុំទៅជាយ៉ាងណា
ខ្ញុំរងារ ហេវ ហើយអស់កំលាំង
ខ្ញុំដូចជាអាចហូបចំណីជ្រូកបាន។
អ្នកបំរើរបស់ពុកខ្ញុំ ពួកគេមានអាហារគ្រប់គ្រាន់
មិនអាចហូបអស់។ បើសិនខ្ញុំអាច... ប៉ុន្តែអត់ទេ...
តាមរឿងរ៉ាវដែលខ្ញុំបានចេញពី ពួកគេ
ខ្ញុំមិនអាចត្រឡប់ទៅវិញទេ។
ពួកគេនឹងស្អប់ខ្ពើមហើយដៀលខ្ញុំ។


ខ្ញុំល្ងង់ណាស់ ។
ប៉ុន្តែគិតយ៉ាងម៉េចបើសិនខ្ញុំទៅវិញនឹងសុំធ្វើជាអ្នកបំរើ?
ខ្ញុំបានចាយចំណែកលក់ចំការរបស់ខ្ញុំអស់
ប៉ុន្តែខ្ញុំអាចធ្វើ
ជាអ្នកបំរើបើសិនពួកគាត់នឹងទទួលខ្ញុំ ។


ខ្ញុំនឹងទៅផ្ទះ
អាឆ្កួត ឯងអស់លុយហើយ ឯងត្រូវតែដើរជាង១៥០០ គ.ម.។

# លូកា ១៥:១៦-១៩


បន្ទាប់ពីការធ្វើដំណើរជាច្រើន
សប្តាហ៍ គាត់ជិតដល់ផ្ទះហើយ ។
ខ្ញុំជិតដល់ហើយ ខ្ញុំគ្មានសិទ្ធិ
មកទីនេះហើយសុំសេចក្តីអនុគ្រោះទេ ។
ខ្ញុំនឹងនិយាយថា
“ពុកអើយខ្ញុំបានធ្វើបាបហើយនឹងមិនគួរត្រូវហៅជាកូនរបស់
ពុកទេ សូមឱ្យខ្ញុំធ្វើដូចជាជើងឈ្នួលរបស់ពុកវិញចុះ” ។


តើអ្នកឃើញបុរសនោះកំពុងមកទីនេះទេ? ខ្ញុំចាស់ហើយ មិនអាចមើលឃើញច្បាស់ដូចមុនទេ ប៉ុន្តែខ្ញុំប្រាប់អ្នក គេដើរដំណើរដូចជាកូនប្រុសរបស់ខ្ញុំ ដែលបាត់ជាយូរណាស់មកហើយ ។
ត្រូវហើយ គាត់ដូចជាចាស់បន្តិចហើយស្គមជាងមុន ប៉ុន្តែខ្ញុំគិតថាជាកូនប្រុសរបស់លោកមែន ។


កូនរបស់ខ្ញុំ !


កូនពុក កូនរបស់ពុក ! កូនបាន មកផ្ទះវិញហើយ !
លោកឪពុក ខ្ញុំបានធ្វើបាបចំពោះ ព្រះហើយនឹងលោកឪពុក ។


ខ្ញុំមិនគួរឱ្យគេហៅជាកូន
របស់លោកឪពុកទៀតទេ ។


យើងបានគិតថាឯងស្លាប់ហើយ
ឥឡូវកូន ដូចជាមានជីវិតរស់ឡើងវិញ
បន្តិចទៀត
ពុកនឹងរៀបចំខ្លួនកូនឱ្យបានស្អាត ។


លូកា ១៥:២០-២២
ឯងមិនអាចចូលក្នុងផ្ទះដោយបែបនេះទេ អ្នកបំរើរបស់ពុកនឹងយកសំលៀកបំពាក់ដ៏ល្អ ហើយនឹងស្បែកជើងសម្រាប់ឯង ចិញ្ចៀនរបស់ឯងបាត់ហើយ អើ ឯងក៏ត្រូវការចិញ្ចៀនដែរ កូនប្រុសរបស់ពុកដែលវង្វេងនោះឥឡូវបានរកឃើញវិញហើយ ។


សម្លាប់កូនគោដែលបានបំប៉ន
ដើម្បីធ្វើពិធីជប់លៀង ហើយអញ្ជើញភ្ញៀវ
យើងនឹងសប្បាយ ព្រោះថ្ងៃនេះយើងត្រូវតែ
មានសេចក្តីរីករាយយ៉ាងខ្លាំង។


ខ្ញុំសប្បាយរីករាយណាស់ ដែលអ្នកទាំងអស់
គ្នាបានចូលរួមជាមួយខ្ញុំក្នុងពិធីដ៏អស្ចារ្យនេះ កូនប្រុសរបស់ខ្ញុំនៅតែ
ខ្សោយមកពីការលំបាកដែលកើតឡើងចំពោះវា ប៉ុន្តែដោយអាហារដ៏ល្អនេះ
វានឹងឆាប់មានកំលាំងវិញ នេះជាថ្ងៃដ៏ប្រសើរជាងគេនៃជីវិតរបស់ខ្ញុំ ។


ខ្ញុំបានឮតន្ត្រីនិងការ រាំទាំងអស់នេះ
តើពួកគេ កំពុងធ្វើអ្វី ?
បងប្រុសច្បងមិនបាននៅផ្ទះអស់រយៈពេល
ពីរបីថ្ងៃហើយ ពេលដែលគាត់បានត្រឡប់
មកផ្ទះវិញ គាត់បានឃើញពិធីជប់លៀង
ដ៏ធំមួយនេះ ។
ប្អូនប្រុសរបស់លោកបានត្រឡប់
មកផ្ទះវិញ រូបរាងគួរឱ្យអាណិតណាស់
គាត់ឈឺ ហើយលុយក៏អស់ដែរ
ពុករបស់លោករីករាយសប្បាយ ចិត្តណាស់
ដែលបានឃើញគាត់ត្រឡប់មកផ្ទះវិញ
សូមប្រញាប់អញ្ជើញចូលទៅខាងក្នុង ។


ខ្ញុំមិនចូលរួមក្នុងពិធីលៀង
ខ្លៅនោះទេ ជីវិតវាពោរពេញដោយ
អំពើបាប ហើយគួរឱ្យអាម៉ាស់ ។
អ្នកបំរើបានប្រាប់ឪពុកនូវអ្វីដែលកូន
ច្បងនិយាយ ហើយគាត់បានចេញមកក្រៅ
និយាយជាមួយកូនច្បងរបស់គាត់ ។


អស់រយៈពេលជាយូរណាស់មកហើយ ពុកបានរងចាំ វា ពុកគិតថាវានឹងវង្វេងជារៀងរហូត ពុកជិតអស់សង្ឃឹម ហើយ ក្រោយមកឃើញវាកំពុងដើរមកតាមផ្លូវ តើឯងជឿថា ពុកមានពរល្អដូចនេះទេ ? ព្រះគឺល្អណាស់ !
ខ្ញុំមិនជឿថាពុកសប្បាយ រីករាយជាមួយអាម្នាក់ប្រព្រឹត្ត បាបដូចនេះ ខ្ញុំមិនរួមចំណែក ក្នុងពិធីនោះជាមួយវាទេ ។

លូកា ១៥:២៣-៣២


នោះជារឿងប្រឌិតរបស់ឯងដែលគួរឱ្យ
ចូលចិត្ត
ប៉ុន្តែឯងកំពុងព្យាយាមប្រៀបធៀបថា
យើងដូចជាកូនច្បងមែនទេ ?
អ្នកណាមានត្រចៀកស្ដាប់
ចូរឱ្យគេស្ដាប់ចុះ ។


អាម្នាក់នេះគួរឱ្យ
គ្រោះថ្នាក់ណាស់ មនុស្ស
គ្រប់គ្នាស្រឡាញ់វា ។
វាធ្វើឱ្យគេមាន
សេចក្តីសង្ឃឹម ។
បាទ ប៉ុន្តែវាជាសេចក្តីសង្ឃឹមខុស ។ តើអ្នកណា អាចសន្យាថា
អ្នកប្រព្រឹត្តអំពើបាបនឹងមានជីវិតអស់កល្ប ជានិច្ចទេ ? វាត្រូវតែងាប់
ហៅអ្នកទាំងអស់គ្នាមក យើងនឹង ជួបជុំគ្នាយប់នេះនៅដំណាក់សម្តេចសង្ឃ ។


យើងនឹងត្រឡប់ទៅស្រុកកាលីឡេវិញនិងសម្រាកមួយរយៈ ជិតដល់ពេលដែលគេនឹងបោះខ្ញុំចូលក្នុងគុក ហើយពួកគេចំអកឱ្យខ្ញុំ និងឆ្កាងខ្ញុំ ប៉ុន្តែថ្ងៃទី៣ខ្ញុំនឹងរស់ពីសេចក្តីស្លាប់ឡើងវិញ។
គាត់និយាយមានន័យយ៉ាង ម៉េច "រស់ពីសេចក្តីស្លាប់ ?"
ខ្ញុំមិនយល់ដែរ ប្រហែល ជារឿងប្រៀបធៀប។


លោកគ្រូ
ជាការប្រញាប់ ! ម៉ាថា បានឱ្យខ្ញុំមករក លោកគ្រូ
ប្អូនរបស់នាង ឡាសារ បានឈឺយ៉ាងខ្លាំងរហូតជិតស្លាប់
គាត់ជា មិត្តភក្តិជិតស្និទ្ធរបស់លោកគ្រូ
បើសិនលោកគ្រូរហ័សទៅនឹងដល់ទីនោះ មុនគាត់ស្លាប់
យើងដឹងថាលោកគ្រូអាចប្រោសឱ្យគាត់ជាបាន ។
ឡាសារឈឺ? យើងត្រូវ ប្រញាប់ឡើង !
ចូរប្រាប់ម៉ារានិងម៉ាថា នោះខ្ញុំនឹងទៅ ហើយប្រាប់ពួកគេថា
ជំងឺនេះមិនដល់ស្លាប់ទេ ប៉ុន្តែសម្រាប់ជាកិត្តិសព្ទដល់ព្រះវិញ ។


ពីរថ្ងៃក្រោយមក...
លោកគ្រូ តាំងពីយើងបានឮថាមិត្តភក្តិរបស់ យើង ឡាសារ ឈឺជិតស្លាប់ វាជិតហួសពីរថ្ងៃហើយ យើងនឹងអស់ពេលពីរថ្ងៃដើម្បីធ្វើដំណើរទៅដល់ទីនោះ តើយើងត្រូវចេញទៅឥឡូវឬ ?
ថ្ងៃស្អែកយើងនឹងចេញដំណើរ អ្នកនឹងឃើញសិរីល្អនៃព្រះ ។




ម៉ាថាយ ២០:១៧-២០, យ៉ូហាន ១១:១-១៥


ព្រះយេស៊ូវនិង សិស្សរបស់ទ្រង់នៅ ខាងក្រៅផ្ទះ ។
ទេ...!
ប្រាប់គេឱ្យរងចាំខ្ញុំនៅទីនោះ វាគ្រោះថ្នាក់ណាស់ បើសិនទ្រង់ចូលមកនៅ ពេលពួកផារិស៊ីនិងសង្ឃជាច្រើនកំពុងនៅទីនេះ ព្រោះពួកគេនៅតែចង់សម្លាប់ទ្រង់ ។
អ៊ា...!
មិត្តកំសត់ ឡាសារ អើយ !


ព្រះជាម្ចាស់អើយ បើសិនទ្រង់បាន គង់នៅទីនេះ
ប្អូនប្រុសរបស់ខ្ញុំម្ចាស់មិនស្លាប់ទេ ប៉ុន្តែឥឡូវនេះទ្រង់អាចសុំអ្វីក៏បានពីព្រះអម្ចាស់
ហើយព្រះអម្ចាស់នឹងធ្វើសម្រាប់ទ្រង់។
ប្អូនប្រុសរបស់ នាងនឹងរស់ពីស្លាប់ ឡើងវិញ។
ខ្ញុំម្ចាស់ដឹងថា ប្អូនខ្ញុំម្ចាស់នឹងរស់ ឡើងដែរ នៅថ្ងៃចុងបំផុតកាលណា មនុស្សត្រូវរស់ពីស្លាប់ឡើងវិញ។


ខ្ញុំជាសេចក្ដីរស់ឡើង
វិញនិងជាជីវិត ។
អ្នកណាដែលជឿលើខ្ញុំ
ទោះបីជាគេបានស្លាប់ គេត្រូវរស់
ឡើងវិញ ហើយអ្នកនៅរស់ដែលជឿ
លើខ្ញុំនឹងមិនស្លាប់ឡើយ តើនាង
ជឿទេ ?


ព្រះករុណាជាម្ចាស់
ខ្ញុំម្ចាស់ជឿថា ទ្រង់ជា
ព្រះមែស៊ី ព្រះរាជបុត្រានៃព្រះ
ដែលហោរាបានទាយថានឹងយាង
មកក្នុងពិភពលោក។


បន្ទាប់ពី ម៉ាថា បាននិយាយ ជាមួយព្រះយេស៊ូវ
នាងបានបញ្ជូន អ្នកបំរើឱ្យទៅនាំនាងម៉ារាមក ។
សូមទៅតាមម៉ារា
នាងយំនៅឯផ្នូរ ។
ហ៊ឹៗៗ
យ៉ូហាន ១១:១៧-៣១


ព្រះជាម្ចាស់
បើសិន ទ្រង់បានគង់នៅទីនេះ
ប្អូនប្រុស របស់ខ្ញុំម្ចាស់មិនស្លាប់ទេ។
តើនាងបានបញ្ចុះ
សពនៅទីណា ?


ពួកខ្ញុំម្ចាស់នឹកស្ដាយ
គាត់ខ្លាំងណាស់ ។


មើលន៎ យេស៊ូវ
ស្រឡាញ់ឡាសារណាស់ ។
គាត់អាចធ្វើឱ្យមនុស្សខ្វាក់មើល
ឃើញ តើគាត់អាចឃាត់មិត្តភក្តិរបស់
គាត់មិនឱ្យស្លាប់បានឬទេ ?


ចូរប្រមៀលថ្មនេះចេញ
ប៉ុន្តែព្រះជាម្ចាស់ជិតដល់ពេល គាត់មានក្លិនស្អុយ ព្រោះគាត់បានស្លាប់ អស់រយៈពេល៤ថ្ងៃហើយ។
តើខ្ញុំធ្លាប់ប្រាប់នាងហើយថា បើសិននាងជឿលើខ្ញុំ នាងនឹងឃើញសិរីល្អរបស់ព្រះមែនទេ ? យកដុំថ្មនោះចេញ។


ព្រះវរបិតា ទូលបង្គំអរគុណទ្រង់ ដែលឮទូលបង្គំ ។ ទូលបង្គំមិនមែន អធិដ្ឋានសម្រាប់ប្រយោជន៍របស់ទូលបង្គំទេ ពីព្រោះទូលបង្គំដឹងថា ទ្រង់តែងតែឮទូលបង្គំ ប៉ុន្តែទូលបង្គំអធិដ្ឋានដើម្បីឱ្យអ្នកណា ដែលសំឡឹងមើលបានជឿថា ទ្រង់បាន បញ្ជូនទូលបង្គំមក ឥឡូវនេះសូម ព្រះវរបិតាដំកើងអង្គទ្រង់ ។

យ៉ូហាន ១១:៣២-៤២


ឡាសារ ចេញមក !
វាបានធ្វើជ្រុលហួសហេតុ ហើយពេលនេះ ។
មែនហើយ វាកំពុង ធ្វើឱ្យខ្មាសគេ ។


ឥឡូវនេះសពចាប់ផ្ដើម
ស្អុយរលួយហើយ ។
នៅពេលមនុស្សទាំងអស់
នេះបានឃើញថាវាជាអ្នកបោកបញ្ឆោត
នោះជាការងាយស្រួលសម្រាប់យើង
ចាប់វាយកទៅសម្លាប់ចោល ។


ស្អីហ្នឹង? ខ្ញុំមិនជឿទេ!
វាមិនអាចកើតឡើងអញ្ចឹងទេ !


សិរីល្អមានដល់ព្រះអង្គ!
អស្ចារ្យមែន !


ទ្រង់ប្រោសឡាសារបាន! ម៉ារាទ្រង់ប្រោសបានមែន!
ឡាសារបានរស់ឡើងវិញ! អស់រយៈ៤ថ្ងៃនៅក្នុងផ្នូរឡាសារបានរស់ឡើងវិញហើយ!

យ៉ូហាន ១១:៤៣-៤៤


ឡាសារ ក្រោយពីស្លាប់៤ថ្ងៃ ចេញមកពីផ្នូរ ដៃនិងជើងរុំជាប់ដោយសំពត់ស្នប ។
ស្រាយគាត់ចេញ ហើយឱ្យគាត់ទៅចុះ ។
នរណាអាចធ្វើបែប នេះបាន ក្រៅពីព្រះ ?


តើមនុស្សទាំងអស់មាន កង្វល់អ្វី ? សូមដោះសំពត់ស្នប នេះចេញពីខ្ញុំ ។
អ្នកបានស្លាប់អស់ រយៈពេល៤ថ្ងៃ ។
លោកគ្រូ ទូលបង្គំរីករាយ ដែលបានជួបទ្រង់ ទូលបង្គំ គិតថា ទ្រង់ជាអ្នកដែលប្រោស ឱ្យទូលបង្គំរស់វិញ ។


អូ៎ ឡាសារ បង
បានទឹកឯងខ្លាំងណាស់ ។
ខ្ញុំឃ្លានណាស់
អញ្ជើញអ្នកកាន់ទុក្ខឱ្យ ទៅផ្ទះ
ហើយយើងនឹងបរិភោគអាហារ ។
មានពរហើយ
ព្រះអម្ចាស់ របស់យើង !


តើអ្នកអាចជឿអ្វីដែលយើងទើបតែបានឃើញទេ
? វាមិនអាចក្លែងបន្លំការអស្ចារ្យនោះតាមមធ្យោបាយណាមួយទេ
ខ្ញុំបានឃើញឡាសារមុនគេបញ្ចុះសពគាត់ ។ គាត់បានស្លាប់
ប្រាកដមែនដោយគ្មានការសង្ស័យឡើយ ។
យើងត្រូវទៅប្រាប់ពួក
អាចារ្យនិងពួកផារិស៊ីភ្លាម ។
នៅពេលរឿងនេះបានឮដល់
ទីក្រុងយេរូសាឡិម ពួកគេនឹងលើក វាធ្វើជាស្តេច
ដូច្នេះយើងត្រូវតែ ទប់ស្កាត់វាជាបន្ទាន់ ។


យេស៊ូវនោះបានធ្វើឧបាយកលដ៏ធំមួយនៅថ្ងៃនេះសូម្បីតែមនុស្សដែលបានឃើញផ្ទាល់គេគិតថា វាបានធ្វើឱ្យមនុស្សម្នាក់រស់ពីសេចក្ដីស្លាប់មែន។
វាមិនសំខាន់នូវអ្វីដែលវាបានធ្វើល្បិចកលនោះទេ តែបើគ្មានអ្នកណាបញ្ឈប់វា នោះវានឹងទាក់ទាញចិត្តមនុស្សទាំងអស់ឱ្យតាមវា។


បើសិនមានការបះបោរមួយទៀត
ពួករ៉ូមអាចទម្លាក់យើងពីអំណាច ព្រោះ ពួកគេសង្ឃឹមថា
យើងអាចរក្សា ភាពស្ងប់ស្ងៀមបាន។


ប៉ុន្តែយេស៊ូវមិនដែលប្រព្រឹត្តអំពើហិង្សាទេ ក៏មិនបាននិយាយប្រឆាំងនឹងនគររ៉ូមដែរ ។
តែសំដីរបស់វាដ៏កំណាច វាហៅយើងជាសាធារណៈថា មនុស្សលាក់ពុត មនុស្សទាំងអស់សើចចំអកដាក់យើងដោយឥតលាក់លៀម ។


ត្រូវកំចាត់វាចេញ វាមិនអាចធ្វើឱ្យខ្លួនវា រស់ពីស្លាប់វិញបានទេ ។
យើងត្រូវកំចាត់វាភ្លាម មុនពេលវាបំផ្លាញការគោរពចំពោះសាសនារបស់យើងទាំងអស់ ។
មុនពួករ៉ូមចាត់វិធានការប្រឆាំងនឹងយើងដែរ ។


គ្រាដដែលនោះនៅកន្លែងផ្សេង
ព្រះយេស៊ូវមានបន្ទូលទៅកាន់សាវកថា...
ពួកគេបានច្រានចោលខ្ញុំ
ហើយឆក់ឱកាសដើម្បីសម្លាប់ ខ្ញុំ
គេមិនយល់ថាខ្ញុំយាងមកនេះគឺជាការសង្គ្រោះសម្រាប់
ពួកគេនោះទេ ។ ខ្ញុំប្រាប់អ្នកថាបន្ទាប់ពីខ្ញុំបានយាងត្រឡប់
ទៅវិញ ជនជាតិរ៉ូមនឹងបំផ្លាញវិហារដែលពួកគេស្រឡាញ់
យ៉ាងខ្លាំងសូម្បីតែថ្មមួយដុំក៏មិននៅគរលើគ្នាដែរ ។


,កុំភ្ញាក់ផ្អើលពេលអ្នកឃើញការទាំងនេះកើតឡើង ដ្បិតនឹងមានសង្គ្រាមជាច្រើន រញ្ជួយផែនដី ជំងឺ ភាពរាំងស្ងួត ហើយនិងគ្រោះមហន្តរាយគ្រប់ប្រភេទ ប៉ុន្តែការកើតឡើងទាំងអស់នេះមិនមែនជាពេលចុងបញ្ចប់នោះទេ។


មានពេលមួយនឹងមកដល់អស់អ្នកណាដែល
ស្រឡាញ់ខ្ញុំត្រូវគេចាប់ដាក់ក្នុងគុក គ្រប់ប្រជាជាតិទាំងអស់
នឹងស្អប់អ្នកដោយសារពួកអ្នកស្រឡាញ់ខ្ញុំ អ្នកខ្លះនឹងស្លាប់ នៅក្នុងកណ្ដាប់ដៃរបស់ពួកគេ
ខ្លះត្រូវបានគេដេញចេញពីផ្ទះ របស់ខ្លួន ហើយគេបង្អត់ការងារធ្វើដែរ។


ទាំងនេះគ្រាន់តែជាការចាប់ផ្ដើម
មានទុក្ខព្រួយតែប៉ុណ្ណោះ ទីក្រុងយេរូសាឡិម
នឹងត្រូវបានសាសន៍ដទៃត្រួតត្រារហូតដល់គ្រា
សាសន៍ដទៃបានសម្រេច ។ នៅពេលនរណាម្នាក់
បានប្រាប់អ្នកថា ខ្ញុំត្រឡប់មកវិញ ហើយអ្នក
ត្រូវទៅទីនោះឬទីនេះដើម្បីជួបខ្ញុំ សូមកុំជឿ
ឱ្យសោះ វានឹងមានមនុស្សជាច្រើនមកក្លែងបន្លំ
ធ្វើជាខ្ញុំ ឬក៏ក្លែងបន្លំនិយាយជំនួសខ្ញុំ ។




ម៉ាថាយ ១០:២២, ២៤:២, ៥-៩, ២១, ២៧-៣១, លូកា ១៩:៤៣-៤៤, ២១:៨, យ៉ូហាន ១១:៤៩-៥៣, វិវរណៈ ២:១០


លោកគ្រូ អ្នកម៉ីងម៉ាថា
ឱ្យខ្ញុំមករកលោកគ្រូ គាត់បានឱ្យខ្ញុំ
ប្រាប់លោកគ្រូថា លោកគ្រូនិងសិស្ស
អាចអញ្ជើញស្នាក់នៅផ្ទះរបស់គាត់បាន
ព្រោះទីក្រុងយេរូសាឡិមគ្មានសុវត្ថិភាព
សម្រាប់លោកគ្រូទៀតទេ មនុស្សខ្លះមិន
ពេញចិត្តដែលលោកគ្រូបានធ្វើឱ្យលោក
ម្ចាស់របស់ខ្ញុំរស់ពីសេចក្ដីស្លាប់វិញ។
តើលោកគ្រូនឹងមកស្នាក់នៅជាមួយ
យើងមួយរយៈទេ ?
យើងរីករាយនឹងទៅ
លេងផ្ទះគេ ខ្ញុំចង់ជួបគេម្ដង
ទៀត មុនពេលសេចក្ដីវេទនា
របស់ខ្ញុំមកដល់។


នោះជាព្រះយេស៊ូវ និងសិស្សរបស់ទ្រង់។
លោកគ្រូ សូមចូលមក ហើយសម្រាក ផ្ទះខ្ញុំក៏ដូចជាផ្ទះរបស់លោកគ្រូដែរ។
ឡាសារមិត្តសំឡាញ់! អ្នកដូចជាសុខភាពល្អជាងមុន ខ្ញុំរីករាយណាស់បានមកលេងផ្ទះរបស់អ្នក ល្អជាង ទៅផ្ទូរបស់អ្នក។


យើងបានរៀបចំពិធី ជប់លៀងមួយ នឹងបានអញ្ជើញ ភ្ញៀវរួចហើយ ។
លោកគ្រូ ជាសេចក្ដីរស់ឡើង វិញនិងជាជីវិតដែរ ។


ម៉ាថាយ ២០:១៩, ២៦:២, យ៉ូហាន ១២:១-២, ១៤:៦
លោកគ្រូ ខ្ញុំបានឮថាសាសន៍ យូដាបានសម្រេចចិត្តចាប់លោកគ្រូ ដោយកំលាំងនិងសម្លាប់ ។
ខ្ញុំបានចូលមកលោកកិយនេះដើម្បីថ្វាយជីវិតរបស់ ខ្ញុំប្រយោជន៍ដល់មនុស្សលោក ខ្ញុំត្រូវបានគេដាក់គុក ហើយឆ្កាង ប៉ុន្តែថ្ងៃទីបីខ្ញុំនឹងរស់ឡើងវិញ ។


ទ្រង់ជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត អ្នកណាជឿលើទ្រង់ នោះមិនត្រូវស្លាប់ទេ។


ម៉ារា តើនាងយកទឹកអប់
សម្រាប់អប់សពមកធ្វើអ្វី ?


ព្រះជាម្ចាស់របស់ខ្ញុំម្ចាស់
អើយ ទ្រង់គឺជាសេចក្តីរស់ឡើង
វិញនិងជាជីវិត ទោះបីជាទ្រង់
បានសុគតក៏ដោយ ទ្រង់នឹងមាន
ព្រះជន្មរស់ឡើងវិញដែរ ។


ម៉ារា ទឹកអប់នេះមានតំលៃ ថ្លៃណាស់
ស្មើនឹងប្រាក់ឈ្នួលមួយឆ្នាំ ហេតុអ្វីនាងខ្ជះខ្ជាយវា ?
ប៉ុន្តែនាងកំពុងចាក់
លាបព្រះបាទលោកគ្រូ ។
អាចយកវាទៅលក់
ហើយនឹងលុយដែលបានមក ចែកឱ្យអ្នកក្រីក្រ ។


ម៉ារាបានយកសក់របស់នាង
ជូតព្រះបាទព្រះយេស៊ូវ ។
កុំរំខាននាង នាងបានរៀបចំ
ការនេះមុន សម្រាប់ថ្ងៃបញ្ចុះសព
របស់ខ្ញុំនៅពេលខាងមុខ ។


ទ្រង់មានបន្ទូលថា
បញ្ចុះសព នេះមានន័យយ៉ាងម៉េច?
ទ្រង់មានបន្ទូលថា
ទ្រង់ត្រូវបានគេឆ្កាងប៉ុន្តែខ្ញុំគិតថាប្រហែលទ្រង់
ប្រៀបធៀបគេមិនឆ្កាងទ្រង់ពិតប្រាកដ
រហូតដល់សុគតទេ។


ខ្ញុំបានប្រាប់អ្នកថា អ្នកគង្វាលចៀមដ៏ល្អ បានស៊ូប្តូរជីវិតដើម្បីសង្គ្រោះចៀម ខ្ញុំត្រូវបានគេ បោះបង់ចោលនិងឆ្កាង ហើយនឹងបញ្ចុះសពខ្ញុំ ប៉ុន្តែនៅថ្ងៃទីបី ខ្ញុំនឹងរស់ឡើងវិញ។
ម៉ារា កំពុងរៀបចំសាកសពខ្ញុំសម្រាប់ ការបញ្ចុះ ពេលកំណត់ខ្ញុំមកដល់ហើយជា ពេលដែលខ្ញុំត្រូវបានគេលើកដំកើងឡើង។ ចូរមក យើងត្រូវទៅទីក្រុងយេរូសាឡិម រឿងនេះនឹងកើតឡើងនៅទីនោះ។
ម៉ាថាយ ២០:១៩, យ៉ូហាន ១២:៣-៨, ១០:១១


លោកគ្រូ មនុស្សនៅទីក្រុងយេរូសាឡិមទាំងអស់កំពុងរង់ចាំលោកគ្រូយាងមក!
ទៅយកសត្វលាមួយឱ្យខ្ញុំជិះ យើងនឹងទៅទីក្រុងយេរូសាឡិមម្តងទៀតជាលើកចុងក្រោយ ។


លោកគ្រូ មនុស្សរាប់ពាន់នាក់កំពុង
រងចាំលោកគ្រូចូលក្នុងទីក្រុងយេរូសាឡិម
ពួកគេនឹងលើកទ្រង់ធ្វើជាស្តេច ។
ខ្ញុំនឹងត្រូវបានគេច្រានចោល
ហើយឆ្កាង ប៉ុន្តែនៅថ្ងៃទីបីខ្ញុំនឹង
រស់ឡើងពីសេចក្តីស្លាប់វិញ ។


សូមអបអរសាទរ ស្តេចនៃសាសន៍យូដា!
មានពរដល់ទ្រង់ ដែលយាង មកដោយព្រះនាមព្រះអម្ចាស់ !
សូមសរសើរ ព្រះរាជបុត្រា នៃពូជហ្លួងដាវីឌ !


សូមបើកផ្លូវសម្រាប់ស្ដេចអ៊ីស្រាអែល !
សូមសរសើរព្រះអម្ចាស់!
ព្រះសង្គ្រោះដែលបានសន្យា ទ្រង់យាងមកដល់ហើយ !
យ៉ូហាន ១២:១២-១៣


មនុស្សទាំងអស់ហៅវាថា ស្ដេចនៃសាសន៍យូដា !
ព្រះរាជបុត្រា នៃពូជ ហ្លួងដាវីឌ សូមជួយរំដោះ ពួកយើងផង !
ពួកគេគិតថា វាជាព្រះ មែស៊ី ដែលគម្ពីរបានសន្យា !
ហេតុអ្វីបានជាវាមកវិហារ ? វាត្រូវតែដឹងថា ជីវិតរបស់វាស្ថិត ក្នុងភាពគ្រោះថ្នាក់ ។


ពួកគេនៅតែបំពានលើដំណាក់
របស់ព្រះ វាមើលទៅដូចជាផ្សារ
ជំនួសឱ្យដំណាក់សម្រាប់អធិដ្ឋាន។
ខ្ញុំអាចលក់មួយនេះឱ្យអ្នកក្នុង
តម្លៃគួរសម វាត្រូវបានអនុញ្ញាត
សម្រាប់ការថ្វាយយញ្ញបូជា។


ខ្ញុំសុំទោស
នេះជាតម្លៃ ពិសេសរបស់ខ្ញុំ
បើសិនអ្នកចង់ បានតម្លៃខ្ពស់ជាងនេះ
សូមទៅ ដូរនៅកន្លែងផ្សេង។
ម៉ាថាយ ២១:១១-១២


ព្រះយេស៊ូវ បានធ្វើម្តងទៀត ទ្រង់បានដេញពួកចោរនិងមនុស្ស ចោលម្សៀតចេញពីវិហារ ។
យកទំនិញនេះចេញពីដំណាក់របស់បិតាអញ ពួកឯងសុទ្ធតែជាពួកចោរកប្លន់ ។
ឯងមកទីនេះដើម្បីចំណេញពីអ្នកដែលមកអធិដ្ឋានឱ្យលុយរបស់ឯងវិនាសជាមួយឯងចុះ ។
គ្រាំង !
ប្រយ័ត្ន!


អ្នកណាឱ្យឯងមានសិទ្ធិធ្វើដូចនេះ ?
ក្ដាំង !
កុំធ្វើឱ្យដំណាក់បិតារបស់អញក្លាយជារូងពួកចោរ ។
ក្រាំង !
ឯងគិតថាឯងជាអ្នកណា ?


លោកគ្រូ ពួកសង្ឃនិងពួកផារិស៊ីបានឱ្យអ្នកស៊ើបការណ៍ សម្ងាត់មកតាមដានយើង ខ្ញុំបានឮគេនិយាយថា គេនឹងចាប់ទ្រង់ ដាក់គុកមុនថ្ងៃបុណ្យរំលងនៅរយៈពេលបីបួនថ្ងៃទៀត។
វាបានសំអាតវិហារក្រោយពីចូលទីក្រុង យេរូសាឡិមដូចជាវាមានជ័យជំនះ អ្នកដឹងថា ការនេះមានន័យយ៉ាងម៉េចចំពោះវា ?


ខ្ញុំបានប្រាប់អ្នកថា ខ្ញុំត្រូវឈឺចាប់ក្នុងកណ្ដាប់ដៃគេ ហើយត្រូវបានគេឆ្កាង ប៉ុន្តែបីថ្ងៃក្រោយមកខ្ញុំនឹងរស់ឡើងវិញ។
បាទខ្ញុំដឹង បទទំនាយបានទាយថា “**សេចក្ដីឧស្សាហ៍ដល់ដំណាក់ទ្រង់បានស៊ីបង្ហិនទូលបង្គំ**”ហើយ “**ផ៉ុកងលោទ្រង់នឹងមកដល់ព្រះវិហាររបស់ទ្រង់ភ្លាម**” ដូច្នេះវាតាំងខ្លួនថា វាជាព្រះមែស៊ី។


ទំនុកដំកើង ៦៩:៩,
ម៉ាថាយ ២១:១២-១៣
យើងត្រូវតែបញ្ឈប់វា
មុនថ្ងៃបុណ្យ រំលងមកដល់ ។ យើងមានអ្នកស៊ើបការណ៍
សម្ងាត់ក្នុងចំណោមពួកសិស្សរបស់វា ។

ខ្ញុំប្រាប់អ្នកមុនថា
ក្រោយពីខ្ញុំចាកចេញទៅ ពួកគេនឹងដាក់ អ្នកក្នុងគុក
វាយអ្នក ហើយខ្លះត្រូវគេសម្លាប់ ។ អ្នកនឹងធ្វើ
ទីបន្ទាល់ពីសេចក្តីស្រឡាញ់និងអំណាចរបស់ខ្ញុំ ។ ពេលដែលគេ
បណ្តើរអ្នកទៅតុលាការ ខ្ញុំនឹងបណ្តាលឱ្យពាក្យសម្តីដែលពួក
អ្នកត្រូវឆ្លើយ ។ កូនក្មេងនឹងធ្វើជាសាក្សីជំទាស់នឹងឪពុកម្តាយ
របស់ពួកគេ ហើយឪពុកម្តាយធ្វើសាក្សីជំទាស់នឹងកូនដែរ ។ គេ
នឹងស្អប់ខ្ពើមពីព្រោះអ្នកមានការទំនាក់ទំនងនិងខ្ញុំ ។ មានហោរា
ក្លែងក្លាយជាច្រើននឹងលេចមកហើយតាំងខ្លួនថាជាព្រះគ្រីស្ទ ។
ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធនឹងគង់នៅជាមួយអ្នក ។




លោកគ្រូ តើមានទីសំគាល់
អ្វីនៅពេលទ្រង់យាងត្រឡប់ មកលោកិយនេះវិញហើយនៅ
ចុងបញ្ចប់នៃពិភពលោក ?
បើសិននរណាម្នាក់និយាយថា
ខ្ញុំត្រឡប់មកតាមពេលកំណត់ឬនៅកន្លែងណាមួយ សូម កុំជឿពួកគេ
ដ្បិតខ្ញុំនឹងមកវិញមែន ប៉ុន្តែរហ័សដូចជាផ្លេកបន្ទោរ ។ ចូរស្មោះត្រង់កុំបែកចេញពីខ្ញុំ
ហើយនៅចុងបញ្ចប់អ្នកនឹងបានរួចផុតពីការជំនុំជំរះដែលនឹងបានធ្លាក់ទៅលើអ្នកមានបាប ។
ដូច្នេះ ចូរចាំយាមចុះ ដ្បិតអ្នកមិនដឹងថ្ងៃណាឬម៉ោងណាដែលខ្ញុំនឹងត្រឡប់មកវិញនោះទេ ។


មុនពេលដែលខ្ញុំត្រឡប់មកវិញ នោះនឹងដូចជាជំនាន់លោកណូអេដែរ មនុស្សលោកទាំងអស់កំពុងរវល់គិតតែការសប្បាយរីករាយ ហើយពួកគេមិនដឹងខ្លួនរហូតដល់ទឹកជំនន់ឡើងបក់បោកពួកគេទៅទាំងអស់ ។ ខ្ញុំនឹងមកមួយរំពេចដូចជាចោរមកនៅពេលយប់ ។


នៅពេលព្រះយេស៊ូវកំពុងបង្រៀន
សិស្ស យូដាសបានលួចទៅជួប
សម្តេចសង្ឃដើម្បីក្បត់ទ្រង់ ។មានបុរសពីរនាក់កំពុងធ្វើការនៅទីវាល
បុរសម្នាក់នឹងត្រូវបាន លើកឡើងមកជួបខ្ញុំ ហើយម្នាក់ទុកនៅទទួលរងទុក្ខវេទនា
ស្ត្រីពីរនាក់ កិនស្រូវជាមួយគ្នា ម្នាក់នឹងត្រូវយកឡើងហើយម្នាក់ទុកនៅ ។ ចូរចាំយាម
និងត្រៀមខ្លួនជាស្រេចដ្បិតខ្ញុំនឹងមកនៅថ្ងៃដែលអ្នកស្មានមិនដល់ ។


លោកគ្រូ ខ្ញុំត្រូវតែទៅជួប បុរសម្នាក់នៅក្នុងទីក្រុង ក្រោយ មកខ្ញុំនឹងត្រឡប់មកវិញ ។
អញ្ជើញទៅ យូដាស ហើយ ធ្វើអ្វីដែលឯងត្រូវធ្វើចុះ ។


បើសិនត្រូវថ្លៃ ខ្ញុំអាចបញ្ជូនយេស៊ូវ ទៅក្នុងកណ្ដាប់ដៃរបស់លោកបាន ។
ប៉ុន្តែ តើឯងជាយូដាស ជាសិស្សរបស់វាមែនឬ ?
បាទ ខ្ញុំបាននៅជាមួយគាត់អស់រយៈពេល៣ឆ្នាំហើយ ប៉ុន្តែខ្ញុំបានធុញទ្រាន់នឹងគាត់ណាស់ ឥឡូវពាក្យដែលគាត់ និយាយដូចជាឆ្កួត ហើយខ្ញុំត្រូវការលុយដែរ ។




ម៉ាថាយ ២៦:១៤-១៦, ម៉ាកុស ១៣:៥-១៣, លូកា ១៧:២៦-៣៧, យ៉ូហាន ១២:២៣-២៤, ពេត្រុសទី២, ៣:១០


ឥឡូវទូលបង្គំមានចិត្តតប់ប្រមល់ហើយត្រូវទូលដូចម្ដេច "ឱព្រះវរបិតាអើយ សូមជួយសង្គ្រោះទូលបង្គំឱ្យរួចពីពេលនេះផង" ប៉ុន្តែដោយហេតុនេះឯង បានជាទូលបង្គំមកដល់លោកិយនេះ។


ឱព្រះវរបិតាអើយ សូម
តម្កើងព្រះនាមទ្រង់ឡើង !



អញបានតម្កើងហើយ ក៏នឹងតម្កើងឡើងទៀតដែរ ។
ព្រះមានបន្ទូលទៅលោកគ្រូ!
សំលេងនោះខ្លាំងដូចផ្គរ ។
ទេវតាក៏មានបន្ទូលទៅលោកគ្រូ !


សំលេងនោះមិនមានប្រយោជន៍
សម្រាប់ខ្ញុំទេ ប៉ុន្តែសម្រាប់ពួកអ្នក ឥឡូវដល់
ពេលសាតាំងជាម្ចាស់នៃលោកិយនេះត្រូវបរាជ័យ
ហើយ បើសិនខ្ញុំត្រូវគេឆ្កាងរហូតដល់ស្លាប់
ខ្ញុំនឹងនាំមនុស្សទាំងអស់មកឯខ្ញុំ។
យើងដឹងហោរាបាន
ទាយថាព្រះមែស៊ីនឹងមានព្រះ
ជន្មអស់កល្បជានិច្ច ហើយអ្នក
និយាយថា អ្នកនឹងស្លាប់ ដូច្នេះ
តើអ្នកណាជាព្រះមែស៊ី ?


អ្នកនឹងមានពន្លឺនៅជាមួយអ្នក មិនយូរទៀតទេ ចូរជឿដល់ពន្លឺដែលកំពុងមានចុះ អ្នកនឹងក្លាយជាកូនរបស់ព្រះ។
និយាយបែបនេះ ខ្ញុំពិបាកយល់...


បើសិនអ្នកណាម្នាក់បោះបង់ខ្ញុំនិងពាក្យរបស់ខ្ញុំចោល អ្នកនោះគឺកំពុងបោះបង់ព្រះវរបិតាចោលដែរ ខ្ញុំជាពន្លឺនៃលោកិយ បើសិនជឿលើខ្ញុំ អ្នកនឹងមិននៅក្នុងទីងងឹតទេ ប៉ុន្តែមានជីវិតអស់កល្បជានិច្ចវិញ។
យ៉ូហាន ១២:២៧-៣៦



## ជំពូក ១១

# ពិធីបុណ្យរំលង
# និង
# សេចក្ដីវេទនារបស់ព្រះគ្រីស្ទ


ទៅរៀបចំបុណ្យរំលង ព្រមទាំងអាហារសម្រាប់ យើងបរិភោគ ។


ខ្ញុំចង់ទទួលទាននៅថ្ងៃបុណ្យរំលងនេះជាមួយអ្នក មុនខ្ញុំទទួលរងទុក្ខវេទនា។ ខ្ញុំនឹងមិនបានទទួលទានបុណ្យនេះទៀតទេ រហូតដល់នគរនៃព្រះបានមកដល់ផែនដីនេះ ហើយនៅថ្ងៃនោះអ្នកនឹង បរិភោគរួមគ្នានៅតុរបស់ខ្ញុំ ហើយអ្នកនឹងអង្គុយនៅលើបល្ល័ង្កដើម្បី ជំនុំជំរះពួកកុលសម្ព័ន្ធទាំង១២នៃសាសន៍អ៊ីស្រាអែល។


ខ្ញុំនឹងប្រាប់អ្នករឿងមួយ ដូច្នេះនៅពេលរឿងនោះ កើតឡើងអ្នកនឹងជឿ គម្ពីរទំនុកតម្កើង ៤១:៩ បានទាយថា " អ្នកដែលទូលបង្គំបានទុកចិត្ត ហើយក៏បានហូបនំប៉័ងរបស់ទូលបង្គំ នោះបានលើកកែងជើងចង់ជាន់ឈ្លីទូលបង្គំដែរ" ខ្ញុំប្រាប់អ្នកថា មានម្នាក់ក្នុងចំណោមពួកអ្នក ដែលដាក់ដៃនៅ លើតុជាមួយខ្ញុំ អ្នកនោះនឹងក្បត់ខ្ញុំ។
ទេ !


តាមសេចក្ដីសម្រេចមក ប៉ុន្តែ វេទនាដល់មនុស្សម្នាក់ដែលនឹងប្រព្រឹត្តដូច្នេះ។


ព្រះជាម្ចាស់ ទូលបង្គំឬ ? ទូលមង្គំមិនចង់ក្បត់ទ្រង់ទេ។
ព្រះអង្គ មិនមែន ទូលបង្គំទេឬ ?
លោកគ្រូ ខ្ញុំមិន ក្បត់លោកគ្រូទេ។

លូកា ២២:៨-២៣


គឺម្នាក់ក្នុងចំណោមពួកអ្នក ដែលជ្រលក់នំបុ័ងក្នុងចានជាមួយខ្ញុំ។


យ៉ូហាន បានខ្សឹបហើយបានសួរព្រះយេស៊ូវពីអ្នកណា
ដែលក្បត់នឹងទ្រង់ ព្រះយេស៊ូវមានបន្ទូលថា
"គឺអ្នកដែលខ្ញុំជ្រលក់ចំណិតនំប៉័ងហុចទៅឱ្យ" ។
ពួកយើងទាំងអស់គ្នាបាន ជ្រលក់នំប៉័ងចូលក្នុងចាន ។


លោកគ្រូ គឺខ្ញុំឬ ?
អ្នកនិយាយត្រូវ


ព្រះយេស៊ូវ បានជ្រលក់
នំបុ័ងហើយហុចឱ្យយូដាស ។


អ្វីដែលអ្នកត្រូវធ្វើ ចូរធ្វើភ្លាមចុះ ។


ម៉ាថាយ ២៦:២៣-២៥,
យ៉ូហាន ១៣:២៦-៣០
យូដាសកំពុងទៅណា ?
ការដែលគាត់ត្រូវធ្វើ លោកគ្រូបានប្រាប់គាត់ឱ្យធ្វើភ្លាម ប្រហែលទៅដាក់ទានឱ្យអ្នកក្រព្រោះគាត់កាន់ថង់លុយ ។


ឥឡូវខ្ញុំត្រូវបានលើកតម្កើង ពួកកូនចៅអើយ ខ្ញុំនឹងមិននៅ ជាមួយអ្នកយូរទៀតទេ។
អ្នកមិនអាចទៅកន្លែងដែលខ្ញុំទៅទេ ឥឡូវនេះ ខ្ញុំឱ្យបញ្ញត្តថ្មីដល់អ្នក ត្រូវស្រឡាញ់គ្នាទៅវិញទៅមក។ មនុស្សទាំងអស់គេនឹងដឹងថា អ្នកជាសិស្សរបស់ខ្ញុំ ដោយសារសេចក្ដីស្រឡាញ់គ្នាទៅវិញទៅមក។


សាការី
បានទាយអំពីពេលនេះថា “**អញនឹងវាយអ្នក
ឃ្វាល ហើយហ្វូងចៀមនឹងត្រូវខ្ចាត់ខ្ចាយទៅ**”
បន្ទាប់ពីខ្ញុំបាន រស់ពីសេចក្តីស្លាប់ឡើងវិញ
ខ្ញុំនឹងទៅស្រុកកាលីឡេមុនអ្នក។
អ្នកទាំងអស់គ្នានឹងបដិសេធខ្ញុំនៅយប់នេះ។


ព្រះជាម្ចាស់ ទោះបីអ្នករាល់គ្នាបដិសេធទ្រង់ ទូលបង្គំមិនបដិសេធទ្រង់ជាដាច់ខាត ។
ពេត្រុស មុនមាន់រងាវពីរដង អ្នកនឹងបដិសេធថាមិនស្គាល់ខ្ញុំបីដង ។


ទូលបង្គំនឹងស្លាប់ ជាមួយទ្រង់ មុនពេល ទូលបង្គំបដិសេធទ្រង់ ។
គ្មានអ្វីធ្វើឱ្យទូលបង្គំ បដិសេធទ្រង់បានទេ ។
ពួកគេមិនអាចធ្វើ ទារុណកម្មទូលបង្គំ ដើម្បីឱ្យ បដិសេធទ្រង់នោះទេ ។


គម្ពីរបរិសុទ្ធបានចែងយ៉ាងច្បាស់ថា
អ្នកទាំងអស់គ្នានឹងបដិសេធខ្ញុំ ហើយ ហោរាអេសាយក៏បានទាយពីខ្ញុំថា
“**គេបាន រាប់ទ្រង់ទុកជាអ្នកទទឹងច្បាប់**”។
ពេត្រុស បន្ទាប់ពីអ្នកប្រែ ចិត្តវិលមកជឿខ្ញុំវិញ ចូរចំរើន
សេចក្ដីជំនឿបងប្អូនរបស់ អ្នកឱ្យរឹងមាំឡើង។

ម៉ាថាយ ២៦:៣៣-៣៥, យ៉ូហាន ១៣:៣១-៣៨, កូរិនថូសទី១, ១១:២៤-២៥




រូបកាយរបស់ខ្ញុំត្រូវបាន
កាច់សម្រាប់អ្នករាល់គ្នា។


យកវាហូប
ឱ្យអស់ចុំះ ។


ទឹកទំពាំងបាយជូរមួយពែងនេះ ជា
តំណាងនៃសញ្ញាថ្មីស្ថិតលើឈាមរបស់ខ្ញុំ
ដែលត្រូវបានហូរចេញ ដើម្បីលប់លៀង
អំពើបាបរបស់អ្នករាល់គ្នា។


សូមយកមួយពែងនេះចែកអ្នករាល់គ្នា
ហើយផឹកវាឱ្យអស់ ខ្ញុំមិនផឹកទឹកទំពាំងបាយជូរ
ម្តងទៀតឡើយ រហូតដល់ខ្ញុំផឹកវាជាមួយ
អ្នកនៅក្នុងនគររបស់ខ្ញុំ ។


ថ្ងៃខាងមុខនៅពេលអ្នកធ្វើពិធីនេះ
អ្នកនឹងរំឭកពីការស្លាប់របស់ខ្ញុំ រហូតដល់
ខ្ញុំមកលោកិយនេះម្តងទៀត ។

យ៉ូហាន ១៤:១-៣,
កូរិនថូសទី១, ១១:២៤-២៦




ប៉ុន្តែ ព្រះអម្ចាស់ ពួកទូលបង្គំ មិនដឹងថា ទ្រង់ទៅទីណាទេ ដូច្នេះ អាចស្គាល់ផ្លូវទៅឯទ្រង់យ៉ាងម៉េច ?


អ្នកស្គាល់ផ្លូវហើយ ពីព្រោះខ្ញុំ ជាផ្លូវ ជាសេចក្ដីពិត និងជាជីវិត
គ្មានអ្នកណាម្នាក់អាចទៅឯព្រះវរបិតាបាន បើមិនចូលតាមខ្ញុំនោះទេ។
បើសិនអ្នកស្គាល់ខ្ញុំអ្នកក៏ ស្គាល់ព្រះវរបិតាដែរ ហើយនឹងបានឃើញទ្រង់ទៀត


លោកគ្រូសូមបង្ហាញព្រះវរបិតាឱ្យយើងឃើញផង យើងនឹងស្កប់ចិត្ត ។
ភីលីព អ្នកបានដើរជាមួយខ្ញុំអស់រយៈ ពេលយ៉ាងយូរហើយ តែអ្នកមិនទាន់ស្គាល់ខ្ញុំទេឬ ? បើសិនអ្នកបានឃើញខ្ញុំ ក៏បានឃើញព្រះវរបិតាដែរ ខ្ញុំនិងព្រះវរបិតា គឺតែមួយទេ ។


ខ្ញុំនឹងមិនទុកអ្នកឱ្យនៅឯកោទេ ខ្ញុំនឹងមកឯអ្នក ។ លោកិយនេះមិនបាន ឃើញខ្ញុំទៀតទេ ប៉ុន្តែខ្ញុំនឹងបញ្ជូនព្រះវិញ្ញាណបរិសុទ្ធ មកសណ្ឋិតក្នុងអ្នកនិងកំសាន្តចិត្តអ្នក ។ ព្រះវិញ្ញាណ បរិសុទ្ធត្រូវបានគង់នៅក្នុងអ្នក ហើយនាំអ្នកឱ្យ ស្គាល់សេចក្ដីពិតទាំងអស់ ។
បើសិនអ្នកស្រឡាញ់ខ្ញុំ ចូរគោរពនូវ ក្រឹត្យវិន័យរបស់ខ្ញុំ ខ្ញុំនឹងឱ្យអ្នកមានសេចក្ដីសុខសាន្ត ដែលលោកិយមិនអាចយកឈ្នះបាន ។


បើសិនអ្នកស្រឡាញ់ខ្ញុំ អ្នកនឹងរីករាយ ពីព្រោះខ្ញុំកំពុងត្រឡប់ទៅព្រះវរបិតារបស់ខ្ញុំវិញ។ ខ្ញុំបានប្រាប់អ្នកពីរឿងទាំងអស់នេះមុនវាកើតឡើង ដើម្បីឱ្យអ្នកជឿកាន់តែរឹងមាំ។
សូមក្រោកឈរ យើងនឹងច្រៀងចំរៀងថ្វាយព្រះ បន្ទាប់មកយើងនឹងទៅសួនដើម្បីអធិដ្ឋាន។



ព្រះយេស៊ូវនិងសិស្សរបស់ទ្រង់ទាំង១១នាក់
ច្រៀងចំរៀងថ្វាយព្រះជាលើកចុងក្រោយ ។

ម៉ាថាយ ២៦:៣០, យ៉ូហាន ១៤:៥-១០, ១៥, ២៥-៣០


មកតាមខ្ញុំដោយស្ងៀមស្ងាត់ យើងទៅកន្លែងសម្ងាត់ដើម្បីអធិដ្ឋាន។


កុំសោកស្ដាយ ព្រោះខ្ញុំបាននិយាយថា នៅពេលបន្តិចទៀត គេនឹងយកខ្ញុំចេញពីអ្នក ហើយបន្តិចក្រោយមក អ្នកនឹងឃើញខ្ញុំវិញ។


ទោះបីអ្នកនឹងយំសោក សេចក្ដីសោកស្ដាយរបស់អ្នកនឹង ត្រឡប់ជាសេចក្ដីអំណរយ៉ាងខ្លាំង ខ្ញុំបានមកពីព្រះវរបិតា ហើយខ្ញុំនឹងត្រឡប់ទៅឯទ្រង់នៅពេលបន្តិចទៀតនេះ ។
អូ៎.. ឥឡូវនេះទ្រង់ មានបន្ទូលយ៉ាងច្បាស់ ។ ពួកទូលបង្គំជឿ ។
តើឥឡូវអ្នកជឿឬ? ពួកអ្នកនឹងបោះបង់ខ្ញុំចោល ក្នុងរយៈពេលខ្លី ហើយត្រូវបានបែកខ្ចាត់ខ្ចាយពីគ្នា ។ សូមនៅទីនេះ ខ្ញុំទៅឆ្ងាយបន្តិចហើយអធិដ្ឋាន ។


ព្រះវរបិតា ដល់ម៉ោងកំណត់ហើយ ទូលបង្គំបានបំពេញភារកិច្ចរួចជាស្រេច ដែលទ្រង់បានប្រទានឱ្យទូលបង្គំធ្វើ ហើយ ឥឡូវសូមតម្កើងទូលបង្គំដោយសិរីល្អដែលទូលបង្គំមានជាមួយនឹងទ្រង់ មុនពិភពលោកបានកើតមក ។ ទូលបង្គំបានបង្រៀនពួកគេអំពីទ្រង់ ហើយពួកគេបានទទួលពាក្យសំដីទាំងអស់របស់ទូលបង្គំ ។


លោកិយនឹងស្អប់គេ ក៏ដូចលោកិយបានស្អប់ទូលបង្គំដែរ ព្រោះទូលបង្គំប្រាប់ពួកលោកិយពិតពីអំពើបាបរបស់ពួកគេ ពួកសិស្សទូលបង្គំមិនមែនខាងលោកិយនេះទេ ទូលបង្គំមិនសូមឱ្យយកគេចេញ ពីលោកិយនេះទេ ប៉ុន្តែសូមទ្រង់ថែរក្សាពួកគេឱ្យរួចពីមេកំណាចវិញ។


ទូលបង្គំក៏អធិដ្ឋានសម្រាប់អស់អ្នកណាដែលនឹងជឿលើទូលបង្គំ
តាមរយៈទីបន្ទាល់សិស្សរបស់ទូលបង្គំដែរ ។ ទូលបង្គំចង់ឱ្យគេទាំង
អស់នៅជាមួយទូលបង្គំដូចទូលបង្គំនៅជាមួយទ្រង់ ព្រះវរបិតាអើយ
សូមទ្រង់ប្រទានសេចក្ដីស្រឡាញ់ដែលទ្រង់មានចំពោះទូលបង្គំ ទៅដល់ពួកគេ
ហើយឱ្យទូលបង្គំគង់នៅក្នុងគេដែរ ។




ម៉ាថាយ ២៦:៣១, ៣៨, យ៉ូហាន
១៦:១៩-២០, ១៧:១-១០


ព្រះវរបិតា បើសិនជាទ្រង់សព្វព្រះហឫទ័យ នោះសូមយកពែងនៃសេចក្ដីក្រោធដែលទូលបង្គំត្រូវផឹកនេះចេញពីទូលបង្គំទៅ ប៉ុន្តែទូលបង្គំមិនចង់ធ្វើតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ ទូលបង្គំនឹងផឹកបើទ្រង់កំណត់ឱ្យ។


ព្រះយេស៊ូវ បានយាងមកផែនដីនេះ
ដើម្បីទទួលបាបមនុស្សលោក ប៉ុន្តែនៅពេលនោះមកដល់
ទ្រង់បានមើលងាយចំពោះសេចក្តីអាម៉ាស់ នៃឈើឆ្កាង
ព្រោះមានន័យថា ព្រះវរបិតាបានធ្វើឱ្យព្រះយេស៊ូវ
ត្រឡប់ជាអ្នកមានបាបជំនួសមនុស្សទាំងអស់នៅគ្រប់ជំនាន់ ។
ព្រះវរបិតាអើយ បើសិនជា
ទ្រង់សព្វព្រះហឫទ័យ នោះសូមយក
ពែងនេះចេញពីទូលបង្គំទៅ ។


ប៉ុន្តែ កុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់ចុះ ។
ញើសរបស់ទ្រង់ក៏ចេញមកក្លាយជាតំណក់ឈាមដ៏ធំៗ ។


រំពេចនោះមានទេវតាលេចមកឯព្រះយេស៊ូវ ហើយបានចំរើនកំលាំងថ្វាយដល់ទ្រង់ ។
ព្រះអង្គដ៏បរិសុទ្ធអើយ សេចក្តីវេទនារបស់ទ្រង់ ដល់ពេលហើយ ប៉ុន្តែព្រះវរបិតាគង់នៅជាមួយទ្រង់ ។ ពួកបរិវារទាំងអស់នៃឋានសួគ៌នឹងទតនៅថ្ងៃស្អែក នៅពេលទ្រង់ទទួលយកអំពើបាបនៃមនុស្សលោកទាំង មូលដាក់នៅលើអង្គទ្រង់ ។


ពួកទេវតាបាននៅទីនោះ
ក្នុងខណៈពេលដែលទ្រង់បានបង្កើតពិភពលោកមក
ហើយពួកទូលបង្គំនឹងនៅក្នុងពេលដែលទ្រង់
រំដោះពិភពលោកវិញដែរ ។


ថ្ងៃស្អែកសាតាំងនឹងចុះ ចាញ់ ហើយបំណុលនៃអំពើ បាបនឹងត្រូវបានសងរួច ។
អ័ប្រាហាំនិងពួកពលបរិវារនៃឋានបរមសុខ កំពុង រង់ចាំការយាងមករបស់ទ្រង់ ពួកគេបានរៀបចំតុមួយ សម្រាប់ទ្រង់ នៅមុខសត្រូវរបស់ទ្រង់ ពែងរបស់ទ្រង់ បានពេញហៀរ ។ ប្រាកដជាសេចក្ដីសប្បុរសនិងសេចក្ដី មេត្តាករុណានៅជាប់ជាមួយទ្រង់ ហើយទ្រង់នឹងគង់ នៅក្នុងដំណាក់នៃព្រះយេហូវ៉ារៀងដរាបទៅ ។




ទំនុកដំកើង ២៣:៥-៦, លូកា
២២:៤១-៤៤, ហេព្រើរ ៦:៦, ១២:២


ព្រះវរបិតាអើយ
ដោយសារហេតុនេះ
បានជាទូលបង្គំ
យាងមកក្នុងលោកិយ ។


អ្នករាល់គ្នាបានដេកលក់អស់ហើយ តើអ្នកមិនអាចចាំយាមនឹងខ្ញុំមួយម៉ោងបានទេ ? ក្រោកឡើង គេបញ្ជូនខ្ញុំទៅក្នុងកណ្ដាប់ដៃនៃមនុស្សអាក្រក់ហើយ ។


លោកគ្រូ ល្អណាស់ដែលបានជួបលោកគ្រូនៅទីនេះ ប៉ុន្តែខ្ញុំមិននឹកស្មានថាមានគេមកតាមសោះ ។


យូដាស តើអ្នកក្បត់ខ្ញុំ
ដោយថើបបែបនេះឬ ?




ម៉ាថាយ ២៦:៤០, ៤៥-៥០, យ៉ូហាន ១២:២៧, ១៨:១-៤


យេស៊ូវ
នៃក្រុង ណាសារ៉ែត
គឺខ្ញុំនេះហើយ


សូមប្រយ័ត្ន! វាមាន
អំណាចយ៉ាងខ្លាំង !
ទាហានទាំងនោះភ័យ
ខ្លាចព្រះយេស៊ូវ ហើយ
ក៏ដួលផ្ងារក្រោយ ។


នោះគឺវា
តើពួកឯងកំពុងខ្លាចអ្វី ?
ចាប់វាទៅ !


ពួកឯងមិនត្រូវចាប់
លោកគ្រូរបស់អញទេ!




យ៉ូហាន ១៨:៤-៦, ១០


ឈប់ !
គ្មានការបង្ហូរឈាមនៅទីនេះទៀតទេ ពេត្រុស
ដាក់ដាវរបស់អ្នកចូលស្រោមវិញ បើសិន
ខ្ញុំត្រូវការខ្ញុំអាចហៅទេវតា១០,000អង្គមកជួយខ្ញុំ
នេះគឺជាពេលវេលានៃសេចក្ដីងងឹត ។
វាកាត់ ត្រចៀកអញ
ដាច់ហើយ !


អ្នកមករកខ្ញុំដោយយកដាវមកជាមួយ ដូច
ខ្ញុំជាឧក្រិដ្ឋជនខ្ញុំធ្លាប់នៅជាមួយពួកអ្នកក្នុងវិហារ ។
តើហេតុអ្វីអ្នកមិនចាប់ខ្ញុំនៅពេលនោះ ?
ខ្ញុំនឹងប្រាប់ពី ហេតុផលដល់ពួកអ្នក
ព្រោះការទាំងនេះត្រូវបាន
សម្រេចតាមបទទំនាយនៃគម្ពីររបស់ព្រះ ។


ព្រះអម្ចាស់អើយ
សូមជួយទូលបង្គំផង !


ឥឡូវនេះល្អដូច
ដើមវិញហើយ ។


គឺខ្ញុំនេះហើយ
ដែល អ្នកត្រូវការ
យើងមិនជំទាស់ទេ សូមចាប់ខ្ញុំទៅ
ហើយអនុញ្ញាតឱ្យអ្នក
ទាំងអស់នេះទៅចុះ ។


នេះជាការអស្ចារ្យ!
គាត់ បានព្យាបាលត្រចៀករបស់ខ្ញុំ !
ត្រចៀកខ្ញុំបានជាដូចដើម !




ម៉ាថាយ ២៦:៥២-៥៧, ម៉ាកុស ១៤:៥១-៥២,
លូកា ២២:៥០-៥១


ទៅឱ្យលឿនឡើង
ពួកគេចង់ឱ្យរឿងនេះចប់មុនពេល
ប្រជារាស្ត្របានដឹងឮ។


គេបាននាំព្រះយេស៊ូវ ទៅកន្លែងដែលពួកសង្ឃ និង សាក្សីទាំងអស់កំពុងជំនុំគ្នា ។
ពួកគេបានប្រាប់អញថា ឯងបាន តាំងខ្លួនជាព្រះមែស៊ី ហើយក៏និយាយពី ព្រះជាម្ចាស់ជាព្រះវរបិតារបស់ឯងដែរ ។ ឯងធ្លាប់និយាយទៀតថា ឯងមិនបានមកពី លោកិយទេ តើឯងមកពីទីណាវិញ ?
តើហេតុអ្វីបានជាលោកសួរខ្ញុំ? ខ្ញុំបានបង្រៀននៅសាលាប្រជុំនិងក្នុងវិហារ ដែរ ខ្ញុំមិនបានបង្រៀនដោយសម្ងាត់ទេ សូមសួរពួកគេដែលធ្លាប់ស្ដាប់ខ្ញុំ ពួកគេដឹង នូវអ្វីដែលខ្ញុំបាននិយាយ ។


ដំង...


ឯងមិនអាចឆ្លើយ
នឹងសម្តេចសង្ឃនូវ
របៀបនេះទេ។
បើសិនខ្ញុំបាននិយាយខុស
ចូរបង្ហាញពីកំហុសនោះចុះ
តែបើខ្ញុំនិយាយត្រូវ តើហេតុអ្វី
លោកវាយខ្ញុំ ?




យ៉ូហាន ១៨:១៩-២៣


វាបាននិយាយថា វាអាចកំទេចព្រះវិហារនិងសង់ឡើងវិញបានក្នុងរយៈពេល៣ថ្ងៃដោយមិនបាច់ប្រើដៃរបស់វា។
អត់ទេ ! វាបាននិយាយថាបើសិនអ្នកផ្សេងកំទេច នោះវានឹងសង់ឡើងវិញ។
ឯងមិនបាននៅទីនោះផង ខ្ញុំបានឮនូវអ្វីដែលវានិយាយ វាបានចង្អុលខ្លួនឯង នៅពេលវាកំពុងនិយាយអំពីការបំផ្លាញវិហារ ខ្ញុំគិតថាវាបាននិយាយពីការបំផ្លាញរូបកាយរបស់វា។


នោះគួរឱ្យអស់សំណើច
តើវាសាងសង់រូបកាយវិញក្នុង
រយៈពេល៣ថ្ងៃយ៉ាងម៉េច ?
ខ្ញុំមិនដឹងទេ ប៉ុន្តែតើវាអាចនឹង
សាងសង់ព្រះវិហារក្នុងរយៈពេល
៣ថ្ងៃយ៉ាងដូម្ដេចដែរ ?


តើឯងបានឮគេកំពុងតែ
ចោទប្រកាន់ឯងឬទេ ?
តើឯងជំទាស់នឹងគេទេ ?


ព្រះយេស៊ូវនៅតែស្ងៀម
អាល្ងង់នេះ
វាមិនព្រមឆ្លើយ


អញបញ្ជាឯងឱ្យស្បថដល់ ព្រះដ៏មានព្រះជន្មរស់ ចូរ ឯងឆ្លើយ តើឯងជាព្រះគ្រីស្ទ ជាព្រះបុត្រានៃព្រះដ៏មាន ព្រះជន្មរស់ឬអត់ ?
ខ្ញុំជារាជបុត្រានៃព្រះមែន ហើយអ្នកនឹងឃើញខ្ញុំ គង់នៅខាងស្តាំនៃព្រះដ៏មានព្រះចេស្តា ហើយនឹងយាង ត្រឡប់មកផែនដីនេះវិញនៅក្នុងពពក ។


យើងមិនត្រូវការសាក្សី ទៀតទេ យើងឮវានិយាយ ផ្ទាល់ត្រចៀកយើងហើយ វាបានប្រមាថដោយអះអាង ថា វាជាបុត្រារបស់ព្រះ ។ វាត្រូវតែងាប់ !
ម៉ាថាយ ២៦:៥៩-៦៥
យកកន្សែងចងភ្នែកវា យើងចង់ ដឹងថា វាជាហោរាដូចម្ដេច ។
សម្ដេចសង្ឃបានគិតថា បន្ទូលរបស់ព្រះយេស៊ូវជាការ ប្រមាថ ដូច្នេះគាត់ហែកអាវខ្លួនឯងដោយបង្ហាញថា គាត់កំពុងមានសេចក្ដីវិនាសអន្តរាយយ៉ាងខ្លាំង ។


មើល៎ បើវាអាច
ទាយត្រូវឬអត់
វាយវាទៅ!
វាបានបំផ្លាញមុខជំនួញ
របស់ខ្ញុំនៅក្នុងវិហារ ។
ចូរឱ្យវាធ្វើ ការអស្ចារ្យ ។


វាយវាទៀត!


ផាំង !
ចូរមើល៍ វាអន់ ណាស់!
ហាស់ហា៎.. ទាយសាកមើល៍ អ្នកណាវាយឯង យើងគិតថា ឯងជាហោរា !
ផាច់ !
ត្រូវព្យាបាលរបួសខ្លួនឯង ឱ្យយើងឃើញការអស្ចារ្យមួយ !


គ្រាដ៍ដែលនោះ
នៅខាងក្រៅវិហារ ពេត្រុស
បានតាមព្រះយេស៊ូវពីចម្ងាយ
ខ្ញុំស្គាល់អ្នក !
ខ្ញុំធ្លាប់ឃើញ អ្នកនៅជាមួយបុរសយេស៊ូវ
តើអ្នកជាសិស្សរបស់យេស៊ូវ នោះមែនទេ ?
ខ្ញុំមិនស្គាល់បុរសយេស៊ូវនោះទេ ខ្ញុំគ្រាន់
តែចង់ឃើញនូវអ្វីដែលកើតឡើងប៉ុណ្ណោះ !




ម៉ាថាយ ២៦:៦៧-៧០,
លូកា ២២:៦៤-៦៥


អ្នកហ្នឹងហើយ ជាសិស្សរបស់ យេស៊ូវ ខ្ញុំតែងតែឃើញអ្នកឯង នៅជាមួយគាត់ជាញឹកញាប់ ។
ស្រីគម្រក់អើយ ! ខ្ញុំមិនដែលជួប បុរសនោះទេតាំងពីខ្ញុំកើតមក ។


កុក គិ កែ កឹត...
កុក គិ កែ កឹត...
មាន់គកនេះរងាវមុន ម៉ោងបន្ទិចមែនទេ ?
ពួកគេកំពុងបណ្ដើរ គាត់ចេញទៅ មើលដូចជា ធ្វើបាបគាត់យ៉ាងខ្លាំង ។




ម៉ាថាយ ២៦:៧១-៧៥, ២៧:១-២,
លូកា ២២:៥៨-៦២, ២៣:១

ពេត្រុស បានឮសំលេងមាន់រងាវ ហើយគាត់បានចាំបន្ទូល
ព្រះយេស៊ូវផ្ដាំថា មុនពេលមាន់រងាវពីរដង គាត់នឹងបដិសេធទ្រង់
ចំនួនបីដង ពេត្រុសបានអៀនខ្មាសនូវភាពកំសាករបស់ខ្លួន។





យកខ្សែតីកន្ទុយ៩វាយវាទៅ!
មកឱ្យលឿន ពួកអញគ្មានពេល ធ្វើការនេះពេញមួយយប់ទេ។
ព្រះជាម្ចាស់អើយ ! ហេតុអ្វីបានជា ទូលបង្គំធ្វើដូច្នេះ? ទូលបង្គំបានបដិសេធ បីដង ដូចទ្រង់មានបន្ទូល ហេតុអ្វីមាន ការនេះកើតឡើង ? តើហេតុអ្វីទ្រង់ ត្រូវរងការឈឺចាប់ដូច្នេះ ?
ព្រះវរបិតា សូមប្រទានកំលាំង


ពេលយូដាសដឹងថា គេនឹង
សម្លាប់ព្រះយេស៊ូវ គាត់យក
ប្រាក់សងពួកសង្ឃរាជវិញ ។
ឯងមកទីនេះចង់បានអ្វី ? តើយើងឱ្យលុយ
មិនគ្រប់គ្រាន់ចំពោះការក្បត់គ្រូរបស់ឯងឬ ?


ខ្ញុំប្តូរគំនិតហើយ ចូរ ដោះលែងទ្រង់វិញចុះ ខ្ញុំនឹង សងលុយអ្នកវិញ។
នេះគឺជាលុយកខ្វក់ដែលប្តូរជីវិត យើងមិន ប៉ះទេ គ្រូរបស់ឯងនឹងស្លាប់មុនថ្ងៃនេះកន្លងផុតទៅ ឯង គ្មានអ្វីត្រូវខ្លាចទេ ប្រហែលយើងអាចប្រើឯងឱ្យជួយ ចាប់សិស្សរបស់វាទៀត។


យកលុយឯងវិញទៅ
អញ លែងត្រូវការហើយ អញមិនអាចរស់
នៅដោយមានកំហុសបែបនេះទេ ។
គ្លិង !
ធ្លឹង !




ម៉ាថាយ ២៧:៣-៦


ខ្ញុំមិនចង់រស់ទៀតទេ


ព្រះជាម្ចាស់អើយ!
ចិត្តរបស់ទូលបង្គំមិនស្ងប់ សោះ
តើហេតុអ្វីចេះតែ ខ្វល់ខ្វាយដូច្នេះ ។


ហេតុអ្វីខ្ញុំមិនអាចគ្រប់គ្រង
ចិត្តលោភលន់របស់ខ្ញុំបាន។


ប្រហែលមានតែ
សេចក្ដីស្លាប់ទេ ធ្វើឱ្យ ចិត្តខ្ញុំស្ងប់បាន ។


ខ្ញុំបានឃើញ គាត់
ប៉ុន្តែខ្ញុំឃាត់ មិនទាន់។
យើងត្រូវប្រញាប់ឡើង
និងកាត់ក្រមាទម្លាក់មក
ប្រហែលគាត់នៅរស់ !


ទោះបីជាពួកគេកំពុងតែឡើងទៅជួយគាត់ក៏ដោយ ក៏ព្រលឹង
របស់យូដាសកំពុងតែធ្លាក់ទៅកន្លែងមានភ្លើងដែលរងទុក្ខវេទនា។




ម៉ាថាយ ២៧:៥, កិច្ចការ ១:១៨


វានៅឆ្ងាយពេក!



អ្ប៎ ធ្វើឱ្យខ្ញុំចង់ក្អួត
អាក្រក់មើលណាស់ !
វាបានធ្លាយពោះហើយពោះវៀន
ចេញទ្រេទ្រលពេញទីវាល ។
ហោរាបានទាយមុនថា
អ្នកក្បត់ ព្រះមែស៊ី
ត្រូវតែស្លាប់ដោយបែបនេះ ។


នៅពេលនោះពួកទាហានបាននាំព្រះយេស៊ូវទៅជួបអ្នកគ្រប់គ្រងក្រុងរ៉ូម ដើម្បីកាត់ទោស ។
តើឯងនាំអ្នកណាមកអ្នក ក្បត់សាសនាម្នាក់ទៀតឬ? នាំ វាចេញទៅវិញ ហើយកាត់ទោសតាមច្បាប់របស់ឯងចុះ ។


ទោសវាសមនឹងស្លាប់ កុំអីយើងមិននាំវា
មកទីនេះទេ ក្រុងរ៉ូមបានដកអំណាចយើងចេញ
ចំពោះការគប់ដុំថ្មសម្លាប់ដល់អ្នកប្រមាថ ដូច្នេះ
យើងមកសុំការអនុញ្ញាតពីលោក ។
តើវាមានទោសអី?


វាថា វាជាស្ដេច
តើឯងជាស្ដេចនៃ សាសន៍យូដាឬ ?
ឥឡូវនេះនគររបស់ខ្ញុំមិនមែននៅ លោកិយនេះទេ បើមែននោះពួកបរិវាររបស់ខ្ញុំនឹង មកប្រយុទ្ធដើម្បីការពារជីវិតខ្ញុំទៅហើយ ។


ដូច្នេះឯងជាស្តេចមែនឬ?


ខ្ញុំមកលោកិយនេះដើម្បីធ្វើជាសាក្សីនៃសេចក្ដីពិត អ្នកដែលនៅជាប់សេចក្ដីពិត គេនឹងស្ដាប់ខ្ញុំ។




សាការី ១១:១២-១៣, ម៉ាថាយ ២៧:៨, ម៉ាកុស ១៥:១៤, លូកា ២៣:១-៤, យ៉ូហាន ១៨:២៩-៣៨, កិច្ចការ ១:១៨


តើខ្ញុំត្រូវវាយវាប៉ុន្មានខ្សែតី ?
គេថា វាយវាឱ្យគ្រប់ចំនួន៣៩ខ្សែតី ។
ឥឡូវយើងនឹងសាកល្បងគ្រូប្រដៅនេះខ្លាំងប៉ុណ្ណា ។
ខ្សែតីកន្ទុយ៩ គឺជាខ្សែតីដែលមានដងឈើ ប្រវែង៩តឹក ដោយធ្វើពីស្បែក៩សរសៃ ១សរសៃ មានប្រវែង១ម៉ែត្រ ហើយនៅចុង ខ្សែមានចងបំណែកថ្ម ឆ្អឹង ឬដែកដែលមុតស្រួច ។


អូយ...!
ដាក់ឱ្យខ្លាំងទៅ!
ឥឡូវមិត្តភក្តិរបស់ឯងនៅឯណា ?
វាមិនទាន់សុំអង្វរទេ ។
ខ្វាប់
!
វាយរបៀបនេះប្រហែលធ្វើឱ្យវាងាប់ ហើយយើងនឹងលែងឃើញនូវការអស្ចារ្យរបស់វាទៀត ។




លូកា ២៣:១១, យ៉ូហាន ១៩:១-២


មើល៍ ខ្នងវាស្នាម ឡើងសុះ!
បាទ ព្រោះអីខ្ញុំចង់វាយ ស្តេចយូរហើយ ។


វាថា វាជាស្តេច ចូរពាក់រ៉ូប
ពណិស្វាយនេះលើវាទៅ ។
ស្តេចត្រូវការម្កុដ៍ដែរ


ហាស់ហាំ !
នេះ នឹងធ្វើជាមកុដដ៏ល្អមួយ
អ៊ូយ!    មុត


យកដំបងរាជ្យនេះ ទៅ អ្ហ៎ ស្ដេចដ៏ល្បីអើយ ។ ហាស់ ហាស់ !
ពាក់លើក្បាលវាឱ្យជាប់ រឹតឱ្យបានតឹង !


យើងអភិសេកឱ្យឯង ជាស្ដេចលើពិភពលោក ទាំងមូល !
អ្ហា៎...!


ឥឡូវក្រោកឈរ ឱ្យត្រង់ ។
កាន់ដំបងរាជ្យឡើង ព្រះអង្គ ។
ហាស់ហា៎... សូមឱ្យ មានព្រះជន្មយឺនយូរ ។
មែន បើវាមានសំណាង វាអាចរស់រហូតដល់ថ្ងៃលិច ។

យ៉ូហាន ១៩:១-៣


ស្ដេចនៃប្រទេសរ៉ូមគេ អត់មានពុកចង្កាទេ ។


ឥឡូវនេះវាមើលដូច
ជាស្ដេចល្អជាងមុនបន្តិច ។


យើងធ្វើបាបវាមិនបានសប្បាយ
សោះ ហើយវាក៏មិនសុំអង្វរយើងដែរ
ត្រូវយកវាទៅឱ្យលោកពីឡាត់វិញ។


មើលនុះន៎ ! ស្ដេចរបស់អ្នក !
ឆ្កាងវាទៅ! ឆ្កាងវាទៅ!
យើងគ្មានស្ដេចទេ មានតែ សេសារ !
មើល៎ បុរសនោះ! តើពួកឯងចង់ឱ្យអញធ្វើ យ៉ាងម៉េចទៅលើវា ?


ពួកឯងអាចយកវាទៅ
ឆ្កាងបាន ! អញរកមិនឃើញ
កំហុសវាសោះ ។


តើលោកនិយាយមានន័យ
យ៉ាងម៉េច វាគ្មានកំហុស ? វាបាន
តាំងខ្លួនវាជារាជបុត្រានៃព្រះ ។




ទំនុកដំកើង ២២, អេសាយ ៥០:៦, ៥៣:៥, ៧, លូកា ២៣:១៣-២២, យ៉ូហាន ១៩:៤-៨ (សេសារ គឺជារបហស្សនាម ស្តេចនៅជំនាន់អាណាចក្ររ៉ូម)


តើឯងជានរណា?
ហេតុអ្វីក៏ឯងមិន ឆ្លើយនឹងអញ? តើឯងមិនដឹងទេថា
អញ មានអំណាចអាចឱ្យឯងងាប់បាន ?
លោកនឹងគ្មានអំណាចទេ
បើសិនជាព្រះវរបិតាខ្ញុំដែលនៅ
ឋានសួគិមិនប្រទានឱ្យលោក ។


អញប្រាប់ពួកឯងឱ្យ ដឹងថា អញមិនឃើញកំហុសវាទេ អញនឹងដោះលែងវា ។
បើលោកដោះលែងវា លោក មិនមែនជាមិត្តជាទីស្រឡាញ់ និងសេសារទេ ។
ឆ្កាងវាទៅ ! ឆ្កាងវាទៅ !
យកវាចេញ ហើយចង់ធ្វើអ្វីក៏ធ្វើទៅ អញនឹងធ្វើកំណត់ហេតុពីទោសរបស់វា ប៉ុន្តែអញ គ្មានទោសនិងឈាមនៃបុរសសុចរិតនេះទេ ។




ម៉ាថាយ ២៧:២៤, យ៉ូហាន ១៩:៩-១៧


ខ្ញុំគិតថា វាលែង
ទៅមុខរួចហើយ ។
ក្រោវ...
ន, លល


ក្រោកឡើង ប្រយ័ត្នអញវាយទៀត !
អ្ហែ៎ អ្នកនោះ ត្រូវ ជួយលីឈើឆ្កាងវា ។
ហេតុអ្វីត្រូវការខ្ញុំជួយ?


តើគាត់ធ្វើអ្វីខុស?
វាស្រឡាញ់
មនុស្សគ្រប់គ្នា ទាំងអស់ ។


ឱព្រះយេស៊ូវអើយ!
ពួកខ្ញុំម្ចាស់អាណិតអាសូរ ដល់ទ្រង់យ៉ាងខ្លាំង ។
កូនស្រីនៃទីក្រុងយេរូសាឡិម កុំយំព្រោះខ្ញុំឡើយ ត្រូវយំសម្រាប់ខ្លួនឯង សម្រាប់កូនអ្នកដែរ ពីព្រោះពេលវេលានឹង មកដល់ប្រជាជននៅទីក្រុងយេរូសាឡិមនឹងលាក់ខ្លួនដោយភ័យខ្លាច ហើយគេនឹងអធិដ្ឋានសុំសេចក្ដីស្លាប់ព្រោះមិនចង់រស់ទៀត ។




ម៉ាថាយ ២៧:៣២, លូកា ២៣:២៦-៣៣


ពួកទាហានបានយកសាញននោង
ជ្រលក់ក្នុងទឹកខ្មេះហុចឱ្យព្រះយេស៊ូវ
នេះនែ៎
ផឹកវាទៅ វាបំបាត់ការឈឺចាប់ ។
អត់ទេ ! ខ្ញុំត្រូវ
ធ្វើតាមព្រះហឫទ័យ
របស់ព្រះវរបិតាខ្ញុំ ។
វានៅតែគិតថា
វាជា រាជបុត្រានៃព្រះ ។


ផ្ដេកវាឱ្យត្រង់
យកញញួរនិងដែក
គោលមកទីនេះ ។


ឥឡូវត្រូវកាន់ឱ្យជាប់
នៅពេល យើងចាប់ផ្ដើមដំ
វានឹងបម្រះយ៉ាងខ្លាំង
ឯងត្រូវកាន់ដៃវាឱ្យនឹងរហូតដល់
ដំទម្លុះឆ្អឹងជាប់និងឈើ ។


ទេ! កូន សម្លាញ់ម្ដាយ!
ឆាំង
ជ្រឹប


អ្នកយល់យ៉ាងម៉េច តើហេតុអ្វីវាគិតថា វាជា រាជបុត្រារបស់ព្រះ ?
ខ្ញុំបានឮថា វាទាក់ទងនឹង បទទំនាយពីបុរាណខ្លះ ប៉ុន្តែ ខ្ញុំមិនខ្វល់ខ្វាយទេ។
ទំនុកដំកើង ២២, អេសាយ ៥២, ម៉ាថាយ ២៧:៣៣-៣៤


កាន់ជើងឱ្យជាប់ នេះត្រូវការ
ដំច្រើនញញួរទម្រាំផ្លុះដល់ឈើ ។


អ៊ូ ! ម៉ារា
ខ្ញុំគិតថា ខ្ញុំមិនអាច ទ្រាំបានទេ ។
ខ្ញុំមិនដែលគិតថា
វានឹងកើតឡើង ដូចនេះទេ ។
ទាញអាស្មើ!
អាជ្រូកកម្ជិល !
អញត្រូវការអ្នកជួយខ្លះ


សាការី ១៣:៦, លូកា ២៣:៣២-៣៤
ឱព្រះវរបិតាអើយ! សូម អត់ទោសឱ្យពួកគេផង ដ្បិតពួកគេ មិនដឹងអ្វីដែលគេធ្វើទេ ។
យើងទាំងអស់គ្នា បានបោះបង់ចោលទ្រង់ ។
យ៉ូហាន ខ្ញុំអរគុណណាស់ ដែលអ្នកបានមកទីនេះ ការនេះអាក្រក់ណាស់ ។



នេះជាសំលៀកបំពាក់របស់ វា ខ្ញុំត្រូវការយកមួយនេះ ។
មិនឱ្យឯងទេ! យើងនឹង ហែកជាបួនចំណែក ។
យើងមិនអាចហែកមួយ នេះដាច់ទេ ព្រោះជាអាវ ចាក់គ្មានថ្នេរ ។
យើងនឹងភ្នាល់លេង ឡុកឡាក់ជាមួយគ្នាសម្រាប់ អាវមួយនោះ ។
ព្រះគម្ពីរបានទាយទុកមុនថាគេបានហែកអាវមួយ ហើយមួយទៀតគេនឹងលេងល្បែងភ្នាល់គ្នា ។


អ្នកណាបោះគ្រាប់ឡុកឡាក់បានលេខខ្ពស់ ជាងគេ អ្នកនោះបាន ទាំងអស់ ។
ប្រយ័ត្ន លីអូ ! មាន ឈាមស្រក់លើឯង ។




ទំនុកដំកើង ២២:១៨, ម៉ាថាយ ២៧:៣៩-៤៣, យ៉ូហាន ១៩:២៣-២៤


ចូរព្រះគ្រីស្ទ ស្តេចនៃ
អ៊ីស្រាអែលចុះពីលើឈើឆ្កាង
ឱ្យយើងបានឃើញ នោះ
យើងនឹងជឿ ។
អ្នកក្លែងក្លាយ !
វាបានទុកចិត្តលើព្រះថា ទ្រង់នឹងសង្គ្រោះវា
ចូរឱ្យព្រះជាម្ចាស់ ជួយវាឥឡូវនេះចុះ
ព្រោះវាមាន សេចក្តីអំណរចំពោះព្រះ ។


ផឹកនេះ
វានឹងជួយបន្ធូរ
ការឈឺចាប់របស់ឯង។
ទេ !


បើសិនឯងជាបុត្រាព្រះមែន ចុះក្រោមដោយខ្លួនឯងមក ហើយ យើងនឹងសម្លាប់ពួករ៉ូមនេះខ្លះ ។
ហេតុអីក៏ឯងចំអកទ្រង់ យ៉ាងនេះ ? ឯងជិតស្លាប់ ហើយ តើឯងនៅតែមិន ខ្លាចព្រះទេឬ ?


យើងសមនឹងទទួលនូវអ្វីដែលយើងបានប្រព្រឹត្ត ប៉ុន្តែនេះជាព្រះយេស៊ូវ ។ ទ្រង់មិនបានធ្វើអ្វីខុសសោះ ។
ព្រះយេស៊ូវអើយ សូមនឹកចាំពីទូលបង្គំផង នៅពេលទ្រង់យាងចូលទៅនគររបស់ទ្រង់ ។


ថ្ងៃនេះអ្នកនឹងបាននៅ
ឋានបរមសុខជាមួយខ្ញុំ។




ទំនុកដំកើង ៦៩:២១, លូកា ២៣:៣៦-៤៣,
យ៉ូហាន ១៩:២៥-២៧



មេឃចាប់ផ្ដើមងងឹតដូចជាពេលយប់អស់រយៈពេល៣ម៉ោង ពេលដែលព្រះយេស៊ូវ កំពុងព្យួរនៅលើឈើឆ្កាង ។ នោះគឺជាម៉ោងនៃសេចក្ដីងងឹត ។ បុរសដែលជាព្រះគ្រីស្ទ យេស៊ូវ កំពុងស្លាប់នៅលើឈើឆ្កាងសម្រាប់អំពើបាបរបស់មនុស្សលោក ។


ដោយសារតែទម្ងន់នៃអំពើបាបបានធ្លាក់មក
លើព្រះយេស៊ូវ ទ្រង់បានស្រែកយ៉ាងខ្លាំងថា...
ឱព្រះអង្គ!
ឱព្រះអង្គ ! នៃទូលបង្គំអើយ
ហេតុអ្វីក៏បោះបង់ចោលទូលបង្គំ ?


ព្រះអម្ចាស់ បានធ្វើឱ្យទ្រង់ត្រឡប់ជាតួបាបជំនួសយើងគ្រប់គ្នា។
ម៉ាថាយ ២៧:៤៥-៥០, លូកា ២៣:៤៤-៤៦, យ៉ូហាន ១៩:៣០, កូរិនថូសទី២, ៥:២១
ព្រះបិតា ទូលបង្គំសូមប្រគល់ វិញ្ញាណក្នុងព្រះហស្តទ្រង់ ។
អ៊ូ៎ យ៉ូហាន មើល៎ ទ្រង់ជិតសុគតហើយ ។ ខ្ញុំ មិនគួរជឿថា ទ្រង់ពិតជា នឹងសុគតមែន !


ព្រះអម្ចាស់ បានធ្វើឱ្យទ្រង់ត្រឡប់ជាតួបាបជំនួសយើងគ្រប់គ្នា។
កិច្ចការបានសម្រេចហើយ!
រួចទ្រង់ក៏សុគត


ហើយភ្លាមៗនោះក៏មាន រញ្ជួយដីយ៉ាងខ្លាំង ។
មកពីយេស៊ូវនេះ ស្តេច នៃសាសន៍យូដា វាជាអ្នក ធ្វើការអស្ចារ្យ ។
តើមានអ្វីកើតឡើង ? មុនដំបូងមេឃងងឹតដូចយប់ ហើយ ឥឡូវមានរញ្ជួយដីទៀត ។
ឥឡូវនេះ វាមិនធ្វើការអស្ចារ្យទេ ព្រោះវាងាប់ហើយ ។


មើល៎មេឃមានពន្លឺថ្ងៃវិញ ហើយ ថ្ងៃនេះចម្លែកមែនទែន ។
មែនហើយ ! ការទាំងអស់នេះកើតឡើង ចំពេលម្នាក់នេះស្លាប់ ។



វាពិតជារាជបុត្រា របស់ព្រះមែន


មេបញ្ជាឱ្យយើងវាយបំបាក់ជើងពួកវា ពួកសង្ឃ
ត្រូវការឱ្យពួកវាងាប់នឹងទម្លាក់សពចុះក្រោមមុនពេល
ថ្ងៃលិច ព្រោះស្អែកជាថ្ងៃបរិសុទ្ធរបស់ពួកគេ ។
បទទំនាយបានទាយរួចហើយថា
ទ្រង់នឹងសុគតនៅ លើឈើឆ្កាង
ហើយគ្មានឆ្អឹងណាមួយត្រូវបានបាក់
នោះទេ បទទំនាយនេះត្រូវប
ានបំពេញដូច្នេះ ។
មិនបាច់បំបាក់ជើងវាទេ ព្រោះវាទើបតែងាប់ ។
តើពួកឯងដឹងនូវអ្វីដែលវានិយាយមុនពេលវាងាប់ទេ ?
វាបាន សុំបិតារបស់វាលើកលែងទោសឱ្យពួកយើង ពីព្រោះយើង សម្លាប់វា ។
មានគេបានប្រាប់អញថា វាជាបុរសបរិសុទ្ធដែល បានធ្វើការអស្ចារ្យយ៉ាង ច្រើន ។


ដូច្នេះពួកទាហានបែរចេញពីព្រះយេស៊ូវ
ទៅវាយបំបាក់ជើងចោរទាំងពីរ ។
ក្វស !
ទំនុកដំកើង ៣៤:២០, សាការី
១២:១០, ម៉ាថាយ ២៧:៥៤,
យ៉ូហាន ១៩:៣១-៣៧


យ៉ាងហោចណាស់
ក៏គេមិនវាយបំបាក់ ជើងទ្រង់ដែរ ។
អ៊ំម៉ារា ខ្ញុំនឹងទៅរក
មនុស្សខ្លះដើម្បីនឹងជួយ
រៀបចំបញ្ចុះសពទ្រង់ ។


ថ្ងៃឈប់សម្រាកនឹងចាប់ផ្តើមនៅពេលថ្ងៃលិច ឥឡូវនេះវារសៀលហើយ ពួកគេត្រូវការធ្វើយ៉ាងប្រញាប់ ដើម្បីបញ្ចុះសពទ្រង់ទាន់ពេល ។

# យេស៊ូវពីណាសារ៉ែត ស្ដេចនៃយូដា



យ៉ូហាន ១៩:៣១, ៣៨


យ៉ូសែប ជាអ្នកមាន គាត់មិនមែន ជាសិស្សម្នាក់ក្នុងចំណោម១២នាក់ទេ គាត់បានសម្រេចចិត្តឱ្យផ្នូរថ្មីផ្ទាល់ខ្លួន ដើម្បីបញ្ចុះសពព្រះយេស៊ូវ ។
ថ្ងៃឈប់សម្រាកនឹងមកដល់ ឆាប់ៗ យើងប្រញាប់យកសព ទ្រង់បញ្ចុះនៅក្នុងផ្នូររបស់ខ្ញុំ ។
នេះជាការប្រពៃណាស់ យ៉ូសែប អ្នកគឺជាមិត្តដ៏ល្អ ។



## ជំពូក ១២

# ការរស់ឡើងវិញ
# បុណ្យប្រមូលផលដំបូង
# និង
# ការចាប់ផ្ដើមនៃពួកជំនុំ


ធ្វើឱ្យលឿនឡើងមេឃ
ចាប់ផ្ដើមងងឹតហើយ ។
អ្នកដឹងទេ ទ្រង់បានប្រាប់យើងច្រើនដងហើយ
នឹងមានការនេះកើតឡើង ខ្ញុំគ្រាន់តែមិនយល់ពីមូលហេតុ
វាមើលទៅដូចជាទ្រង់ចង់សុគតដោយរបៀបនេះ ។ ទ្រង់ជ្រាប
ពីពេលវេលានឹងអ្វីៗទាំងអស់ចំពោះរឿងនេះ ហើយទ្រង់
ទើបតែប្រាប់យើងម្ដងទៀតនៅយប់មិញ ។


យើងឥតមានពេលគ្រប់គ្រាន់ ដើម្បីរៀបចំទឹកអប់សម្រាប់អប់ ព្រះសពទ្រង់ទេ ។
មកតាមផ្លូវនេះ សូមប្រយ័ត្ន ពេលបោះជំហានចុះ ។


យើងនឹងមកវិញពេលដែលថ្ងៃឈប់សម្រាកបានកន្លងផុត ។
ប៉ុន្តែគិតពីពេលនេះទៅនោះនឹងនៅ៣ថ្ងៃទៀត !
យើងធ្វើបានតែប៉ុណ្ណឹងទេ


ពួកសង្ឃបានត្រឡប់ទៅជួប លោកពីឡាត់ម្ដងទៀត។
លោក អ្នកបោកបញ្ឆោត ដែលយើងឆ្កាងវាធ្លាប់និយាយថា ក្រោយពីនៅក្នុងផ្នូរ៣ថ្ងៃវានឹងរស់ពី ស្លាប់ឡើងវិញ។
វានឹងជាការអាក្រក់មួយ បើសិនជាពួកសិស្សរបស់វាលួច យកសពទៅ ដូច្នេះលោកគួរតែ ដាក់ទាហានយាមខាងមុខផ្នូរ កុំឱ្យការនេះកើតឡើង។
អញនឹងបញ្ជូនកងការពារ ទៅទីនោះ ចូររក្សាឱ្យមាន សន្តិសុខបំផុត។




ម៉ាថាយ ២៧:៥៩-៦៦, យ៉ូហាន ១៩:៤០


ពួកឯងកុំភ័យពីខ្មោចព្រះមែស៊ីរបស់ពួកឯង
បាត់ទៅណា យើងមិនដែលធ្វើឱ្យបាត់សាកសព
មួយណាទេ។ មែនទេអ្នកទាំងអស់គ្នា ?
ឃាស់ឃា៎...


៣ថ្ងៃក្រោយបន្ទាប់ពីគេ បញ្ចុះសពទ្រង់។
នេះជាលើកទីមួយ ហើយដែលយើងមក យាមខ្មោចដូចនេះ។
វាជិតភ្លឺហើយ ពួកទាហានផ្សេង នឹងមកផ្លាស់វេនយាមម្តង។


អស់រយៈពេល៣ថ្ងៃបន្ទាប់មក ពួកស្ត្រី
បាននាំគ្នាទៅឯផ្នូរព្រះយេស៊ូវ ។
ព្រះអាទិត្យជិតរះ
យើងប្រញាប់ ទៅ
វាគម្រប់៣ថ្ងៃហើយ ។
ខ្ញុំស្តាយដែល
យើងមិនបានធ្វើការ
អប់ព្រះសពជាមុន ។




ម៉ាថាយ ២៨:១-២, លូកា ២៤:១


អ៊ូ មួយនេះ ពិតជាធំណាស់ !
សូមស្តាប់ពួកបុរសនោះស្រែក ! ប្រហែលជាមានអ្នកខ្លះត្រូវរបួស ។


ស្អីគេនោះ...?
អ្ហា៎...!


ទ្រង់កំពុងប្រមៀលថ្មចេញ !
គឺជាព្រះ...!
ទ្រង់នឹងសម្លាប់យើង!
ឱព្រះមាតានៃព្រះអើយ សូមមានមេត្តាផង !


កុំរត់ចោលខ្ញុំ!
ព្រះ   អើយសូមមេត្តាផង!
វាមិនអាចកើតឡើងទេ!
ចង់រស់រត់   ឱ្យលឿន!
ម៉ាថាយ ២៨:២-៤


ថ្មនោះធំណាស់ តើយើង ត្រូវរកពួកបុរសជួយប្រមៀល ចេញយ៉ាងម៉េច ?
ខ្ញុំមិនដឹងទេ ប៉ុន្តែព្រះសពបានបញ្ចុះ ៣យប់៣ថ្ងៃហើយ បើមិនបានដាក់គ្រឿង ក្រអូបព្រះសពពិតជាមានក្លិន ។
គេមិនបានដឹងថាមានពួក ទាហានយាមខាងមុខផ្នូរទេ ។


ពីរបីនាទីក្រោយមក...
អ៊ុំ មានគេប្រមៀល ថ្មចេញហើយ!


ព្រះសពរបស់ទ្រង់បាត់
ហើយ ផ្នូរនៅទទេ !


អ៊ូ ! តើអ្នកជាអ្នកណា?
ឯណាសពព្រះយេស៊ូវ?
នោះគឺជា
សំពត់ស្នបទេតើ !
ចូរកុំភ័យឡើយ ! ខ្ញុំ ដឹងថា
អ្នកកំពុងរកព្រះ យេស៊ូវ ដែលគេបានឆ្កាង ទ្រង់
មិននៅទីនេះទេ ទ្រង់មាន ព្រះជន្មរស់ឡើងវិញ
ដូចទ្រង់ ធ្លាប់មានព្រះបន្ទូល ។


ចូរមកមើលកន្លែងដែលគេផ្តេកព្រះសព ទ្រង់ ហើយទៅប្រាប់ពួកសិស្សទ្រង់ថា ព្រះយេស៊ូវនឹងជួបពួកគេនៅស្រុកកាលីឡេ។


ព្រះយេស៊ូវនៅមាន
ព្រះជន្មរស់ ! លោកថា ទ្រង់បាន
រស់ពីសេចក្តីស្លាប់ដូចឡាសារ !

# ម៉ាកុស ១៦:៣-៨


បុរសទាំងនោះ ជាទេវតា !
ព្រះយេស៊ូវនៅ មានព្រះជន្មរស់ !
ប្រញាប់ឡើង យើង ត្រូវទៅប្រាប់ពួកសាវក របស់ទ្រង់។


ព្រះយេស៊ូវមាន ព្រះជន្មរស់ ! យើងទើប តែមកពីផ្នូរ ។
ព្រះយេស៊ូវមិននៅទី នោះទេ តែមានទេវតា នៅទីនោះ ។


យើងនៅចាំបានថា ព្រះយេស៊ូវ ធ្លាប់មានបន្ទូល គឺទ្រង់នឹងមានព្រះជន្មរស់ឡើងវិញនៅថ្ងៃទីបី ។
ពួកទេវតាបានប្រាប់យើងថា ព្រះយេស៊ូវ នឹងជួបពួកអ្នកនៅស្រុកកាលីឡេ !


ពេត្រុស
តើអ្នកទៅណា ?
ទៅផ្ទះ


យ៉ូហាន បានរត់តាមពេត្រុស ប៉ុន្តែគាត់
រត់លឿនជាង ហើយទៅដល់ផ្នូរមុន ។
យ៉ូហាន !
ចាំខ្ញុំផង ខ្ញុំមិនអាចរត់លឿន
ដូចអ្នកបានទេ។






យ៉ូហាន ២០:២-៩


យ៉ូហាន សំពត់ស្នបបានបត់យ៉ាងស្អាត វាមើលហាក់ដូចជាទ្រង់ក្រោកឡើង ហើយបានដើរចេញប៉ុណ្ណោះ ។
ប៉ុន្តែ...ទេមិន អាចអញ្ជឹងទេ ។
ប៉ុន្តែពួកទេវតានៅឯណា? ប្រហែលជាពួកស្រីៗមើល ឃើញអ្វីផ្តេសផ្តាសហើយ ។


តើអ្នកបានឃើញពួកបុរស
ស្លៀកពាក់ខោអាវពណ៌សទេ ?
នោះគ្មានអ្វីទេ គ្មានមនុស្ស
គ្មានទេវតា សពទ្រង់ក៏បាត់ដែរ ។


នាងបានស្រែកទ្រហោយំ យ៉ាងខ្លាំង...
ហេតុអ្វីនាងយំ?


ពីព្រោះគេយកសពព្រះអម្ចាស់
របស់ខ្ញុំចេញ ហើយខ្ញុំមិនដឹងគេ
យកទៅទុកឯណាទេ។


ម៉ារា


លោកគ្រូ!


ម៉ារា ឥឡូវនេះកុំប៉ះខ្ញុំ
ខ្ញុំមិនទាន់ឡើងទៅជួបព្រះវរបិតានៅ
ឡើយទេ
ចូរទៅប្រាប់ពួកសាវកនូវអ្វី
ដែលនាងបានឃើញហើយខ្ញុំនឹងជួប
ពួកគេនៅស្រុកកាលីឡេ ។
ព្រះជាម្ចាស់អើយ
ទ្រង់នៅមាន
ព្រះជន្មរស់ ។

យ៉ូហាន ២០:៧-១៧


ពួកសាវកគេមិនបានជឿនូវដំណឹងដែល
ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញនោះទេ ។
យ៉ូហាននិងពេត្រុសបានទៅមើល
នៅផ្នូរមិនបានឃើញអ្វីទេដូច្នេះខ្ញុំគិតថាមាន
នរណាម្នាក់លួចយកសពចេញ ពួកស្ត្រីឆ្កួតនោះ
ត្រូវឈប់និយាយ វាគ្រាន់តែធ្វើឱ្យពួកយើង
ពិបាកចិត្តថែមទៀត ។
យើងត្រូវតែត្រឡប់
ទៅភូមិអេម៉ោសវិញ គ្មាន
ប្រយោជន៍អ្វីសម្រាប់ពួកយើង
នៅទីនេះទៀតទេ ។


នេះជាថ្ងៃទីបី
មែនហើយ ប៉ុន្តែហេតុអី ក៏ទ្រង់ឱ្យគេសម្លាប់ បើទ្រង់គង់ តែរស់ឡើងវិញដ៏ដែលហ្នឹង ?
អើហ្នឹងហើយ បើទ្រង់ ចង់ធ្វើជាស្តេចមែន ទ្រង់មិន គួរធ្វើការទាំងនេះដោយ អាថិកំបាំង តើមែនទេ ?



តើខ្ញុំអាចដើរជាមួយ
អ្នកផងបានទេ ?
អឺយ៉ា ! ខំតែភ័យ
តើអ្នកមកពីណា ?
មិនអីទេ នេះជា
ថ្ងៃល្អសម្រាប់យើងដើរ
ជាមួយគ្នា។


ខ្ញុំបានឮអ្នកនិយាយគ្នា នៅ
ពេលខ្ញុំដើរជិតដល់ ហើយមើល
ទៅអ្នកដូចជាកើតទុក្ខ ។
តើអ្នកមិនបានដឹងនូវអ្វីដែលបាន
កើតឡើងទាំងបីថ្ងៃមុននេះអំពីយេស៊ូវ
មកពីក្រុងណាសារ៉ែតឬទេ ?


យើងបានសង្ឃឹមថា ទ្រង់ជាព្រះមែស៊ី ប៉ុន្តែគេ បានឆ្កាងទ្រង់ហើយ ។
ព្រឹកមិញស្ត្រីខ្លះបានទៅឯផ្នូររកព្រះសពទ្រង់ មិនឃើញទេ គេអះអាងថាបានឃើញពួកទេវតា ប្រាប់គេពីទ្រង់នៅមានព្រះជន្មរស់ ។




ទំនុកដំកើង ២២, សាការី ១៣:៧, លូកា ២៤:១៣-២៦


ហោរាអេសាយបានទាយថា
ព្រះគ្រីស្ទនឹងយាងមកនៅពេលដែលនគរអ៊ីស្រាអែលឬយូដាគ្មានស្ដេច
(អេសាយ ៧:១៦) ឥឡូវនេះ ដល់ពេលហ្នឹងហើយ
ហោរាអេសាយក៏បានទាយទៀតថា ទ្រង់នឹងមកតាមពូជពង្ស អ៊ីសាយ
ដែលជាឪពុករបស់ស្ដេចដាវីឌ (អេសាយ ១១:១)


តើព្រះយេស៊ូវនៃក្រុងណាសារ៉ែតនេះដែលត្រូវគេឆ្កាង
បានតាំងខ្លួនជាព្រះគ្រីស្ទស្មើនឹងព្រះវរបិតាឬ ?
ការតាំងខ្លួនរបស់ទ្រង់គឺមានការបញ្ជាក់យ៉ាងច្បាស់នៅក្នុងព្រះគម្ពីរបរិសុទ្ធ។
ចូរនឹកចាំពីបទទំនាយដែលគម្ពីរបរិសុទ្ធបានចែង...
ហោរាអេសាយបានទាយថា
គេនឹងហៅព្រះគ្រីស្ទថា
"ព្រះដ៏មានអំណាចព្រះចេស្ដា ព្រះបិតាដ៏អស់កល្បជានិច្ច"
តើព្រះយេស៊ូវបានមានបន្ទូលថា បើអ្នកបានឃើញទ្រង់
អ្នកនោះក៏បានឃើញព្រះវរបិតាដែរឬទេ ?


តែសេចក្តីស្លាប់មិនមែនជាចុងបញ្ចប់រឿងនោះទេ
ហោរាអេសាយបានទាយតាមការបង្ហាញរបស់ព្រះយេហូវ៉ាថា
ព្រះជន្មរបស់ព្រះសង្គ្រោះនឹងបន្តទៀតក្រោយ ពេលសុគត
(អេសាយ ៥៣:១០) ទ្រង់នឹងត្រូវបានតម្កើងឡើង
នឹងបានលើកឡើងឱ្យគង់នៅទីខ្ពស់ណាស់
(អេសាយ៥២:១៣) ទ្រង់នឹងធ្វើជាអ្នកសង្គ្រោះ
រហូតដល់ចុងបំផុតនៃផែនដី (អោសាយ ៤៩:៦)
ទ្រង់នឹងមិនអន់ថយ (អេសាយ ៤២:៤)
ព្រះមែស៊ីនឹងជាអ្នកតាំងសញ្ញាថ្មីឡើង
(អេសាយ ៤២:៦)


ហោរាបានទាយថា
ព្រះគ្រីស្ទនឹងធ្វើឱ្យមនុស្សខ្វាក់មើលឃើញ
ហើយនិងឱ្យអ្នកទោសមានសេរីភាព
(អេសាយ ៤២:៧) ទ្រង់នឹងធ្វើជាអ្នកគង្វាល
នៃជនជាតិអ៊ីស្រាអែល (អេសាយ ៤០:១១)
ហើយទ្រង់យាងមកក្រុងស៊ីយ៉ូន (ក្រុងយេរូសាឡិម)
ជាអ្នកប្រោសលោះ (អេសាយ ៥៩:២០)



ហោរាអេសាយបានទាយថា
អ៊ីស្រាអែលនឹងបដិសេធទ្រង់ (អេសាយ ៥៣:១,៣)
ព្រះវរបិតាបង្ហាញឱ្យហោរាទាំងអស់ដឹងមុនអំពីសេចក្ដីវេទនា
របស់ទ្រង់ ហើយមិត្តភក្តិរបស់ព្រះគ្រីស្ទនឹងក្បត់ទ្រង់ (ទំនុកដំកើង
៤១:៩) ដោយសារប្រាក់៣០ដួង (សាការី ១១:១២-១៣)
នៅពេលព្រះយេស៊ូវ នៅចំពោះមុខអ្នកចោទប្រកាន់
ទ្រង់មិនឆ្លើយដោះសារទេ (អេសាយ ៥៣:៧)

ទ្រង់នឹងរងរបួសហើយមានស្នាមជាំ
(អេសាយ ៥៣:៥) ហើយគេនឹង
បោចពុកចង្ការបស់ទ្រង់ (អេសាយ ៥០:៦)
គេនឹងស្តោះទឹកមាត់ដាក់ព្រះភក្ត្រទ្រង់
និងសំឡឹងមើលព្រះកាយអាក្រាតរបស់ទ្រង់ដែរ
(អេសាយ ៥០:៦)




ទ្រង់នឹងបែរខ្នងឱ្យគេវាយ (អេសាយ ៥០:៦) រហូតដល់ព្រះភក្ត្រទ្រង់មានស្នាមរបួសខ្លាំងជាងអ្នកទោសដទៃផ្សេងទៀត (អេសាយ ៥២:១៤) ហោរា សាការីមានបទទំនាយដល់យើងថា ព្រះសង្គ្រោះនឹងត្រូវគេចាក់ដោយលំពែង ហើយនិងមិត្តភក្តិរបស់ទ្រង់នឹងវាយ និងបង្កឱ្យមានរបួសនៅលើព្រះហស្ត របស់ទ្រង់ដែរ (សាការី ១២:១០, ១៣:៦-៧)


ទ្រង់នឹងដូចជាកូនចៀមដែលគេយកទៅសម្លាប់
(អេសាយ ៥៣:៧) លទ្ធផលទាំងអស់នេះគឺជា
សេចក្ដីសុគតរបស់ទ្រង់ (អេសាយ ៥៣:៨, ១២ ទំនុកដំកើង ២២:១៥)
គេនឹងយកសពទ្រង់ទៅបញ្ចុះក្នុងផ្នូររបស់បុរសអ្នកមានម្នាក់
(អេសាយ ៥៣:៩)


ប៉ុន្តែនេះមិនមែនជារឿងខ្លោចផ្សារដែលទ្រង់មិនអាចគ្រប់គ្រងបានទេ
! តើព្រះយេស៊ូវធ្លាប់មានបន្ទូលថា គ្មានអ្នកណាអាចដកជីវិតពីទ្រង់បាន
ប៉ុន្តែទ្រង់បាន ដាក់ជីវិតរបស់ទ្រង់ចុះដោយបំណងរបស់ទ្រង់មែនឬទេ ? (យ៉ូហាន
១០:១៨) ហោរាអេសាយបានទាយថា ព្រះវរបិតាសព្វព្រះហឫទ័យឱ្យព្រះគ្រីស្ទមាន
ស្នាមជាំ ព្រោះព្រះជន្មរបស់ទ្រង់ត្រូវបានថ្វាយទុកជាយញ្ញបូជាលោះអំពើបាប
(អេសាយ ៥៣:១០)


ដោយសារអំពើបាបរបស់មនុស្សទាំងអស់ទ្រង់ត្រូវបានគេវាយ (អេសាយ ៥៣:៨) ព្រោះទ្រង់បានស្ពាយអំពើបាបរបស់មនុស្សទាំងអស់ (អេសាយ ៥៣:១២) ហើយនឹងពេលទ្រង់សុគត ទ្រង់នឹងធ្វើឱ្យ មនុស្សជាច្រើនសុចរិតវិញ (អេសាយ ៥៣:១១)
អស្ចារ្យមែន!




ទ្រង់នឹងធ្វើជាអ្នកកាត់ក្តី និងវាយផែនដីដោយដំបងរាជ្យនៃព្រះឱស្ឋរបស់ទ្រង់ (អេសាយ ១១:៤) ទ្រង់នឹងគ្រប់គ្រងប្រទេសអ៊ីស្រាអែលដែលផ្លាស់ប្ដូរថ្មី នៅទីក្រុងថ្មី នៅលើផែនដីថ្មី (អេសាយ ៦៦) នោះមានថ្ងៃមួយនឹងមកដល់ គ្រប់ទាំងជង្គង់បានលត់ចុះនៅចំពោះទ្រង់ ហើយគ្រប់ទាំងអណ្ដាតបានសារភាព (អេសាយ ៤៥:២៣)


ហោរាអេសាយក៏បានទាយដែរថា
ស្ត្រីព្រហ្មចារីយម្នាក់នឹងមានគភ៌ ( អេសាយ ៧:១៤ ,
៥៩:២០) កូនរបស់នាងនឹងប្រសូត្រមក ( អេសាយ ៩:៦)
ហើយបុត្រនោះនឹងចំរើនព្រះកាយឡើង ( អេសាយ ៤៩:៧)


តាមបទទំនាយរបស់ហោរាមីកា
ទ្រង់នឹងប្រសូត្រនៅទីក្រុងបេថ្លេហិមនៃស្រុកយូដា ( មីកា ៥:២)
ដោយការនោះបានកើតរួចហើយ ។ បទទំនាយយ៉ាងច្រើន បានប្រាប់យើងថា
ទ្រង់នឹងមកពីវង្សតំណនៃហ្លួងដាវីឌ ( យេរេមា ២៣:៥-៦ ទំនុកដំកើង ៨៩)
យ៉ូសែបនិងនាងម៉ារា គេទាំងពីរជាពូជរបស់ស្តេចដាវីឌ


លោក នេះជាផ្ទះរបស់ខ្ញុំ
សូមអញ្ជើញចូល ព្រោះយប់ហើយ
ចូរសម្រាកនៅទីនេះមួយយប់សិនចុះ
ខ្ញុំចង់ឮពីការទាយរបស់ហោរាអំពីព្រះយេស៊ូវទៀត។


លោក ពួកយើងនឹងមានកិត្តិយស
បើសិនជាលោកអធិដ្ឋានសម្រាប់ការ
ទទួលទានអាហាររបស់យើង ។


មានពរហើយ
ឱព្រះជាម្ចាស់នៃយើងអើយ ដែលជា
ស្ដេចនៃសកលលោក ជាអ្នកប្រទាននំប៉័ងមកពីដី
សូមអរព្រះគុណទ្រង់សម្រាប់នំប៉័ងនេះ ។


ចូរយក
ហើយបរិភោគចុះ
ព្រះយេស៊ូវ !
គឺជាទ្រង់មែន។
លោកគ្រូ!


អ៊ូ ទ្រង់បាត់ហើយ!
ទ្រង់បាត់មែន!
នោះជាព្រះយេស៊ូវដែលបាន
នៅជាមួយយើងពេញមួយថ្ងៃ !
មិនត្រូវសង្ស័យទេ
ដែលទ្រង់បានដឹងពីបទទំនាយ
ទាំងអស់នោះ ។


ព្រះយេស៊ូវនៅមានព្រះជន្ម ! សេចក្ដីស្លាប់មិនអាចឃុំគ្រងព្រះអង្គបាន ! ទ្រង់ នៅមានព្រះជន្មរស់! ចូរយើងទៅយេរូសាឡិម វិញដើម្បីប្រាប់សាវក។

លូកា ២៤:២៨-៣២


គ្រាដដែលនោះ នៅ
ទីក្រុងយេរូសាឡិម...
ដាក់រនុកទ្វារឱ្យជាប់
ព្រោះអីពួក សង្ឃកំពុងតែខឹងខ្លាំង
ពេលដែលបាត់ សាកសពព្រះយេស៊ូវ
គេចោទយើង ជាអ្នកលួច ។
យើងលួចពី
ក្រុមទាហាននោះ
យ៉ាងម៉េច ?


ទ្រង់ធ្លាប់មានបន្ទូលពិតមែនថា ទ្រង់នឹងរស់ឡើងវិញនៅថ្ងៃទី៣ ។
ខ្ញុំមិនជឿថាទ្រង់នៅមានព្រះជន្មរស់ លុះត្រាខ្ញុំឃើញទ្រង់និងបានលូកដៃចូលក្នុងស្នាមដែកគោលនៅព្រះហស្តទ្រង់ ។


ខ្មោចលង...!
ជួយផង !
ជាព្រះយេស៊ូវ !
ចូរកុំខ្លាចអី ! ថូម៉ាស អ្នកថាមិនជឿ
បើសិនអ្នកមើលមិនឃើញ ដូច្នេះចូរអ្នកស្ទាប
ស្នាមប្រហោងដែកគោល ហើយលូកដៃចូល
ក្នុងស្នាមលំពែងម្ខាងនេះ ។


ឱព្រះជាម្ចាស់
ជាព្រះនៃទូលបង្គំអើយ !
ថូម៉ាស មានពរហើយ
ពីព្រោះអ្នកបានឃើញនឹងជឿ ប៉ុន្តែ
អស់អ្នកណាដែលមិនបានឃើញខ្ញុំ
ហើយនៅតែជឿ គេនឹងមានព្រះពរ
ច្រើនជាងទៀត ។




យ៉ូហាន ២០:២៦-៣១,
លូកា ២៤:៣៦-៤៣


អ្នកត្រូវទៅប្រាប់សិស្សខ្ញុំ ទាំងអស់ផ្សេងទៀតថា ទៅជួបខ្ញុំនៅ កាលីឡេ ខ្ញុំនឹងនិយាយជាមួយអ្នក ទាំងអស់នៅទីនោះ ។
មានការសសេរយូរមកហើយ នៅក្នុងព្រះ បន្ទូលដែលព្រះគ្រីស្ទនឹងរងទុក្ខសម្រាប់អំពើបាបរបស់អ្នក ហើយទ្រង់នឹងរស់ឡើងវិញពីសេចក្ដីស្លាប់ក្នុងថ្ងៃទី៣ ហើយដំណឹងល្អនឹងបានផ្សព្វផ្សាយក្នុងព្រះនាមទ្រង់គ្រប់ ទាំងសាសន៍ដោយចាប់ផ្ដើមពីក្រុងយេរូសាឡិម ។


ប្រហែល៤០ថ្ងៃក្រោយមក ព្រះយេស៊ូវ កំពុងបង្រៀនសិស្សក្រៅទីក្រុងយេរូសាឡិម ។
គ្រប់ទាំងអំណាចទាំងអស់បានប្រទាន
មកខ្ញុំ ទាំងនៅឋានសួគ៌និងផែនដី ចូរទៅបង្រៀន
គ្រប់សាសន៍ទាំងអស់ ព្រមទាំងធ្វើពិធីជ្រមុជទឹកឱ្យគេដោយ
នូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រានិងព្រះវិញ្ញាណបរិសុទ្ធចុះ
ហើយបង្រៀនឱ្យគេកាន់តាមគ្រប់ទាំងសេចក្ដីដែលខ្ញុំបានបង្គាប់
អ្នករាល់គ្នាផង ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នក
រាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប ។




ម៉ាថាយ ២៨:១៨-២០, លូកា ២៤:៤៤-៤៩, យ៉ូហាន ១៤:២-៤


ចូរទៅទីក្រុងយេរូសាឡិម ហើយរងចាំព្រះវិញ្ញាណបរិសុទ្ធ មកសណ្ឋិតលើអ្នក ទ្រង់នឹងប្រទានអំណាចឱ្យអ្នកនិយាយក្នុងនាមរបស់ខ្ញុំ។
ទ្រង់កំពុងឡើងលើ !
ទ្រង់ទៅបាត់ហើយ ទ្រង់ត្រឡប់ទៅឋានសួគ៌វិញ។


ខ្ញុំគង់នៅជាមួយអ្នកគ្រប់ពេលវេលារហូតដល់ចុងបញ្ចប់ផែនដី ។
ទ្រង់កំពុងយាងទៅឯព្រះវរបិតាទ្រង់វិញ ។


នៅពេលពួកគេកំពុងមើលទៅ លើ ភ្លាមនោះមានទេវតាពីរអង្គ លេចមកហើយពោលថា...
តើហេតុអ្វីក៏ពួក អ្នកនៅតែមើលទៅ លើមេឃទៀត?
ស្អីហ្នឹង ? តើនោះជាអ្នកណា ?
នោះជាទេវតា២អង្គ ដែលខ្ញុំបានឃើញនៅឯផ្នូរ ។


នៅថ្ងៃណាមួយព្រះយេស៊ូវនឹង ត្រឡប់មកវិញលើពពក ដូចដែលអ្នក ទាំងអស់គ្នាឃើញទ្រង់ឡើងទៅ ។
ទ្រង់បានត្រឡប់ទៅ ព្រះបិតាទ្រង់នៅឋានសួគ៌ វិញហើយ ។
ចូរត្រឡប់ទៅទីក្រុង យេរូសាឡិមវិញ ដើម្បីរងចាំ ព្រះវិញ្ញាណបរិសុទ្ធចុះ ។
លូកា ២៤:៤៩-៥១, កិច្ចការ ១:៣-១១



ពួកសាវកព្រះយេស៊ូវបានទៅទីក្រុងយេរូសាឡិមវិញ ដូចទ្រង់បានបង្គាប់ ហើយនៅទីនោះ ពួកគេបានបន្តអធិដ្ឋានអស់រយៈពេល១០ថ្ងៃនិងរងចាំការសន្យាពីអំណាចដែលនឹងមកពីឋានសួគ៌ដ៏ខ្ពស់ ពួកគេមានការភ័យខ្លាចក្នុងការនិយាយដោយចំហរ ដែលព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ គេខ្លាចមានទោសប្រហារជីវិតដល់ពួកគេ។


កន្លែងដែលពួកគេកំពុងអធិដ្ឋានបានរញ្ជួយ
និងមានខ្យល់យ៉ាងខ្លាំងឆ្លងកាត់បន្ទប់នោះ ហើយ
មានអណ្តាតភ្លើងមកសណ្ឋិតលើពួកគេម្នាក់ៗ។


ពួកគេបានពោរពេញដោយព្រះវិញ្ញាណ
បរិសុទ្ធ ហើយចាប់ផ្ដើមសរសើរតម្កើងព្រះ
ក្នុងភាសារផ្សេងៗដែលពួកគេមិនធ្លាប់ចេះ។


នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធសណ្ឋិតលើពួកគេ បានធ្វើ ឱ្យពួកគេលែងខ្លាចមនុស្សទៀត
ហើយពួកគេចេញទៅខាង ក្រៅនឹងសសើរតម្កើងព្រះអង្គនៅទីប្រជុំជន។
មានពរហើយព្រះអម្ចាស់ និងព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ របស់យើងរាល់គ្នា !
ខ្ញុំគិតថា ប្រហែលជាពួកគេស្រវឹង ប៉ុន្តែគេកំពុងតែនិយាយភាសារបស់ ខ្ញុំយ៉ាងល្អឥតខ្ចោះ គ្មានចម្លែក បន្តិចសោះ។


ពួកអ្នកជនជាតិអ៊ីស្រាអែលអើយ! អ្នកបានឃើញ
ព្រះយេស៊ូវធ្វើការអស្ចារ្យជាច្រើន ទាំងនេះគឺជាភស្តុតាងដែល
ព្រះអម្ចាស់គង់ជាមួយទ្រង់ ទោះបីពួកអ្នកបានឆ្កាងទ្រង់ក៏ដោយ
ក៏ព្រះវរបិតាបានប្រោសទ្រង់ឱ្យរស់ពីសេចក្តីស្លាប់ផងដែរ ។


កិច្ចការ ១:១២-១៤, ២:១-១៣, ៣២, ៣៦
ពួកគេកំពុងតែនិយាយ
ភាសាខ្ញុំដែរ តើពួកបុរសនេះចេះ ភាសាទាំងអស់នេះបានល្អយ៉ាង
ម៉េច ? ព្រោះគេជាមនុស្សមាន ចំណេះដឹងទាប ។


១០០០ឆ្នាំមុន
ស្តេចដាវីឌបានទាយពីព្រះសង្គ្រោះថា
“ដ្បិតទ្រង់នឹងមិនទុកព្រលឹងទូលបង្គំ ឱ្យជាប់នៅក្នុងស្ថានឃុំព្រលឹងមនុស្ស
ស្លាប់ទេ ក៏មិនឱ្យអ្នកបរិសុទ្ធរបស់ទ្រង់ឃើញសេចក្តីស្អុយរលួយដែរ”។


ដូច្នេះចូរឱ្យពួកវង្សអ៊ីស្រាអែលទាំងអស់ដឹង
ប្រាកដថា ព្រះអម្ចាស់បានលើកព្រះយេស៊ូវនេះ
ដែលពួកអ្នករាល់គ្នា បានឆ្កាង
ឱ្យទ្រង់ធ្វើជាព្រះអម្ចាស់ហើយជាព្រះគ្រីស្ទផង។


តើយើងត្រូវធ្វើដូចម្ដេច? ដោយយើងបានឆ្កាងព្រះគ្រិស្ទ ។
ត្រូវប្រែចិត្តនឹងជឿលើព្រះយេស៊ូវ នោះទ្រង់នឹងអត់ឱនទោសអំពើបាបរបស់អ្នក ហើយអ្នកនឹងទទួលនូវអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ បន្ទាប់មកត្រូវប្រតិបត្តិតាមទ្រង់ដោយទទួលពិធីជ្រមុជទឹក ។


ព្រះយេស៊ូវជាព្រះអម្ចាស់!
ខ្ញុំជឿលើព្រះយេស៊ូវ
សូមជ្រមុជឱ្យខ្ញុំដែរ !
ពួកគេដែលទទួលជឿបន្ទូលនៃព្រះដោយអំណរ បានទទួល ពិធីជ្រមុជទឹក
ហើយថ្ងៃដដែលនោះមានមនុស្សប្រហែល ជាងពាពាន់នាក់កើនឡើងថែមទៀត ។


ជាច្រើនខែក្រោយមក...
ខ្ញុំមានអារម្មណ៍ហាក់ដូចជា ព្រះយេស៊ូវទើបតែនៅជាមួយ យើងពីម្សិលមិញ ។
បាទ ប៉ុន្តែអ្នកដឹងទេថា ឥឡូវនេះ ខ្ញុំពិតជាមានអារម្មណ៍ថា ទ្រង់គង់នៅជាមួយខ្ញុំខ្លាំងជាងពេលមុនដែល យើងដើរជាមួយទ្រង់ទៅទៀត ។
ឥឡូវនេះមានមនុស្សរាប់ពាន់ នាក់តាមព្រះយេស៊ូវគ្រីស្ទ ហើយ កើនឡើងរៀងរាល់ម៉ោង ។
ទំនុកដំកើង ២, ១៦:២, កិច្ចការ ២:២៧, ៣៧-៤១


លោកម្ចាស់អើយ សូម ដាក់ទានឱ្យអ្នកពិការក្រដូចខ្ញុំ មួយកាក់មក ។
ពេត្រុស ខ្ញុំឥតមាន លុយសោះ តើអ្នកមាន មួយកាក់ទេ ?
អត់ទេ! ប៉ុន្តែតាំងពីមាន ព្រះវិញ្ញាណសណ្ឋិតលើយើងមក យើង មានអំណោយទានខ្លះឱ្យដល់គាត់ ។


ខ្ញុំមិនមានប្រាក់ឬមាស នោះទេ ប៉ុន្តែអ្វីដែលខ្ញុំមាននោះ ខ្ញុំនឹងឱ្យដល់អ្នក ដោយសារ ព្រះនាមព្រះយេស៊ូវគ្រីស្ទចូរអ្នក ក្រោកឡើងដើរទៅចុះ ។
កុំលេងសើចនឹងវា ជើងវា ពិការតាំងពីកំណើតមក ជើង របស់វាស្វិតដើរលែងកើត ។


ព្រះយេស៊ូវគ្រីស្ទ បានប្រោសអ្នកឱ្យជា ពេញលក្ខណៈ ។


អឺយ៉ា!
ឱព្រះដ៏មានអំណាច ព្រះចេស្ដា !
ជើងរបស់គាត់កំពុងជាត្រឹមត្រូវវិញ !


ខ្ញុំមិនគួរជឿ ប៉ុន្តែអ្នកពិការនោះអាចដើររួច !
សិរីល្អមានដល់ព្រះអង្គ ! អរគុណព្រះយេស៊ូវ !
មិនមែនទេ គាត់កំពុងលោត
កិច្ចការ ៣:១-១១


នោះគឺបុរសពិការ ពីមុនជើងរបស់គាត់ស្វិត នៅសល់តែឆ្អឹង ។
ពួកគេថា ជើងគាត់បានជាដោយឈ្មោះយេស៊ូវ គឺម្នាក់ដែលបានឆ្កាង ។
ហេតុអ្វីក៏អ្នកមើលមកយើងដូចជាយើងបានធ្វើការ អស្ចារ្យនេះ ? ព្រះនៃអ័ប្រាហាំ អ៊ីសាក និង យ៉ាកុប ត្រូវបានលើកតម្កើងព្រះរាជបុត្រារបស់ទ្រង់ គឺជា ព្រះយេស៊ូវដែលអ្នកបានឆ្កាង ។


អ្នកបានសម្លាប់ព្រះជាម្ចាស់នៃជីវិត
ប៉ុន្តែព្រះវរបិតាបានប្រោសឱ្យទ្រង់មានព្រះជន្មរស់
ពីសុគតឡើងវិញ យើងបានឃើញទ្រង់មាន
ព្រះជន្មរស់មែន បុរសនេះបានជាឡើងវិញដោយ
មានជំនឿក្នុងព្រះនាមព្រះយេស៊ូវ ។


ខ្ញុំយល់ថា ពួកអ្នកបានឆ្កាងព្រះយេស៊ូវ ដោយខ្វះការយល់ដឹង តែហោរាបានឱ្យដឹងមុន ថា រឿងរ៉ាវទាំងនេះនឹងកើតឡើង ។
អ្នកទាំងអស់គ្នាស្គាល់ខ្ញុំ មានតែព្រះអង្គទេដែលអាចប្រទានឱ្យជើងខ្ញុំជាឡើងវិញ ចូរជឿហើយតាមព្រះយេស៊ូវចុះ ។


ចូរកែប្រែចិត្តគំនិតតាមព្រះ
យេស៊ូវចុះ ហើយធ្វើជាសាវករបស់
ទ្រង់ នោះអំពើបាបរបស់អ្នកនឹង
បានលុបបំបាត់ ។

ពួកមេដឹកនាំសាសនា ដែល
បានឆ្កាងព្រះគ្រីស្ទបានបញ្ជូន ពួកទាហានមកចាប់
ពេត្រុស និង យ៉ូហាន ។




កិច្ចការ ៣:១២, ១៤-១៩, ៤:១-៣


នោះជាការអស្ចារ្យ
ដូចដែល ព្រះយេស៊ូវបានធ្វើនៅពេល
ទ្រង់នៅទីនេះ ។
ខ្ញុំមានអ្នកជិតខាងដែលអះអាងថា
គាត់បានឃើញព្រះយេស៊ូវមានព្រះជន្ម
រស់បន្ទាប់ពីទ្រង់សុគត មានពួកគេថា
ទ្រង់បានបង្ហាញអង្គទ្រង់ឱ្យមនុស្សជាង
៥០០នាក់ឃើញក្នុងពេលតែមួយ ។


ឥឡូវពួកគេចាប់អ្នកខ្វិនដែលអាចដើរបានថាខុសច្បាប់ដែរ ។
ខ្ញុំនឹងទៅរកពួកសាវកផ្សេងដើម្បីសួរទៀត ។


ខ្ញុំបានគិតថា យើងបាន កំចាត់ពួកក្បត់សាសនានោះហើយ នៅពេលដែលយើងបានឆ្កាងអ្នកដឹកនាំរបស់ពួកវា ។
ពួកវាបាន អះអាងថា យេស៊ូវ រស់ឡើងវិញ ។
ដូច្នេះយើងនឹងសម្លាប់វាម្តងទៀត ហើយនឹងអ្នកដើរតាមវាទាំងអស់ដែរ ។
កិច្ចការ ៤:៣-៦


អើ ល្អហើយ បន្តិច
ទៀតអាពីរនាក់នេះនឹងទៅ
ជួបវានៅទីនោះដែរ ។
ពួកវាថា ឥឡូវវានៅ
ឯឋានសួគ៌ជាមួយបិតាវា ។


យើងបានដឹងថា បុរសនេះ
បានពិការតាំងពីកំណើតមក ។ តើ
ឯងអាចធ្វើឱ្យវាជាយ៉ាងម៉េច ? តើ
ឯងធ្វើការនេះក្នុងនាមណា ?
បុរសនេះហើយបានជាដោយនូវព្រះនាម
ព្រះយេស៊ូវគ្រីស្ទនៃស្រុកណាសារ៉ែត
ដែលលោកទាំងអស់គ្នា បានឆ្កាងទ្រង់
តែព្រះបិតាបានប្រោសឱ្យមានព្រះជន្មរស់ពីសុគត
ឡើងវិញ ចូរនឹកចាំខគម្ពីរថា
“ថ្មដែលពួកជាងសង់ផ្ទះបាន ចោលចេញ
នោះបានត្រឡប់ជាថ្មជ្រុងយ៉ាងឯកហើយ” ។


ហើយគ្មានសេចក្ដីសង្គ្រោះដោយសារ អ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាន នាមណាទៀតបានប្រទានមកមនុស្សលោកឱ្យ យើងរាល់គ្នាបានសង្គ្រោះនោះឡើយ ។


តាមពិតពួកបុរសទាំងនេះ
គឺគ្មានចំណេះដឹង
ពួកគេមិនដែលរៀន សូត្រទេ
តែពួកគេនិយាយតាមសំដី
ហោរាយ៉ាងងាយស្រួល ។


គ្មានប្រយោជន៍ក្នុងការមិនទទួលស្គាល់ភាពអស្ចារ្យនេះទេ មនុស្សគ្រប់គ្នាដឹងថា វាបានជាសះស្បើយ ហើយពួកគេដឹងទៀតថា វាជាសាវករបស់យេស៊ូវដែលធ្វើការនេះក្នុងឈ្មោះវា។ ឥឡូវយើងមានបញ្ហាធំ។
ខ្ញុំចំណាំពួកវាបាន ពួកវាបានដើរជាមួយយេស៊ូវមែន។


ដេញវាចេញពីទី
នេះឱ្យអស់ទៅ!
បើគួរគប្បីនៅចំពោះព្រះ
ឱ្យ យើងខ្ញុំស្ដាប់តាមលោករាល់គ្នាជាជាង
ស្ដាប់ព្រះ នោះសូមពិចារណាចុះ ។ ប៉ុន្តែ
យើងមិនអាចឈប់និយាយអំពីអ្វីដែល
យើងបានឃើញនិងឮនោះទេ ។




ទំនុកដំកើង ១១៨:២២, កិច្ចការ ៤:៧-២១

បយកង្អកដឹកនាមសាសនាឃិរសាងេល និកាយសាដុសិ៊ បយកកេមិនចៀមានការរស់លើងវិញបិសេចក្តិស្លាប់តេ

( ម៉ាថាយ ២២:២៣, កិច្ចការ ២៣:៦-៨)


ដំណឹងល្អបានផ្សព្វផ្សាយពាសពេញប្រទេស
អ៊ីស្រាអែល មានមនុស្សជាច្រើនបានជឿព្រះ
យេស៊ូវ និង ទទួលធ្វើពិធីជ្រមុជទឹក។
ព្រះយេស៊ូវមានព្រះជន្មរស់ពី
សុគតឡើងវិញ ហើយទ្រង់គង់នៅ
ជាមួយយើងសព្វថ្ងៃនេះដែរ។


ហើយពួកជំនុំព្រះយេស៊ូវក្លាយ
ជាមហាគ្រួសារដែលមានសមាជិក
រាប់ពាន់នាក់ ពេញដោយសេចក្ដី
ស្រឡាញ់ និង ភាពសុខសាន្ត។
តើអ្នកបានឮដំណឹងល្អ
អំពីព្រះយេស៊ូវគ្រីស្ទទេ ?


នៅក្នុងពួកជំនុំព្រះយេស៊ូវ
គេបានផ្ដល់កិត្តិយសនិងភាព
គួរសមដល់ពួកស្ត្រី ។
តាំងពីក្រុមគ្រួសារខ្ញុំបាន
ជឿលើព្រះយេស៊ូវគ្រីស្ទ នោះមាន
សុភមង្គលនៅក្នុងគ្រួសារជាលើក
ដំបូងបង្អស់ ។


កិច្ចការ ១៣៖៣០-៣២, ៤៖១០
ពួកគ្រីស្ទានពោរពេញដោយ
ក្តីអំណរ ហើយពួកគេក៏ច្រៀង
ក្នុងពេលធ្វើការ ។
ពួកគ្រីស្ទានមានការកើនឡើងរាប់ពាន់នាក់ ហើយ
ពួកគេបន្តចែកគ្នានូវអ្វីដែលគេមាន ។ រាល់ថ្ងៃគេ
បានផ្សាយដំណឹងល្អពីផ្ទះមួយទៅផ្ទះមួយ ហើយ
ដល់មនុស្សដែលគេជួបនៅតាមផ្លូវផងដែរ ។


ពួកជនជាតិអ៊ីស្រាអែលទាំងអស់គ្នា
ត្រូវ ដឹងថា
ព្រះអម្ចាស់បានប្រាប់ពួកឰយុកោរបស់យើងថា
ពូជ របស់គេត្រូវបានអាស្រ័យនៅស្រុកដទៃ
ហើយរស់នៅទីនោះ ជាទាសកររយៈពេល៤០០ឆ្នាំ
បន្ទាប់មកព្រះទ្រង់មានបន្ទូលថា
នឹងកាត់ទោសសាសន៍ដទៃនោះ
ហើយនឹងរំដោះប្រជារាស្ត្រ ទ្រង់
ឱ្យនៅទឹកដីដែលព្រះបានឱ្យអ័ប្រាហាំ។


ប៉ុន្តែស្ដេចសាឡូម៉ូនបានសង់ដំណាក់របស់ព្រះមួយ
តែព្រះអម្ចាស់មិនគង់នៅក្នុងវិហារដែលធ្វើដោយដៃមនុស្ស
នោះទេ ដូចហោរាបានទាយ “ផ្ទៃមេឃជាបល្ល័ង្ករបស់អញ ហើយ
ផែនដីជាកំណល់កល់ជើងអញ ដូច្នេះតើឯងរាល់គ្នានឹងសង់វិហារ
យ៉ាងណាឱ្យអញ តើមានកន្លែងណាសម្រាប់ជាទីសម្រាកដល់អញ
តើមិនមែនដៃអញដែលបង្កើតរបស់ទាំងនេះទេឬអី” ។


ប៉ុន្តែស្តេចសាឡូម៉ូនបានសង់ដំណាក់របស់ព្រះមួយ
តែព្រះអម្ចាស់មិនគង់នៅក្នុងវិហារដែលធ្វើដោយដៃមនុស្ស
នោះទេ ដូចហោរាបានទាយ “ផ្ទៃមេឃជាបល្ល័ង្ករបស់អញ
ហើយ ផែនដីជាកំណល់កល់ជើងអញ
ដូច្នេះតើឯងរាល់គ្នានឹងសង់វិហារ យ៉ាងណាឱ្យអញ
តើមានកន្លែងណាសម្រាប់ជាទីសម្រាកដល់អញ
តើមិនមែនដៃអញដែលបង្កើតរបស់ទាំងនេះទេឬអី” ។
ស្ទេផាន
កុំធ្វើ ដូចឆ្កួតអញ្ចឹង ។
ឯងនិយាយជំទាស់
នឹងវិហាររបស់យើង!

អេសាយ ៦៦:១, កិច្ចការ ៧:១-៥៧




ស្ទេផាន អ្នកបានតាំងខ្លួនថា ជាជនជាតិយូដាយ៉ាងម៉េច បើនិយាយដូច្នេះ ?
តើអ្នកចង់បំផ្លាញក្រឹត្យវិន័យនិងប្រពៃណី របស់យើងហើយយកអ្វីមកដាក់ជំនួសវិញ ? តើដាក់បុរសស្លាប់ម្នាក់ ដែលគ្មាននរណាបាន ឃើញតាំងពីពួករ៉ូមបានឆ្កាងវាមែនឬ ?


មើលន៎ ខ្ញុំបានឃើញមេឃបើកចំហ
ហើយកូនមនុស្សកំពុងឈរខាងស្តាំព្រះហស្ត
នៃព្រះ។ អូ៎ មានសិរីល្អម្ល៉េះទេ !


បិទត្រចៀកឯង
កុំស្ដាប់ សំដីប្រមាថបែបនេះ!
វាសមនឹងស្លាប់!
យកវាចេញពីទីក្រុង
ហើយ គប់នឹងដុំថ្មឱ្យវាងាប់ទៅ !


អា៎ប្រមាថ !
យើងបានឆ្កាងយេស៊ូវ ប៉ុន្តែចំពោះឯង យើង គប់នឹងដុំថ្ម ។
វាព្យាយាមបំផ្លាញ សាសនារបស់យើង !
ព្រះយេស៊ូវទ្រង់នៅតែជា ព្រះអម្ចាស់ ទោះបីអ្នកបាន សម្លាប់ខ្ញុំដោយដុំថ្មក៏ដោយ ។


វាបានប្រមាថសាសនារបស់ យើង វាគួរតែនឹងស្លាប់ សូល តើអាជ្ញាធមិ អនុញ្ញាតឱ្យយើងធ្វើការនេះទេ ?
ខ្ញុំនឹងយល់ព្រមចំពោះការសម្លាប់ វាបាន វាជាសាមាជិកម្នាក់ដែលដើរតាម យេស៊ូវពីស្រុកណាសារ៉ែត ដែលបានស្លាប់ ហើយ យើងត្រូវតែបញ្ឈប់ការប្រមាថនេះ ។ ចូរគប់សម្លាប់វានឹងដុំថ្មទៅ ។


សូល សូមជួយ
មើលអាវខ្ញុំផង ។
ឱព្រះជាម្ចាស់យេស៊ូវ ! សូមទទួល
ព្រលឹងវិញ្ញាណរបស់ទូលបង្គំ ហើយសូម
កុំដាក់ទោសពួកគេចំពោះការនេះ ។
កិច្ចការ ៧:៥៨-៥៩


ភូ
ភូស
ស!!



ហើយនៅពេលនោះគឺជាពេលដែលមានការបៀតបៀនយ៉ាងខ្លាំង
ចំពោះពួកក្រុមជំនុំនៅទីក្រុងយេរូសាឡិម អ្នកជឿព្រះទាំងអស់បាន
ចាកចេញពីទីក្រុង លើកលែងតែពួកសាវកទាំង១២នាក់ប៉ុណ្ណោះ។


នេះគ្រាន់តែជាការចាប់ផ្ដើមប៉ុណ្ណោះ!
ត្រូវតែបំបាត់ពួកអាគ្រីស្ទបរិស័ទទៅ !
សម្លាប់អាប្រមាថ នេះទៅ !


សូល ជាពួកផារិស៊ីបានទាស់
ប្រឆាំងនឹងពួកក្រុមជំនុំ ហើយបាន
ចូលគ្រប់ផ្ទះ នឹងចាប់មនុស្សទាំង
ប្រុសទាំងស្រីដាក់គុក ។
មានអ្នកដើរតាមគ្រីស្ទ នៅក្នុងផ្ទះនោះទៀតទេ?
សូមកុំធ្វើបាបប៉ាខ្ញុំអី !
ចាប់ស្រីនោះដែរ
កិច្ចការ ៧:៥៩ - ៨:៣


ពេលដដែលនោះ នៅកន្លែងផ្សេងមានគ្រីស្ទាន
ម្នាក់ឈ្មោះ ភីលីព កំពុងអធិដ្ឋាន មានទេវតា
មួយអង្គបានពោលមកគាត់ថា...
ភីលីព
ចូរក្រោកឡើង ហើយ
ទៅទិសខាងត្បូងតាមផ្លូវធំ ដែល
ចុះពីយេរូសាឡិមទៅក្រុងកាសា ។


ខ្ញុំមិនដឹងថាហេតុអ្វីបានជាទ្រង់ឱ្យខ្ញុំចុះទៅទីនោះ ប៉ុន្តែខ្ញុំនឹងទៅកន្លែងណាដែលទ្រង់ប្រាប់ឱ្យទៅ។


នេះមើលទៅដូចជាកន្លែងហ្នឹងហើយ តើខ្ញុំត្រូវធ្វើអ្វីទៀតព្រះអង្គ?


ព្រះអង្គ
តើទ្រង់
ត្រូវការអ្វីទៀត ?


មានអ្នកធ្វើដំណើរផ្លូវឆ្ងាយមួយក្រុម! ព្រះអង្គ តើនេះជាហេតុផលដែលទ្រង់ឱ្យទូលបង្គំមកទីនេះឬ ? តើមាននរណាម្នាក់នៅក្រុមនោះដែលព្រះអង្គបានរើសសម្រាប់ទ្រង់ឬ ?
ចូរទៅចូលរួមជាមួយការធ្វើដំណើររបស់គេចុះ ?
កិច្ចការ ៨:២៦-២៩



នោះមានបុរសម្នាក់ ដែលមានអំណាចល្បី ដែលបំរើ មហាក្សត្រីយ៍នៃប្រទេសអេធីយ៉ូពី
គាត់ជាមន្ត្រីម្នាក់ ត្រួតត្រាលើអស់ទាំងព្រះរាជទ្រព្យ គាត់បានទៅ ទីក្រុងយេរូសាឡិម
ដើម្បីថ្វាយបង្គំក្នុងរបៀប ជាជនជាតិយូដា ឥឡូវនេះបានត្រឡប់ទៅ
អេធីយ៉ូពីវិញ ហើយគាត់កំពុងអានព្រះគម្ពីរ ។


ទ្រង់ត្រូវគេនាំទៅដូចជាដឹកចៀមទៅសំលាប់
ទ្រង់មិនបានហើបព្រះឱស្ឋសោះ ដូចជាកូនចៀមដែលគ
នៅមុខអ្នកកាត់រោមវា ដ្បិតគេបានដកព្រះជន្មទ្រង់
ពីផែនដីចេញហើយ...


ខ្ញុំបានឮលោកកំពុងតែអាន គម្ពីរហោរាអេសាយ តើលោកយល់ នូវអ្វីដែលកំពុងអាននោះទេ ?
អ្នកបានដឹងនូវអ្វីដែលខ្ញុំកំពុង អាន ! តែខ្ញុំមិនអាចយល់ទេ បើសិន គ្មានអ្នកណាម្នាក់ជួយពន្យល់ខ្ញុំ សូម ឡើងមកជិះជាមួយខ្ញុំ ។


តើលោកទើបតែមកពីយេរូសាឡិមឬ ?
បាទហ្នឹងហើយ ខ្ញុំបានទៅទីនោះដើម្បីថ្វាយបង្គំ។ សាសនារបស់ប្រទេសខ្ញុំមិនដែលបាននាំសេចក្ដីសុខសាន្ដមកដល់ខ្ញុំសោះ ព្រះហាក់ដូចជានៅឆ្ងាយពីខ្ញុំណាស់។


ខ្ញុំធ្លាប់អានពីព្រះមែស៊ីដែលបានសន្យាហើយ ឥឡូវនេះពេលខ្ញុំបានទៅយេរូសាឡិម មានមនុស្ស រាប់ពាន់នាក់ប្រកាសថា ទ្រង់បានយាងមកហើយ តែទ្រង់ត្រូវបានគេឆ្កាង បន្ទាប់មកទ្រង់មាន ព្រះជន្មរស់ពីសុគតឡើងវិញ។
ខ្ញុំកំពុងស្រាវជ្រាវខគម្ពីរដែលហោរាបានសរសេរ ដើម្បីដឹងថា តើការនេះបានទាយពិតមែនឬអត់។ តើក្នុងខគម្ពីរនេះហោរាអេសាយបានទាយពីខ្លួនគាត់ឬ ពីអ្នកផ្សេង ? តើអ្នកដឹងទេ ?
អេសាយ ៥៣, កិច្ចការ ៨:២៧, ៣០-៣៤


លោកទើបតែមកពីទីក្រុងយេរូសាឡិម ដូច្នេះលោកដឹងថា ទោះបីព្រះយេស៊ូវ បានធ្វើការអស្ចារ្យយ៉ាងខ្លាំងក៏ដោយ ក៏អ្នកដឹកនាំរបស់យើងបានបោះបង់ចោលទ្រង់ដែរ។


ដូចលោកបានដឹង
គម្ពីរអេសាយត្រូវបាន
សរសេរឡើងជិត៨០០ឆ្នាំកន្លងមកហើយ ។
ជំពូក៥៣ទាំងអស់នេះជាបទទំនាយតែមួយ
ក្នុងចំណោមបទទំនាយជាច្រើន ដែលទាយពី
ព្រះមែស៊ី ហើយបានចែងថា “ទ្រង់ត្រូវគេមើល
ងាយហើយត្រូវមនុស្សបោះបង់ចោល”




ខ៧ បានចែងថា ពេលទ្រង់ឈរ
ពីមុខអ្នកជំនុំជំរះ ទ្រង់នឹងមិន
និយាយការពារអង្គទ្រង់ទេ ។

ហោរាអេសាយបានទាយថា ព្រះយេស៊ូវនឹង
រងរបួសក្នុងការសងអំពើបាបរបស់យើង ហើយ
ខ៥បានចែងថា ទោសនៃអំពើបាបដែលយើងសម
នឹងទទួល នោះនឹងធ្លាក់លើព្រះយេស៊ូវ ។


ជាពិសេសខ្ញុំពេញចិត្តខ៦បានចែងថា
“យើងទាំងអស់គ្នា  បានទាសចេញដូចចៀម
គឺយើងបានឃរចេញទៅតាមផ្លូវយើងរៀងខ្លួន
ហើយព្រះយេហូវ៉ាបានទម្លាក់អំពើទុច្ចរិតរបស់យើងទាំងអស់គ្នាទៅលើទ្រង់”
នោះឱ្យយើងដឹងថា មនុស្សគ្រប់គ្នាបានបែកចេញពីបំណងរបស់ព្រះ ហើយបាន
ទៅតាមផ្លូវនៃអំពើបាបរបស់ខ្លួន តែព្រះវរបិតាបានដាក់អំពើបាបរបស់យើង
លើព្រះយេស៊ូវ ដូច្នេះនៅពេលទ្រង់សុគត ទ្រង់បានសងជំនួសនូវការ
មិនស្ដាប់បង្គាប់របស់យើងទាំងអស់គ្នា។
បាប


ខ៨ បានចែងថា
គេបានយកទ្រង់ចេញពីគុកនិងបាន
ធ្វើគតទ្រង់ ដើម្បី សងនូវ
អំពើរំលងរបស់រាស្ត្រទ្រង់។
បាប


ខ៩ បានចែងថា ព្រះ
យេស៊ូវត្រូវបានសុគតជាមួយពួក
អាក្រក់ នឹងបានបញ្ចុះព្រះសពទ្រង់
នៅក្នុងផ្នូររបស់អ្នកមាន ។
INRI
បាប
ខ៩ បានបន្តទៀតថា ព្រះយេស៊ូវ
ឥតប្រព្រឹត្តអំពើបាបដូចមនុស្សទេ ហើយខ១០បាន
ចែងថា ព្រះវរបិតាសព្វព្រះហឫទ័យឱ្យព្រះយេស៊ូវ
មានស្នាមជាំ ហើយឱ្យឈឺចាប់ ពីព្រោះព្រះជន្មទ្រង់
ត្រូវបានថ្វាយជាយញ្ញបូជាលោះបាប ។


ខ១0 បានថែងទៀតអំពីការរស់
ឡើងវិញរបស់ទ្រង់និងកិច្ចការដែលទ្រង់
ត្រូវធ្វើបន្ទាប់ទៀត។
អេសាយ ៥៣:៣-១០, កិច្ចការ ៨:៣៥,
រ៉ូម ២:១៦, កូរិនថូសទី២, ៥:២១


ហើយមានបទទំនាយជាច្រើនផ្សេងទៀតបាន ចែងថា បន្ទាប់ពីការរស់ឡើងវិញរបស់ព្រះយេស៊ូវ ទ្រង់នឹងគង់លើបល្ល័ង្ក ។ បន្ទាប់ពីយើងស្លាប់ យើងនឹងឈរនៅចំពោះព្រះភក្រ្តទ្រង់ នឹងរៀបរាប់នូវការដែលបានប្រព្រឹត្តនៃជីវិតយើង ។


ខ្ញុំបានឮពួកអាចារ្យហើយនិងពួកសង្ឃ
និយាយអំពីបទទំនាយនៃព្រះមែស៊ីជាច្រើនដង
ហេតុអ្វីពួកគេជាច្រើនបដិសេធទ្រង់?
ពួកអាចារ្យហើយនិងពួកសង្ឃខ្លះគេបានទទួលស្គាល់ទ្រង់ ប៉ុន្តែខ្លះ
មានការអាក់អន់ចិត្តដោយទ្រង់បានបង្ហាញពីសេចក្ដីកំពុតរបស់គេ ពួកគេ
ចង់បានព្រះសង្គ្រោះដែលនឹងសម្លាប់ពួកទាហានរ៉ូម ពួកគេមិនចង់បានព្រះ
ដែលចង្អុលបង្ហាញអំពើបាបរបស់ពួកគេទេ ពួកគេចង់គ្រប់គ្រងលើនគរមួយ
ប៉ុន្តែមិនចង់ឱ្យព្រះគ្រប់គ្រងលើចិត្តរបស់ពួកគេទេ។


តើមានបទទំនាយផ្សេងទៀត ដែលព្រះយេស៊ូវបានបំពេញឬទេ ?
ទំនុកដំកើង២២បាន ទាយថា ទ្រង់នឹងសុគត ដោយគេឆ្កាង ។
ប៉ុន្តែ គម្ពីរទំនុកដំកើងបានសរសេរ កាលពី១000ឆ្នាំមុន មនុស្សដែលមាន ទោសធ្ងន់ៗគេមិនបានដាក់ទោសដោយ របៀបឆ្កាងទេ តើនេះមែនឬអត់ ?


បាទ តែទ្រង់ជ្រាបទាំងអស់មុនពេលវា នឹងកើតឡើង មានបទទំនាយជាង៣៤០ ដែលបាន ទាយអំពីព្រះមែស៊ី នេះហើយជាមូលហេតុដែលយើងដឹង ថា ព្រះយេស៊ូវ គឺជាព្រះពិតប្រាកដតែមួយអង្គ ដែលព្រះវរបិតាបានបញ្ជូនមក ។



ទំនុកដំកើង ២២:១៦ បានឱ្យដឹងថា

ព្រះហស្ថនិងព្រះបាទរបស់ទ្រង់ត្រូវបានគេចាក់ទម្លុះ-ការនេះត្រូវ
បានបំពេញ នូវពេលគេឆ្កាងព្រះយេស៊ូវដោយទម្លុះនឹងដែកគោល

ទំនុកដំកើង ២២:១៤-១៥ បានឱ្យដឹងថា

ទ្រង់បានស្រេកហើយគ្រប់ទាំងឆ្អឹងរបស់ទ្រង់ត្រូវបានដាច់ចេញពីសន្លាក់ពេលដែលទ្រង់សុគត

ប៉ុន្តែ ទំនុកដំកើង ៣៤:២០ បានប្រាប់យើងថា

គ្មានឆ្អឹងមួយណាត្រូវបានបាក់នៅពេលគេឆ្កាងទ្រង់ ។ ដូចអ្នកបាន ដឹងហើយ
នោះគឺជាទម្លាប់ត្រូវតែបំបាក់ឆ្អឹងរបស់គេដែលត្រូវបានឆ្កាង ប៉ុន្តែព្រះយេស៊ូវ
ទ្រង់បានសុគតមុនពេលដែលគេបំបាក់ឆ្អឹងទ្រង់ ។

ទំនុកដំកើង ២២:១៧ បានឱ្យដឹងថា
គេនឹងមើលទៅភាពអាក្រាតរបស់ទ្រង់ និង ខ១៨ ប្រាប់ថា
គេបានយក សំលៀកបំពាក់ទ្រង់មកលេងជាល្បែងផ្សងសំណាង
ហើយសំលៀកបំពាក់ផ្សេងទៀត ពួកគេក៏កាត់ជាបំណែកតូចៗចែកគ្នា។

សាការី ១២:១០ បានឱ្យដឹងថា ព្រះហស្តទ្រង់ត្រូវទម្លុះ
ហើយក្រោយមកពួកយូដានឹងឃើញស្នាមទម្លុះ
អេសាយ ៥០:៦ បានប្រាប់ថា គេនឹងវាយខ្នងទ្រង់
ហើយទ្រង់ក៏ត្រូវបានគេវាយយ៉ាងខ្លាំងទៅលើព្រះគណ្ឋរបស់ទ្រង់ ។

ទំនុកតំកើង ១៦:១០ បានប្រាប់យើងថា ទោះបីគេនឹងបញ្ចុះសពទ្រង់
សពរបស់ទ្រង់នឹងមិននៅក្នុងផ្នូរយូរ រហូតដល់ស្អុយរលួយនោះទេ
ហើយបទទំនាយបានប្រាប់យើងថា ទ្រង់ត្រូវបានមិត្តភក្តិរបស់ទ្រង់ក្បត់
ហើយអ្នកក្បត់ទ្រង់នោះ គាត់បានចងកសម្លាប់ខ្លួន
ហើយរូបកាយរបស់គាត់បានធ្លាក់បែកពោះនៅក្នុងទីវាលមួយ
បន្ទាប់មកទីវាលនោះ គេនឹងបានទិញសម្រាប់បញ្ចុះសពអ្នកដទៃ។
គ្រប់ការទាំងនេះហើយនឹងបទទំនាយជាច្រើនទៀត
នឹងត្រូវបានកើតឡើងដូចពួកហោរាបានសសេរ គ្មានការសង្ស័យសោះ
ដែលព្រះយេស៊ូវគ្រីស្ទនៃក្រុងណាសារ៉ែត គឺជាព្រះមែស៊ី
ជាព្រះសង្គ្រោះនៃពិភពលោក។


ខ្ញុំជឿថា ព្រះយេស៊ូវទ្រង់ជាព្រះមែស៊ី
ទ្រង់ គឺជាកូនចៀមនៃការសន្យា
ដែលបានមកទទួលអំពើបាប របស់យើង
យើងមិនត្រូវការធ្វើការបូជាទៀតទេ
ព្រះយេស៊ូវ ជាទ្វារទៅព្រះ
ខ្ញុំនឹងធ្វើជាសាវករបស់ព្រះយេស៊ូវ ។


មានទឹកនៅទីនេះ ! តើអ្វីដែលមិនអាចឱ្យខ្ញុំទទួលពិធីជ្រមុជទឹក ?
ខ្ញុំនឹងធ្វើពិធីជ្រមុជទឹកឱ្យ បើសិនជាអ្នកបានទទួលជឿទ្រង់ដោយអស់ពីចិត្តនោះ ។
អ៊ូ ! ខ្ញុំពិតជាជឿមែនហើយ !


ខ្ញុំសូមធ្វើពិធីជ្រមុជទឹកឱ្យអ្នក ដោយនូវព្រះនាមនៃព្រះអម្ចាស់ និងព្រះសង្គ្រោះរបស់យើង គឺជាព្រះយេស៊ូវគ្រីស្ទ។


សរសើរព្រះអង្គ!




កិច្ចការ
៨:៣៦-៣៩

ពួកជំនុំបានកើតឡើងនៅប្រទេសអេធីយ៉ូពី ហើយបន្តរហូតដល់ពេល បច្ចុប្បន្ននេះដែលគ្រីស្ទានជាច្រើនត្រូវបានសម្លាប់ដោយពួកមូស្លីម ។



# ជំពូក ១៣

## ចូរទៅគ្រប់ទីកន្លែងក្នុងពិភពលោក


នៅទីក្រុងយេរូសាឡិមវិញ
ពួកគ្រីស្ទានបានជួបគ្នាដោយសម្ងាត់
ដើម្បីថ្វាយបង្គំ ច្រៀងសរសើរព្រះ និង
អានព្រះបន្ទូលទ្រង់ ព្រោះមានការ
ភ័យខ្លាចសម្រាប់ជីវិតរបស់គេ ។
បងប្អូនជាទីស្រឡាញ់ ព្រះអម្ចាស់យើងបានរងទុក្ខ
ដើម្បីលោះអំពើបាបរបស់យើង ដូច្នេះយើងមិនត្រូវឆ្ងល់ទេ
បើសិនយើងត្រូវទទួលការរងទុក្ខសម្រាប់ទ្រង់ ។ចូរកុំឆ្ងល់អំពីការ
បៀតបៀនដែលយើងកំពុងតែជួបប្រទះឱ្យសោះ ។


ព្រះយេស៊ូវមានបន្ទូលថា “បើអ្នកណាចង់មកតាមខ្ញុំនោះត្រូវផ្ទុកឈើឆ្កាងមកតាមខ្ញុំចុះ” នេះមានន័យថា បើសិនសភាពការណ៍តម្រូវឱ្យយើងធ្វើដូច្នេះ យើងគួរតែលីឈើឆ្កាងរបស់យើងទៅភ្នំនៃការឆ្កាងនោះដែរ ។ ឥឡូវគម្ពីរទំនុកតំកើងជំពូក ២២ ប្រាប់យើងថា...


ព្រះអម្ចាស់សូមជួយពួកទូលបង្គំផង
នោះ សូល ជាឃាតករ !
នៅឱ្យស្ងៀម ! សាសនាដទៃនេះមិន
អនុញ្ញាតឡើយ អ្នកកំពុងតែប្រមាថសាសនា
ដូនតាជាតិយើង ។ ពួកអាឆោតល្ងង់ ! បើឯងមិន
ចង់ងាប់ ត្រូវបោះបង់ជំនឿនេះចោល ។
ចាប់អ្នកដឹកនាំ របស់ពួកវា
យើងនឹង យកវាធ្វើជាគំរូ ។


យើងមានព្រះមែស៊ីគ្រប់គ្រាន់ហើយ យើងមិនត្រូវការទៀតទេ។ តើហេតុអីឯងចង់ថ្វាយបង្គំជាងឈើដែលងាប់នោះ ?
ព្រះអម្ចាស់យេស៊ូវរបស់យើងនៅមានព្រះជន្មរស់ ហើយទ្រង់បង្កើតសកលលោកដែរ។
ឯងប្រហែលជាប្តូរគំនិតនៅពេលដែលយើងដាក់ប្រពន្ធរបស់ឯងនៅក្នុងគុក រហូតដល់ងាប់ស្អុយរលួយ។




មា៉ថាយ ១៦:២៤, មា៉កុស ៨:៣៤,
កិច្ចការ ៩:១-២


នេះជាអ្នកស្រឡាញ់ព្រះគ្រីស្ទម្នាក់ទៀត ។
យើងបានដឹងមុនថា ប្រហែល មានបញ្ហានេះនឹងកើតឡើងនៅពេល យើងជឿព្រះ ធ្វើជាគ្រីស្ទាន ។


មែនហើយ
យើងគួរ អធិដ្ឋានឱ្យគាត់
ដែលព្រះនឹងបន្ទន់ ចិត្តគាត់
ហើយបណ្ដាលឱ្យគាត់
ឃើញសេចក្ដីពិត ។
បញ្ហានេះគឺសូល
ជនផារិស៊ី ម្នាក់
គាត់បានបញ្ចេញសេចក្ដីសំអប់
និងការគំរាមសម្លាប់ ។


សូមចងចាំថា ក្នុង
ចំណោមពួកយើងមានអ្នកខ្លះ
ដែលមិនជឿនៅដំបូងដែរ ។
តែវាហួសពេលហើយ
សូល ពោរពេញ
ដោយសេចក្ដីសំអប់ ។


ណើ្ហយ៎ សូល ខ្ញុំគិតថា ឯងបានបោសសំអាតពួកក្រុមដែលដើរតាមយេស៊ូវនៅទីក្រុងយេរូឡិមជិតអស់ហើយ ។
អត់ទេ ! បើយើងសម្លាប់នឹងដាក់គុកកាន់តែច្រើន ពួកវាកើនឡើងកាន់តែច្រើន ។ ពួកវាបានបែកចេញទៅទីក្រុងផ្សេងៗទៀត សាលាប្រជុំនៅក្រុងដាម៉ាសមានពួកវាជាច្រើន ។


ខ្ញុំនឹង ទៅភ្លាម ។
ខ្ញុំនឹងចេញដីកាឱ្យឯងក្នុង
ការចាប់ខ្លួនគេ ហើយអាច ទៅទីក្រុងដាម៉ាសបាន ។
សូល បានគិតថា វាជាកាតព្វកិច្ចរបស់គាត់ដើម្បីការពារសាសនានិងជាតិ
របស់គាត់ ដើម្បីទប់ស្កាត់សេចក្ដីជំនឿដទៃ ។ ប៉ុន្តែគាត់បានខ្វល់ខ្វាយក្នុងចិត្ត
ព្រោះគ្រីស្ទានមានភាពសុខសាន្ត និងទំនុកចិត្តដែលគាត់មិនធ្លាប់មាន ។


ភ្លាមនោះក៏លេចចេញពន្លឺដែលភ្លឺជាងព្រះអាទិត្យទៅទៀតនៅចំពីមុខសូល ។
សូល! សូល! ហេតុអ្វីឯងបៀតបៀនអញ?
សេះរបស់គាត់ភ័យខ្លាចនិងកញ្ច្រោលយ៉ាងខ្លាំង ធ្វើឱ្យគាត់ធ្លាក់ទៅលើផ្លូវ ហើយវារត់បាត់ ។


ព្រះជាម្ចាស់អើយ តើទ្រង់ ជាអង្គណាដែលថា ទូលបង្គំ កំពុងបៀតបៀនទ្រង់?
អញជាព្រះយេស៊ូវ ដែលឯងបៀតបៀន នៅពេលឯងដាក់ទោសលើអ្នកដើរតាមអញនោះ ។
ព្រះជាម្ចាស់ តើទ្រង់ ចង់ឱ្យទូលបង្គំធ្វើអ្វី ?
ចូរក្រោកឡើងនឹងចូលទៅទីក្រុង ហើយ គេនឹងប្រាប់ឯងពីអ្វីដែលត្រូវធ្វើ ។
កិច្ចការ ៩:១-៦


តើឯងបានឮ
សំលេងនោះទេ ?
ឮ តែខ្ញុំមិនយល់នូវ
ការនិយាយនោះទេ ?
ខ្ញុំក៏មិនយល់ដែរ
សំលេងឮដូចផ្គរលាន់ ។


វាជាសំលេង
របស់ព្រះ!
ខ្ញុំមើលមិនឃើញទេ !
ជួយខ្ញុំផង ខ្ញុំមើលមិនឃើញ
ទេ សូមនាំខ្ញុំទៅទីក្រុងផង ។


នៅទីក្រុងនោះ មានបុរសម្នាក់ដែលជឿ
ព្រះយេស៊ូវបានទៅជួបសូល ហើយនិយាយថា...
ខ្ញុំឈ្មោះ អាន្ន៉ានាស ព្រះយេស៊ូវបាន
និម្មិតឱ្យខ្ញុំឃើញដើម្បីមកជួបលោក ទ្រង់
នឹងធ្វើឱ្យលោកមើលឃើញវិញ។
អរគុណ ខ្ញុំ
ពិតជាខ្វាក់មែន


ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ
ចូរឱ្យភ្នែករបស់លោកបានមើល
ឃើញវិញ ។


ខ្ញុំមើលឃើញហើយ! តើអ្នកថាជាព្រះយេស៊ូវដែលធ្វើការនេះឬ ? សូមប្រាប់ខ្ញុំទៀតអំពីព្រះយេស៊ូវ ។


ដូច្នេះ អាន្ន៉ានាសបានបើកព្រះគម្ពីរបរិសុទ្ធ ហើយ
បង្ហាញប្រាប់សូលពីបទទំនាយអំពីព្រះយេស៊ូវ ។
បាទ ខ្ញុំពិតជាល្ងង់មែន វាមាននៅក្នុង
ព្រះគម្ពីររហូត ប៉ុន្តែខ្ញុំមើលមិនឃើញ ព្រោះខ្ញុំ
កាន់តាមសាសនារបស់ខ្ញុំជ្រុលពេក ។ ខ្ញុំចង់ទទួល
ពិធីជ្រមុជទឹក ហើយដើរតាមព្រះយេស៊ូវ ។
ព្រះបានប្តូរឈ្មោះសូល
ទៅជា ប៉ុល វិញ ។
កិច្ចការ ៩:៧-១៩


ឥឡូវ សូល បានប្ដូរទៅជា ប៉ុល ជាមនុស្សថ្មីដែលមានដំណឹងថ្មី គាត់ឈប់សម្លាប់គ្រីស្ទានទៀតហើយ គាត់ចង់បញ្ចុះបញ្ចូលអ្នកផ្សេងៗទៀតឱ្យទទួលជឿលើព្រះយេស៊ូវគ្រីស្ទវិញ ។
ខ្ញុំអាចយល់ពីការសង្ស័យរបស់អ្នក ពីមុនខ្ញុំក៏មិនជឿដែរ តែខ្ញុំសូមប្រាប់អ្នកថា ព្រះយេស៊ូវនៃក្រុងណាសារ៉ែត បានបំពេញគ្រប់បទទំនាយដែលទាយពីព្រះមែស៊ីទាំងអស់ ។
ប៉ុន្តែភស្តុតាងដ៏សំខាន់ជាងគេ គឺព្រះវរបិតាប្រោសទ្រង់ឱ្យមានព្រះជន្មរស់ពីសុគតឡើងវិញ ។


តើឯងឆោតល្ងង់ទេឬអី ?
ហេតុអ្វីក៏ ព្រះមែស៊ីឱ្យសត្រូវរបស់យើងធ្វើគតទ្រង់ ?
ទ្រង់ជាកូនចៀមនៃ
ព្រះ ដែលលោះអំពើបាប របស់យើង។


នៅពេលដដែលនោះ ព្រះក៏បានឈោងទៅរក សាសន៍ដទៃផងដែរ មានមេទាហានរ៉ូមម្នាក់ដែល បានអធិដ្ឋានស្វែងរកព្រះ ។
ព្រះជាម្ចាស់ ទូលបង្គំដឹងថា ទ្រង់ជាព្រះតែមួយ អង្គដែលបានបង្កើតមនុស្សទាំងអស់ សាសនារបស់ជនជាតិ ទូលបង្គំពេញដោយសេចក្ដីពុករលួយ ហើយមិនបានផ្ដល់ភាព សុខសាន្តទេ សូមទ្រង់បង្ហាញផ្លូវរបស់ទ្រង់ដល់ទូលបង្គំ ហើយទូលបង្គំនឹងដើរតាម ។


តើអ្នកជាអ្នកណា? ហើយមកពីណា ?
ការអធិដ្ឋានរបស់អ្នក ទ្រង់បានជ្រាបហើយ
ព្រះទ្រង់បានបញ្ជូនខ្ញុំមក ចូរប្រាប់កូនទាហានទៅ ឯក្រុងយ៉ុបប៉េ
ទៅកាន់ផ្ទះស៊ីម៉ូន ដែលជាអ្នកលក់ ស្បែកសត្វ
អ្នកនឹងឃើញផ្ទះនោះនៅក្បែរឆ្នេរសមុទ្រ សួររកបុរសម្នាក់ឈ្មោះ ពេត្រុស
គាត់នឹងមកទីនេះ ហើយប្រាប់ការពិតពីព្រះអម្ចាស់ដល់អ្នក ។



លោកពេត្រុស ចៅហ្វាយរបស់យើងជាអ្នកគិតពីសាសនាយ៉ាងខ្លាំង គាត់ជាមនុស្សល្អ តែគាត់មានបញ្ហាស្មុគ្រស្មាញជាច្រើន គាត់អធិដ្ឋានរាល់ថ្ងៃ ហើយដាក់ទានទៅអ្នកក្រ តែព្រះគ្មានមេត្រីនឹងគាត់សោះ។
ព្រះបានតាំងស្ពានមេត្រីដោយសារព្រះលោហិតនៃឈើឆ្កាងទ្រង់។
នោះមានន័យយ៉ាងម៉េច ?
ចាំខ្ញុំពន្យល់ដល់មេរបស់អ្នក។


មេទាហាននោះ ឃើញពេត្រុសនៅមាត់ ទ្វារ ហើយបានលុតជង្គង់ពីមុខពេត្រុស ។
សូមក្រោកឡើង កុំធ្វើអញ្ចឹងដាក់ ខ្ញុំឡើយ ខ្ញុំក៏ជាមនុស្សដូចលោកដែរ សូមហៅទាំងអស់គ្នាមក ខ្ញុំនឹងប្រាប់ ដំណឹងល្អដល់ពួកអស់លោក ។




កិច្ចការ ៩:២០-២២,
១០:១-២៧. ៣៨-៤១


ខ្ញុំបានដើរជាមួយព្រះយេស៊ូវអស់រយៈពេល៣ឆ្នាំកន្លះ ខ្ញុំបានឃើញគេ
ឆ្កាងទ្រង់ ហើយឃើញទ្រង់មានព្រះជន្មរស់ឡើងវិញបន្ទាប់ពីទ្រងសុគត ។
យើងមានគ្នាជាង៥00នាក់ ដែលមកជុំគ្នាដើម្បីស្តាប់ទ្រង់បង្រៀនបន្ទាប់ពីទ្រង់
មានព្រះជន្មរស់ឡើងវិញ ។ ទ្រង់បានបរិភោគជាមួយយើង ហើយយើងបាន ស្ទាបព្រះកាយទ្រង់
ព្រះអង្គបានបង្រៀនយើងឱ្យស្រឡាញ់ខ្មាំងសត្រូវនៃយើងហើយអធិដ្ឋានឱ្យអ្នកបៀតបៀន ។
ទ្រង់បានបញ្ជូនព្រះវិញ្ញាណមក...


មេទ័ពកូនេលាស និងពួកគ្រួគាត់ទាំងអស់
បានជឿដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយ
ពួកគេទាំងអស់បានទទួលពិធីជ្រមុជទឹក
នៅថ្ងៃដដែលនោះ ។


ពេលដ៏ដែលនោះនៅសាលាប្រជុំនៅឯក្រុងអាន់ទីយ៉ូក ប៉ុល
កំពុងអធិប្បាយប្រាប់ដល់ជនជាតិយូដានៅថ្ងៃឈប់សម្រាក ។
អ្នកបានស្គាល់ខ្ញុំហើយ
ខ្ញុំបានបៀតបៀនគ្រីស្ទាន រហូតដល់សម្លាប់
ប៉ុន្តែព្រះយេស៊ូវបានបង្ហាញអង្គទ្រង់ឱ្យខ្ញុំឃើញ
នូវពន្លឺដ៏ភ្លឺចែងចាំង ហើយមានសំលេងដូចជាផ្គរលាន់
បានប្រាប់ខ្ញុំ ឱ្យអធិប្បាយព្រះបន្ទូលរបស់ទ្រង់ ។
ខ្ញុំបានស្រាវជ្រាវនូវបទគម្ពីរ ដែលទាក់ទងនឹងព្រះមែស៊ី
ហើយបានឃើញថា ព្រះយេស៊ូវ
បានបំពេញគ្រប់បទទំនាយទាំងអស់ ។


ព្រះបានមានបន្ទូលថា ទ្រង់នឹងរើសតាំងបុត្រ
ដែលចេញពីវង្សហ្លួងដាវីឌ ដើម្បីធ្វើជាព្រះសង្គ្រោះ
ដល់អ៊ីស្រាអែល ហើយថា អ្នកដឹកនាំនៅយេរូសាឡិម
កាត់ទោសប្រហាជីវិតដល់ព្រះសង្គ្រោះនោះដែរ ។
មានសេចក្តីចែងទុកមក ក្នុងទំនុក ដំកើងជំពូកទី២ថា
“ឯងជាកូនអញ អញបាន បង្កើតឯងនៅថ្ងៃនេះ” ។


ក្នុងទំនុកដំកើងមួយទៀតក៏បានទាយថាទ្រង់នឹង
“មិនព្រមឱ្យអ្នកបរិសុទ្ធរបស់ទ្រង់ឃើញសេចក្ដីពុករលួយដែរ”
បទទំនាយនេះមានន័យថា ថ្វីបើទ្រង់នឹងសុគត
ព្រះសពរបស់ ទ្រង់មិនស្អុយរលួយទេ។
ចូរដឹងថា ក្នុងព្រះយេស៊ូវអ្នកអាច
ស្វែងរកការអត់ឱនទោសទាំងស្រុងពីអំពើបាប
ដែលលោកម៉ូសេមិនអាចឱ្យបាន។




ទំនុកដំកើង ២:៧, ១៦:១០, កិច្ចការ ២:២៧, ១០:៤៧, ១៣:៣៥, ១៤:៣៤


ពីព្រោះអ្នកបដិសេធដំណឹងល្អនៃជីវិត
អស់កល្ប យើងនឹងយកដំណឹងនេះឱ្យដល់សាសន៍
ដទៃវិញ ដូចដែលហោរាបានថ្លែងប្រាប់ ។
ឯងសមនឹង ងាប់ដោយគប់នឹងដុំ ថ្ម
ចំពោះសំដីប្រមាថ របស់ឯង ។


នៅពេល ប៉ុល បានដឹងច្បាស់ថា សាសន៍យូដា
ភាគច្រើននៅតែបន្តការបដិសេធព្រះគ្រីស្ទតាម
គោលការណ៍ប្រជាជាតិរបស់ពួកគេ គាត់បានសម្រេច
ចិត្តខំប្រឹងធ្វើកិច្ចការឆ្ពោះទៅលើសាសន៍ដទៃដែលជា
ប្រជាជាតិផ្សេងៗក្រៅពីអ៊ីស្រាអែល ។


ចូរសរសើរតម្កើងដល់ព្រះ ហើយបុត្រា របស់ទ្រង់គឺព្រះយេស៊ូវ សេចក្តីសង្គ្រោះ បានមកដល់សាសន៍ដទៃហើយ!
ប៉ុល សូម ជ្រមុជទឹកឱ្យខ្ញុំ!
សូមប្រាប់យើងថែមទៀត ពីបទទំនាយដែលទាក់ទង នឹងព្រះយេស៊ូវ ។
ពួកសាសន៍ដទៃជាច្រើនបានជឿដំណឹងល្អ ហើយកាន់ខ្ជាប់ក្នុងព្រះគុណនៃព្រះ ។

ពួកយូដាបានខឹងយ៉ាងខ្លាំងហើយបានដេញប៉ុលនិងបាណាបាស ចេញពីទីក្រុង
ហើយបើសិនជាត្រឡប់មកវិញពួកគេគំរាមសម្លាប់ ។ដូច្នេះប៉ុលនិងបាណាបាសបានទៅអាស៊ី
ហើយផ្សាយដំណឹងល្អដល់មនុស្សគ្រប់គ្នាដែលគេបានជួប ។




នៅក្រុងលីស្ត្រា
ពួកយូដាបានគប់ប៉ុលនឹង
ដុំថ្មរហូតដល់ស្លាប់
ហើយបោះចោលសព
របស់គាត់ទៅក្រៅទីក្រុង ។
សូមព្រះអត់ទោសឱ្យគេផង
គេបានសម្លាប់ ប៉ុល ហើយ ។
កិច្ចការ ១៤:១៨-២០


ព្រះជាម្ចាស់បានធ្វើការអស្ចារ្យ ដោយប្រោសឱ្យប៉ុលរស់ឡើងវិញ។
ប៉ុល ខ្ញុំបានគិតថាអ្នក ស្លាប់បាត់ទៅហើយ !
ខ្ញុំមិនទាន់ស្លាប់ទេ កិច្ចការយើងទើបតែ ចាប់ផ្តើម ព្រះបានបង្ហាញឱ្យខ្ញុំឃើញការឈឺចាប់ជាច្រើន ដែលខ្ញុំត្រូវរងទុក្ខដោយព្រះនាមទ្រង់ ឥឡូវយើងត្រឡប់ទៅទីក្រុងវិញ។


ឱព្រះអម្ចាស់ជាព្រះនៃយើង
រាល់គ្នា ទ្រង់គួរនឹងទទួលសិរីល្អ
កិត្តិនាមនិងការសរសើរ...
នៅទីក្រុងភីលីពនៅដែនខេត្តម៉ាសេដូន ប៉ុល និង ស៊ីឡាស់ ត្រូវបានវាយចំនួនពាន់ខ្សែតី
ហើយគេបានចាប់ដាក់គុកទៀត ទោះបីគេមានការឈឺចាប់យ៉ាងណាក៏ដោយ ក៏ចិត្តរបស់គេ
នៅតែពេញដោយសេចក្ដីអំណរ ហើយនៅពាក់កណ្ដាល អាធ្រាត គេបានច្រៀងសរសើរព្រះ ។


ឆ្កាំ! យេស៊ូវ ជាព្រះអម្ចាស់!


ខ្វាច់ !
នៅឆ្នាំបន្តបន្ទាប់ទៀត ប៉ុល ត្រូវបាន
គេវាយនិងដំបងបីដងក្នុងពេលខុសៗគ្នា
តែគាត់នៅបន្តផ្សាយដំណឹងល្អ។
កិច្ចការ ១៤:១៩-២០, ១៦:២៣-២៥,
កូរិនថូសទី២, ១១:២៤-២៥


នៅពេលប៉ុល បានធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយដើម្បី
អធិប្បាយ គាត់មានគ្រោះថ្នាក់លិចសំពៅបីលើកខុសៗគ្នា ។
មានពេលមួយនោះ ប៉ុលត្រូវបានរសាត់ក្នុង
សមុទ្ររយៈពេលមួយថ្ងៃមួយយប់ ទម្រាំ
មានសំពៅផ្សេងមកសង្គ្រោះគាត់ ។
ប៉ុលតែងតែជួបចោរប្លន់ដែរ ។
តែគាត់នៅតែបន្តក្នុង
ការផ្សាយដំណឹងល្អ ។


ប៉ុល មានសេចក្ដីវេទនាដូចជា ឈឺ ត្រជាក់ ក្ដៅ ឃ្លាន គ្មានសេចក្ដីសុខគ្រប់បែបយ៉ាងក្នុងការដែលគាត់ធ្វើដំណើរគ្រប់ទីកន្លែង ដើម្បីនឹងប្រាប់គេអំពីព្រះយេស៊ូវ ។
ព្រះជាម្ចាស់ សូមទ្រង់ប្រោសរូបកាយនេះឱ្យជាផង ដើម្បីឱ្យទូលបង្គំអាចទៅផ្សាយដំណឹងល្អនៅទីក្រុងផ្សេងទៀត ។


ប៉ុល បានធ្វើដំណើរពីទីក្រុងមួយទៅទីក្រុងមួយ ដើម្បីដាស់តឿនជំទាស់នឹងការ
ថ្វាយបង្គំរូបចម្លាក់ នឹងប្រាប់ពួកគេអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។
ឥឡូវអ្នកបានបែរមករកព្រះដោយបានបោះបង់
រូបចម្លាក់របស់អ្នកចោល ព្រះអម្ចាស់បានរាប់អ្នកជាសុចរិត
ដោយសេចក្ដីជំនឿ មិនមែនដោយសារការប្រព្រឹត្តតាម
ក្រឹត្យវិន័យទេ ឥឡូវនេះអ្នកទាំងអស់គ្នាគឺជាអវយវៈនៃ
រូបកាយរបស់ទ្រង់ ហើយជាពួកដំណាក់នៃព្រះ។
សរសើរព្រះអង្គ!

កូរិនថូសទី១, ១០:១៤, ១២:១២-១៣, ១៨, កូរិនថូសទី២, ១១:២៥, កាឡាទី ២:៦, អេភេសូរ ២:១៩




នៅពេលដែលពួកគេបានប្រែចិត្តទៅរកព្រះ គេបានបោះបង់ចោលនូវរូបចម្លាក់និងវត្ថុស័ក្តិសិទ្ធិផ្សេងៗ ពួកគេបានប្រមូលរបស់គ្រប់យ៉ាងដែលទាក់ទងសាសនានិងអំពើបាបរបស់ខ្លួនគេដុតចោលក្នុងភ្លើង ។ ២០ឆ្នាំក្រោយមកមានអ្នកជឿជាច្រើននៅពាសពេញពិភពលោក ហើយថ្វាយបង្គំព្រះអម្ចាស់ដោយសារព្រះយេស៊ូវគ្រីស្ទ ។


ព្រះយេស៊ូវបានឱ្យពួកសាវកដឹងមុនថា
“គ្រានោះគេនឹងបញ្ជូនអ្នករាល់គ្នាទៅឱ្យមានសេចក្តីវេទនា
ព្រមទាំងសម្លាប់អ្នករាល់គ្នា
ហើយគ្រប់ទាំងសាសន៍នឹងស្អប់អ្នករាល់គ្នា
ដោយព្រោះនាមខ្ញុំ នៅ គ្រានោះ
មនុស្សជាច្រើននឹងរវាតចិត្តចេញ
គេនឹងក្បត់គ្នា ហើយនឹងស្អប់គ្នាទៅវិញទៅមក
ក៏នឹងមានហោរាក្លែងក្លាយជាច្រើនកើតឡើង
នាំឱ្យមនុស្សជាច្រើនវង្វេងដែរ ។
ព្រះវរបិតាអើយ
សូមកុំដាក់ ទោសពួកគេ
ចំពោះអ្វីដែលគេ
បានធ្វើមកលើពួកទូលបង្គំ ។




នៅពេលពួកមនុស្សដែលបានឃើញព្រះយេស៊ូវផ្ទាល់បានចាស់អស់ទៅ ហើយពួកជំនុំរបស់ព្រះបានរីកចំរើនពាសពេញចក្រភពរ៉ូម ក្នុងពេលនោះពួករ៉ូមក៏ចាប់ផ្តើមស្វែងរកពួកគ្រីស្ទាន ហើយ ធ្វើទុក្ខបុកម្នេញរហូតដល់ពួកគេស្លាប់ ប្រសិនបើអ្នកជឿព្រះ ណាមិនព្រមបដិសេធព្រះគ្រីស្ទនោះ ពួកគេយកទៅដាក់ក្នុង ទីលានប្រកួត ហើយពួកមនុស្សផ្សេងទៀតបានអង្គុយមើល សត្វតោនិងខ្លាខាំហែកស៊ីពួកអ្នកជឿព្រះនោះជាដុំៗ ។


ក្រៀវ... !
យ៉ា...!

ពេលខ្លះគ្រីស្ទានត្រូវបានគេកាប់រហូតដល់
ស្លាប់ ដោយពួកពេជ្ឈឃាតរ៉ូម អ្នកអង្គុយមើល
បានឆ្ងល់យ៉ាងខ្លាំងថា ពួកអ្នកជឿទាំងឡាយមិន
បោះបង់ជំនឿរបស់គេចោលទេ
ពួកគេបានស៊ូ ស្លាប់ដើម្បីព្រះយេស៊ូវ ។




ម៉ាថាយ ២៤:៩-១១


នៅពេលពួករ៉ូមកំពុងតែបៀតបៀនពួកគ្រីស្ទាន ពួកទាហានរ៉ូម
ក៏បានបំផ្លាញទីក្រុងយេរូសាឡិមនិងវិហារសាសនាអ៊ីស្រាអែល
ដែរ ព្រះយេស៊ូវបានទាយពីវិហារនេះមុនពេលដែលទ្រង់សុគត ។
តើអ្នកបានឃើញវិហារនេះទេ
? ខ្ញុំប្រាប់អ្នករាល់គ្នា វិហារនេះត្រូវវិនាស
ហើយ គ្មានថ្មណាមួយនៅគរលើគ្នាទេ ។



៤០ឆ្នាំបន្ទាប់ពីព្រះយេស៊ូវបានទាយ នៅឆ្នាំទី៧០ក្រោយ គ.ស.
ទាហានរ៉ូមមកនឹងបំផ្លាញទីក្រុងយេរូសាឡិមព្រមទាំងវិហារនៅទីនោះ
ដែរ ហើយនៅពេលភ្លើងបានឆេះផ្នែកខាងក្នុងវិហារដែលធ្វើអំពីឈើ
មាសរបស់វិហារនោះរលាយហូរចូលទៅក្នុងប្រហោងថ្មនិងប្រហោង
គ្រឹះ នៅពេលទាហានព្យាយាមរកមាស ពួកគេត្រូវតែវាយថ្មទាំងអស់
ចេញពីគ្នា នេះហើយជាបទទំនាយរបស់ព្រះគ្រីស្ទត្រូវបានបំពេញ។

សាសន៍យូដានៅយេរូសាឡិមនិងនៅអ៊ីស្រាអែលដែលមានជីវិត
រស់នៅក្រោយពីសង្គ្រាម
បានចេញទៅរស់នៅប្រទេសដទៃ ហើយ
កូនចៅរបស់ពួកគេជាច្រើនបានរស់នៅរហូតដល់សព្វថ្ងៃនេះ។




សាសន៍អ៊ីស្រាអែលជាគ្រីស្ទាន
បានចេញទៅរស់នៅ ប្រទេសផ្សេងដែរ
នៅទីនោះពួកគេផ្សាយដំណឹងល្អរបស់ ព្រះគ្រីស្ទ
ហើយពួកជំនុំព្រះក៏បានរីកចំរើនយ៉ាងច្រើន។




ម៉ាថាយ ២៤:២, លូកា ១៩:៤៣-៤៤


ពួកសាវករបស់ព្រះយេស៊ូវ បានបន្តអធិប្បាយពីការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ រហូតដល់ពួកគេស្លាប់ ពួកគេបានស្លាប់ម្តងម្នាក់ៗដោយមានសេចក្តីក្លាហាន ពីព្រោះគេដឹងថា គេមានដំណាក់នៅឋានសួគ៌ដែលល្អជាងនៅលោកិយនេះ ។
អ្នកខ្លះត្រូវបាន ពួករ៉ូមឆ្កាង ។
អ្នកផ្សេងទៀតត្រូវបានគេវះ ទាំងរស់ស្រាវយកពោះវៀនចេញ ហើយកាត់គេជាកំណាត់ៗ ។



អ្នកខ្លះត្រូវសម្លាប់
ដោយគប់នឹងដុំថ្ម ។
អ្នកផ្សេងទៀតត្រូវបាន
សត្វស៊ីទាំងរស់ ។
អ្នកខ្លះត្រូវបានកាត់ក្បាល ។


អ្នកខ្លះទៀតត្រូវគេឆ្កាងក្បាលចុះក្រោម ។
អ្នកខ្លះត្រូវបានគេដាក់ចូលក្នុងខ្ទះខ្លាញ់
ដែលក្តៅបន្តិចម្តងៗរហូតដល់ស្លាប់ ។
ទូលបង្គំមិនសមនឹង
ស្លាប់ដូចទ្រង់ទេ ។
ម៉ាថាយ ១៤:១០, យ៉ូហាន ២១:១៨
ខ្ញុំនឹងទៅកន្លែង ល្អជាងនេះ
សូមព្រះអត់ ទោសឱ្យពួកអ្នក ។
ពួកគេទាំងអស់បានស្លាប់ក្នុងសេចក្តីជំនឿ ហើយ
នឹងមានការអះអាងថា ពួកគេនឹងមានរូបកាយថ្មី
នឹងដំណាក់ដ៏ល្អដែលរងចាំពួកគេនៅឋានសួគ៌ ។

៦០ឆ្នាំបន្ទាប់ពីព្រះយេស៊ូវមាន ព្រះជន្មរស់ឡើងវិញ ក្នុងចំណោម
សាវករបស់ទ្រង់គឺមានតែ យ៉ូហានម្នាក់ដែលនៅរស់ គេបាន
និរទេសគាត់ទៅកាន់កោះមួយ មានឈ្មោះប៉ាត់ម៉ុស ហើយ ព្រះវិញ្ញាណបរិសុទ្ធបានលើក
គាត់ទៅឋានសួគ៌ នៅទីនោះ ព្រះបង្ហាញឱ្យគាត់ឃើញពី ថ្ងៃអនាគត។




យ៉ូហាន
អញនឹងបង្ហាញឱ្យឯងឃើញ
អ្វីដែលកើតឡើងនូវថ្ងៃអនាគត  អ្វីដែលឯងឃើញត្រូវ
កត់ទុកនៅក្នុងសៀវភៅ  ហើយផ្ញើរសៀវភៅនេះទៅ
វិហារទាំង៧នៅអាស៊ី ។


នៅពេលជំនាន់នេះជិតចប់ ព្រះយេស៊ូវនឹងត្រឡប់មកវិញ
ហើយបើកផ្នូរអស់អ្នកណាដែលជឿលើទ្រង់ ទាំងអ្នកក្នុងផ្នូរ
ហើយអ្នកនៅរស់ដែលជឿព្រះ នឹងឡើងទៅជួបព្រះយេស៊ូវ
ក្នុងផ្ទៃមេឃ ហើយនឹងនៅជាមួយទ្រង់អស់កល្បជានិច្ច។
នៅថ្ងៃចុងបញ្ចប់ព្រះនឹងដាក់សេចក្ដី
វេទនាយ៉ាងខ្លាំងនៅលើផែនដី ភ្លើងនឹង ធ្លាក់
ហើយនោះនឹងមានសេចក្ដីវេទនា ផ្សេងៗ
នឹងធ្វើឱ្យមនុស្សភាគច្រើននៅលើ ផែនដីនេះស្លាប់។


មានមនុស្សម្នាក់នឹងលេចមក ហើយតាំងខ្លួនគាត់ជាព្រះដែល
អាចនឹងសង្គ្រោះ ហើយគាត់បានបោកបញ្ឆោតមនុស្សជាច្រើន
គាត់នឹងធ្វើឱ្យមនុស្សទទួលសញ្ញាសំគាល់មួយនៅលើថ្ងាស ឬនៅ ខ្នងដៃស្តាំរបស់គេ
ដើម្បីបង្ហាញនូវភក្តីភាពរបស់គេចំពោះគាត់ នឹងការគ្រប់គ្រងរដ្ឋាភិបាលរបស់គាត់ ។

អស់អ្នកណាដែលអត់ទទួលសញ្ញាសំគាល់នោះនឹងត្រូវសម្លាប់ដោយកាត់ក្បាល
នោះជាពេលមួយដែលមនុស្សនៅសល់លើផែនដី នឹងត្រូវវេទនាយ៉ាងខ្លាំង។




ថែស្សាឡូនីចទី១, ៤:១៤, ៤:១៦-១៧, ថែស្សាឡូនីចទី២, ២:៣-៤, វិវរណៈ ១:៩,
១១, ៨:១-១៣, ៩:១៨, ១៣:១៦, ២០:៤


ព្រះយេស៊ូវ នឹងត្រឡប់មកវិញនៅថ្ងៃចុងបញ្ចប់
ដូចដែលហោរាបានទាយ ។
ទ្រង់នឹងយាងមកជាលើកទីពីរនេះដោយមាន
អំណាចនិងសិរីល្អរបស់ទ្រង់ មិនដូចមនុស្សដែល
តែងតែស្លាប់ទេ មេឃនឹងបើកចំហ ហើយទ្រង់
នឹងយាងមកវិញដោយគង់នៅលើសេះស ។
ទ្រង់ នឹងមានពន្លឺដូចព្រះអាទិត្យ
ហើយនៅលើសិរសារបស់ទ្រង់
មានពាក់ម្កុដជាច្រើន
ក្នុងព្រះហស្តរបស់ទ្រង់នឹងមានផ្កាយប្រាំពីរ
ហើយដាវនៃសេចក្តីពិតនឹងចេញពីព្រះឱស្ឋទ្រង់ដែរ ។

ទ្រង់នឹងយាងមកប្រឈមមុខនឹងសាតាំង ហើយទម្លាក់វាចូលក្នុងបឹងភ្លើង ហើយនៅទីនោះវានឹងទទួលសេចក្ដីរងទុក្ខវេទនាអស់កល្បជានិច្ច វានឹងមិនមកល្បួងមនុស្សទៀតទេ ព្រះយេស៊ូវនឹងទម្លាក់សេចក្ដីស្លាប់ដែលជាសត្រូវចុងក្រោយរបស់ទ្រង់ចូលទៅក្នុងបឹងភ្លើងនោះដែរ ហើយផែនដីត្រូវបង្កើតជាថ្មី។



ថែស្សាឡូនីចទី១, ៤:១៦, វិវរណៈ ១:១៦, ១៩:១១-២១. ២០:១០-១៥. ២១:១-៤



ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទបានផ្សព្វផ្សាយជាង
២០០០ឆ្នាំមកហើយ
ព្រះយេស៊ូវបានមានបន្ទូល ប្រាប់ថា
ដំណឹងអំពីនគររបស់ទ្រង់នឹងផ្សាយពាស
ពេញពិភពលោករហូតដល់គ្រប់សាសន៍
គ្រប់ កុលសម្ព័ន្ធ
គ្រប់គ្រួសារទាំងអស់បានឮដំណឹងល្អ។


នោះមានព្រះតែមួយអង្គ
ហើយទ្រង់មាន បុត្រាតែមួយ
មានសេចក្តីជំនឿតែមួយ ហើយព្រះ
គម្ពីរបរិសុទ្ធតែមួយដែរ ។ នោះគ្រាន់តែមានផ្លូវ
តែមួយចូលទៅឋានបរមសុខបន្ទាប់ពីយើងស្លាប់
ហើយព្រះយេស៊ូវគឺជាផ្លូវ
ជាសេចក្តីពិត និងជាជីវិត
ដូចមនុស្សជាច្រើននៅគ្រប់ទាំងសាសន៍
បានយល់ដឹងហើយ ។



ដំណឹងល្អនៃព្រះគ្រីស្ទ គឺខុសពីសាសនាផ្សេងៗទូទាំងសកលលោក ដំណឹងល្អរបស់ព្រះយេស៊ូវ វាមិនផ្សព្វផ្សាយដោយសារការគំរាមកំហែងឬបង្ខិតបង្ខំទេ ព្រះយេស៊ូវបង្រៀនសិស្សរបស់ទ្រង់ឱ្យចេះស្រឡាញ់សត្រូវរបស់ខ្លួន ហើយមានចិត្តពេញដោយសេចក្ដីអំណរនិងការច្រៀងសរសើរ ថ្ងៃនេះមនុស្សគ្រប់សាសន៍និងគ្រប់ភាសាមានសេចក្ដីអំណរ ចំពោះការអត់ឱនទោស នឹងជីវិតអស់កល្បជានិច្ចដោយសារព្រះយេស៊ូវ។



យ៉ូហាន ៣:១៦, ១៤:៦

ទោះបីយ៉ាងណាប្រហែលជាង២០០០ឆ្នាំកន្លងមកហើយតាំងពីព្រះយេស៊ូវមានព្រះជន្មរស់ពីសុគតឡើងវិញក៏ដោយ នោះនៅមានមនុស្សខ្លះមិនទាន់បានឮពីដំណឹងល្អទេ ដូច្នេះត្រូវការនរណាម្នាក់ទៅប្រាប់ដល់ពួកគេ ។

Our desire is that after reading *Good and Evil®* you will be motivated to read the entire Bible and that it will come alive to you. Make it a daily habit to read a portion of the Bible and then pray that God will help you understand and apply it.

Copyright © 2008, 2017
Michael and Debi Pearl.

ALL RIGHTS RESERVED.

*Author:* Michael Pearl

*Artist:* Danny Bulanadi

*Coloration:* Clint Cearley

https://goodandevilbook.com/